## សៀវភៅស្ដីអំពី

# ការទូតសភាបែបបុរេសកម្ម

ការបោះពុម្ពពិសេសសម្រាប់ ASEP 11

ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០២១



PCAsia
PARLIAMENTARY CENTRE OF ASIA
Strengthening Parliamentary Capacity

## សៀវភៅស្តីអំពី

# ការធ្វើតេស្តបែបប្រសេកម្ម

ការបោះពុម្ពពិសេសសម្រាប់ ASEP 11

ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០២១

# បុព្វកថា

ក្នុងនាមជាម្ចាស់ផ្ទះនៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី១១ (ASEP 11) សភាកម្ពុជាបានព្យាយាមលើកកម្ពស់ស្មារតីពហុភាគីនិយមបែបបើកចំហនិងប្រកបដោយបរិយាបន្ន សណ្តាប់ធ្នាប់អន្តរជាតិដោយផ្អែកលើច្បាប់ជាគោលការទូតសភានិងភាពជាដៃគូដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមមូលបទ "ការពង្រឹងភាពជាដៃគូសភាដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងសម័យ និងក្រោយវិបត្តិកូវីដ-១៩"។ ក្នុងនោះមានប្រធានបទចំនួនបីសម្រាប់កិច្ចពិភាក្សាដែលផ្តោតលើបុរេសកម្មសភាដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម ការទប់ស្កាត់ការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងការលើកកម្ពស់ការស្តារឡើងវិញផ្នែកសង្គម-សេដ្ឋកិច្ចក្រោយវិបត្តិកូវីដ-១៩ ក៏ដូចជាការលើកកម្ពស់ការស្តារឡើងវិញនូវបរិស្ថានបៃតង (green recovery) និងការឆ្លើយតបទៅនឹងអន្តរកម្មនៃសន្តិសុខទឹក ថាមពល និងស្បៀង។

វិបត្តិសុខភាពសាធារណៈជាសកលដែលកំពុងអូសបន្លាយនេះជាសូចនាករ និងជាការក្រើនរំលឹកដ៏ច្បាស់លាស់មួយនៃភាពអាស្រ័យគ្នាទៅវិញទៅមក ទាំងរវាងប្រជាជាតិនិងរវាងទ្វីបនានា។ វិបត្តិនេះក៏ជាសារដាស់តឿនសហគមន៍អន្តរជាតិឱ្យគិតគូរពីការសហការគ្នា និងការពង្រឹងប្រព័ន្ធពហុភាគីនិយម ដើម្បីរួមគ្នាដោះស្រាយវិបត្តិសកលក្នុងកម្រិតនិងទំហំបែបនេះប្រកបដោយប្រសិទ្ធភាព។ មេរៀនដែលពួកយើងទទួលបានពីវិបត្តិនៃជំងឺរាតត្បាតជាសកលនេះគឺថា គ្មាននរណាម្នាក់ក្នុងចំណោមពួកយើងមានសុវត្ថិភាពនោះទេ ដរាបណាទាំងអស់គ្នាមិនមានសុវត្ថិភាព។ គ្មានប្រទេសឬតំបន់ណាមួយមានភាពស៊ាំទៅនឹងការរាតត្បាតនៃជំងឺនេះទេ។ ដូច្នេះ ពួកយើងចាំបាច់ត្រូវបន្តពង្រឹងអភិបាលកិច្ចសកល លើកកម្ពស់ភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងបង្កើតភាពជាអ្នកដឹកនាំរួមគ្នាដើម្បីដោះស្រាយបញ្ហា និងការប្រឈមសកល។ ពួកយើងចាំបាច់ត្រូវអំពាវនាវជាប្រចាំដល់ប្រទេសមហាអំណាចធំៗឱ្យសហការគ្នានិងចៀសវាងការប្រឈមមុខដាក់គ្នាដើម្បីបុព្វហេតុសន្តិភាពនិងវិបុលភាពពិភពលោក។

ស្របពេលដែលពួកយើងប្រកាន់យកស្មារតីពហុភាគីនិយម ពួកយើងត្រូវដឹងថាប្រព័ន្ធពហុភាគីមានឧបសគ្គនិងចំណុចខ្សោយជាក់លាក់មួយចំនួន។ ការអនុវត្តជាក់ស្តែងគឺជាបញ្ហាចម្បងមួយ។ ពួកយើងត្រូវអនុវត្តសេចក្តីសម្រេចចិត្តដែលត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌពហុភាគី។ រដ្ឋាភិបាលទាំងឡាយគួរមានទំនួលខុសត្រូវកម្រិតខ្ពស់ក្នុងការអនុវត្តកិច្ចព្រមព្រៀងឬសេចក្តីសម្រេចចិត្តពហុភាគី។ ត្រង់ចំណុចនេះ ខ្ញុំសូមធ្វើការសង្កត់ធ្ងន់លើសារៈសំខាន់នៃភាពជាម្ចាស់ថ្នាក់ជាតិក្នុងការផ្តល់ជូននូវការប្តេជ្ញាចិត្តអន្តរជាតិ។ ឧទាហរណ៍ ដំណើរការបង្កើតសន្តិភាព និងកសាងសន្តិភាពក្នុងប្រទេសកម្ពុជាដែលត្រូវបានផ្តួចផ្តើមឡើងក្នុងយន្តការពហុភាគី នឹងមិនអាចសម្រេចជាផ្លែផ្កាបានទេ បើសិនពុំមានគោលនយោបាយឈ្នះ-ឈ្នះ ដែលមិនអាចខ្វះបានក្រោមការដឹកនាំពីសំណាក់ **សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន** ដែលនាំមកនូវអត្រាកំណើនសេដ្ឋកិច្ចជាមធ្យមលើសពី ៧% ចាប់តាំងពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០២០ កំណើនគួរឱ្យកត់សម្គាល់នៃកម្រិតជីវភាពរបស់ប្រជាជន និងសមាហរណកម្មយ៉ាងរលូនទៅក្នុងស្ថាប័ននិងកិច្ចព្រមព្រៀងតំបន់និងអន្តរជាតិធំៗ។

ពិភពលោកកំពុងស្ថិតក្នុងចំណុចរបត់មួយ។ ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរឹតតែមានភាពពិបាកប៉ាន់ស្មាន និងប្រកបដោយការប្រឈមមុខនឹងគ្នាកាន់តែខ្លាំង។ បញ្ហាសន្តិភាព និងសន្តិសុខក៏កំពុងមានភាពស្មុគស្មាញនិងអាចប្រែប្រួលគ្រប់ពេល។ ការគំរាមកំហែងចំពោះសុខភាពសាធារណៈ និងបរិស្ថានរបស់យើងទាំងអស់គ្នាកំពុងកើនឡើងកាន់តែញឹកញាប់ និងកាន់តែធ្ងន់ធ្ងរ។ ហេតុនេះ ស្ថាប័នសភា ក៏ដូចជាសមាជិក សមាជិកាសភាគ្រប់រូប ត្រូវបោះជំហានទៅមុខ និងប្រកាន់ខ្ជាប់នូវតួនាទីសំខាន់របស់ខ្លួន។ ក្នុងនាមជាស្ថាប័នដែលតំណាងឱ្យប្រជាពលរដ្ឋ សភាត្រូវមានភាពបុរេសកម្មកាន់តែខ្លាំងក្នុងការលើកកម្ពស់ការដោះស្រាយជម្លោះដោយសន្តិភាព ដោយផ្អែកលើច្បាប់អន្តរជាតិ ការលើកកម្ពស់ស្មារតីពហុភាគីនិយម ការលើកទឹកចិត្តឱ្យមានកិច្ចការពារបរិស្ថានដើម្បីរួមគ្នាបន្ថយល្បឿននៃការប្រែប្រួលអាកាសធាតុ និងការបង្កើតសណ្តាប់ធ្នាប់ពិភពលោកដោយផ្តោតលើប្រជាពលរដ្ឋជាស្នូលដោយមិនមានការរើសអើង។ កើតចេញពីប្រជាជន និងដើម្បីប្រជាជនគួរតែជាពាក្យពេចន៍ដែលត្រូវបានគេយកមកអនុវត្ត មិនមែនត្រឹមតែជាពាក្យស្លោកនោះទេ។ ខ្ញុំសង្ឃឹមថា គណៈប្រតិភូនៃកិច្ចប្រជុំ ASEP នឹងឈានទៅសម្រេចបាននូវការប្តេជ្ញាចិត្តរួមដ៏មុតមាំមួយក្នុងការបង្កើនភាពជាដៃគូសភាដើម្បីសន្តិភាព វិបុលភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។ ត្រង់ចំណុចនេះ ខ្ញុំសូមស្នើនូវគោលការណ៍ M5P2 (ការគោរពគ្នាទៅវិញទៅមក ការរៀនសូត្រពីគ្នាទៅវិញទៅមក ការយោគយល់ពីគ្នាទៅវិញទៅមក ការជឿទុកចិត្តគ្នាទៅវិញទៅមក និងការគិតពីផលប្រយោជន៍ទៅវិញទៅមក ដើម្បីសន្តិភាពនិងវិបុលភាពប្រកបដោយចីរភាព)។

ការបោះពុម្ពជាពិសេសនេះ ដែលរៀបចំដោយមជ្ឈមណ្ឌលសភាអាស៊ី (PCAsia) ពិតជាការរួមចំណែកក្នុងការលើកកម្ពស់ស្មារតីនៃភាពជាដៃគូ សាមគ្គីភាព និងទំនួលខុសត្រូវរបស់ពលរដ្ឋ។ ការបោះពុម្ពផ្សាយនេះផ្តល់នូវទស្សនៈ និងការយល់ឃើញចម្រុះលើបញ្ហាអន្តរជាតិនានាដែលជះឥទ្ធិពលដល់អាស៊ីនិងអឺរ៉ុប ពីសំណាក់ពលរដ្ឋពីទ្វីបទាំងពីរ។ ការបោះពុម្ពផ្សាយនេះក៏អាចផ្តល់ជាព័ត៌មានសារវតារ និងបទវិភាគក្នុងការគាំទ្រដល់កិច្ចពិភាក្សានានានៅក្នុងកិច្ចប្រជុំ ASEP ១១ ផងដែរ។ ដើម្បីកសាងសហគមន៍មួយដែលផ្តោតលើប្រជាជនជាស្នូលពិតប្រាកដ ពួកយើងត្រូវផ្តល់សិទ្ធិអំណាចផ្នែកបញ្ចេញមតិដល់គ្រប់ភាគីពាក់ព័ន្ធ ធានាឱ្យមានការចូលរួមដោយបរិយាបន្ននៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងមានភាពក្លាហានក្នុងការយកផលប្រយោជន៍ប្រជាជនជាចម្បងនិងជាស្នូលនៃកិច្ចសន្ទនានិងកិច្ចសហប្រតិបត្តិការរបស់ពួកយើង។

ដូច្នេះហើយ ខ្ញុំសូមឆ្លៀតយកឱកាសនេះបង្ហាញនូវក្តីគោរពនិងការកោតសរសើរចំពោះអ្នកចូលរួមសរសេរអត្ថបទទាំងអស់ ក៏ដូចជាចំពោះ មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) សម្រាប់ការផ្តួចផ្តើមរៀបចំ និងបោះពុម្ពសៀវភៅបែបនេះ។ ទស្សនៈ និងគំនិតរបស់លោកអ្នកពិតជាត្រូវបានផ្សព្វផ្សាយ។ ខ្ញុំក៏សូមលើកទឹកចិត្តដល់គណៈប្រតិភូនៃកិច្ចប្រជុំ ASEP ចំណាយពេលវេលាក្នុងការពិចារណាដោយយកចិត្តទុកដាក់ពីគំនិត និងធាតុចូលដែលមាននៅក្នុងសៀវភៅបោះពុម្ពជាពិសេសនេះ។

**លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី**
**អនុប្រធាននៃរដ្ឋសភា និងជាប្រធាននៃក្រុមការងារកិច្ចប្រជុំ ASEP នៃរដ្ឋសភាកម្ពុជា**

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយ មជ្ឈមណ្ឌលសភាអាស៊ី (PCAsia)។ អត្ថបទដើមជាភាសាអង់គ្លេសនៅទំព័របន្ទាប់។

# PREFACE

As the host of the Eleventh Asia-Europe Parliamentary Partnership meeting (ASEP 11), the Parliament of Cambodia has endeavoured to promote open and inclusive multilateralism, rules-based international order, parliamentary diplomacy and partnership for peace and sustainable development under the theme of "Strengthening Parliamentary Partnership for Peace and Sustainable Development in the Era of COVID-19 and Beyond". There are three topics for panel discussions with a focus on proactive parliaments for peace, security, and shared prosperity, containing the COVID-19 pandemic and promoting post-COVID-19 socio-economic recovery, as well as promoting a green recovery and addressing the water-energy-food security nexus.

The on-going global public health crisis is an indicator and a stark reminder of the complex interdependence between nations and continents. It is also a wakeup call for the international community to work together and strengthen the multilateral system to effectively address a global crisis of such scale and magnitude. We have learned from the pandemic crisis that none of us is safe unless everyone is safe. No country or region is immune from the outbreak. Therefore, we need to continuously strengthen global governance, promote international cooperation and partnership, and forge collective leadership to address global issues and challenges. We must consistently call upon major powers to work together and avoid confrontation, for the sake of world peace and prosperity.

As we embrace multilateralism, we need to be aware that the multilateral system has certain constraints and weaknesses. Enforcement is the core issue here. We need to enforce the decisions made within multilateral frameworks. National governments should be held accountable in implementing multilateral agreements or decisions. Here I would like to stress the importance of national ownership in delivering international commitments. For instance, the peace-making and peacebuilding process in Cambodia initiated within a multilateral mechanism would not have been achieved without the indispensable win-win policy spearheaded by Samdech Prime Minister Hun Sen, which led to an economic growth rate that averaged over 7% from 1994 until 2020, a landmark increase in the people's living standards, and a steady integration into major regional and international institutions and agreements.

The world is at an inflection point. Geopolitical competition is getting more unpredictable and confrontational. Peace and security issues are becoming more complex and volatile. Threats to public health and our natural environment are increasing in frequency and severity. Therefore, parliamentary institutions and every parliamentarian must step forward and be counted. As the people's representatives, parliaments need to be more proactive in promoting peaceful settlement of disputes based on international law, advancing multilateralism, encouraging respect for the environment to slowdown climate change, and forging an inclusive people-centric world order. By the people and for the people should be words in action, and not just a slogan. It is my hope that the ASEP delegates will come up with a firm, collective commitment to enhance parliamentary partnership for peace, prosperity and sustainable development. Here I would like to propose the principle of M5P2 (mutual respect, mutual learning, mutual understanding, mutual trust, and mutual interest for sustainable peace and prosperity).

This special edition volume published by the Parliamentary Centre of Asia (PCAsia) contributes to the enhancement of that spirit of partnership, solidarity and citizen responsibility. This publication provides diverse perspectives and insights on various international issues affecting Asia and Europe, offered by individual citizens from across both continents. It can serve as background information and analysis to support the discussions at ASEP 11. To build a truly people-centred community, we need to empower the voices of all stakeholders, be more inclusive in our decision-making process, and be bold in putting people's interest at the front and center of our dialogue and cooperation.

In this connection, my sincere regards and appreciation go to the contributors to this volume and the Parliamentary Centre of Asia (PCAsia) for taking this initiative. Your wisdom and thoughts are heard. I would like to encourage ASEP delegates to spend time to slowly consider the ideas and inputs in this volume.

**Kittisangahakbindit KHUON Sudary**
Vice President of the National Assembly
and President of the ASEP Group of
the Cambodian National Assembly

# សេចក្ដីផ្ដើម

មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) បានចាប់បដិសន្ធិនៅដើមឆ្នាំ២០២១នេះ ដោយស្នងពីវិទ្យាស្ថានសភាកម្ពុជា (PIC)។ វិទ្យាស្ថាននេះមានវត្តមាននៅកម្ពុជា ចាប់តាំងពីឆ្នាំ២០១១ ដែលបានបង្កើតឡើងស្របតាមសំណូមពររបស់សភាកម្ពុជា ក្នុងបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍសមត្ថភាពមន្ត្រីរបស់សភាកម្ពុជា។ ជាពិសេស វិទ្យាស្ថានសភាកម្ពុជាក៏បានវិវត្តខ្លួនទៅជាមជ្ឈមណ្ឌលសភាអាស៊ី ឆ្លើយតបទៅតាមបំណងប្រាថ្នារបស់សភាមួយចំនួន ដែលមានតម្រូវការចង់ឱ្យមជ្ឈមណ្ឌលជួយគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់សភានៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងទិសដៅជួយជម្រុញឱ្យមានការចែករំលែកទៅវិញទៅមកនូវឧត្តមានុវត្តន៍សភា នៅកម្រិតថ្នាក់តំបន់ និងជួយសម្របសម្រួលឱ្យមានមជ្ឈមណ្ឌលស្នូល ក្នុងការប្រមូលនិងផ្សព្វផ្សាយកិច្ចការស្រាវជ្រាវ និងចំណេះដឹងសភា។

ជាងនេះទៀត ដោយមានការគាំទ្រ តាមរយៈសេចក្ដីសម្រេចរបស់មហាសន្និបាតអាយប៉ា (AIPA) មជ្ឈមណ្ឌលសភាអាស៊ីក៏មានបេសកកម្មចូលរួមចំណែកលើកកម្ពស់សមត្ថភាពរបស់មន្ត្រីសភានៅក្នុងតំបន់ ដើម្បីជួយឱ្យមន្ត្រីសភាបំពេញការងារកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ជារួមបេសកកម្មនេះក៏ឆ្លើយតបទៅនឹងរាល់សំណើរបស់សភា ដែលសំណូមពរមកមជ្ឈមណ្ឌលឱ្យជួយរៀបចំវគ្គបណ្ដុះបណ្ដាលនានា, ជួយជម្រុញឱ្យមានការចែករំលែកគ្នាទៅវិញទៅមកនូវបទពិសោធន៍ និងជួយលើកកម្ពស់មិត្តភាពនិងការយោគយល់គ្នាទៅវិញទៅមករវាងសភា។ តាមរយៈយន្តការទាំងនេះ មជ្ឈមណ្ឌលនឹងខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីជួយសម្របសម្រួលឱ្យមានការផ្លាស់ប្ដូរបទពិសោធន៍ និងកិច្ចសហប្រតិបត្តិការត្រីកោណរវាងខាងត្បូង និងខាងជើង។

ការអនុវត្តបេសកកម្មបែបនេះរបស់មជ្ឈមណ្ឌលសភាអាស៊ី គឺពិតជាមានសារៈសំខាន់ជាពិសេស បើពិនិត្យមើលទៅលើបរិបទនៃការអនុវត្ត ទាំងក្នុងបរិបទសង្គមក្រោយជម្លោះ និងក្នុងអំឡុងពេលកំពុងមានជម្លោះ។ ក្នុងករណីបែបនេះ គឺចាំបាច់ត្រូវមានរដ្ឋបាលសភាប្រកបដោយសមត្ថភាព និងអព្យាក្រឹតភាព ដែលអាចជួយសម្រាលភាពតានតឹង និងអាចចូលរួមចំណែកក្នុងការពង្រឹងសន្តិភាព និងស្ថិរភាព តាមរយៈយន្តការប្រជាធិបតេយ្យរបស់សភារៀងៗខ្លួន។ នេះជាបុរេលក្ខខណ្ឌដើម្បីធានានូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចីរភាពពិតប្រាកដ។

ស្របតាមបេសកកម្មរបស់ខ្លួន ដើម្បីធានាភាពជាម្ចាស់របស់សភាលើរាល់ការអនុវត្តសកម្មភាពនានា មជ្ឈមណ្ឌលសភាអាស៊ីត្រូវបំពេញការងាររបស់ខ្លួនទៅតាមគោលការណ៍ឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែង ដោយផ្ដោតជាសំខាន់លើគោលដៅនៃការបណ្ដុះបណ្ដាលជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការប្រតិបត្តិការងារជាក់ស្ដែង ដែលស៊ីចង្វាក់ទៅនឹងរបៀបវារៈការងាររបស់សភា។

យោងតាមវិធីសាស្ត្រនេះ មជ្ឈមណ្ឌលសភាអាស៊ីបានរៀបចំកម្មវិធីបណ្ដុះបណ្ដាលលើជំនាញជាច្រើន ដូចជា ជំនាញស្រាវជ្រាវសភា ការទូតសភា ការវិភាគថវិកា/ការិយាល័យថវិកាសភា កិច្ចការគណៈកម្មការសភា និងកម្មវិធីមួយចំនួនផ្សេងទៀត។ ក្នុងន័យធ្វើយ៉ាងណាឱ្យមានភាពស្របគ្នាបន្ថែមទៀតរវាងការអនុវត្តទៅនឹងតម្រូវការជាក់ស្ដែងរបស់សភាជាសមាជិកអាយប៉ា គ្រប់កម្មវិធីរបស់មជ្ឈមណ្ឌលសភាអាស៊ីតែងផ្សារភ្ជាប់ទៅនឹងមូលបទចំនួនបី ដែលមានវិសាលភាពលើសពីព្រំដែនជាតិ ហើយដែលជាមូលបទកំពុងមានការចាប់អារម្មណ៍ខ្លាំងនៅក្នុងតំបន់។ មូលបទទាំងនេះរួមមាន បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ការវិភាគសារពើពន្ធនិងសេដ្ឋកិច្ច និងការកសាងសន្តិភាពនិងសុវត្ថិភាពសាធារណៈតាមរយៈសភា ដោយក្នុងមូលបទនីមួយៗមានការបញ្ចូលនូវអភិក្រមផ្អែកតាមគោលការណ៍យេនឌ័រ និងសិទ្ធិមនុស្ស។

ការសម្រេចជោគជ័យលើមូលបទខាងលើ គឺទាមទារនូវកិច្ចខិតខំប្រឹងប្រែងពហុភាគី និងភាពជាម្ចាស់នៅក្នុងកម្រិតក្នុងស្រុក ឬកម្រិតជាតិ ដែលនេះជាចំណុចរួមគ្នាមួយស្របទៅនឹងប្រធានបទ ដែលសភាកម្ពុជាបានជ្រើសរើសសម្រាប់ក្រុមពិភាក្សានៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ (ASEP 11)។ ដូច្នេះមជ្ឈមណ្ឌលសភាអាស៊ី បានរៀបចំធ្វើការ **បោះពុម្ពជាពិសេស** នេះឡើង ដើម្បីគាំទ្រដល់ការចូលរួមនៅក្នុងព្រឹត្តការណ៍ដ៏មានសារៈសំខាន់នេះ។

ក្នុងនោះរួមមានជំពូកមួយ ដែលរៀបចំជាពិសេសសម្រាប់ប្រធានបទនៃក្រុមពិភាក្សានីមួយៗនៃកិច្ចប្រជុំខាងលើនេះ។ ជំពូកនេះមានទិសដៅ ដើម្បីបង្ហាញពីទស្សនៈរបស់ប្រជាពលរដ្ឋទាំងពីទ្វីបអាស៊ី និងអឺរ៉ុប ដោយធ្វើការគូសបញ្ជាក់ពីចំណុចគោលមួយចំនួននៃកិច្ចពិភាក្សា ដែលបានជ្រើសរើសដោយស្របគ្នាទៅនឹងបទពិសោធន៍របស់យើងដែលធ្វើការនៅក្នុងតំបន់។

នៅក្នុងជំពូកទី១ ស្ដីពី "បុរេសកម្មសភា ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម" អ្នកនិពន្ធបានព្យាយាមរំលេចអំពីការពង្រឹងកិច្ចសហប្រតិបត្តិការ ដោយប្រើប្រាស់នូវអភិក្រមតាមបែបអាស៊ី និងអឺរ៉ុប ចំពោះពហុភាគីនិយម និងចំពោះសេចក្ដីត្រូវការសម្រាប់បុរេសកម្មសភា ដើម្បីចូលរួមចំណែកឱ្យកាន់តែមានលក្ខណៈច្បាស់លាស់នៅក្នុងកិច្ចការនេះ ជាពិសេសសម្រាប់អ្នក ដែលពាក់ព័ន្ធនៅក្នុងដំណើរការពង្រឹងសន្តិភាព សន្តិសុខ និងការគ្រប់គ្រងគ្រាមានអាសន្នជាដើម។

ជំពូកទី២ មានការពិភាក្សាទៅលើ "ការលើកកម្ពស់ការស្ដារសេដ្ឋកិច្ចសកលឡើងវិញ ក្នុងសម័យ និងក្រោយវិបត្តិកូវីដ-១៩" ដោយផ្ដោតទៅលើ ការពង្រឹងប្រព័ន្ធពាណិជ្ជកម្មពហុភាគី រួមទាំងការកែទម្រង់អង្គការពាណិជ្ជកម្មពិភពលោក រួមជាមួយនឹងអភិក្រមឆ្ពោះទៅការកសាងសេដ្ឋកិច្ច ដែលមានភាពធន់ និងមានចីរភាព ក្នុងអំឡុងពេល និងក្រោយពីការងើបឡើងពីវិបត្តិនៃការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩។

អត្ថបទនៅក្នុងជំពូកទី ៣ បរិយាយអំពី "ការឆ្លើយតបទៅនឹងអន្តរកម្មនៃសន្តិសុខទឹក ថាមពល និងស្បៀង ក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ" ដោយរួមមានការពិភាក្សាពីតម្រូវការនូវការពង្រឹងសកម្មភាព ទាំងក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ ដើម្បីរួមគ្នាកម្រិតនូវការកើនឡើងនៃសីតុណ្ហភាពសកល ដើម្បីជួយបញ្ចៀសនូវមហន្តរាយបរិស្ថាន រួមមានទាំងផលប៉ះពាល់ដល់សុវត្ថិភាពនៃធនធាននិងជីវៈចម្រុះ។

ការវិភាគ និងទស្សនទាននានា ត្រូវបានលើកយកមកបង្ហាញដោយអ្នកស្រាវជ្រាវនៅក្នុងសៀវភៅនេះ។ ដូច្នេះមជ្ឈមណ្ឌលសភាអាស៊ីសង្ឃឹមថា ការបោះពុម្ពជាពិសេសនេះអាចចាត់ទុកថា ជាការចូលរួមចំណែកដ៏តូចមួយសម្រាប់ដំណើរការនៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប និងកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEP-ASEM) ហើយនេះជាការសរបញ្ជាក់នូវទស្សនៈមួយចំនួនរបស់ប្រជាពលរដ្ឋជូនដល់សមាជិក សមាជិកាសភា ដែលជាតំណាងរបស់ខ្លួន ដើម្បីយកទៅពិចារណា សម្រាប់កិច្ចប្រជុំនៃភាពជាដៃគូសភាអាស៊ី-អឺរ៉ុប នាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ នាពេលខាងមុខនេះ។

បន្ថែមពីលើការបោះពុម្ពមុនដំណើរការនៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ នេះ មជ្ឈមណ្ឌលសភាអាស៊ីនឹងធ្វើការបោះពុម្ពម្ដងទៀតនាក្រោយកិច្ចប្រជុំនេះ ដែលនឹងមានបញ្ចូលបន្ថែមនូវអត្ថបទ ដែលគ្របដណ្ដប់ទៅលើកិច្ចពិភាក្សាវែកញែកនៅក្នុងកិច្ចប្រជុំ និងអត្ថបទនៃសេចក្ដីថ្លែងការណ៍រួមនៃកិច្ចប្រជុំ។ ជាមួយគ្នានេះដែរ ការបោះពុម្ពជាពិសេសសម្រាប់កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប លើកទី១១ (ASEP 11) ធ្វើឡើងដើម្បីចូលរួមចំណែកគាំទ្រដល់ដំណើរការរៀបចំនៃកិច្ចប្រជុំផង និងសម្រាប់ផ្ដល់ជាយន្តការដល់ប្រជាពលរដ្ឋ ដែលមានចំណាប់អារម្មណ៍មកពីតំបន់ទាំងពីរ បានធ្វើការសិក្សា និងអាចផ្ដល់ជាធាតុចូលផង។

មជ្ឈមណ្ឌលសភាអាស៊ី សូមឆ្លៀតយកឱកាសនេះសម្ដែងនូវសេចក្ដីថ្លែងអំណរគុណ ចំពោះអ្នកស្រាវជ្រាវទាំងអស់ដែលបានចែករំលែកនូវទស្សនៈផ្ទាល់ខ្លួននៅក្នុងសៀវភៅនេះ។ ជាមួយគ្នានេះដែរ យើងក៏សូមអំពាវនាវដល់អ្នកអានទាំងអស់ សូមពិចារណាពីការចូលរួមជាអ្នកសរសេរនៅក្នុងសៀវភៅបែបនេះនាពេលអនាគត ដែលទស្សនៈរបស់ លោកអ្នក នឹងពិតជាអាចជួយដល់មជ្ឈមណ្ឌលសភាអាស៊ី ក្នុងការផ្ដល់ព័ត៌មានដែលមានបច្ចុប្បន្នភាព និងភាពសមស្របជានិច្ចជាមួយនឹងប្រធានបទថ្មីៗ ដែលជាផលប្រយោជន៍រួម។


**អ៊ុំ សារិទ្ធ**
**សមាជិកស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាល នៃ**
**មជ្ឈមណ្ឌលសភាអាស៊ី**

**គីម យាត ដារ៉ារិទ្ធ**
**សមាជិកស្ថាបនិក និងជានាយកប្រតិបត្តិ នៃ**
**មជ្ឈមណ្ឌលសភាអាស៊ី**


**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដែលបកដោយ មជ្ឈមណ្ឌលសភាអាស៊ី (PCAsia)។ អត្ថបទដើមជាភាសាអង់គ្លេសនៅទំព័របន្ទាប់។

# INTRODUCTION



The Parliamentary Centre of Asia (PCAsia) was established in early 2021 as the successor to the Parliamentary Institute of Cambodia (PIC), founded in 2011. First formed upon request of the Cambodian Parliament to develop the capacity of its staff, the evolution to PCAsia came from a desire among stakeholders to support parliamentary capacity development throughout Southeast Asia, to help strengthen the exchange of good parliamentary practices at the regional level, and to provide a focal point to collect and disseminate parliamentary research and knowledge among parliaments.

The mission of PCAsia, encouraged through resolutions of the General Assembly of the ASEAN Inter-parliamentary Assembly (AIPA), is to contribute to improving the capacity of parliamentary staff throughout the region to perform their roles efficiently and effectively, responding to requests from parliaments to provide training, enable exchange of experience, and promote friendship and mutual understanding. Through these means PCAsia endeavors to help facilitate experience sharing and triangular cooperation with the South and the North.

Fulfillment of PCAsia's mission is of special importance considering an implementation context that includes post-conflict and in-conflict societies. In such cases, a competent and neutral parliamentary administration is essential to help diffuse tensions and contribute to peace and stability through respective democratic mechanisms – a pre-condition for sustainable socio-economic development. To ensure parliamentary ownership of the activities, PCAsia adopts a demand-driven development process focusing on skills-based on-the-job training aligned with respective parliamentary agenda.

Taking this approach, PCAsia has put in place a number of programs including training on parliamentary research, parliamentary diplomacy, budget analysis/PBO, parliamentary committee work, and others. In order to further align its practices with the needs of AIPA Member Parliaments, all PCAsia programs incorporate a shared focus on three main transnational themes of particular interest to the region: Environment and Climate Change, Fiscal and Economic Analysis, and Peace-building and Public Safety through Parliaments, each integrating a human rights- and gender-based approach.

These PCAsia themes, all of which require multilateral efforts combined with ownership at the local or national level, have much in common with those selected as panel discussion topics for ASEP 11 by the Cambodian Parliament. Therefore, PCAsia has organized this Special Edition to support participation in this important event. One chapter is dedicated to each of the panel's discussion themes, designed to provide a variety of individual perspectives from citizens of both Asia and Europe, highlighting some key points of discussion selected in consideration of our experience working in the region.

In chapter one on "Proactive Parliaments for Peace, Security and Shared Prosperity" authors explore strengthening cooperation by utilizing the various European and Asian approaches to multilateralism and on the need for proactive parliaments to be firmly involved in those processes, especially those involving peace, security and emergency management.

Chapter two takes a look at "Promoting Global Economic Recovery in the Era of COVID-19 and Beyond" with a focus on strengthening multilateral trading systems including reform of the WTO, together with approaches towards building resilient and sustainable economies during the post-pandemic recovery.

Articles in the final chapter three on "Addressing the Water-Energy-Food Security Nexus under Climate Change" discuss the need for strengthened action at the national, regional and international levels to limit the rise in global temperatures to help avert environmental catastrophes including those affecting resource security and biodiversity.

While the analysis and opinions expressed within are those of the authors, PCAsia hopes that this volume can be considered as a modest contribution to the ASEP-ASEM process, presenting a sample of citizen views for consideration by their parliamentary representatives during the ASEP 11 meeting on 16 Nov 2021.

In addition to this pre-ASEP 11 edition, PCAsia will print a post-ASEP 11 version integrating texts covering the meeting discussions and debates, as well as the final Declaration. Together, these ASEP 11 Special Editions are being produced in support of the ASEP meeting, offering a channel for interested citizens from both continents to learn about and provide input to the ASEP-ASEM process.

PCAsia would like to take this opportunity to thank all the authors who have shared their individual perspectives. We also call upon readers to act as future contributors, whose insights can help PCAsia to provide information that is always current and relevant on these subjects of shared interest.

**HE Mr OUM Sarith**
Founding Member &
Chair of PCAsia BoD

**Mr Dararith KIM YEAT**
Founding Member &
Executive Director

# សេចក្តីសង្ខេបនៃបទវិភាគ

## សេចក្តីផ្តើម

ការបោះពុម្ពផ្សាយពិសេសសម្រាប់កិច្ចប្រជុំភាពជាដៃគូសភាអាស៊ីអឺរ៉ុបលើកទី១១ អំពីបុរេសកម្មនៃការទូតសភា ជាបណ្តុំនៃមតិយោបល់និងការយល់ឃើញពីអ្នកជំនាញនិងពលរដ្ឋពីអឺរ៉ុប និងអាស៊ី។ គោលបំណងនៃសៀវភៅនេះគឺដើម្បីចែករំលែកទស្សនៈជាលក្ខណៈបុគ្គលជាមួយសមាជិក សមាជិកាសភា សម្រាប់ជាមូលដ្ឋានក្នុងការពិនិត្យ និងពិភាក្សាច្បាប់ និងក្នុងការជះឥទ្ធិពលដល់ការយល់ឃើញរបស់រដ្ឋាភិបាលរៀងៗខ្លួនអំពីវិធីសាស្ត្រល្អបំផុតក្នុងការដោះស្រាយបញ្ហាបន្ទាន់ៗសព្វថ្ងៃនេះ។ ក្នុងកម្មវិធីទាំងឡាយណាដែលសមាជិក សមាជិកាសភាជួបប្រជុំគ្នា ដូចជាកិច្ចប្រជុំភាពជាដៃគូសភាអាស៊ីអឺរ៉ុបលើកទី១១ (ASEP 11) ទស្សនៈរបស់ពលរដ្ឋប្រកបដោយពិពិធភាពទាំងនេះអាចជួយសម្រួលកិច្ចសន្ទនារវាងប្រជាជាតិនិងប្រជាជាតិនៅទ្វីបផ្សេងៗគ្នា។ ក្នុងនាមជាអ្នកតំណាងពលរដ្ឋ សមាជិក សមាជិកាសភាមានទំនួលខុសត្រូវក្នុងការពិចារណាមតិយោបល់របស់ពលរដ្ឋ។ កិច្ចការទាំងនេះអាចជួយរដ្ឋាភិបាលក្នុងការទទួលស្គាល់មតិយោបល់ផ្សេងៗដែលស្តែងចេញតាមរយៈសភា ជាពិសេសនៅពេលដែលសភាទាំងនោះចូលរួមជាមួយគ្នា បង្កើតជាកិច្ចព្រមព្រៀងបែបកុងសង់ស៊ីស និងបង្ហាញជំហររួមមួយ។ ជាសេចក្តីផ្តើម អត្ថបទនៃបទវិភាគនេះនឹងចែករំលែកការយល់ឃើញចេញពីការសម្រាំងយកអត្ថបទមួយចំនួនដើម្បីផ្តល់ជាសេចក្តីសង្ខេបជាមុនពីទស្សនៈផ្សេងៗដែលមាននៅក្នុងសៀវភៅនេះ។

## បុរេសកម្មសភាដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម

ក្នុងសតវត្សរ៍ទី២១ ឱកាសនិងបញ្ហាប្រឈមជាច្រើនឆ្លងហួសពីព្រំដែននៃរដ្ឋនីមួយៗ ហើយទាមទារនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ។ បច្ចុប្បន្ន លើសពេលណាៗទាំងអស់ តថភាពនេះកំពុងត្រូវបានស្តែងឲ្យឃើញកាន់តែច្បាស់តាមរយៈការរាតត្បាតជាសកលនៃជំងឺកូវីដ១៩ និងតម្រូវការរបស់យើងក្នុងការធ្វើការរួមគ្នាក្នុងនាមជាប្រជាជាតិផ្សេងៗដើម្បីដោះស្រាយបញ្ហាប្រឈមមួយនេះដែលមិនធ្លាប់ជួបប្រទះពីមុនមក។ អង្គការពហុភាគីជាច្រើនបានលេចរូបរាងតាំងពីការបិទបញ្ចប់សង្គ្រាមលោកលើកទី២ ដើម្បីជំរុញស្ថិរភាពតំបន់ គ្រប់គ្រងជម្លោះនិងវិបត្តិសុខភាព សម្រេចគោលដៅរួម និងដោះស្រាយបញ្ហាប្រឈមសកលផ្សេងៗទៀតដោយផ្អែកទៅតាមក្បួនច្បាប់នានា។ បញ្ហានៅត្រង់ថាសេចក្តីសម្រេចពហុភាគីភាគច្រើនត្រូវបានធ្វើឡើងនៅក្រៅដែនសមត្ថកិច្ចរបស់ស្ថាប័ននានាដែលតំណាងពលរដ្ឋ។ នេះជាភាពទន់ខ្សោយមួយដែលអាចនាំមកនូវកង្វះការគាំទ្រពីសំណាក់ពលរដ្ឋទូទៅ។ ការទូតសភា ជាពិសេសការទូតសភាពហុភាគី នាំយកមតិយោបល់របស់ពលរដ្ឋទៅកាន់វេទិកាតស៊ូមតិ និងការចចារកិច្ចការសកល និងផ្តល់ជាយានក្នុងការចែករំលែកទស្សនៈរបស់ពួកគេក្នុងអំឡុងពេលវិបត្តិតាមរយៈសភារបស់ពួកគេផ្ទាល់។ វាជាការផ្តល់ធម្មានុរូបភាព ទម្ងន់នយោបាយ និងភាពធន់ ទៅដល់ការសម្រេចចិត្តទាំងនេះ ក៏ដូចជាជួយឲ្យអង្គការអន្តររដ្ឋាភិបាលកាន់តែមានគណនេយ្យភាព និងតម្លាភាព ស្របពេលជំរុញឲ្យមានការយល់ពីគ្នារវាងពលរដ្ឋនិងប្រទេស។

ការរីករាលដាលជាសកលនៃវីរុសកូវីដ១៩ ជាបញ្ហាប្រឈមមិនធ្លាប់មានពីមុនចំពោះរដ្ឋាភិបាល ពលរដ្ឋ និងសភានានានៅក្នុងពិភពលោក។ ក្នុងទ្វីបអាស៊ី អឺរ៉ុប និងទ្វីបដទៃ ប្រជាពលរដ្ឋមិនត្រឹមតែទទួលរងការគំរាមកំហែងផ្នែកសុខភាពប៉ុណ្ណោះទេ តែជីវភាពនិងសេរីភាពប្រចាំថ្ងៃក៏រងផលប៉ះពាល់ដែរ។ នៅក្នុងអត្ថបទនេះបង្ហាញថា សភាជាច្រើនដែលកំពុងប្រើប្រាស់ឧបករណ៍និងនីតិវិធីថ្មីៗចុងក្រោយ បានបំពេញតួនាទីដ៏សំខាន់ក្នុងការសហការជាមួយរដ្ឋាភិបាលដើម្បីជួយទប់ស្កាត់ផលប៉ះពាល់ដល់សុខភាពនិងសន្តិសុខសេដ្ឋកិច្ច។ នៅប្រទេសបារាំង សំណុំនៃច្បាប់ជាច្រើន រួមមាន "សេចក្តីថ្លែងការណ៍ស្តីពីស្ថានភាពអាសន្ននៃសុខភាព" ត្រូវបានអនុម័តដោយសភាទាំងពីរថ្នាក់ ដោយផ្តល់អាទិភាពទៅលើកិច្ចព្រមព្រៀងនយោបាយជាតិបែបកុងសង់ស៊ីស ដោយទទួលស្គាល់ថា កិច្ចប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកម្រិតសិទ្ធិពលរដ្ឋដើម្បីផលប្រយោជន៍រួម ពេលខ្លះគួរត្រូវតែត្បិតដៃក្រោយមានការពិចារណាសមម្យេមួយ។ នៅប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០២០ សភាជាន់ទាបបានដឹកនាំកិច្ចប្រជុំមួយតាមរយៈសន្និសីទវីដេអូ ដោយពិនិត្យលើ "តួនាទីសភាសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការកម្ចាត់ជំងឺកូវីដ១៩" ដែលផ្តល់ឱកាសឲ្យអ្នកចូលរួមប្រៀបធៀបកិច្ចការដែលបានធ្វើនៅប្រទេសជាច្រើនផ្សេងៗគ្នា និងពិភាក្សាពីវិធីបង្កើនកិច្ចសហប្រតិបត្តិការក្នុងការឆ្លើយតបនឹងជំងឺរាតត្បាតសកលប្រកបដោយប្រសិទ្ធភាពខ្ពស់។

ផ្ទុយពីកិច្ចការដ៏សំខាន់ដែលបំពេញដោយសភាមួយចំនួន ឱកាសជាច្រើន សម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិរួម មានការផ្លាស់ប្តូរព័ត៌មាន និងការសហការលើការព្យាបាលនិងជម្រើសនៃការស្រាវជ្រាវនានាបានមើលរំលងទាំងស្រុងដោយសារតែកង្វះឆន្ទៈនយោបាយ។ នៅក្នុងអត្ថបទនេះបង្ហាញថា ការបំពេញការងាររបស់សភា ដោយសភារៀងៗខ្លួនក្តី និងជាសមូហភាពក្តីបានឆ្លុះបញ្ចាំងពីផលប្រយោជន៍ដែលប្រទេសនីមួយៗមានសភាដែលមានអំណាចមិនថាក្នុងកំរិតជាតិតំបន់ ឬអន្តរជាតិ។

នេះមិនមែនចង់និយាយថា មានវិធីសាស្ត្រតែមួយ ដែលអាចយកទៅអនុវត្តគ្រប់កាលៈទេសៈនោះទេ។ ខុសពីអភិក្រម អឺរ៉ុបចំពោះពហុភាគីនិយកម្ម ដែលផ្តោតសំខាន់លើស្ថាប័នប្រកបដោយបរិយាបន្ននិងគ្រប់ជ្រុងជ្រោយជាមួយនឹងការប្តេជ្ញារបស់រដ្ឋសមាជិកដែលចងដោយច្បាប់ "វិធីរបស់អាស៊ាន" បានជ្រើសយកនីតិវិធីដែលមានលក្ខណៈក្រៅផ្លូវការ ពោលគឺតំបន់និយកម្មដែលចូលរួមដោយពហុក្រុម និងរួមមានវេទិកានានាជាច្រើន ជាមួយនឹងសេចក្តីសម្រេចចិត្តដែលមិនត្រូវចងដោយច្បាប់ និងផ្អែកលើកិច្ចព្រមព្រៀងជាលក្ខណៈកុងសង់ស៊ីស។ បញ្ហាប្រឈមធំបំផុតសម្រាប់តំបន់អាស៊ាន និងប្រហែលសម្រាប់ពិភពលោកទាំងមូល គឺជម្លោះរវាងមហាអំណាចធំៗ និងកង្វះសមត្ថភាពក្នុងការរឹតត្បិតសកម្មភាពរបស់ពួកគេ។ ជម្រើសទ្វេភាគីនិយមពីសំណាក់សហរដ្ឋអាម៉េរិកនិងចិន កំពុងក្លាយជាឧបសគ្គរាំងស្ទះដល់ពហុភាគីនិយមនិយាយជារួម និងប៉ះពាល់ដល់ភាពមជ្ឈភាពអាស៊ាន ភាពស្អិតរមួត និងសារៈសំខាន់របស់អង្គការនេះ បើនិយាយដោយឡែក។

បញ្ហាប្រឈមចំពោះពហុភាគីនិយមនេះទាមទារឲ្យសភាមានភាពបុរេសកម្មកាន់តែខ្លាំង និងពង្រឹងតួនាទីដែលមានស្រាប់និងតួនាទីថ្មីរបស់ខ្លួន រួមមានតួនាទីនៃការទូតសភាជាដើម។ សមាជិកសភាអាចបញ្ជូនសារនិងលើកកម្ពស់ផលប្រយោជន៍ជាតិរបស់ខ្លួន ហើយក្នុងពេលជាមួយគ្នានោះក៏អាចលើកទឹកចិត្តស្ថាប័ននីតិប្រតិបត្តិរបស់ខ្លួនឲ្យលះបង់ក្តីបារម្ភបន្ទាន់របស់ប្រទេសខ្លួននៅពេលខ្លះ ដើម្បីឈោងចាប់អភិក្រមបែបសហប្រតិបត្តិការដែលជាយានឆ្ពោះទៅដោះស្រាយបញ្ហាប្រឈមសកលរយៈពេលយូរប្រកបដោយចីរភាព។ កិច្ចការនេះអាចរាប់បញ្ចូលការគាំទ្រកិច្ចប្រឹងប្រែងបែបពហុភាគីក្នុងការប្រយុទ្ធប្រឆាំងការប្រែប្រួលអាកាសធាតុ វិធានការណ៍សេដ្ឋកិច្ចនិងរូបិយវត្ថុក្នុងការដោះស្រាយ និងការងើបឡើងវិញពីវិបត្តិដែលបណ្តាលមកពីកូវីដ១៩ និងគំនិតផ្តួចផ្តើមសង្គមនិងសុខភាព ដើម្បីឲ្យពិភពលោកត្រៀមខ្លួនប្រសើរជាងមុនក្នុងការទប់ទល់ទៅនឹងគ្រោះអាសន្ននានានៅពេលអនាគត។ ជាការពិតណាស់ កិច្ចប្រឹងប្រែងទាំងអស់នេះត្រូវតែរួមបញ្ចូលនូវតួនាទីតំណាង និងភាពជាអ្នកដឹកនាំដ៏រឹងមាំរបស់ស្ត្រី ជាពិសេសក្នុងដំណើរការដោះស្រាយជម្លោះ និងការកសាងសន្តិភាព។ ជាផ្នែកមួយនៃកិច្ចប្រឹងប្រែងទាំងនេះ អាស៊ីនិងអាស៊ានគួរតែព្យាយាមកសាងភាពជាដៃគូកាន់តែរឹងមាំជាមួយនឹងសហភាពអឺរ៉ុប ដែលអាចសហការជាមួយគ្នាក្នុងការបង្កើតសណ្តាប់ធ្នាប់ថ្មីមួយនៃពហុភាគីនិយមដែលមានគោលដៅដោះស្រាយបញ្ហាប្រឈមរួម និងបញ្ចៀសគ្រោះថ្នាក់នៃជម្លោះនិងការប៉ះទង្គិចរវាងមហាអំណាចនានា។

## ការលើកកម្ពស់ការងើបឡើងវិញនៃសេដ្ឋកិច្ចសកលក្នុងបរិបទកូវីដ១៩ និងក្រោយកូវីដ១៩

ក្នុងនាមជាស្ថាប័នស្នូលមួយនៃពហុភាគីនិយម អង្គការពាណិជ្ជកម្មពិភពលោកមានការវិវត្តគួរឲ្យកត់សម្គាល់ ដោយធ្វើឲ្យមានប្រព័ន្ធពាណិជ្ជកម្មពិភពលោកសេរីស្ទើរតែទាំងស្រុង ជាពិសេសការកាត់បន្ថយពន្ធនាំចូលរវាងប្រទេសនានា ស្របពេលជាមួយគ្នានេះ ក៏សង្កត់ធ្ងន់ទៅលើគោលការណ៍ដូចជា សមភាព កិច្ចសហប្រតិបត្តិការ និងការចរចា ដែលរួមចំណែកជួយឲ្យមានសន្តិភាព។ ប្រព័ន្ធពាណិជ្ជកម្មពហុភាគីដែលផ្អែកលើបទបញ្ញត្តិនេះបានផ្តល់ប្រយោជន៍យ៉ាងធំធេងដល់ទាំងប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍។ ប្រព័ន្ធនេះបានជួយឲ្យអាស៊ីធ្វើសមាហរណកម្មចូលទៅក្នុងទីផ្សារពិភពលោកយ៉ាងទូលំទូលាយដែលនាំឲ្យមានកំណើននៃការនាំចេញយ៉ាងគំហុក បង្កើតបានកំណើនការងាររាប់លានកន្លែង និងធ្វើកម្រិតនៃការអភិវឌ្ឍមានកំណើនថេរ។ អ្នកប្រើប្រាស់នៅអឺរ៉ុបបានទទួលប្រយោជន៍ពីទំនិញនិងសេវាកម្មពីអាស៊ីក្នុងតម្លៃថោកជាងមុន។ ក៏ប៉ុន្តែបញ្ហាធំៗបានកើតឡើង។ សហរដ្ឋអាម៉េរិក ដែលជាស្ថាបនិកចម្បងមួយនៃសណ្តាប់ធ្នាប់អន្តរជាតិក្រោយឆ្នាំ១៩៤៥ កំពុងតែងាកទៅរកការចរចាទ្វេភាគី ហើយថែមទាំងមានសង្គ្រាមពន្ធនាំចូលជាមួយនឹងដៃគូពាណិជ្ជកម្មរបស់ខ្លួនទៀត។ ប្រព័ន្ធដោះស្រាយជម្លោះរបស់អង្គការពាណិជ្ជកម្មពិភពលោក កំពុងត្រូវបានគំរាមកំហែងខ្លាំង ពេលដែលសហរដ្ឋអាម៉េរិកបានរាំងការតែងតាំងបេក្ខជនទៅកាន់សាលាឧទ្ធរណ៍ ដោយសារក្តីព្រួយបារម្ភអំពី អភិក្រមបែបសកម្មនិយម និងពីការគំរាមកំហែងដល់អធិបតេយ្យភាពរដ្ឋ។

ជាការឆ្លើយតប អាស៊ីកំពុងដំណើរការនូវផែនការទាក់ទងនឹងគំនិតផ្តួចផ្តើមអន្តរតំបន់ដូចជា CPTPP និង RCEP-16 ហើយ RCEP-16 នេះអាចនឹងក្លាយជាកិច្ចព្រមព្រៀងពាណិជ្ជកម្មធំបំផុតរបស់ពិភពលោកបើគិតលើចំនួនប្រជាជន និងចំណូលសរុប។ សហភាពអឺរ៉ុបកំពុងស្វះស្វែងឲ្យមានកំណែទម្រង់អង្គការពាណិជ្ជកម្មពិភពលោកតាមរយៈការពង្រឹងការអនុវត្តច្បាប់ ការផ្តល់អំណាចទៅឲ្យគណៈកម្មាធិការក្នុងការកែប្រែច្បាប់ជាបន្តបន្ទាប់ និងការព្យាយាមកាត់បន្ថយក្តីព្រួយបារម្ភរបស់សហរដ្ឋអាម៉េរិកអំពី សាលាឧទ្ធរណ៍។

ក៏ប៉ុន្តែ កិច្ចការជាច្រើនទៀតចាំបាច់ត្រូវធ្វើដើម្បីដោះស្រាយភាពតានតឹងដ៏ធំមួយក្នុងសកលភាវូបនីយកម្ម។ ភាពតានតឹងនោះក៏ដោយសារតែ រដ្ឋនីមួយៗចង់បានអធិបតេយ្យភាពពេញលេញ ហើយពលរដ្ឋទាមទារនូវសិទ្ធិបញ្ចេញមតិលើសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់ជីវភាពរបស់ពួកគេ ខណៈដែលពាណិជ្ជកម្មពិភពលោកទាមទារនូវប្រព័ន្ធពហុភាគីដែលផ្អែកទៅលើច្បាប់។ ការដែលប្រព័ន្ធនេះជារឿយៗមានលក្ខណៈការិយាធិបតេយ្យ មានគម្លាតនិងកាត់ផ្តាច់ពីប្រជាពលរដ្ឋ អាចមើលឃើញយ៉ាងច្បាស់តាមរយៈភាពបរាជ័យនៃការចរចា TTIP រវាងសហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប។ ហេតុនេះ ដើម្បីកសាងប្រព័ន្ធពហុភាគីដែលកាន់តែរឹងមាំនិងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងពាណិជ្ជកម្មពិភពលោកនិងបទបញ្ញត្តិនានា ការបញ្ចេញមតិយោបល់របស់ប្រជាពលរដ្ឋនិងស្ថាប័នតំណាងរបស់ពួកគេគួរតែមានតួនាទីកាន់តែធំ។

កិច្ចការនេះមានសារៈសំខាន់ណាស់ ដោយសារពិភពលោកមានគម្រោងធ្វើឱ្យមានការងើបឡើងវិញនូវសេដ្ឋកិច្ចប្រកបដោយចីរភាពពីវិបត្តិកូវីដ១៩។ អាស៊ាន និងរដ្ឋជាសមាជិកបានអនុវត្តនូវវិធិសាស្ត្រមួយ ដែលផ្តោតលើការពង្រឹងសង្វាក់នៃការផ្គត់ផ្គង់ និងការធ្វើពិពិធកម្មបណ្តាញនៃការផ្គត់ផ្គង់ ពាណិជ្ជកម្ម រួមទាំងការសម្របសម្រួល និងការធ្វើសេរីភាវូបនីយកម្មវិនិយោគ ដែលរួមមានការកសាងទីផ្សារអាស៊ានមួយប្រកបដោយភាពប្រកួតប្រជែង។ ដើម្បីពង្រឹងនូវភាពប្រកួតប្រជែងនៃតំបន់នេះ រដ្ឋជាសមាជិកបានចាប់ផ្តើមវិនិយោគលើបច្ចេកវិទ្យា និងប្រព័ន្ធឌីជីថល ការអភិវឌ្ឍជំនាញ និងការគាំពារសង្គម។ ដោយឆ្លុះបញ្ចាំងនូវអាទិភាពរបស់ខ្លួន ផែនការស្តារឡើងវិញរបស់អឺរ៉ុបបានសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាអឺរ៉ុបនាខែកក្កដា ឆ្នាំ២០២០ ដោយបានអនុម័តនូវទឹកប្រាក់សរុបចំនួន ៧៥០ ប៊ីលានយូរ៉ូទាំងកម្ចី និងជំនួយឥតសំណងសម្រាប់ប្រទេសជាសមាជិក ដើម្បីសម្រេចនូវវត្ថុបំណងក្នុងការបង្កើតការងារ គាំទ្រកំណើន បង្កើនភាពធនផ្នែកសេដ្ឋកិច្ច និងសង្គម និងលើកកម្ពស់ការផ្លាស់ប្តូរបែបឌីជីថល និងបៃតង។ ដើម្បីទទួលបាននូវថវិកាខាងលើនេះ ផែនការស្តារឡើងវិញរបស់ជាតិនីមួយៗត្រូវតែបង្ហាញនូវគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងថាមពលស្អាត និងអាចផលិតឡើងវិញ ការកសាងនូវការជួសជុលឡើងវិញ ការកសាងបណ្តាញ ការតភ្ជាប់ ការធ្វើទំនើបកម្មឌីជីថលក្នុងវិស័យសាធារណៈ (រួមមានផ្នែកសុខាភិបាល និងយុត្តិធម៌) ការរក្សាទុកនូវទិន្នន័យផ្នែកឧស្សាហកម្ម និងការអប់រំតាមបែបឌីជីថល។

## ការដោះស្រាយបញ្ហាអន្តរកម្មនៃសន្តិសុខទឹក ថាមពល និងស្បៀងក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ

ដើម្បីទទួលបានការយល់ដឹងអំពីអន្តរកម្មរវាងសន្តិសុខធនធាន និងការប្រែប្រួលអាកាសធាតុ សៀវភៅផែនទីនេះផ្តល់ការយល់ឃើញអំពី សន្តិសុខថាមពលពីអឺរ៉ុប និងការយល់ឃើញអំពីសន្តិសុខស្បៀងពីអាស៊ី ជាមួយនឹងពិពិធភាពនៃការយល់ឃើញអំពីមូលហេតុផ្សេងៗ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងវិធីសាស្ត្រខ្លះៗ ដែលនឹងត្រូវយកមកអនុវត្តក្នុងការដោះស្រាយបញ្ហាទាំងនោះ។

ខណៈដែលការផ្គត់ផ្គង់ស្បៀង និងថាមពលទៀងទាត់ មានសារៈសំខាន់ចំពោះប្រជាជនក្នុងសម័យទំនើប ផលប៉ះពាល់ដល់បរិស្ថាន និងជីវិសាស្ត្រចម្រុះក៏ចាំបាច់ត្រូវបានពិចារណាផងដែរ។ ជាផ្នែកមួយនៃការធ្វើឲ្យមានតុល្យភាពនេះ សហភាពអឺរ៉ុបបានជម្រុញឲ្យមានការលូតលាស់នៃប្រភពថាមពលជំនួសផ្សេងៗនៅអឺរ៉ុប។ ស្របពេលដែលមានភាពវិជ្ជមានក្នុងវិស័យអាកាសធាតុ ផលវិបាកមួយទៀត គឺការថយចុះនៃផលិតកម្មថាមពលសរុប ដោយសារកម្រិតនៃផលិតកម្មសម្រាប់ប្រភពថាមពលមិនកកើតឡើងវិញបានធ្លាក់ចុះ។ សព្វថ្ងៃនេះ លើសពីពាក់កណ្តាលនៃតម្រូវការថាមពលរបស់សហភាពអឺរ៉ុបត្រូវបានផ្គត់ផ្គង់ដោយបណ្តាប្រទេសនៅក្រៅសហភាពអឺរ៉ុប ដែលបង្កឲ្យមានស្ថានភាពភូមិសាស្ត្រនយោបាយមួយដែលស្មុគស្មាញ និងមិននឹងនរ។

បញ្ហាធនធានដ៏ធំមួយសម្រាប់អាស៊ី គឺការផ្គត់ផ្គង់ស្បៀង ស្របពេលដែលតំបន់នេះកំពុងមានតម្រូវការស្បៀងខ្ពស់បំផុត ហើយខណៈប្រជាជនក៏កំពុងកើនឡើងយ៉ាងឆាប់រហ័ស។ គួរឲ្យព្រួយបារម្ភ ការសិក្សាបានបង្ហាញថា សីតុណ្ហភាពកើនឡើងអាចនឹងបណ្តាលឲ្យមានការធ្លាក់ចុះនូវទិន្នផលដំណាំយ៉ាងគំហុកក្នុងប៉ុន្មានទសវត្សរ៍ខាងមុខនេះ។ សភាសិង្ហបុរីបានបោះជំហានដ៏សំខាន់ក្នុងការដោះស្រាយបញ្ហានេះនៅពេលដែលខ្លួនបានបង្កើត “ភ្នាក់ងារស្បៀងសិង្ហបុរី”។ ភ្នាក់ងារនេះកំពុង

បំពេញភារកិច្ចស្វែងរកវិធីនានាសម្រាប់ឲ្យទីក្រុងទាំងឡាយដែលជាទីលំនៅនៃប្រជាជនពាក់កណ្តាលនៃប្រជាជនសរុបរបស់ពិភពលោក រួមចំណែកដល់ផលិតកម្មស្បៀងសកលជាមួយនឹងវិធីសាស្ត្រកសិដ្ឋានទីក្រុងប្រកបដោយចីរភាព និងការបង្រួញខ្សែចង្វាក់ការផ្គត់ផ្គង់ស្បៀង ដែលអាចជួយបង្ការការខ្វះខាតចំណីអាហារ និងកាត់បន្ថយដានកាបូនរបស់ស្បៀង។

ប៉ុន្តែសន្តិសុខស្បៀងមិនមែនជាក្តីព្រួយបារម្ភធំតែមួយគត់របស់អាស៊ីទេ។ ក្នុងនាមជាប្រភពនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពាក់កណ្តាលនៃការបញ្ចេញសរុបរបស់ពិភពលោក អាស៊ីក៏ជាតំបន់ដែលងាយប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ កាន់តែធ្ងន់ធ្ងរជាងនេះទៀតនោះ ទីក្រុងធំៗនៃអាស៊ីអាគ្នេយ៍មានទីតាំងឋិតនៅលើដីទន់ក្នុងតំបន់ដីល្បាប់ និងតំបន់ដីសណ្តទីដែលមានការវិវត្តនគរូបនីយកម្មដ៏ឆាប់រហ័ស និងការប្រើប្រាស់ទឹកក្រោមដីច្រើន កំពុងបណ្តាលឲ្យមានការស្រុតលិចផ្ទៃដីខាងលើ ដែលនាំឲ្យមានការកើនឡើងនៃទឹកជំនន់។ បញ្ហាប្រឈមមួយទៀតសម្រាប់អាស៊ីនោះគឺការកាប់បំផ្លាញព្រៃឈើដែលភាគច្រើនបណ្តាលមកពីការទន្ទ្រានយកដីដើម្បីធ្វើកសិកម្ម និងការកាប់ឈើ។ ហេតុការណ៍នេះត្រូវបានជំរុញដោយតម្រូវការសកលដ៏ច្រើនសម្បើមលើកសិផល និងការកើនឡើងនៃវិនិយោគពីអន្តរជាតិ ជាមួយនឹងភាពលំបាកក្នុងការអនុម័តច្បាប់ប្រកបដោយប្រសិទ្ធភាព ហើយពេលខ្លះការអនុវត្តច្បាប់ដែលមានស្រាប់ក៏នៅមានលក្ខណៈទន់ខ្សោយនៅឡើយ។ នេះជាមូលហេតុដែលរួមចំណែកបង្កើនបរិមាណឧស្ម័នកាបូនិកនៅក្នុងបរិយាកាស ដែលនាំឲ្យឡើងកម្តៅផែនដីនិងកើនកម្ពស់ទឹកសមុទ្រ។ ទោះយ៉ាងណាក៏ដោយ មានសញ្ញានៃការលើកទឹកចិត្តមួយចំនួន ដែលគួរឱ្យកត់សម្គាល់ពោលគឺទីផ្សារកាបូនរបស់ប្រទេសចិន ដែលតំណាងនូវជំហានដ៏សំខាន់នៃការប្តេជ្ញាចិត្តរបស់អាស៊ីក្នុងការអភិវឌ្ឍអាកាសធាតុប្រកបដោយចីរភាព។

ទន្ទឹមនឹងនេះ សហភាពអឺរ៉ុបក៏កំពុងប្រឈមមុខនឹងបញ្ហាផ្សេងៗរបស់ខ្លួនផងដែរ ស្របពេលដែលខ្លួនព្យាយាមក្លាយជាអ្នកដឹកនាំសកលក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងការគម្រាមកំហែងទៅនឹងជីវសាស្ត្រចម្រុះ។ ក្រោយជោគជ័យជាច្រើនរួមមាន កិច្ចព្រមព្រៀងទីក្រុងប៉ារីស និងសន្និសីទការប្រែប្រួលអាកាសធាតុសហប្រជាជាតិ ក្នុងឆ្នាំ២០១៧ សហភាពអឺរ៉ុបបានសម្រេចខ្លះៗនូវការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ស្របពេលដែលខ្លួនអាចរក្សាអត្រាកំណើនសេដ្ឋកិច្ចដ៏ល្អមួយ ក៏ប៉ុន្តែគោលដៅអាកាសធាតុជាតិបច្ចុប្បន្ននៅតែមិនទាន់សម្រេចបានដូចការប្តេជ្ញាក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។ កិច្ចព្រមព្រៀងបៃតងអឺរ៉ុបគឺជាជំហានបន្ទាប់ដ៏សំខាន់មួយឆ្ពោះទៅគោលដៅក្នុងការសម្រេចបាននូវអព្យាក្រឹត្យកាបូនក្នុងតំបន់អឺរ៉ុប ដែលបង្កើតនូវវេទិកាមួយសម្រាប់កម្មវិធី៥៥ នៅក្នុងតំបន់អឺរ៉ុប (EU Fit-for-55 program) ដែលពង្រឹងនូវការប្តេជ្ញាចិត្ត ខណៈស្វែងរកការដឹកនាំពិភពលោកមួយ ដែលតម្រូវឲ្យមានការពិចារណាឡើងវិញនូវគោលនយោបាយនានាទាក់ទងនឹងធនធាននិងបរិស្ថាន។ ឆ្លើយតបចំពោះបញ្ហាទាំងនេះនៅថ្នាក់ជាតិ សភាអាចរួមចំណែកតាមរយៈការបង្កើតច្បាប់ប្រកបដោយការគិតគូរពិចារណាគ្រប់ជ្រុងជ្រោយ លើកកម្ពស់ការយល់ដឹងសាធារណៈ និងជួយពាំនាំមតិយោបល់ពីអង្គការសង្គមស៊ីវិលក៏ដូចជាតាមដាននិងត្រួតពិនិត្យ ការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពពីសំណាក់រដ្ឋាភិបាល ភ្នាក់ងារនិងស្ថាប័នជំនាញពហុភាគីនានា។ ការរួមចំណែកនេះក៏អាចជួយដល់សកម្មភាពពហុភាគីនានាតាមរយៈការនាំមកនូវធម្មានុរូបភាព និងគណនេយ្យភាពប្រជាធិបតេយ្យទៅកាន់កិច្ចប្រឹងប្រែងនានាក្នុងការបន្សាំខ្លួន និងកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ កិច្ចប្រជុំអន្តរសភា (ដូចជា ASEP, IPU, AIPA -ល-) ក៏ជាព្រឹត្តិការណ៍សំខាន់ផងដែរសម្រាប់ការផ្លាស់ប្តូរទៅវិញទៅមកដែលអាចប្រើប្រាស់សម្រាប់ជម្រុញកិច្ចព្រមព្រៀងអន្តរតំបន់ និងការប្តេជ្ញាចិត្តរួម។

## សេចក្តីបញ្ចប់

រួមជាមួយនឹងតំណាងសភាពីអាស៊ីនិងអឺរ៉ុប មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) មានការប្តេជ្ញាចិត្តរួមគ្នាមួយក្នុងការកសាងការយល់ដឹងលើបញ្ហាដែលប៉ះពាល់ដល់យើងទាំងអស់គ្នា ដែលរួមមានបញ្ហាសន្តិសុខផ្នែកសុខាភិបាលនិងការគ្រប់គ្រងវិបត្តិ បញ្ហាសេដ្ឋកិច្ចនិងពាណិជ្ជកម្ម និងបញ្ហាប្រែប្រួលអាកាសធាតុនិងសន្តិសុខផ្នែកធនធាន។ ស្របពេលដែលសភាកំពុងមានភាពបុរេសកម្មក្នុងការបង្កើនតួនាទីរបស់ខ្លួន ដើម្បីពង្រឹងការកសាងសន្តិភាព ការប្រឹងប្រែងចងក្រងសៀវភៅនេះ គឺសំដៅជួយផ្តល់មតិយោបល់ទៅកាន់អ្នកពាក់ព័ន្ធជាច្រើនផ្សេងៗគ្នាដែលមានចំណែកសំខាន់ក្នុងដំណើរការនៃកិច្ចសន្ទនា និងជួយដោះស្រាយជម្លោះដែលចាំបាច់ក្នុងការកសាងពិភពលោកមួយដែលប្រកបដោយសន្តិភាពនិងស្ថិរភាពប្រសើរជាងមុន។ PCAsia សង្ឃឹមថា ការរួមចំណែកពីសំណាក់អ្នកជំនាញនិងពលរដ្ឋក្នុងសៀវភៅនេះអាចផ្តល់ជាទស្សនៈថ្មីៗសម្រាប់សមាជិក សមាជិកាសភា នៅក្នុងដំណើរការបំពេញមុខងាររបស់ខ្លួន ដើម្បីសម្រេចគោលដៅទាំងនេះ ដែលរួមចំណែកជួយកសាងអនាគតមួយប្រកបដោយបរិស្ថានស្អាត មានសន្តិភាព សុវត្ថិភាព វិបុលភាព និងភាពធន សម្រាប់យើងទាំងអស់គ្នា។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ មជ្ឈមណ្ឌលសភាអាស៊ី (PCAsia) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Proactive Parliamentary Diplomacy: ASEP 11 Special Edition ដែលអាចទាញយកពីគេហទំព័រ ៖ https://www.pcasia.org ។

# មាតិកា


បុព្វកថា ទំ. ២
Preface ទំ. ៤
សេចក្តីផ្តើម ទំ. ៦
Introduction ទំ. ៨
សេចក្តីសង្ខេបនៃបទវិភាគ ទំ. ១០


ជំពូកទី 01


ទំ. ១៧ - ទំ. ៧៣


## បុរេសកម្មសភាដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម


ទំ. ១៨ ១.១ ការកសាងពហុភាគីនិយមថ្មីនៅអឺរ៉ុប និងអាស៊ី

ទំ. ២១ ១.២ ការពង្រឹងភាពជាដៃគូសភាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

ទំ. ២៤ ១.៣ តួនាទីសភាក្នុងការតទល់នឹងបញ្ហាប្រឈមឆ្លងដែន៖ ទស្សនទានមួយបែបអឺរ៉ុប

ទំ. ២៨ ១.៤ ការឆ្លើយតបរបស់តំបន់អាស៊ីទៅនឹងវិបត្តិកូវីដ-១៩ ដំណាក់កាលដំបូង

ទំ. ៣២ ១.៥ ASEAN Policy Responses to the Economic Impacts of COVID-19

ទំ. ៣៦ ១.៦ សភានៅអឺរ៉ុបប្រឈមនឹង វិបត្តិកូវីដ-១៩

ទំ. ៤០ ១.៧ តើសភាអាចមានភាពនិម្មិតបានក្នុងកម្រិតណា?

ទំ. ៤៥ ១.៨ វិធីបែបអាស៊ានឆ្ពោះទៅរកពហុភាគីនិយមដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាព

ទំ. ៤៩ ១.៩ បុរេសកម្មសភា ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម៖ ទស្សនៈបែបអាស៊ី

ទំ. ៥៣ ១.១០ បញ្ហាប្រឈមសន្តិសុខនៅអាស៊ី៖ ទស្សនៈបែបអឺរ៉ុប

ទំ. ៥៧ ១.១១ ការត្រួតពិនិត្យរបស់សភាទៅលើការប្រើប្រាស់កម្លាំង និងកងកម្លាំងប្រដាប់អាវុធ

ទំ. ៦០ ១.១២ Role of Women in Conflict Resolution and Peacebuilding in ASEAN

ជំពូកទី
# ០២
ទំ. ៧៥ - ទំ. ១០១

## ការលើកកម្ពស់ការងើបឡើងវិញនៃសេដ្ឋកិច្ចសកលក្នុងបរិបទកូវីដ១៩ និងក្រោយកូវីដ១៩


ទំ. ៧៦ | ២.១ កិច្ចព្រមព្រៀងពាណិជ្ជកម្មពហុភាគី ជួបប្រទះបញ្ហាប្រឈម
ទំ. ៧៩ | ២.២ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី៖ ទស្សនៈមួយបែបអាស៊ី
ទំ. ៨៣ | ២.៣ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី៖ ទស្សនៈមួយបែបអឺរ៉ុប
ទំ. ៨៨ | ២.៤ Reforming the World Trade Organization: Towards a Sustainable and Effective Multilateral Trading System
ទំ. ៩២ | ២.៥ ASEAN Preparing for a Post-Pandemic Resilient Recovery
ទំ. ៩៧ | ២.៦ European Union recovery plan (Next Generation Europe)


### បញ្ជីផែនទី


ទំ. ៨២ | ផែនទី ១៖ ពាណិជ្ជកម្មអឺរ៉ុប-អាស៊ី


ជំពូកទី
# ០៣
ទំ. ១០៣ - ទំ. ១៤៧

## ការដោះស្រាយបញ្ហាអន្តរកម្មនៃសន្តិសុខទឹក ថាមពល និងស្បៀងក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ


ទំ. ១០៤ | ៣.១ សន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុ៖ ទស្សនៈពីប្រទេសសិង្ហបុរី
ទំ. ១០៨ | ៣.២ បណ្តាទីក្រុងនៅអាស៊ានប្រឈមនឹងហានិភ័យបរិស្ថាននិងការប្រែប្រួលអាកាសធាតុ
ទំ. ១១៤ | ៣.៣ ការប្រែប្រួលអាកាសធាតុ និងការការពារតំបន់ព្រៃធម្មជាតិ៖ ទស្សនៈពីខាងតំបន់អាស៊ីអាគ្នេយ៍
ទំ. ១១៨ | ៣.៤ ប្រសិទ្ធភាពនៃច្បាប់ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ
ទំ. ១២៥ | ៣.៥ សន្តិសុខថាមពលអឺរ៉ុប៖ បញ្ហាប្រឈមក្នុងការធ្វើពិពិធកម្ម និងការបំបែកកាបូនឌីអុកស៊ីតចេញពីរបាយឥន្ធនៈ
ទំ. ១៣០ | ៣.៦ សហភាពអឺរ៉ុប និងបញ្ហាប្រឈមទៅនឹងការប្រែប្រួលអាកាសធាតុ៖ អំណាចកំពូលក្នុងការចេញបទបញ្ញត្តិ
ទំ. ១៣៣ | ៣.៧ Climate Legislation from Asia and Europe: EU Fit-for-55 and China's Carbon Market
ទំ. ១៤០ | ៣.៨ On Biodiversity: Updates on the UN Biodiversity Conference (Cop15)


### បញ្ជីផែនទី


ទំ. ១០៩ | ផែនទី ២៖ ទីក្រុង និងទីក្រុងធំៗនៅអាស៊ីអាគ្នេយ៍
ទំ. ១២១ | ផែនទី ៣៖ ផូស៊ីលឥន្ធនៈ និងការបញ្ចេញឧស្ម័ន $CO_2$ តាមប្រទេស
ទំ. ១២៣ | ផែនទី ៤៖ កម្រិតហានិភ័យនៃការប្រែប្រួលអាកាសធាតុ



ស្ពានឆ្លងទន្លេកាម៉ានៅជិតទីក្រុង Perm ប្រទេសរុស្ស៊ី ឥឡូវនេះជាផ្នែកមួយនៃផ្លូវស្ទូត្រថ្មី ដែលភ្ជាប់កំពង់ផែសមុទ្រនៅមហាសមុទ្រប៉ាស៊ីហ្វិកជាមួយប្រទេសនៅអឺរ៉ុប។
Sergei Prokudin-Gorskii

ជំពូកទី

# ០១

# បុរេសកម្មសភាដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម


ទំ.១៨ | ១.១ ការកសាងពហុភាគីនិយមថ្មីនៅអឺរ៉ុប និងអាស៊ី
*ដោយ សាស្ត្រាចារ្យ មីហ្សែល ហ្វូសហ្សេ*

ទំ.២១ | ១.២ ការពង្រឹងភាពជាដៃគូសភាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព
*ដោយ បណ្ឌិត ឈាង វណ្ណរិទ្ធិ*

ទំ.២៤ | ១.៣ តួនាទីសភាក្នុងការតទល់នឹងបញ្ហាប្រឈមឆ្លងដែន៖ ទស្សនទានមួយបែបអឺរ៉ុប
*ដោយ លោក ហ៊្សាវីយេ នូទីន*

ទំ.២៨ | ១.៤ ការឆ្លើយតបរបស់ឥណ្ឌូណេស៊ីទៅនឹងវិបត្តិកូវីដ-១៩ ដំណាក់កាលដំបូង
*ដោយ លោកស្រី ដេវី អាំមីលៀ ត្រេស្នា វីចាយ៉ានទី & លោក ហារីយូណូ អាឌី អាំងគួរ*

ទំ.៣២ | ១.៥ ASEAN Policy Responses to the Economic Impacts of COVID-19
*By Dr. Sryneath CHHUOR*

ទំ.៣៦ | ១.៦ សភានៅអឺរ៉ុបប្រឈម នឹងវិបត្តិកូវីដ-១៩
*ដោយ សាស្ត្រាចារ្យ មីហ្សែល ហ្វូសហ្សេ*

ទំ.៤០ | ១.៧ តើសភាអាចមានភាពនិម្មិតបានក្នុងកម្រិតណា?
*ដោយ បណ្ឌិត ម៉ូរីហ្ស៍ វុន វីស្ស៍*

ទំ.៤៥ | ១.៨ វិធីបែបអាស៊ានឆ្ពោះទៅរកពហុភាគីនិយម ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាព *ដោយ ឯកអគ្គរាជទូត ពូ សុធីរៈ*

ទំ.៤៩ | ១.៩ បុរេសកម្មសភា ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាពរួម៖ ទស្សនៈបែបអាស៊ី *ដោយ លោក ហេង សន្យា*

ទំ.៥៣ | ១.១០ បញ្ហាប្រឈមសន្តិសុខនៅអាស៊ី៖ ទស្សនៈបែបអឺរ៉ុប
*ដោយ លោក ហ្វ្រេដេរីក ហ្គ្រារេ*

ទំ.៥៧ | ១.១១ ការត្រួតពិនិត្យរបស់សភាទៅលើការប្រើប្រាស់កម្លាំង និងកងកម្លាំងប្រដាប់អាវុធ *ដោយ បណ្ឌិត ម៉ាគឹស មូហ៍លីន*

ទំ.៦០ | ១.១២ Role of Women in Conflict Resolution and Peacebuilding in ASEAN
*By Dr. Lison GUIGNARD and Thyda KEM*

# ១.១ ការកសាងពហុភាគីនិយមថ្មីនៅអឺរ៉ុប និងអាស៊ី

## អំពីពហុភាគីនិយម

> “ពហុភាគីនិយមជាទម្រង់ស្ថាប័នមួយដែលសម្របសម្រួលទំនាក់ទំនងរវាងរដ្ឋបី ឬច្រើន ដោយផ្អែកលើមូលដ្ឋាននៃគោលការណ៍ប្រតិបត្តិរួម ។ គោលការណ៍នេះ បញ្ជាក់ច្បាស់ពីការអនុវត្តសមស្របតាមប្រភេទសកម្មភាព ដោយមិនគិតពីផលប្រយោជន៍ពិសេស (particularistic interests) ឬយុទ្ធសាស្រ្តបន្ទាន់របស់ភាគី ដែលអាចកើតមានឡើងក្នុងកាលៈទេសៈជាក់លាក់ណាមួយ [១, ទំ. ៥៧១]។”

ពហុភាគីនិយមបង្កប់នូវអត្ថន័យពីសមត្ថភាពក្នុងការលះបង់ផលប្រយោជន៍រយៈពេលខ្លីដើម្បីផលប្រយោជន៍រយៈពេលវែងក្នុងបុព្វហេតុនៃគុណតម្លៃរួម។ ក្នុងន័យនេះ សហភាពអឺរ៉ុបបានទទួលយកនូវឥទ្ធិពលនៃទម្រង់នេះចាប់តាំងពីការកកើតសហភាពអឺរ៉ុបដំបូង ក្នុងប្រភេទជាអង្គការពហុភាគី ដែលឲ្យតម្លៃលើគោលដៅរួមនៃកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មតំបន់ស្មើនឹងផលប្រយោជន៍ជាតិ។ ក្នុងកម្រិតសកល រដ្ឋជាសមាជិកនៃសហភាពអឺរ៉ុបតែងតែគាំទ្រការប្រើប្រាស់ប្រព័ន្ធដ៏រឹងមាំសម្រាប់ដោះស្រាយជម្លោះ និងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងគាំទ្រស្ថាប័នអន្តរជាតិនានា រាប់បញ្ចូលទាំងអង្គការអាកាសចរណ៍អន្តរជាតិ (ឆ្នាំ១៩៩៤) រហូតដល់អង្គការពាណិជ្ជកម្មពិភពលោក (១៩៩៥) អង្គការយូណេស្កូ តុលាការយុត្តិធម៌អន្តរជាតិ កម្មវិធីស្បៀងអាហារពិភពលោក អង្គការសុខភាពពិភពលោក UNDP ឬ UNEP និងក្រុមធនាគារពិភពលោក។ ដើម្បីគាំទ្របុព្វហេតុទាំងនេះ ប្រទេសជាសមាជិកនៃសហភាពអឺរ៉ុបចូលរួមចំណែកនូវថវិកា ៤០% នៃថវិកាបច្ចុប្បន្នរបស់អង្គការសហប្រជាជាតិ។

## វិបត្តិបច្ចុប្បន្ននៃពហុភាគីនិយម

ឥរិយាបថសហការគ្នានេះកំពុងតែទទួលការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ហើយអ្វីដែលជាចំណុចល្អរួមកាន់តែពិបាកកំណត់។ រដ្ឋបាលសហរដ្ឋអាម៉េរិកបច្ចុប្បន្នកំពុងតែបំផ្លាញមួយចំណែកធំនូវអ្វីដែលជាមូលដ្ឋានគ្រឹះស្ថាប័ននៃសកលភាវូបនីយកម្ម និងបានបំផ្លាញទំនុកចិត្តដែលធុរកិច្ចអន្តរជាតិតែងតែមានពីប្រតិបត្តិការនានាដែលអាចស្មានទុកជាមុនបានដោយផ្អែកលើប្រព័ន្ធមួយដែលឈរលើមូលដ្ឋានច្បាប់។

យន្តការនៃមជ្ឈត្តកម្មពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោកត្រូវបានរាំងស្ទះតាំងពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ ដោយការបដិសេធរបស់ប្រតិភូអាម៉េរិកក្នុងការចាត់តាំងចៅក្រមថ្មីនៅក្នុងស្ថាប័នឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក។ នៅក្នុងឆ្នាំ២០២០ ក្នុងអាកប្បកិរិយាស្រដៀងគ្នានេះ សហរដ្ឋអាម៉េរិកនៅតែស្ថិតនៅក្រៅកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុដដែល។ សេតវិមាន (White House) បច្ចុប្បន្នបានគាំទ្រការដកខ្លួនរបស់អង់គ្លេសចេញពី សហភាពអឺរ៉ុប (Brexit) និងគាំទ្រកិច្ចខិតខំប្រឹងប្រែងនានាដែលធ្វើឲ្យភាពរួបរួមគ្នាក្នុងសហភាពអឺរ៉ុបចុះខ្សោយ។ នេះជាលើកដំបូងហើយចាប់តាំងពីឆ្នាំ១៩៥០មកដែលរដ្ឋបាលអាម៉េរិកមិនចូលរួមពេញលេញក្នុងប្រតិបត្តិការសមាហរណកម្មរបស់សម្ព័ន្ធមិត្តអឺរ៉ុបរបស់ខ្លួន។

ជម្លោះពាណិជ្ជកម្មនិងពន្ធគយរវាងសហរដ្ឋអាម៉េរិកជាមួយចិន កាណាដា ម៉ិកស៊ិក ប្រេស៊ីល បារាំង អាល្លឺម៉ង់ ជប៉ុន និងកូរ៉េខាងត្បូង កំពុងរំខានជាពិសេសដល់ពួកក្រុមសម្ព័ន្ធមិត្តយុទ្ធសាស្រ្ត។ ការរុះរើជាប្រព័ន្ធនៃសណ្តាប់ធ្នាប់អន្តរជាតិក្រោយឆ្នាំ១៩៤៥ កំពុងត្រូវបានធ្វើឡើងដោយស្ថាបនិកដំបូងដ៏សំខាន់មួយរបស់ប្រព័ន្ធនេះ។ ជាលទ្ធផល “ឆ្មានៃពាណិជ្ជវិស័យនិយម (mercantilist cat) មួយត្រូវបានព្រលែងឲ្យចេញពីបាវ”។ អ្វីដែលជាហានិភ័យនោះគឺពិភពលោកត្រូវបែកបាក់ជាប្លុកពាណិជ្ជកម្មតំបន់ ជាក់ស្តែងគឺ ប្លុកសហរដ្ឋអាម៉េរិក សហភាពអឺរ៉ុប និងចិន[២]។

កត្តាផ្សេងៗទៀតកំពុងតែលេចឡើង ធ្វើឲ្យមានការធ្លាក់ចុះនូវកិច្ចសហប្រតិបត្តិការ និងនាំទៅរកការបង្កើតឲ្យមានគោលនយោបាយមួយដែលត្រូវធ្វើឲ្យមានតុល្យភាពអំណាចជាងមុន ជាពិសេសនៅអាស៊ី ជាកន្លែងដែលមានស្ថានភាពផ្ទុយគ្នាពីអឺរ៉ុប ដែលមិនមានផែនការសន្តិសុខ (security matrix) នោះទេ [១, ទំ. ៥៦២] [B]។

ដូចនេះហើយ បើសិនជាពហុភាគីនិយមមិនទាន់មានសភាព «ធ្លាក់ចុះទន់ខ្សោយបំផុត» នៅឡើយ នោះទាមទារឲ្យមានការបង្កើតជាបន្ទាន់នូវទម្រង់ វិសាលភាព និងព្រំដែនថ្មីសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលអ្នកជំនាញហៅថា «ពហុជាតិ» [៣]។ ការគំរាមកំហែងនិងបញ្ហាប្រឈមនានាកំពុងតែមានសភាពកាន់តែធ្ងន់ធ្ងរ ហើយបញ្ហាអន្តរជាតិមួយចំនួនមិនអាចដោះស្រាយបានតាមវិធីសាស្ត្រទ្វេភាគីដ៏សាមញ្ញបាននោះទេ ឧទាហរណ៍ដូចជា បញ្ហាបរិស្ថាន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីថ្មីដែលពឹងផ្អែកលើច្បាប់ ដំណើការនៃប្រព័ន្ធហិរញ្ញវត្ថុអន្តរជាតិ សន្តិសុខទូរគមនាគមន៍ និងភេរវកម្ម។

ចំពោះគ្រប់បញ្ហានីមួយៗ កិច្ចពិភាក្សា «ពហុជាតិ» បង្ហាញនូវផ្លូវឆ្ពោះទៅមុខដែលអាចធ្វើទៅបាន។ ឧទាហរណ៍ សហភាពអឺរ៉ុបនិងចិនអាចធ្វើការដោះស្រាយបញ្ហាពាក់ព័ន្ធនឹង WTO ព្រោះចិនត្រូវការស្ថិរភាពពាណិជ្ជកម្មដែលផ្អែកលើច្បាប់ ដរាបណារាល់កិច្ចព្រមព្រៀងស្តីពី ការការពារវិនិយោគផ្ទាល់ពីបរទេសត្រូវរៀបចំដោយប្រទេសចិន។ សហភាពអឺរ៉ុបក៏អាចចូលរួមក្នុងកិច្ចពិភាក្សាជាមួយចិនទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព និងការលើកស្ទួយសេដ្ឋកិច្ចដែលអំណោយផលដល់បរិស្ថានជាងមុន ហើយសមស្របជាមួយពាណិជ្ជកម្ម។ ការដឹងពីហានិភ័យដែលបន្សល់ទុកពីការបរាជ័យនៃសេដ្ឋកិច្ចសន្តិសហត្ថិភាព (peaceful economic coexistence) ដែលមានស្រាប់ បាននាំឲ្យបារាំងនិងអាល្លឺម៉ង់បង្កើតបាននូវសម្ព័ន្ធភាពដើម្បីពហុភាគីនិយមថ្មីមួយនៅអង្គការសហប្រជាជាតិ នាទីក្រុងញូវយ៉ក កាលពីថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ដែលពេលនេះមានប្រទេសជាង៦០ នៅទូទាំងពិភពលោកបានចូលជាសមាជិក ក្នុងនោះរួមមាន កាណាដា ម៉ិកស៊ិក ស៊ីលី សិង្ហបុរី និងហ្គាណាផងដែរ។

## សម្ព័ន្ធភាពដើម្បីពហុភាគីនិយម

«សម្ព័ន្ធភាពដើម្បីពហុភាគីនិយម» បង្កើតឡើងដោយរដ្ឋមន្ត្រីការបរទេសបារាំងនិងអាល្លឺម៉ង់ គឺជាបណ្តាញក្រៅផ្លូវការមួយ នៃបណ្តាប្រទេសដែលមានជំនឿរួមគ្នាថា សណ្តាប់ធ្នាប់ពហុភាគីដែលផ្អែកលើច្បាប់ គឺជាវិធីតែមួយគត់ដែលអាចធានាបាននូវសន្តិភាពនិងស្ថិរភាពអន្តរជាតិ ហើយមានតែតាមរយៈកិច្ចសហប្រតិបត្តិការប៉ុណ្ណោះ ដែលអាចឲ្យយើងដោះស្រាយបញ្ហារួមនានាបាន។

ក្នុងកាលៈទេសៈមួយដែលគោលការណ៍គន្លឹះ នៃសណ្តាប់ធ្នាប់អន្តរជាតិផ្អែកលើច្បាប់ និងលិខិតូបករណ៍សំខាន់ៗនៃកិច្ចសហប្រតិបត្តិការអន្តរជាតិកំពុងតែជួបនឹងបញ្ហាប្រឈម សម្ព័ន្ធភាពដើម្បីពហុភាគីនិយមមានបំណងបង្រួបបង្រួមប្រទេសទាំងឡាយដែលជឿជាក់លើភាពខ្លាំង និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការពហុភាគី។ រាល់ប្រទេសដែលបានរួមដៃក្នុងការធ្វើសកម្មភាពសម្រាប់បុព្វហេតុនេះជឿជាក់ ថាគោលបំណងនិងគោលការណ៍នៃច្បាប់អន្តរជាតិ យុត្តិធម៌ និងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ គឺជាគ្រឹះដែលមិនអាចខ្វះបានសម្រាប់ការធានាឲ្យបាននូវសន្តិភាព ស្ថិរភាព និងវិបុលភាព។

សម្ព័ន្ធភាពនេះមានបំណងស្តារឡើងវិញនូវការប្តេជ្ញាចិត្តជាសកលចំពោះសណ្តាប់ធ្នាប់អន្តរជាតិមួយដែលផ្អែកលើច្បាប់ លើកស្ទួយគោលការណ៍នេះ និងធ្វើការកែសម្រួលត្រង់ចំណុចណាដែលចាំបាច់។ គោលដៅរបស់សម្ព័ន្ធភាពនេះគឺ៖

- ការពារ និងរក្សាទំនៀមទំលាប់អន្តរជាតិ កិច្ចព្រមព្រៀង និងស្ថាប័ននានា ដែលកំពុងទទួលរងសម្ពាធ ឬការបំផ្លិចបំផ្លាញ
- ប្រកាន់យករបៀបវារៈដែលមានភាពបុរេសកម្មជាងមុន នៅក្នុងផ្នែកណាមួយនៃគោលនយោបាយដែលខ្វះអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងទប់ទល់ឲ្យបានទៅនឹងបញ្ហាប្រឈមថ្មីនានាដែលទាមទារការអនុវត្តសកម្មភាពរួមគ្នា និង
- ជំរុញកំណែទម្រង់ផ្សេងៗដោយមិនបោះបង់នូវគោលការណ៍និងគុណតម្លៃគន្លឹះនានា ដើម្បីធ្វើឲ្យស្ថាប័នពហុភាគី និងសណ្តាប់ធ្នាប់នយោបាយនិងសេដ្ឋកិច្ចសកលមានបរិយាបន្ន និងប្រសិទ្ធភាពជាងមុនក្នុងការសម្រេចឲ្យបាននូវលទ្ធផលជាក់ស្តែងសម្រាប់ប្រជាជនទូទាំងពិភពលោក។

សម្ព័ន្ធភាពនេះនឹងជំរុញរបៀបវារៈពហុភាគីមួយដែលគោរពយ៉ាងពេញលេញនូវតួនាទីដ៏សំខាន់របស់អង្គការសហប្រជាជាតិ ក៏ដូចជាអនុលោមតាមគោលបំណងនិងគោលការណ៍នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិនិងច្បាប់អន្តរជាតិ។ ដៃគូទាំងឡាយនៃសម្ព័ន្ធភាពនេះមានការប្តេជ្ញាចិត្តក្នុងការដើរតួជាកម្លាំងចលករក្នុងការការពារ អភិវឌ្ឍន៍ និងកែសម្រួលសណ្តាប់ធ្នាប់អន្តរជាតិមួយដែលផ្អែកលើនីតិរដ្ឋ។

ក្នុងវិស័យគោលនយោបាយការបរទេស ពហុភាគីនិយមមានន័យថា រដ្ឋទាំងឡាយសហការគ្នា ដើម្បីជំរុញការសម្រេចគោលដៅរួម ធ្វើឲ្យមានតុល្យភាព និងធ្វើនិយតកម្មផលប្រយោជន៍ដែលមានភាពប្រកួតប្រជែង។ ភាគីទាំងនោះធ្វើបែបនេះព្រោះគេដឹងថា នៅចុងបញ្ចប់ រដ្ឋទាំងអស់ជាអ្នកទទួលបានផលច្រើនបំផុត ប្រសិនបើគេធ្វើការរួមគ្នា និងព្រមព្រៀងគ្នាអនុវត្តតាមច្បាប់។ កិច្ចសហប្រតិបត្តិការបែបនេះពឹងផ្អែកលើគោលការណ៍ និងគុណតម្លៃជាក់លាក់នានាដែលប្រកាន់យកដោយគ្រប់តួអង្គទាំងអស់។ ក្នុងសម័យសកលភាវូបនីយកម្ម ស្ទើរតែគ្រប់ប្រទេសនៅលើសកលលោកមានការទាក់ទងគ្នាទៅវិញទៅមក។ ជម្លោះដែលកើតមានឡើងក្នុងតំបន់មួយអាចនឹងជះឥទ្ធិពលដោយផ្ទាល់លើជីវិតរបស់ប្រជាជនដែលរស់នៅតំបន់ឆ្ងាយពីគ្នារាប់ពាន់ម៉ាល (mile)។ បាតុភូតមួយចំនួនដូចជា ការប្រែប្រួលអាកាសធាតុបង្កឡើងនូវបញ្ហាជាច្រើន ដែលមិនឈប់នៅត្រឹមព្រំដែននៃប្រទេសមួយទេ ដូចនេះហើយទើបនាពេលបច្ចុប្បន្នកិច្ចសហប្រតិបត្តិការពហុភាគីកាន់តែមានសារៈសំខាន់ជាងពេលណាៗទាំងអស់។

ក្នុងចំណោមកិច្ចផ្តួចផ្តើមនានាដែលត្រូវបានព្រមព្រៀងដោយសម្ព័ន្ធភាពដើម្បីពហុភាគីនិយម ក៏មានការទទូចឲ្យមានសកម្មភាពដើម្បីពង្រឹងការគោរពច្បាប់មនុស្សធម៌អន្តរជាតិ និងសកម្មភាពមនុស្សធម៌ដែលផ្អែកលើគោលការណ៍ពាក់ព័ន្ធនឹង៖ ទំនុកចិត្តនិងសន្តិសុខក្នុងលំហរទូរគមនាគមន៍ ភាពជាដៃគូអន្តរជាតិសម្រាប់ព័ត៌មាននិងប្រជាធិបតេយ្យ ជំហររួមមួយលើបញ្ហាបំរែបម្រួលអាកាសធាតុនិងសន្តិសុខ បច្ចេកវិទ្យានាពេលអនាគត ការរំសាយនិងគ្រប់គ្រងសព្វាវុធ ទំនិញនិងសេវាសាធារណៈសកលការពង្រឹងស្ថាប័នអន្តរជាតិ និងសមភាពយេនឌ័រ។



“

**សម្តីរបស់លោក Sovann Ke ក្នុងកិច្ចប្រជុំពេញអង្គស្តីពី ពហុភាគីនិយម[៤].**

**សម្រាប់លោក Sovann Ke (តំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ) អង្គការសហប្រជាជាតិជាស្ថាប័នតំណាង ដែលមានសមត្ថភាពបំផុតក្នុងការការពារគុណធម៌នៃពហុភាគីនិយម និងជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយដទៃទៀត ដែលសក្តិសមបំផុតក្នុងការទប់ទល់ជាមួយនឹងបញ្ហាប្រឈមនៅសតវត្សរ៍ទី២១នេះ។ តាមរយៈការធ្វើការរួមគ្នានេះហើយ ទើបសហគមន៍អន្តរជាតិអាចសម្រេចសមិទ្ធផលជោគជ័យសំខាន់ៗបាន។ លោកក៏បានលើកឡើងពីសន្ធិសញ្ញាទីក្រុងប៉ារីស និងរបៀបវារៈ២០៣០ ជាភស្តុតាងដែលឆ្លុះបង្ហាញពីឥទ្ធិពលដ៏ «លើសលុប» នៃការងារការទូត។ ក្នុងពេលជាមួយគ្នានោះផងដែរ លោកក៏បានធ្វើការរិះគន់លើឯកត្តោភាគីនិយមដែលធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់វិបុលភាពនៃសហគមន៍ទាំងមូល។ លោកបានលើកយកកម្ពុជាជាឧទាហរណ៍៖ កម្ពុជាបានទទួលសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍឆាប់រហ័សក្នុងរយៈពេល២០ឆ្នាំ កន្លងមកនេះ ជាមួយនឹងកំណើនសេដ្ឋកិច្ចខ្ពស់៧%ក្នុងមួយឆ្នាំ។ ការណ៍នេះអាចសម្រេចបានទៅរួច ក៏ដោយសារតែពាណិជ្ជកម្ម ការទូត និងកិច្ចសហប្រតិបត្តិការ។ ជាការពិតណាស់ បើគ្មានពហុភាគីនិយម ឬកិច្ចសហប្រតិបត្តិការទេ សេដ្ឋកិច្ចនឹងកាន់តែធ្លាក់ចុះ មនុស្សកាន់តែក្រីក្រ ហើយរបៀបវារៈ២០៣០ នឹងនៅតែជាអ្វីដែលយើងមិនអាចឈោងទៅសម្រេចបាន។ លោកបានព្រមានថា ស្ថានការណ៍បែបនេះនឹងច្បាស់ជាបំផុសឲ្យកើតមានឡើងនូវមនោគមន៍វិជ្ជា និងជម្លោះដ៏គ្រោះថ្នាក់។**

”

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ១.២ ការពង្រឹងភាពជាដៃគូសភាសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

## សេចក្តីផ្តើម

ប្រព័ន្ធអន្តរជាតិកំពុងមានសភាពកាន់តែស្មុគស្មាញឡើង និងវិវឌ្ឍយ៉ាងរហ័សក្នុងទិសដៅឆ្ពោះទៅពិភពពហុភាពពិភពលោកមួយដែលមានភាពប្រទាក់ក្រឡាគ្នាដ៏ស្មុគស្មាញ មានការពឹងផ្អែកគ្នាទៅវិញទៅមក និងមានលទ្ធភាពធ្វើអន្តរសកម្មភាពជាមួយគ្នា។ ប្រទេសជាតិទាំងឡាយកំពុងតែមានការពឹងផ្អែកគ្នាទៅវិញទៅមកកាន់តែខ្លាំង។ បញ្ហាសកលកាន់តែមានភាពប្រទាក់ក្រឡាគ្នាកាន់តែខ្លាំង។ ច្បាស់ណាស់ថា បច្ចុប្បន្ននេះគ្មានប្រទេសណាមួយអាចដោះស្រាយបញ្ហាសកលបានតែឯកឯងទេ ដូចជាបញ្ហាការប្រែប្រួលអាកាសធាតុ ភេរវកម្ម អំពើហិង្សាជ្រុលនិយម គ្រោះធម្មជាតិ និងជំងឺរាតត្បាតសកលជាដើម។ កិច្ចសហប្រតិបត្តិការពីគ្រប់ពហុភាគីដែលពាក់ព័ន្ធត្រូវបានទទួលស្គាល់ថា ជាវិធីសាស្ត្រចាំបាច់ចម្បងក្នុងការផ្តល់នូវដំណោះស្រាយគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពសម្រាប់បញ្ហាប្រឈមរួមទាំងនេះ ។ អត្ថបទនេះមានគោលបំណងបង្ហាញពីតួនាទីរបស់សភាក្នុងការដោះស្រាយបញ្ហាសកល ដោយសង្កត់ធ្ងន់លើការធ្វើឲ្យសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) និងថា តើគេអាចប្រើភាពជាដៃគូសភាអាស៊ី-អឺរ៉ុបបែបណាដើម្បីជាយន្តការក្នុងការសម្រេចគោលដៅទាំងនេះ។

## តួនាទីរបស់សភាក្នុងការដោះស្រាយបញ្ហាសកល

បញ្ហាប្រឈមសកលនានាដូចជា ការប្រែប្រួលអាកាសធាតុ និងអំពើហិង្សាជ្រុលនិយមកាន់តែមានសភាពស្មុគស្មាញ និងមានឥទ្ធិពលឆ្លងហួសព្រំដែនជាតិ។ សភាបានចាប់ផ្តើមកែសម្រួលបែបបទប្រតិបត្តិការរបស់ខ្លួន ដើម្បីកំណត់ទីតាំងខ្លួនឯងក្នុងការដោះស្រាយបញ្ហាសកលនានាឲ្យមានប្រសិទ្ធភាព។ សភាបានទទួលស្គាល់ថាវិធីតែមួយគត់ដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាទាំងនេះ គឺមានតែតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូប៉ុណ្ណោះ។

តួនាទីអន្តរជាតិមួយចំនួនរបស់សភា គឺរួមចំណែកក្នុងដំណើរការនៃការចរចាអន្តររដ្ឋាភិបាល និងក្នុងដំណើរការនៃការកសាងស្ថាប័ន អនុវត្តការត្រួតពិនិត្យរបស់សភាលើដំណើរការចរចាជាអន្តរជាតិ ផ្តល់សច្ចាប័ន និងពង្រឹងការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានា លើកកម្ពស់កិច្ចសន្ទនាពហុភាគីដែលពាក់ព័ន្ធពីបញ្ហាអន្តរជាតិ និងការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ ព្រមទាំងផ្សព្វផ្សាយព័ត៌មានពីបញ្ហា និងអង្គការអន្តរជាតិនានាទៅកាន់ប្រជាពលរដ្ឋ។

បញ្ហាសកល និងការចូលរួមពីខាងក្រៅកាន់តែពាក់ព័ន្ធខ្លាំងសម្រាប់សភា និងប្រជាពលរដ្ឋ។ សមាជិក សមាជិកាសភាត្រូវធ្វើការប្រាស្រ័យឆ្លើយឆ្លង និងប្រមូលធាតុចូលសម្រាប់ម្ចាស់ឆ្នោត និងពីម្ចាស់ឆ្នោតរបស់ខ្លួន ជាពិសេសលើបញ្ហាអន្តរជាតិទាំងឡាយណា ដែលប៉ះពាល់ដល់សន្តិសុខសុខមាលភាពសេដ្ឋកិច្ចសង្គមរបស់ម្ចាស់ឆ្នោត។ ស្របពេលដែលការផ្តល់គំនិតយោបល់តាមបែបប្រជាធិបតេយ្យមានការកើនឡើង ដោយសារតែវត្តមានរបស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT) សមាជិក សមាជិកាសភាកាន់តែត្រូវធ្វើការប្រាស្រ័យឆ្លើយឆ្លងជាមួយម្ចាស់ឆ្នោតរបស់ខ្លួនឲ្យកាន់តែមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកកាន់តែខ្ពស់របស់ពួកគេ។ ស្របពេលជាមួយគ្នានេះ សមាជិក សមាជិកាសភាដែលធ្វើការជាពិសេសលើបញ្ហាការបរទេសអាចអញ្ជើញថ្នាក់ដឹកនាំក្រសួង ស្ថាប័នរបស់រដ្ឋាភិបាល និងភ្នាក់ងាររដ្ឋ ដើម្បីរាយការណ៍ និងឆ្លើយតបទៅនឹងសំណួរដេញដោលលើបញ្ហាអន្តរជាតិ ការបរទេស និងគោលនយោបាយពាណិជ្ជកម្ម ដែលប៉ះពាល់ដល់ប្រជាពលរដ្ឋរបស់ខ្លួន។

## តួនាទីរបស់សភាក្នុងការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ការកសាងភាពជាដៃគូសកលដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានបង្ហាញក្នុងគោលដៅទី១៧នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) របស់អង្គការសហប្រជាជាតិ។ ដូចដែលគោលដៅនេះចង់បង្ហាញ ភាពជាដៃគូអន្តរជាតិ និងកិច្ចសហប្រតិបត្តិការរវាងពហុភាគីដែលពាក់ព័ន្ធមានសារៈសំខាន់ណាស់ក្នុងការសម្រេចឲ្យបានSDGs។ SDGs ក៏បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃបរិយាបន្នពោលគឺការចូលរួមពីគ្រប់ផ្នែកនៃសង្គម ដើម្បីកៀរគរ និងចែករំលែកចំណេះដឹងនិងជំនាញ ក៏ដូចជាដើម្បីផ្តល់នូវ

ធនធានបច្ចេកទេស និងហិរញ្ញវត្ថុដែលចាំបាច់។ ស្ថាប័នសភាដែលដើរតួជាស្ពានយ៉ាងសំខាន់ក្នុងការតភ្ជាប់រដ្ឋ និងសង្គម គឺជាតួអង្គចូលរួមដ៏គន្លឹះមួយនៅក្នុងការកៀរគរធនធាន និងតម្រង់ទិសរបៀបវារៈជាតិឆ្ពោះទៅរកការសម្រេចឲ្យបាននូវគោលដៅតំបន់ និងអន្តរជាតិ។ ហេតុដូចនេះហើយ ភាពជាដៃគូរវាងរដ្ឋ-ឯកជន និងសង្គមស៊ីវិលមានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យកិច្ចសហការក្នុងការអនុវត្ត SDGs មានភាពរឹងមាំ។ គោលដៅទី១៦ នៃ SDG បង្ហាញយ៉ាងច្បាស់នូវសារៈសំខាន់នៃការលើកកម្ពស់សង្គមប្រកបដោយសន្តិភាព និងបរិយាបន្នសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ សេចក្តីប្រកាសរបៀបវារៈ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិបានចែងថា «យើងទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់សភាជាតិនីមួយៗតាមរយៈការអនុម័តច្បាប់ និងការអនុម័តថវិកា និងតួនាទីរបស់សភាក្នុងការធានាឲ្យបាននូវគណនេយ្យភាព ដើម្បីប្រសិទ្ធភាពនៃការអនុវត្តការប្តេជ្ញាចិត្ត»។

ដូចមានចែងនៅក្នុងសេចក្តីប្រកាសនេះ សភាមានតួនាទីសំខាន់បួនក្នុងការសម្រេចឲ្យបាននូវ SDGs ក្នុងនោះមានដូចជា មុខងារត្រួតពិនិត្យ មុខងារនីតិកម្ម មុខងារតំណាង និងការត្រួតពិនិត្យថវិកា។ ដើម្បីសម្រេចបាននូវបេសកកម្មនេះ សភាអាចបង្កើនការចូលរួមថ្នាក់ជាតិ ផ្តល់នូវវេទិកាសម្រាប់កិច្ចពិភាក្សា និងកិច្ចសន្ទនាជាតិ និងអន្តរជាតិ លើកទឹកចិត្តឲ្យមានការជជែកដេញដោល និងរកការឯកភាពរួមគ្នារវាងភាគីពាក់ព័ន្ធជាតិ ការបង្កើតក្របខ័ណ្ឌច្បាប់ដែលរឹងមាំដែលអាចលើកទឹកចិត្តភាគីពាក់ព័ន្ធទាំងអស់ឲ្យចូលរួមអនុវត្ត SDGs ប្រមូលធាតុចូលពីប្រជាពលរដ្ឋ និងក្រុមសង្គមស៊ីវិល បែងចែកមូលនិធិក្នុងកម្រិតសមស្រប និងធ្វើការត្រួតពិនិត្យ ដោយប្រើប្រាស់ការត្រួតពិនិត្យប្រចាំឆ្នាំលើរបាយការណ៍ សំណួមពរ និងការវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្ត SDGs ដែលធ្វើឡើងដោយគណៈកម្មការដែលពាក់ព័ន្ធ។

ការចូលរួមចំណែករបស់សភាក្នុងការធ្វើរបាយការណ៍វាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ (VNRs) បានជួយដល់ការវាយតម្លៃ និងតាមដានពីវឌ្ឍនភាពនៃការអនុវត្ត SDGs។ តួនាទីគន្លឹះនៃ VNRs គឺការរៀបចំផែនការ ការធ្វើស្ថាបនីយកម្ម ការប្រមូលធាតុចូលនិងទិន្នន័យ ការសរសេរនិងត្រួតពិនិត្យឡើងវិញ ការធ្វើបទបង្ហាញនិងការបន្តតាមដាន។ លទ្ធផលរំពឹងទុករបស់ VNRs គឺការធ្វើឲ្យប្រសើរឡើងនូវភាពជាដៃគូនៃពហុភាគីដែលពាក់ព័ន្ធ និងការលើកកម្ពស់ការចូលរួមឲ្យបានសកម្ម ដោយមានការគោរពភាពជាម្ចាស់នៃគ្រប់ភាគីដែលពាក់ព័ន្ធ។ ជាងនេះទៅទៀត ការផ្តល់អាទិភាពទៅលើ SDGs ដោយធ្វើការរៀបចំផែនការអភិវឌ្ឍន៍ជាតិ លើកកម្ពស់ការយល់ដឹងសាធារណៈ និងការតស៊ូមតិលើគោលនយោបាយ ព្រមទាំងការអភិវឌ្ឍយន្តការវាយតម្លៃប្រកបដោយប្រសិទ្ធភាពនិងបរិយាបន្នទាក់ទងនឹងការអនុវត្ត SDGs ត្រូវបានចាត់ទុកថាជាបញ្ហាសំខាន់។

បញ្ហាប្រឈមចម្បងសម្រាប់សភា ជាពិសេសសភាក្នុងបណ្តាប្រទេសនៅអាស៊ី គឺការធ្វើយ៉ាងណាដើម្បីបង្កើនការចូលរួម និងឥទ្ធិពលរបស់សភាលើរបៀបវារៈនៃ SDGs ដោយហេតុថា កម្មវិធីទាំងឡាយទាក់ទងនឹង SDGs ភាគច្រើនត្រូវបានរៀបចំនិងគ្រប់គ្រងដោយស្ថាប័ននីតិប្រតិបត្តិ។ វេទិកាសភាអន្តរជាតិដូចជា សហភាពអន្តរសភា (IPU) វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក (APPF) វេទិកាសភាពិភពលោកស្តីពី ការអភិវឌ្ឍប្រកបដោយចីរភាព (WPFSD) និងកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) ត្រូវតែចំណាយកម្លាំង និងធនធានបន្ថែមទៀត ដើម្បីប្រមូលផ្តុំនូវការមូលមតិជាអន្តរជាតិ និងរៀបចំយុទ្ធសាស្ត្រចូលរួមទាក់ទងនឹង SDGs។

## តួនាទីនៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP)

កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) គឺជាកិច្ចប្រជុំនៃសមាជិក សមាជិកាសភាមកពីអាស៊ី និងអឺរ៉ុប ដែលរៀបចំឡើងដើម្បីស្វែងរកធាតុចូលជាគោលនយោបាយ និងអនុសាសន៍ ដើម្បីផ្តល់ទៅកាន់កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM)។ ASEP គឺជាដៃនៃសភារបស់ ASEM ហើយកិច្ចប្រជុំដំបូងរបស់ ASEP ត្រូវបានធ្វើឡើងក្នុងឆ្នាំ១៩៩៦។ ដោយ ASEP ជាវេទិកាក្រៅផ្លូវការ ហេតុនេះសេចក្តីប្រកាសរបស់ ASEP មិនមានចំណងគតិយុត្តិទេ។

ASEP មានគោលដៅចម្បងពីរ។ ទី១ គឺជាវេទិកាសម្រាប់ទំនាក់ទំនងអន្តរសភា សម្រាប់ការផ្លាស់ប្តូរគំនិតយោបល់ និងការទូតរវាងសភានានា និងជាយានក្នុងការលើកកម្ពស់ការយោគយល់គ្នារវាងប្រជាជន និងរវាងប្រទេសនៅអាស៊ី និងអឺរ៉ុប។ ទីពីរ ASEP ផ្តល់នូវតំណភ្ជាប់រវាងសភានៅអាស៊ី និងអឺរ៉ុប ជាមួយនឹង ASEM ដែលធ្វើឲ្យសភាចូលរួមបានសកម្មក្នុងដំណើរការរបស់ ASEM ជាពិសេសក្នុងកិច្ចប្រជុំរៀងរាល់ពីរឆ្នាំម្តង។

ការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ជាផ្នែកគន្លឹះមួយនៃកិច្ចសហប្រតិបត្តិការដែលសម្របសម្រួលដោយកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM)។ ក្នុងសេចក្តីថ្លែងការណ៍រួមកាលពីឆ្នាំ២០១៨ ថ្នាក់ដឹកនាំ ASEM បានសង្កត់ធ្ងន់លើសារៈសំខាន់នៃភាពជាដៃគូពហុ

ភាគីដែលពាក់ព័ន្ធក្នុងការសម្រេចឲ្យបាននូវបរិយាបន្នសង្គម និងសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងការអភិវឌ្ឍ ដែលផ្តោតសំខាន់លើប្រជាពលរដ្ឋ។ ជាងនេះទៅទៀត ថ្នាក់ដឹកនាំ ASEM ក៏បានស្នើឲ្យមានការផ្សារភ្ជាប់បញ្ហានៃទំនាក់ទំនង ASEM ជាមួយនឹងការអភិវឌ្ឍប្រកបដោយចីរភាពដើម្បីជួយដោះស្រាយរបៀបវារៈ២០៣០។ ទន្ទឹមនឹងនេះ នៅក្នុងសេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី១០(ASEP10)បានផ្តោតសំខាន់លើសារៈសំខាន់នៃពហុភាគីនិយម និងភាពជាដៃគូអន្តរជាតិដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព។

## សេចក្តីបញ្ចប់

សព្វថ្ងៃនេះ ស្ថាប័នសភាកំពុងតែដើរតួរកាន់តែសំខាន់ក្នុងការដោះស្រាយបញ្ហាសកលជាច្រើនដែលស្មុគស្មាញ និងប្រទាក់ក្រឡាគ្នា។ ទាក់ទងនឹង SDGs សភាមានតួនាទីសំខាន់ជាច្រើនដូចជា ការត្រួតពិនិត្យ ការតាក់តែងច្បាប់ និងការត្រួតពិនិត្យថវិកា។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីបង្កើនឥទ្ធិពលរបស់ខ្លួនក្នុងការតម្រង់ និងចូលរួមអនុវត្ត SDGs សភាត្រូវតែពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាពស្ថាប័នរបស់ខ្លួន និងអភិវឌ្ឍយុទ្ធសាស្ត្រចូលរួមប្រកបដោយប្រសិទ្ធភាព។

ASEPជាវេទិកាមួយក្នុងចំណោមវេទិកាសភាអន្តរជាតិគន្លឹះផ្សេងទៀត ដែលអាចជួយលើកកម្ពស់កិច្ចសន្ទនា និងកិច្ចពិគ្រោះយោបល់ថ្នាក់សភាលើរបៀបវារៈ SDG ជាពិសេសក្នុងការកសាងភាពជាដៃគូអន្តរជាតិ និងកិច្ចសហការនៃពហុភាគីដែលពាក់ព័ន្ធចាំបាច់។ ក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ការកសាងសមត្ថភាព ការចែករំលែកចំណេះដឹង និងកិច្ចខិតខំប្រឹងប្រែងរួមលើ SDGs ត្រូវតែមានការលើកកម្ពស់បន្តទៀត។

អនុសាសន៍ជាក់លាក់សម្រាប់ ASEP រួមមាន (១) លើកទឹកចិត្តសមាជិក ASEP ទាំងអស់ឲ្យចូលរួមក្នុងការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ(VNR)សម្រាប់ប្រទេសរបស់គេនីមួយៗ និងបង្កើតយន្តការសម្រាប់ចែករំលែកចំណេះដឹងជុំវិញលទ្ធផលនៃការវាយតម្លៃដោយស្ម័គ្រចិត្តថ្នាក់ជាតិ (២) បង្កើតកម្មវិធីកសាងសមត្ថភាពដល់ប្រទេសកំពុងអភិវឌ្ឍដែលជាសមាជិក ASEP ស្តីពី SDGs សម្រាប់សមាជិក សមាជិកា និងមន្ត្រីសភា(៣) បង្កើតបេសកជនពិសេស ASEP ទទួលបន្ទុក SDGs ដើម្បីចូលរួមដោយប្រសិទ្ធភាពជាមួយនឹងសមាជិក សមាជិកាសភានៃ ASEP និងអង្គការអន្តរជាតិនានា ដូចជាអង្គការសហប្រជាជាតិជាដើម។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ១.៣ តួនាទីរបស់សភាក្នុងការទប់ទល់នឹងបញ្ហាប្រឈមឆ្លងដែន៖ ទស្សនៈមួយបែបអឺរ៉ុប

យើងរស់នៅក្នុងពិភពសកលភាវូបនីយកម្មដែលមានទាំងឱកាស និងបញ្ហាប្រឈម រួមមានទាក់ទងទៅនឹងបញ្ហាដូចជា ការកើនឡើងកម្តៅផែនដី ពាណិជ្ជកម្ម ទេសន្តប្រវេសន៍ ការរក្សាជីវៈចម្រុះ ឧក្រិដ្ឋកម្មឆ្លងដែន អភិបាលកិច្ចសមុទ្រ និងការពង្រីកហួសព្រំដែនជាតិ ដែលបញ្ហាទាំងនេះទាមទារឲ្យមានការដោះស្រាយតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ដោយសារតែសកលភាវូបនីយកម្ម ធ្វើឲ្យមានភាពស្រពិចស្រពិលអំពី ព្រំដែនដែលត្រូវបានចាត់ទុកក្នុងគោលនយោបាយជាតិ និងនៅក្នុងគោលនយោបាយទំនាក់ទំនងអន្តរជាតិ។ ជាការពិតណាស់ អ្វីដែលត្រូវសម្រេចនៅទីក្រុងប៉េកាំង ឬវ៉ាស៊ីនតោន ដោយរដ្ឋាភិបាល ឬដោយទីផ្សារសកល ច្បាស់ជានឹងអាចជះឥទ្ធិពលដល់បច្ចុប្បន្ននិងអនាគតនៃប្រជាពលរដ្ឋនៅប្រទេសប្រេស៊ីល អេស្ប៉ាញ កម្ពុជា ឬនៅអូស្ត្រាលី។

បន្ទាប់ពីឆ្លងកាត់ប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃជម្លោះបំផ្លិចបំផ្លាញ ជាបទពិសោធន៍ពេលនេះបណ្តាប្រទេសនៅអឺរ៉ុបមានជាស្រេចនូវវិធីសាស្ត្រកិច្ចសហប្រតិបត្តិការអន្តរជាតិដ៏រឹងមាំ ដែលរៀបចំតាមរយៈស្ថាប័ន និងច្បាប់របស់សហភាពអឺរ៉ុប (EU) ក្នុងនោះរួមមានគោលការណ៍ចម្បងៗស្តីពី ការផ្ទេរផ្នែកខ្លះនៃអធិបតេយ្យភាពជាតិទៅរដ្ឋាភិបាលសហភាព (supra-national level)។ មិនប្លែកទេ សហភាពអឺរ៉ុបគឺជាជើងឯកនៃពហុភាគីនិយម ដែលជឿជាក់យ៉ាងម៉ុតមាំលើប្រព័ន្ធពហុភាគីនិយមអាស្រ័យច្បាប់ ថាជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតក្នុងការដោះស្រាយបញ្ហាប្រឈមរួមនាពេលបច្ចុប្បន្នដោយយុត្តិធម៌ និងមានការចូលរួម។

ទោះបីជាមានការប្រឆាំងទៅនឹងវិធីសាស្ត្រនេះ ពីសំណាក់មហាអំណាចក្នុងសហគមន៍អន្តរជាតិមួយចំនួនក៏ដោយ តែបណ្តាប្រទេសនៅអាស៊ីបានទទួលស្គាល់វិធីសាស្ត្រនេះជារួមដូចដែលត្រូវបានបញ្ជាក់ក្នុងកិច្ចប្រជុំ ASEP ១០ នៅទីក្រុងព្រុចសែល កាលពីឆ្នាំ២០១៨។ ពហុភាគីនិយមជាប្រធានបទមួយក្នុងចំណោមប្រធានបទសំខាន់ពីរ នៃកិច្ចប្រជុំនោះ។ ពេលថ្មីៗនេះ ការប្តេជ្ញាចិត្តរួមមួយត្រូវបានធ្វើឡើងក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេស ASEM ធ្វើឡើងនៅទីក្រុងម៉ាឌ្រីដ ប្រទេសអេស្ប៉ាញ ក្នុងខែធ្នូ ឆ្នាំ២០១៩ ក្រោមមូលបទ «អាស៊ី និង អឺរ៉ុប៖ រួមគ្នាដើម្បីពហុភាគីនិយមប្រកបដោយប្រសិទ្ធភាព» ។

ជាការពិតណាស់ វិធីតាមបែបអឺរ៉ុប និងអាស៊ីមានលក្ខណៈខុសគ្នា ទាំងលើវិធីសាស្ត្រ និងខ្លឹមសារ។ តាមបែបអឺរ៉ុប កិច្ចព្រមព្រៀងត្រូវចងដោយច្បាប់ ឯបែបអាស៊ី គឺនិយមការឯកភាពគ្នាបែបកុងសង់ស៊ីស និងការទុកចិត្តគ្នាផ្អែកលើទំនាក់ទំនងល្អ និងអធិបតេយ្យភាពជាតិ។ ទំនាក់ទំនងសេដ្ឋកិច្ចគឺជាអាទិភាពរបស់រដ្ឋាភិបាលនៃបណ្តាប្រទេសនៅអាស៊ី ផ្ទុយទៅវិញការប្តេជ្ញាចិត្តគោរពសិទ្ធិមនុស្ស ឬការទប់ស្កាត់ទៅនឹងការប្រែប្រួលអាកាសធាតុ ជាអាទិភាពដូចគ្នាចំពោះអឺរ៉ុប។ ទោះជាយ៉ាងនេះក៏ដោយ ទ្វីបទាំងពីរមានចំណាប់អារម្មណ៍ចម្បងដូចគ្នាប្រឆាំងទៅនឹងរបបគាំពារនិយម និងរបបឯកោនិយម ហើយទ្វីបទាំងពីរក៏យល់ស្របដូចគ្នាចំពោះតម្រូវការរក្សាប្រព័ន្ធពហុភាគីមួយបើកចំហរ។

ក្នុងខណៈពេលដែលសកលភាវូបនីយកម្មបាននាំមកនូវផលប្រយោជន៍ជាច្រើន ដូចជាការធ្វើឲ្យមនុស្សរាប់លាននាក់ក្នុងពិភពលោកចាកចេញពីភាពក្រីក្រ តែវាក៏បានធ្វើឲ្យមូលដ្ឋានគ្រឹះវប្បធម៌ សង្គម និងសេដ្ឋកិច្ចរបស់យើងមានអស្ថិរភាព បង្កភាពភ័យខ្លាច និងអសន្តិសុខក្នុងបណ្តាប្រទេសជាច្រើនក្នុងទ្វីបអឺរ៉ុបផងដែរ។ មនុស្សភ័យខ្លាចថាពួកគេកំពុងតែបាត់បង់ភាពម្ចាស់ការលើអនាគតរបស់ខ្លួន ហើយមានអារម្មណ៍អសុវត្ថិភាពជាមួយស្ថានភាពបច្ចុប្បន្នរបស់ពួកគេ។ ការណ៍នេះបាននាំឲ្យមានការប្រឆាំងទៅ «ក្រុមវរជន និងក្រុមការិយាធិបតេយ្យដែលមានគម្លាតឆ្ងាយពីពួកគេ» ហើយជាអ្នកធ្វើ សេចក្តីសម្រេចចិត្តនានា ស្របពេលជាមួយនឹងការកើនឡើងនៃការប្រឆាំងទៅនឹងពហុវប្បធម៌និយម ដែលនាំឲ្យលេចចេញនូវការពង្រឹងគោលនយោបាយប្រជានិយមនៅស្ទើរពាសពេញទ្វីបអឺរ៉ុប។ សព្វថ្ងៃនេះ មេដឹកនាំនយោបាយជាច្រើនកំពុងប្រឈមនឹងការខ្វះសេចក្តីទុកចិត្តពីប្រជាពលរដ្ឋ ដោយបានចាត់ទុកអ្នកនយោបាយទាំងនោះថា ជាផ្នែកមួយនៃពិភពលោកដ៏សែនឆ្ងាយដាច់ពីស្ថានភាពពិតរបស់ពួកគេ។ គម្លាតរវាងអ្នកធ្វើសម្រេចចិត្ត និងអ្នកបោះឆ្នោតកាន់តែរីកធំ ដូចមានស្តែងចេញនៅក្នុងការជជែកដេញដោលទាក់ទងនឹងវិបត្តិនៃប្រជាធិបតេយ្យក្នុងប្រព័ន្ធអភិបាលកិច្ច។

សកលភាវូបនីយកម្មក៏បានគាំទ្រដល់ការកសាងស្ថាប័នអន្តរជាតិ៖ អង្គការពហុភាគីនានាបានរីកសាយភាយតាំងពីទសវត្សរ៍១៩៩០ដើម្បីគ្រប់គ្រងដំណើរការនិងឥទ្ធិពល

នៃសកលភាវូបនីយកម្ម។ អង្គការទាំងនេះត្រូវបានបង្កើតឡើងដើម្បីជំរុញស្ថិរភាពតំបន់គ្រប់គ្រងជម្លោះ គាំទ្រការរីកលូតលាស់នៃសេដ្ឋកិច្ច កាត់បន្ថយគម្លាតអភិវឌ្ឍន៍ កសាងវិបុលភាព និងដោះស្រាយបញ្ហាប្រឈមសកល ដោយផ្អែកលើទិដ្ឋភាពច្បាប់។ អង្គការទាំងនេះមានទម្រង់ខុសៗគ្នារាប់ចាប់ពីអង្គការដែលបានធ្វើសមាហរណកម្មយ៉ាងស៊ីជម្រៅដូចជាសហភាពអឺរ៉ុប រហូតដល់អង្គការដែលទន់ខ្សោយដូចជាសមាគមសម្រាប់កិច្ចសហប្រតិបត្តិការតំបន់អាស៊ីខាងត្បូង (SAARC) ជាដើម។

កាន់តែញឹកញាប់ ការធ្វើសេចក្តីសម្រេចចិត្តលើបញ្ហាគោលនយោបាយគន្លឹះដែលប៉ះពាល់ដល់ប្រជាពលរដ្ឋច្រើនតែងត្រូវបានយកមកពិភាក្សា និងសម្រេចក្នុងក្របខ័ណ្ឌតំបន់និងពហុភាគី៖ ពី WTO រហូតដល់ APEC អំពីបញ្ហាពាណិជ្ជកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច ពី EAS និង ARF ដល់ NATO អំពីបញ្ហាសន្តិសុខ ពី UNFCC ដល់ AOSIS អំពីបញ្ហាបម្រែបម្រួលអាកាសធាតុ។ ក្រុមប្រទេស G20 ក៏ពិភាក្សាលើបញ្ហាទាំងអស់នេះដែរ។ នេះគឺដោយសារតែបញ្ហាដែលមានលក្ខណៈសកលមានចំនួនកាន់តែច្រើនឡើងហើយកាន់តែមានភាពស្មុគស្មាញផ្នែកបច្ចេកទេស។ ការធ្វើសេចក្តីសម្រេចចិត្តទាំងនេះភាគច្រើនត្រូវបានធ្វើឡើងដោយគ្មានការត្រួតពិនិត្យពីស្ថាប័នតំណាងជាតិ ដូចជាសភា ដែលនាំឲ្យសភាពិបាកក្នុងការអនុវត្តមុខងារត្រួតពិនិត្យ និងវិនិច្ឆ័យទៅលើស្ថាប័នលើជាតិទាំងនោះ។ នេះគឺជាចំណុចខ្សោយដ៏ធំមួយ ដែលនាំឲ្យមានកង្វះការគាំទ្រពីប្រជាពលរដ្ឋកម្រិតមធ្យម លើសេចក្តីសម្រេចចិត្តដែលធ្វើឡើងដោយស្ថាប័នទាំងនោះ។ និយាយជាទូទៅ ដំណើរការសមាហរណកម្មតំបន់ពិតជាទទួលរងការលំបាកពីឱនភាពប្រជាធិបតេយ្យ៖ វិធីសាស្ត្រសម្រេចពីថ្នាក់លើមកក្រោមតែងត្រូវប្រើជាញឹកញាប់ ហើយការចូលរួមពីភាគីពាក់ព័ន្ធផ្សេងៗនៅមានកម្រិត រួមមានកង្វះការចូលរួមទាំងពីសមាជិក សមាជិកាសភាដែលជាប់ឆ្នោត និងតំណាងសង្គមស៊ីវិល។

នៅពេលដែលការធ្វើសេចក្តីសម្រេចចិត្តធំៗ កំពុងត្រូវបានធ្វើឡើងដាច់កាន់តែឆ្ងាយពីប្រជាពលរដ្ឋ ការអភិវឌ្ឍចម្បងនិងដោយឡែកមួយផ្សេងទៀតក៏កំពុងកើតមានឡើង៖ គោលនយោបាយ និងការសម្រេចចិត្តរបស់រដ្ឋាភិបាលស្ថិតនៅក្រោមការពិនិត្យវិនិច្ឆ័យកាន់តែខ្លាំងពីក្រុមសង្គមស៊ីវិល បណ្តាញព័ត៌មាន និងប្រជាជនសាមញ្ញ។ អ្នកបោះឆ្នោតទទួលបានការអប់រំប្រសើរជាងមុន ដោយចេះប្រើជាប្រយោជន៍ដ៏ពេញលេញពីប្រព័ន្ធព័ត៌មានសង្គម ដែលនាំឲ្យមានការផ្លាស់ប្តូរដំណើរការប្រជាធិបតេយ្យ៖ ប្រជាពលរដ្ឋងាយស្រួលទទួលបានព័ត៌មានសំបូរបែបងាយស្រួលបញ្ចេញមតិយោបល់ និងងាយស្រួលសាកល្បងជះឥទ្ធិពលដោយផ្ទាល់ដល់ការធ្វើសេចក្តីសម្រេចចិត្ត។

នេះគឺជារឿងល្អមួយ៖ ជាធម្មតាត្រូវតែមានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីឲ្យមានការទទួលស្គាល់ពីសាធារណជនលើគោលនយោបាយ និងកិច្ចព្រមព្រៀងអន្តរជាតិដែលប៉ះពាល់ផ្ទាល់ដល់ជីវភាពរបស់ពួកគេ។ សាធារណជនពេលនេះរំពឹងថា មេដឹកនាំនឹងធ្វើសកម្មភាពប្រកបដោយតម្លាភាព និងតាមរបៀបរបបប្រជាធិបតេយ្យ។ ព័ត៌មាន កិច្ចសន្ទនា និងការចូលរួម គឺជាពាក្យគន្លឹះក្នុងការអះអាងពីភាពស្របច្បាប់។ តម្រូវការឲ្យភាពស្របច្បាប់ និងគណនេយ្យភាពកំពុងតែកើនឡើងគ្រប់ទីកន្លែង។

ក្នុងបរិបទនៃការប្រឈមជាសកល និងការរំពឹងទុកបែបប្រជាធិបតេយ្យថ្មី តួនាទីរបស់សមាជិក សមាជិកាសភាគឺពិតជាសំខាន់។ ក្នុងនាមជាអ្នកតំណាងឲ្យប្រជាពលរដ្ឋសមាជិក សមាជិកាសភាត្រូវតែបញ្ចេញសម្លេងនៅក្នុងការជជែកដេញដោល និងការចរចាពីកិច្ចការសកល ត្រូវព្យាយាមតម្រង់ និងជះឥទ្ធិពលលើគោលនយោបាយ និងធ្វើសកម្មភាពការទូតឲ្យស្របទៅនឹងការទូតនៃអង្គនីតិប្រតិបត្តិដែរ។ ការទូតសភាបំពេញបន្ថែមនូវភាពស្របច្បាប់ភាពស្និតស្នាញ និងទម្ងន់ផ្នែកនយោបាយលើការធ្វើសេចក្តីសម្រេចចិត្តនានា។ ការណ៍នេះអាចសម្រេចបានដោយសភាជាតិ ដោយការរួមចំណែក និងការពិនិត្យតាមដានការអនុវត្តគោលនយោបាយរបស់ប្រទេសខ្លួន ដើម្បីដោះស្រាយបញ្ហាសកលនានា (ដូចដែលបានឃើញថ្មីៗនេះ ក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអឺរ៉ុប-កាណាដា ឬ CETA)។

នេះពិតជាសំខាន់ និងមានប្រយោជន៍ ប៉ុន្តែកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីដោះស្រាយបញ្ហាប្រឈមឆ្លងដែនជាញឹកញាប់ត្រូវបានដោះស្រាយរួមគ្នាដោយអង្គការពិភពលោក អង្គការតំបន់ និងអនុតំបន់។ ហេតុដូចនេះហើយកិច្ចប្រតិបត្តិការរួមពហុភាគីបានក្លាយជាព្រំដែនថ្មីសម្រាប់សមាជិក សមាជិកាសភា ដែលតែងរំពឹងចង់ឃើញអង្គការអន្តររដ្ឋាភិបាលកាន់តែមានគណនេយ្យភាព និងតម្លាភាព។

នេះប្រហែលជាមិនមែនជារឿងងាយស្រួលទេ ព្រោះរដ្ឋអធិបតេយ្យមានការស្ទាក់ស្ទើរក្នុងការប្រគល់អំណាចទៅឲ្យអង្គនីតិប្បញ្ញត្តិជាតិរបស់គេ។ ការមិនចង់ផ្តល់អំណាចដល់សភាថ្នាក់លើជាតិ កាន់តែខ្លាំងជាងនេះទៅទៀត (សភាអឺរ៉ុបត្រូវប្រឈមនឹងបញ្ហានេះជារៀងរាល់ថ្ងៃ)។ ដើម្បីសម្រេចបានភាពស្របច្បាប់កម្រិតខ្ពស់ថែមទៀត និងដើម្បីឲ្យអង្គការតំបន់មានគណនេយ្យភាព និងដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមរួម សភាតំណាងតំបន់ត្រូវតែបង្កើតឡើង និងទទួល

បានការពង្រឹង ដើម្បីចូលរួមចំណែក និងត្រួតពិនិត្យលើការធ្វើសេចក្តីសម្រេចចិត្តដែលធ្វើឡើងដោយអង្គការទាំងនោះ។

អង្គការថ្នាក់តំបន់ និងអន្តរជាតិជាច្រើនជុំវិញពិភពលោក បានបង្កើតសភាតំណាងសម្រាប់ខ្លួនគេ (IPU, WTO, AIPA, APF, APA) ឬសភាតំបន់ (EP, PAP)។ ជាការពិតណាស់ អង្គការសភាទាំងនោះមានលក្ខណៈខុសៗគ្នាទៅលើរបៀបនៃការបង្កើត អំណាច និងនីតិវិធីអនុវត្តការងារ ប៉ុន្តែជាក់ស្តែង គឺស្ថាប័នសភាអន្តរជាតិទាំងនេះច្រើននៅមានភាពទន់ខ្សោយ ហើយតួនាទី ឥទ្ធិពល អំណាច និងជាតុចូលផ្នែកគោលនយោបាយនៅមានកម្រិត។

នេះមិនមានន័យថា ការទូតសភាគួរតែជំនួសការទូតបែបប្រពៃណីនោះទេ។ គោលការណ៍ទូទៅនៅតែរក្សាដដែល ពោលគឺ៖ អង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាលជាអ្នកតំណាងឲ្យរដ្ឋក្នុងការចរចាកិច្ចព្រមព្រៀងអន្តរជាតិ ហើយសភាជាអ្នកត្រួតពិនិត្យលើសកម្មភាពរបស់រដ្ឋាភិបាល និងជះឥទ្ធិពលលើគោលនយោបាយដែលធ្វើឡើងដោយរដ្ឋាភិបាលក្នុងការយកទៅចរចាលើកិច្ចព្រមព្រៀង ជាអ្នកផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងទាំងនោះ ជាអ្នកការអនុម័តច្បាប់ និងធ្វើវិភាជន៍ថវិកាសមស្រប ដើម្បីឲ្យរដ្ឋាភិបាលយកប្រការនៃកិច្ចព្រមព្រៀងទៅប្រើ និងជាអ្នកត្រួតពិនិត្យលើដំណើរការអនុវត្តទាំងមូលតែម្តង។

ប៉ុន្តែការចូលរួមរបស់សភាក្នុងវិស័យការទូតពិតជាមានប្រយោជន៍៖ សភាមិនចាំបាច់ប្តេជ្ញាធ្វើតាមដូចដែលអ្វីរដ្ឋាភិបាល បានរៀបចំទេ ហេតុដូចនេះហើយសភាអាចមានភាពងាយស្រួលក្នុងការបត់បែន ជាពិសេសក្នុងស្ថានភាពរសើប ឬពេលដែលមានការមិនឯកភាពគ្នាខ្លាំង។ សភាអាចស្នើ និងធ្វើការពិភាក្សារកដំណោះស្រាយប្រកបដោយនវានុវត្តន៍។ ការចូលរួមរបស់សភាធ្វើឲ្យមានមធ្យោបាយសន្ទនាចម្រុះ ដែលផ្តល់ឱកាសបន្ថែមដើម្បីទាញយកផលប្រយោជន៍ ព្រោះសភាមិនមានតួនាទីជាផ្លូវការនៅក្នុងការចរចានោះទេ។ ឧទាហរណ៍៖ សភាអឺរ៉ុបមានទំនោរក្នុងការបង្ហាញសារត្រង់ៗពីបញ្ហាអភិបាលកិច្ច និងសិទ្ធិមនុស្ស ឬពីការចូលទៅកាន់ទីផ្សារដែលទាក់ទងនឹងចិន។ សារទាំងនេះជួយសម្រួលដល់ការងាររបស់រដ្ឋជាសមាជិករបស់សហភាពអឺរ៉ុប និងដាក់សម្ពាធលើគណៈកម្មការអឺរ៉ុបឲ្យរក្សាតុល្យភាពត្រឹមត្រូវរវាងគុណតម្លៃ និងផលប្រយោជន៍។

បន្ថែមពីលើនេះសភានៃបណ្តារដ្ឋជាសមាជិកសហភាពអឺរ៉ុប ដែលពិតជាមានឥទ្ធិពលផ្ទាល់លើគោលនយោបាយក្នុងស្រុក និងសកលតាមរយៈកិច្ចដដែកដេញដោលនៅក្នុងសភារបស់ខ្លួន ការវិភាជន៍ថវិកា សវនការ និងការធ្វើសេចក្តីសម្រេច សភាអឺរ៉ុប (EP) នៅតែត្រូវបានទទួលស្គាល់ជាផ្លូវការថា ជាស្ថាប័នតំណាងដែលកើតឡើងពីការបោះឆ្នោតរបស់ EU ហើយសមាជិករបស់សភានេះ មានការចូលរួមដោយផ្ទាល់ក្នុងការធ្វើសេចក្តីសម្រេចចិត្ត៖ EP ជាអ្នកធ្វើច្បាប់រួមគ្នាជាមួយក្រុមប្រឹក្សាអឺរ៉ុបក្នុងបញ្ហាជាច្រើន លើកលែងតែបញ្ហាការបរទេស និងពន្ធ។ EP អនុម័ត ឬច្រានចោលច្បាប់និងកិច្ចព្រមព្រៀងអន្តរជាតិ(ឧទាហរណ៍៖ការបដិសេធកិច្ចព្រមព្រៀងអឺរ៉ុប-អាម៉េរិក ស្តីពីការចែករំលែកទិន្នន័យហិរញ្ញវត្ថុក្នុងឆ្នាំ២០១០ ឬការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយសិង្ហបុរីនៅ ខែកុម្ភៈ ២០១៩) និងបោះឆ្នោតលើសេចក្តីសម្រេច ដើម្បីជះឥទ្ធិពលដល់គោលនយោបាយរបស់សហភាពអឺរ៉ុបលើបញ្ហានានាដែលត្រូវបានលើកយកមកដោះស្រាយនៅក្នុងវេទិកាអន្តរជាតិ ដូចជាការប្រែប្រួលអាកាសធាតុ ឬសន្តិសុខទូរគមនាគមន៍ជាដើម។ ស្ថាប័ននេះក៏ជាអ្នកអនុម័តថវិកាប្រចាំឆ្នាំ និងត្រួតពិនិត្យការងាររបស់រដ្ឋាភិបាលពហុជាតិ តែក្នុងស្ថានភាពផ្សេងមួយចំនួន ជារឿយៗស្ថាប័ននេះដំណើរការដោយមិនមានការត្រួតពិនិត្យ (free of any check and balance)។

នៅក្នុងសហភាពអឺរ៉ុប ច្បាប់ច្រើនជាង ៦០% លែងត្រូវបានសម្រេចនៅថ្នាក់ជាតិទៀតហើយ ប៉ុន្តែគឺនៅថ្នាក់សហភាពអឺរ៉ុប។ ក្នុងករណីមានភាពផ្ទុយគ្នា ឬមានជម្លោះច្បាប់របស់សហភាពអឺរ៉ុបមានអាទិភាពលើច្បាប់ជាតិ៖ EP ដែលជាស្ថាប័នដែលកើតពីការបោះឆ្នោតដោយផ្ទាល់ បន្តិចម្តងៗយកមុខងារនីតិកម្ម និងត្រួតពិនិត្យទៅគ្រប់គ្រង។

សមាជិក សមាជិកាសភាដែលចូលរួមចំណែកក្នុងការងាររបស់សភាថ្នាក់តំបន់ក៏ប្រឈមនឹងបញ្ហាផ្ទាល់របស់ពួកគេផងដែរ៖ ដោយពួកគេត្រូវគ្រប់គ្រងផ្សេង ហើយពេលខ្លះអាចមានទំនាស់ទៅនឹងផលប្រយោជន៍ ដែលអាចជាទំនាស់ទាក់ទងនឹងប្រយោជន៍របស់ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ឬក៏បញ្ហាជាក់លាក់ទាក់ទងនឹងគណបក្សនយោបាយរបស់គេ[A]។ សំខាន់បំផុតពួកគេត្រូវកំណត់នូវអ្វីដែលជាផលប្រយោជន៍ក្នុងតំបន់ និង/ឬ សកល(រយៈពេលវែង)។ ការណ៍នេះតម្រូវឲ្យមានការប្រកាន់ខ្ជាប់នូវវប្បធម៌នយោបាយដោយផ្អែកលើការកសាងការឯកភាពបែបកុងសង់ស៊ីសដែលផ្តល់អាទិភាពដល់តម្រូវការសកលលើសតម្រូវការមូលដ្ឋាន ឬជាតិ។ នៅក្នុងបរិបទតំបន់ (ប៉ុន្តែជាញឹកញាប់ផងដែរនៅក្នុងបរិបទជាតិ និងអាស្រ័យលើប្រព័ន្ធនយោបាយ)គេត្រូវផ្សារភ្ជាប់និងជំរុញឲ្យមានការព្រមព្រៀងដើម្បីស្វែងរកការឯកភាពបែបកុងសង់ស៊ីស។ នៅពេលពិភាក្សាអំពីសេដ្ឋកិច្ច នៅពេលដោះស្រាយវិបត្តិ នៅពេលប្រយុទ្ធ

ប្រឆាំងនឹងអំពើភេរវកម្ម នៅពេលដោះស្រាយបញ្ហាសង្គម ការការពារទិន្នន័យ ការប្រែប្រួលអាកាសធាតុ ឬសន្តិសុខថាមពល គេត្រូវតែគិតដល់សហគមន៍ទាំងមូល។

នេះគឺជាហេតុផលដែលគេត្រូវការសភាថ្នាក់តំបន់ដែលរឹងមាំ ដើម្បីត្រួតពិនិត្យលើការងាររបស់ស្ថាប័នថ្នាក់លើជាតិ ដើម្បីពិនិត្យមើលលើការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ថាប័នទាំងនោះ តាមដានការអនុវត្ត បង្ហាញការគាំទ្រលើគោលនយោបាយមួយចំនួន និងធ្វើវិសោធនកម្ម ឬជំទាស់ទៅនឹងអ្វីមួយ។ ទោះបីជាស្ថាប័នសភាទាំងនេះមិនមានអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយផ្ទាល់ក៏ដោយ ក៏ការផ្តួចផ្តើម សេចក្តីថ្លែងការណ៍ និងសេចក្តីសម្រេចដែលធ្វើឡើងដោយស្ថាប័ននេះអាចមានឥទ្ធិពលខ្លាំងដល់ «ការទូតផ្លូវការ» ដែលធ្វើឡើងដោយអង្គនីតិប្រតិបត្តិ។ គេអាចចូលរួមចំណែក និងជះឥទ្ធិពលលើការអភិវឌ្ឍអន្តរជាតិ ដោយការបញ្ចេញនូវទស្សនៈផ្សេងៗដែលពេលខ្លះខុសពីទស្សនៈរបស់អង្គការតំបន់ ដោយសារតែលទ្ធភាពនៃការបត់បែនរបស់គេ។

នៅក្នុងពិភពសកលភាវូបនីយកម្មដែលមានតួអង្គមិនមែនរដ្ឋកំពុងមានឥទ្ធិពលកាន់តែខ្លាំងឡើង ពិភពលោកមួយ ដែលការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗស្តីពី កិច្ចការសាធារណៈឆ្លងហួសពីព្រំដែនជាតិ ភាគច្រើនការធ្វើសេចក្តីសម្រេចចិត្តទាំងនោះត្រូវបានគេធ្វើឡើងនៅក្នុងវេទិកាសកល និងតំបន់ សន្និបាតសភាថ្នាក់តំបន់ និងសកល ដូចជា ASEP ដែលត្រូវតែមានការផ្តល់អំណាច ដើម្បីធ្វើឲ្យវេទិកាទាំងនោះមានគណនេយ្យភាព និងបន្ថែមភាពស្របច្បាប់លើការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ថាប័នទាំងនោះ។ សមាជិក សមាជិកាសភាដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តថ្នាក់ជាតិ។ ដូចគ្នានេះដែរ សមាជិកសមាជិកាសភាក៏ត្រូវតែក្លាយខ្លួនជាតួអង្គសំខាន់នៅក្នុងរចនាសម្ព័ន្ធតំបន់ដែលការធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗកាន់តែច្រើនកំពុងតែត្រូវបានធ្វើឡើងនៅក្នុងវេទិកាទាំងនោះ ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ១.៤ ការឆ្លើយតបរបស់ឥណ្ឌូណេស៊ីទៅនឹងវិបត្តិ កូវីដ-១៩ ដំណាក់កាលដំបូង

## តួនាទីនៃការទូតសភា

«សភាពធម្មតាតាមបែបគន្លងថ្មី» (“A new normal” ) ជាពាក្យដែលត្រូវបានប្រើប្រាស់ជាញឹកញាប់នៅក្នុងឆ្នាំ ២០២០ ដើម្បីរៀបរាប់ពីស្ថានការណ៍រួមរបស់យើងទាំងអស់គ្នា។ ការផ្ទុះឡើងនៃជំងឺដែលបង្កដោយវីរុសកូរ៉ូណាក្នុងឆ្នាំ ២០១៩ ( កូវីដ-១៩ ) ដែលពេលនេះជាជំងឺរាតត្បាតសកល បានផ្លាស់ប្តូរវិធីរស់នៅរបស់យើង។

ពេលវេលាកន្លងផុតពីមួយថ្ងៃទៅមួយថ្ងៃក្នុងអំឡុងពេលវិបត្តិនេះ គឺកំពុងតែកំណត់សកម្មភាពរបស់យើង។ “ការសម្រេចចិត្តរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋក្នុងរយៈពេលពីរ-បីសប្តាហ៍ខាងមុខនេះ អាចនឹងមានឥទ្ធិពលដល់ពិភពលោកនៅរយៈពេលច្រើនឆ្នាំខាងមុខទៀត ការសម្រេចចិត្តដែលក្នុងពេលធម្មតាអាចត្រូវការរយៈពេលច្រើនឆ្នាំក្នុងការគិតពិចារណាត្រូវបានធ្វើក្នុងរយៈពេលត្រឹមតែប៉ុន្មានម៉ោងប៉ុណ្ណោះ។ បច្ចេកវិទ្យាថ្មីមួយចំនួនដែលមិនមានការអភិវឌ្ឍពេញលេញ និងពេលខ្លះមានគ្រោះថ្នាក់ថែមទៀត ត្រូវបានយកមកប្រើប្រាស់ទាំងប្រញាប់ប្រញាល់ ព្រោះតែហានិភ័យនៃការមិនធ្វើសកម្មភាពអ្វីនោះវាមានទំហំធំជាង។ ប្រទេសទាំងអស់ដើរតួជាកណ្តុរពិសោធន៍សម្រាប់សង្គមក្នុងទ្រង់ទ្រាយធំមួយ។”[៥]

លទ្ធភាពរបស់ប្រទេសនីមួយៗក្នុងការឆ្លើយតបនឹងការកាត់បន្ថយផលប៉ះពាល់នៃជំងឺរាតត្បាតសកលនេះ គឺពិតជាកត្តាកំណត់ជោគវាសនារបស់ប្រជាជាតិទាំងនោះសម្រាប់ឆ្នាំបន្តបន្ទាប់ខាងមុខ។ ទោះជាយ៉ាងនេះក្តី ជំងឺរាតត្បាតនេះ គឺជាបញ្ហាប្រឈមដ៏ធំដែលមិនមានប្រទេសណាមួយអាចប្រយុទ្ធប្រឆាំងតែឯងបាននោះទេ។ មនុស្សខ្លះបានប្រៀបធៀបសង្គ្រាមប្រឆាំងនឹងកូវីដ-១៩ ទៅនឹងសង្គ្រាមលោកលើកទី២ ដោយគ្រាន់តែខុសគ្នាត្រង់ថា ម្តងនេះជំនួសឲ្យការប្រយុទ្ធប្រឆាំងរវាងគ្នានឹងគ្នា ប្រជាជាតិទាំងអស់គឺជាបក្សពួកតែមួយ។ ជាការពិតណាស់ ប្រទេសទាំងអស់ត្រូវតែការពារពលរដ្ឋរបស់ខ្លួនប្រឆាំងនឹងវីរុសដែលឆ្លងដោយមិនប្រកាន់ពូជសាសន៍ ជំនឿ ឬទស្សនៈនយោបាយនោះទេ។ តែការឆ្លើយតបនៅត្រឹមកម្រិតជាតិមួយបានបង្ហាញថាមិនមានប្រសិទ្ធភាពសម្រាប់ដោះស្រាយភាពស្មុគស្មាញនៃបញ្ហាប្រឈមដែលបណ្តាលមកពីជំងឺរាតត្បាតសកលនេះឡើយ។ វីរុសនេះបាននាំមកនូវផលវិបាកជាបន្តបន្ទាប់ដែលលាតសន្ធឹងហួសពីសុខភាពរបស់ពលរដ្ឋម្នាក់ៗហើយឆ្លងហួសព្រំដែនជាតិនីមួយៗថែមទៀតផង។ ដូចនេះ ជំងឺរាតត្បាតសកលនេះ គឺជាចំណុចរបត់មួយដែលកំហិតឲ្យយើងស្តារឡើងវិញនូវជំនឿរបស់យើងទៅលើគុណតម្លៃនៃកិច្ចសហប្រតិបត្តិការ និងកិច្ចសហការជាសកល។

កូវីដ-១៩ ក៏ជាការដាស់តឿន និងជាការក្រើនរំលឹកដ៏ខ្លាំងក្លាមួយពីតម្រូវការនៃកិច្ចសហប្រតិបត្តិការ និងសាមគ្គីភាពជាសកល ព្រោះជំងឺនេះវាបានវាយលុកពិភពលោកចំពេលដែលប្រព័ន្ធពហុភាគីកំពុងទទួលរងសម្ពាធពីការប្រកួតប្រជែងគ្នារវាងមហាអំណាចធំៗ។ នៅក្នុងសិក្ខាសាលាតាមប្រព័ន្ធវីដេអូដែលធ្វើឡើងដោយសហភាពអន្តរសភា ( IPU ) និងការិយាល័យអង្គការសហប្រជាជាតិសម្រាប់ការកាត់បន្ថយហានិភ័យបណ្តាលមកពីគ្រោះមហន្តរាយ ( UNDRR ) នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ អគ្គនាយកអង្គការសុខភាពពិភពលោក ( WHO ) បានសង្កត់ធ្ងន់ថា សាមគ្គីភាពជាសកល គឺចាំបាច់សម្រាប់ប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតនេះ [៦] ដែលសារនេះមានស្មារតីដូចគ្នាទៅនឹងសាររបស់ប្រធានសភាឥណ្ឌូនេស៊ី លោកស្រី Puan Maharani ។ នៅក្នុងសុន្ទរកថាបើករបស់លោកស្រីថ្លែងទៅកាន់ក្រុមពិភាក្សាតាមប្រព័ន្ធវីដេអូ ដែលរៀបចំឡើងដោយគណៈកម្មាធិការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរសភានៃរដ្ឋសភាឥណ្ឌូនេស៊ីលោកស្រីបានអំពាវនាវស្រដៀងគ្នា ដោយសូមឲ្យមានសាមគ្គីភាពជាអន្តរជាតិ ហើយត្រូវពិនិត្យមើលជាថ្មីម្តងទៀតលើគោលគំនិតនៃការធ្វើការរួមគ្នាជាក្រុមគ្រួសារនៃប្រជាជាតិ ដែលជាគោលគំនិតគាំទ្រយ៉ាងប្តូរផ្តាច់ដោយអតីតប្រធានាធិបតីឥណ្ឌូនេស៊ី Soekarno កាលពី៧៥ឆ្នាំមុន [៧]។

សភាដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្វិលកង់នៃកិច្ចសហប្រតិបត្តិការសកល។ សភាក៏ដូចជាសមាជិក សមាជិកាសភាម្នាក់ៗដែរមានតួនាទីពិសេសមួយក្នុងការជំរុញទំនាក់ទំនងឆ្លងដែន ដើម្បីប្រមូលផ្តុំសាមគ្គីភាពក្នុងចំណោមសមាជិកសមាជិកាសភាទាំងអស់។ទោះជាយ៉ាងណាក៏ដោយការកើនឡើងនៃតួនាទីអន្តរជាតិរបស់សភាទាមទារការគាំទ្រជារួមពីអង្គការអន្តរសភានានា។ នវានុវត្តន៍ ( Innovation )

គឺជាពាក្យគន្លឹះ ជាពិសេសចាប់តាំងពីពេលមានកូវីដ-១៩ របៀបដែលមនុស្សទាក់ទងគ្នាទៅវិញទៅមកបានផ្លាស់ប្តូរ។ ពេលនេះបានកន្លងផុតទៅហើយ ដែលថា តួនាទីរបស់អង្គការអន្តរសភាពីមុន គឺមានត្រឹមតែធ្វើការសម្របសម្រួលការទំនាក់ទំនង និងការប្រាស្រ័យឆ្លើយឆ្លងរវាងសមាជិកសមាជិកាសភាតាមរយៈសន្និបាតប្រចាំឆ្នាំប៉ុណ្ណោះ។ នវានុវត្តន៍ថ្មីៗរួមមានការប្រមូលព័ត៌មាន និងចងក្រងថ្មីៗរបស់ IPU ពីរបៀបដែលសភាកំពុងទប់ទល់នឹងជំងឺរាតត្បាតសកល និងសិក្ខាសាលាតាមប្រព័ន្ធវីដេអូជាច្រើនជាមួយអង្គការអន្តរជាតិជាដៃគូ ដែលផ្តោតលើបញ្ហាផ្សេងៗទាក់ទងនឹងវិបត្តិនេះ។

## ការឆ្លើយតបជាក់លាក់របស់សភាឥណ្ឌូនេស៊ីចំពោះវិបត្តិកូវីដ-១៩

រដ្ឋាភិបាលឥណ្ឌូនេស៊ីបានដើរតួនាទីនាំមុខក្នុងការអះអាងឡើងវិញពីការគាំទ្រនូវកិច្ចសហប្រតិបត្តិការ និងកិច្ចសហការអន្តរជាតិ។ រួមគ្នាជាមួយប្រទេសហ្គាណា លិចតិនស្តាញ ន័រវែស សិង្ហបុរី និងស្វីស ឥណ្ឌូណេស៊ីបានដាក់ចេញនូវសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិស្តីពីសាមគ្គីភាពសកលដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺដែលបណ្តាលមកពីវីរុសកូរ៉ូណា២០១៩។ សេចក្តីសម្រេចដែលត្រូវបានគាំទ្ររួមគ្នាដោយប្រទេស១៨៨ ផ្តោតសំខាន់លើកិច្ចសហប្រតិបត្តិការអន្តរជាតិដែលជាឧបករណ៍ស្នូលក្នុងការដោះស្រាយជំងឺរាតត្បាតសកលនេះបានជំរុញឲ្យមានការផ្លាស់ប្តូរព័ត៌មានរបកគំហើញវិទ្យាសាស្ត្រ និងឧត្តមានុវត្តន៍ ក្រោមការដឹកនាំរបស់អង្គការសុខភាពពិភពលោក។ លើសពីនេះទៀតប្រទេសឥណ្ឌូនេស៊ីគឺជាអ្នកចូលរួមក្នុងគម្រោងពិសោធន៍ប្រៀបធៀប និងវាយតម្លៃពីប្រសិទ្ធភាពនៃការព្យាបាលជំងឺកូវីដ-១៩ ដោយឈរលើស្មារតីសាមគ្គីភាពរបស់អង្គការសុខភាពពិភពលោក ( WHO Solidarity Trial ) ផងដែរ។ ការពិសោធន៍ និងវាយតម្លៃនេះមានគោលបំណងពន្លឿនការរកឲ្យឃើញផ្នែកវេជ្ជសាស្ត្រ ឱសថ និងវិធីសាស្ត្រព្យាបាលសម្រាប់កូវីដ-១៩ ដែលមានប្រសិទ្ធភាព[៩]។ ក្រៅពីអង្គការសហប្រជាជាតិ ឥណ្ឌូណេស៊ីក៏បានលើកទឹកចិត្តយ៉ាងសកម្មដល់កិច្ចសហប្រតិបត្តិការ និងកិច្ចសហការនៅក្នុងអង្គការផ្សេងៗដូចជា G20, អាស៊ាន, G77, D8, OIC, MIKTA, WTO, WIPO, ICAO, និងIMO ជាដើម។

កូវីដ-១៩ ក៏បានផ្លាស់ប្តូររបៀបដែលសភាធ្វើការផងដែរ។ ការចងក្រងរបស់ IPU ពីការឆ្លើយតបរបស់សភាទៅនឹងរោគរាតត្បាតសកលដែលបានរៀបរាប់ខាងលើ ជួយឲ្យយើងអាចចែករំលែក និងប្រៀបធៀបការអនុវត្តរបស់សភា [១០]។ វាបង្ហាញថា ការធ្វើការពីចម្ងាយ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងប្រាស្រ័យឆ្លើយឆ្លង ក៏ដូចជាការអនុវត្តការរក្សាគម្លាតបុគ្គលបានក្លាយជាវិធានការបង្ការរួមក្នុងចំណោមសភានានា។ សភាតំណាងរាស្ត្រនៃសាធារណរដ្ឋឥណ្ឌូនេស៊ីបានប្រកាន់យកសភាពធម្មតាតាមបែបគន្លងថ្មីនេះ ដោយអនុវត្តតាមនីតិវិធីទាំងអស់ខាងលើនេះ។ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ សភាតំណាងរាស្ត្រឥណ្ឌូនេស៊ីបានបើកសម័យប្រជុំរបស់ខ្លួនក្រោមវិធានការការពារជាច្រើន ដោយមានសមាជិក សមាជិកាសភាខ្លះចូលរួមដោយផ្ទាល់ និងច្រើននាក់ទៀតចូលរួមតាមរយៈប្រព័ន្ធវីដេអូ។ បន្ទាប់ពីការបើកសម័យប្រជុំនោះមក ការរៀបចំស្រដៀងគ្នានេះត្រូវបានអនុវត្តសម្រាប់សភា និងលេខាធិការដ្ឋានសភា រាល់ការពិភាក្សារវាងលេខាធិការដ្ឋាន និងសមភាគីនីតិប្បញ្ញត្តិរបស់ខ្លួន នាពេលបច្ចុប្បន្ននេះត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធវីដេអូ។

ជាញឹកញាប់វិបត្តិតែងតែនាំមកនូវការខូចខាតផ្នែកប្រជាធិបតេយ្យ។ ដូចនៅក្នុងប្រទេសភាគច្រើនដែរ នៅក្នុងប្រទេសឥណ្ឌូនេស៊ី អំណាចចម្បងក្នុងការសម្រេចចិត្តលើគោលនយោបាយដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតសកល គឺជាសិទ្ធិអំណាចរបស់ស្ថាប័ននីតិប្រតិបត្តិ។ ដើម្បីធានាថា កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកែសម្រួលវិធានការសុខភាពសាធារណៈនិងសង្គម ដែលមិនធ្វើឲ្យខូចដល់ប្រជាធិបតេយ្យ តម្លាភាពនិងគណនេយ្យភាពនោះ ក្នុងខណៈពេលដែលកំពុងគ្រប់គ្រងហានិភ័យនៃការកើតឡើងជាថ្មីនៃករណីឆ្លង ការបិទសភាមិនមែនជាជម្រើសសម្រាប់ប្រទេសឥណ្ឌូនេស៊ីទេ។

ទោះបីសភាឥណ្ឌូនេស៊ីបានចាប់ផ្តើមបើកសម័យប្រជុំរបស់ខ្លួននៅចុងខែមីនា ពោលគឺ ប៉ុន្មានសប្តាហ៍បន្ទាប់ពីការរកឃើញពីករណីដំបូងនៃកូវីដ-១៩ ដែលបានប្រកាសដោយប្រធានាធិបតី Jokowi ក៏ដោយ ការងាររបស់សភាមិនដែលឈប់ឡើយ។ មួយថ្ងៃបន្ទាប់ពីមានករណីដំបូងត្រូវបានប្រកាស សភាឥណ្ឌូនេស៊ីតាមរយៈប្រធានសភាលោកស្រី Puan Maharani បានរំលឹករដ្ឋាភិបាលឲ្យផ្តល់អាទិភាពលើសុខភាព និងសុវត្ថិភាពសាធារណៈច្រើនជាងបញ្ហាដទៃទៀត រួមទាំងផលប៉ះពាល់សេដ្ឋកិច្ចផងដែរ។ លោកស្រីបានជំរុញឲ្យរដ្ឋាភិបាលមានតម្លាភាពក្នុងការគ្រប់គ្រងករណីឆ្លង ពង្រឹងការត្រួតពិនិត្យតាមព្រំដែន និងពិនិត្យរកមេរោគឲ្យបានលឿន ហើយត្រូវគិតពីវិធានការទប់ទល់បុរេសកម្មផ្សេងៗទៀត។ លោកស្រីថែមទាំងស្នើឲ្យមានការបង្កើតក្រុមការងារសម្របសម្រួលរួម ដើម្បីប្រយុទ្ធប្រឆាំង

នឹងជម្ងឺរាតត្បាតសកលនេះ[១១]។ ការអំពាវនាវទាំងនេះត្រូវបានធ្វើឡើងស្របពេលមានការព្រួយបារម្ភជាសាធារណៈថា ស្ថាប័ននីតិប្រតិបត្តិកំពុងផ្តោតលើការកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចមកពីជំងឺរាតត្បាតសកលជាជាងការត្រៀមរៀបចំនិងកាត់បន្ថយផលវិបាកដែលកើតឡើងភ្លាមៗបន្ទាប់ពីការឆ្លងលើកដំបូង។

មិនមានប្រទេសណាមួយស្មានដល់ថា នឹងមានការរីករាតត្បាតជាសកលនៃជម្ងឺកូវីដ-១៩ បែបនោះទេ។ ដូចនេះហើយ វាសមហេតុផលដែលរដ្ឋាភិបាលទាំងអស់នៅលើពិភពលោកបានប្រើអំណាចក្នុងគ្រាអាសន្នរបស់ពួកគេដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺនេះ។ ប៉ុន្តែភាពចាំបាច់ក្នុងការធ្វើសកម្មភាពឲ្យបានរហ័សនិងអង់អាចមិនមែនជាលេសដើម្បីប្រមូលផ្តុំអំណាច និងសមត្ថកិច្ចទាំងអស់នៅស្ថាប័ននីតិប្រតិបត្តិនោះទេ។ ការប្រមូលផ្តុំអំណាចអាចនាំឲ្យមានការរំលោភអំណាច។ ត្រង់នេះហើយដែលធ្វើឲ្យអំណាចតាមរដ្ឋធម្មនុញ្ញរបស់សភាមានសារៈសំខាន់ជាងពេលណាៗទាំងអស់។

ក្នុងបរិបទនេះហើយ ទើបសភាឥណ្ឌូនេស៊ីបានបង្កើតក្រុមការងារសភាមួយ ដើម្បីត្រួតពិនិត្យ និងតាមដានការគ្រប់គ្រងវិបត្តិកូវីដ-១៩។ ក្រុមនេះត្រូវបានប្រគល់ភារកិច្ចទាក់ទងនឹងការតាមដានពីរបៀបដែលស្ថាប័ននីតិប្រតិបត្តិឆ្លើយតបចំពោះបញ្ហាទាក់ទងនឹងសុខភាព បន្ទាប់ពីរដ្ឋាភិបាលបានប្រកាសដាក់ជំងឺកូវីដ-១៩ ជាភាពអាសន្ននៃសុខភាពសាធារណៈ តាមរយៈបទបញ្ជារបស់ប្រធានាធិបតីដែលប្រកាសនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០។ ក្រុមការងារនេះបានចាប់ផ្តើមពីការលុបចោលនូវការវិធានការរបស់អន្តរស្ថាប័ននានាដែលមានលក្ខណៈមិនរួមគ្នា (interinstitutional ego-sectoral) [C] ក្នុងការគ្រប់គ្រងវិបត្តិនេះ។ ក្រុមនេះត្រូវបានចាត់តាំងឲ្យតាមដានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងស្រុកដែលចាំបាច់ត្រូវប្រើដើម្បីដោះស្រាយវិបត្តិសុខភាព រួមមានដូចជា កញ្ចប់ឧបករណ៍ធ្វើតេស្តកេមេរោគឆ្លង (PCR) ការស្រាវជ្រាវរកវ៉ាក់សាំង និងវិធានការផ្សេងៗទៀត។

សភាក៏បានធ្វើការដេញដោលគ្នាទៅលើបទបញ្ញត្តិរបស់រដ្ឋាភិបាលដែលបានចេញជំនួសច្បាប់ស្តីពី គោលនយោបាយហិរញ្ញវត្ថុ និងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋ ដោយសារបទបញ្ញត្តិទាំងនេះបានផ្តល់សិទ្ធិអំណាច និងភាពបត់បែនដល់រដ្ឋាភិបាលក្នុងការរំលោភលើដែនសមត្ថកិច្ចច្បាប់ដែលមានស្រាប់ និងនីតិវិធីនានាក្នុងការចេញនូវគោលនយោបាយហិរញ្ញវត្ថុក្នុងពេលមានជំងឺរាតត្បាតសកល។

បទបញ្ញត្តិថ្មីត្រូវបានគេមើលឃើញថា ផ្តល់ក្របខ័ណ្ឌច្បាប់ធំធេង ដែលអាចឲ្យរដ្ឋាភិបាលចេញគោលនយោបាយថវិកាហិរញ្ញវត្ថុ និងរូបិយវត្ថុ ដើម្បីដោះស្រាយផលប៉ះពាល់ដោយសារកូវីដ-១៩។

បទបញ្ញត្តិនេះបានអនុញ្ញាតឲ្យរដ្ឋាភិបាលបង្កើនឱនភាពថវិកាដល់ជាង៣% នៃផលិតផលក្នុងស្រុកសរុប ដែលពីមុនត្រូវបានហាមឃាត់យ៉ាងតឹងតែង ដោយច្បាប់ហិរញ្ញវត្ថុរបស់រដ្ឋ។ ការធ្វើបែបនេះក៏បានកាត់ចេញនូវនីតិវិធីចាំបាច់នានាលើការកែប្រែរចនាសម្ព័ន្ធថវិការបស់រដ្ឋ ដោយគ្មានការពិគ្រោះយោបល់ជាមុនជាមួយសភា។ ចំណុចចម្រូងចម្រាសនៃបទបញ្ញត្តិនេះត្រូវបានរិះគន់ដោយសាធារណៈជនមួយចំនួនថា បទបញ្ញត្តិនេះបានផ្តល់អភ័យឯកសិទ្ធិដល់អាជ្ញាធរ ព្រោះពួកគេមិនអាចទទួលរងការចោទប្រកាន់ក្រោមច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណី នៅពេលអនុវត្តគោលនយោបាយក្នុងពេលមានជំងឺរាតត្បាតសកលនោះទេ។

ការដេញដោលបានបញ្ចប់នៅថ្ងៃទី១២ ខែឧសភា ដែលត្រូវបានកត់សម្គាល់ ដោយមានការអនុម័តបទបញ្ញត្តិនេះទៅជាច្បាប់ដោយសភាឥណ្ឌូនេស៊ី។ ការអនុម័តនេះត្រូវបានធ្វើឡើងបន្ទាប់ពីមានការពិភាក្សាគ្នាយ៉ាងក្តៅគគុកលើខ្លឹមសាររបស់បទបញ្ញត្តិនេះដែលនៅក្នុងការពិភាក្សានោះសភាបានទទួលស្គាល់ថា វិបត្តិដ៏ធំដែលកំពុងតែកើតឡើងនេះ ទាមទារឲ្យមានការឆ្លើយតបជាពិសេសមួយ។ គេបានទទួលស្គាល់ថា ការផ្លាស់ប្តូររចនាសម្ព័ន្ធថវិការបស់រដ្ឋដោយគ្មានការពិគ្រោះយោបល់ជាមុនជាមួយសភា គឺធ្វើឡើងក្នុងករណីចាំបាច់ ដើម្បីអាចឲ្យរដ្ឋាភិបាលអនុវត្តសកម្មភាពដែលចាំបាច់បានឆាប់រហ័ស ដើម្បីទប់ស្កាត់កុំឲ្យមានគ្រោះមហន្តរាយហិរញ្ញវត្ថុបន្ថែមទៀត។

ទោះជាយ៉ាងណា ការពង្រីកអំណាច និងសមត្ថកិច្ចពិសេសដែលត្រូវបានផ្តល់ឲ្យរដ្ឋាភិបាលក្នុងពេលមានវិបត្តិមិនមែនគ្មានដែនកំណត់នោះទេ។ ចំណុចលេចធ្លោមួយនៃការដេញដោលរបស់សភា ដែលមិនគួរមើលរំលងនោះគឺការបន្ថែមកថាខណ្ឌបញ្ចប់ ដោយបានចែងថា ភាពបត់បែននៃឱនភាពថវិកាត្រូវផុតកំណត់ត្រឹមឆ្នាំ២០២៣។ រដ្ឋាភិបាលក៏បានប្តេជ្ញាចិត្តវិលត្រឡប់ទៅរកដំណើរការធម្មតាឡើងវិញ សម្រាប់ការដេញពិភាក្សាពីថវិកាក្នុងឆ្នាំ២០២១។ លើសពីនេះទៅទៀតស្ថាប័ននីតិប្រតិបត្តិក៏បាននិយាយថាខ្លួននឹងស្នើសុំឲ្យមានការដេញដោលពីសភាលើកញ្ចប់ថវិកានៃឆ្នាំក្រោយនៅពាក់កណ្តាលខែមិថុនា ឆ្នាំ២០២០។ ការដេញដោលនេះក៏រួមបញ្ចូលការដេញដោលលើបំណុលសាធារណៈផងដែរ។

យោងតាមច្បាប់ដែលបានអនុម័ត ឥណ្ឌូណេស៊ីបានវិភាជថវិកាបន្ថែមសរុបប្រមាណជា ៤០៥,១ ទ្រីលានរូពា (Rp) (២៧,៦ ប៊ីលានដុល្លារអាមេរិក) សម្រាប់វិស័យរួមមាន សុខាភិបាល (៥,១ ប៊ីលានដុល្លារអាមេរិក) ប្រព័ន្ធគាំពារសង្គម (៧,៥ប៊ីលានដុល្លារអាមេរិក) ការជួយសម្រួលដល់វិស័យពន្ធ និងឥណទានអាជីវកម្មរបស់ប្រជាពលរដ្ឋ (៤,៨ ប៊ីលានដុល្លារអាមេរិក) និងកម្មវិធីស្តារឡើងវិញ (១០,២ ប៊ីលានដុល្លារអាមេរិក) [១២]។ ច្បាប់នេះក៏បានកំណត់កំរិតឱនភាពនៃថវិកាត្រឹមប្រហែល ៥,០៧% នៃផលិតផលក្នុងស្រុកសរុប ឬប្រហែល ៨៥២,៩ ទ្រីលានរូពា (៥៧,៩ ប៊ីលានដុល្លារអាមេរិក)។ ដើម្បីផ្តល់ហិរញ្ញប្បទានទ្រទ្រង់ឱនភាពថវិកា រដ្ឋាភិបាលបានស្នើឲ្យផ្តល់មូលប័ត្របំណុលរដ្ឋដែលមានតម្លៃស្មើនឹង ៥៧,១១ ប៊ីលានដុល្លារអាមេរិក[១៣]។ ក្នុងកិច្ចប្រជុំសភាមួយ ការជជែកដេញដោលមួយបានកើតឡើង ស្តីពីការធ្វើបែបណាដើម្បីរក្សាអត្រាការប្រាក់ទាបសម្រាប់មូលប័ត្របំណុលទាំងនេះ។ ក្តីបារម្ភចម្បងរបស់សភាគឺតើត្រូវកាត់បន្ថយផលវិបាកហិរញ្ញវត្ថុក្នុងប៉ុន្មានទសវត្សរ៍ខាងមុខដោយរបៀបណា[១៤]។ ដើម្បីដោះស្រាយបញ្ហានេះ សភាចាំបាច់ត្រូវពិនិត្យវិនិច្ឆ័យឲ្យបានច្បាស់លាស់ពីផែនការបំណុល ការស្នើសុំ និងលទ្ធភាពនៃការទូទាត់ជាពិសេសដើម្បីធានាថា ថវិកាដែលបានបង្កើនតាមរយៈបំណុលនឹងត្រូវយកទៅប្រើប្រាស់ដើម្បីគាំទ្រដល់អ្នកដែលរងផលប៉ះពាល់ខ្លាំង។ សរុបសេចក្តីមក ការគ្រប់គ្រងបំណុល គឺជាផ្នែកមួយក្នុងចំណោមផ្នែកជាច្រើនដែលសភាចាំបាច់ត្រូវចូលរួម ជាពិសេសនៅពេលមានវិបត្តិ។



ក្រុងតាគីរាំង ខេត្តបាន់តែន ប្រទេសឥណ្ឌូនេស៊ី ការប្រមូលផ្តុំចាក់វ៉ាក់សាំងសម្រាប់មនុស្សចាស់ និងអ្នកបើកបរ នៅមជ្ឈមណ្ឌលវ៉ាក់សាំង Grab។
Toto Santiko Budi

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ១.៥ ASEAN POLICY RESPONSES TO THE ECONOMIC IMPACTS OF COVID-19

ASEAN Member States (AMS) have taken targeted and decisive measures in response to the impact of COVID-19 through three broad interventions: fiscal stimulus packages, monetary and financial measures, and sector-specific interventions [17, 26]. Fiscal stimulus was intended to boost the health, social and economic sectors, particularly in the hardest hit segments of population and industries, whereas monetary measures were undertaken to promote adequate liquidity and increase confidence with the concerns related to production cuts [17]. The effectiveness in identifying targets and resource allocation was considered crucial to maintain livelihoods, employment and economic activities before moving forward towards a recovery. The effectiveness of these responses will ultimately depend on the disbursement and absorption capacity of each measure [26].

## FISCAL STIMULUS PACKAGES

The extent of fiscal stimulus measures have been limited by each country's fiscal space, including costs of borrowing, scope of public debt, and level of development. Some AMS have relaxed fiscal targets and increased borrowing to finance spending to fight the outbreak [17]. Some members, such as Cambodia, have also put in place reductions of nonessential current expenditure to allocate the saved funds for the health sector and to cushion the virus' economic impact [27, 28]. Fiscal intervention for ASEAN economies can be classified under three categories [17]:

- Tax/fees/charges/moratoriums that reduce financial burdens on affected businesses and industries to help them survive and resume operations
- Household subsidies (including cash allowances and subsidies for social security and health protection), particularly those identified as low-income and vulnerable
- Financing and moratorium/restructuring of loans for affected business, including individuals and small and medium enterprises (SMEs).

As of December 2020, AMS have employed a wide range of measures amounting to a combined USD 421 billion, equivalent to an average of 10.2% of GDP in 2019 [29]. Individually, Indonesia has had the largest package, reaching USD 116 billion, or 11% of GDP in 2019 and comprising about 27% of the total regional package (Figure 3.1); Singapore with almost USD 90 billion had the second largest package, yet stands first in GDP equivalent (25.3%) over the same period. As shown in Figure 3.1, Malaysia and Thailand stand in the middle, followed by Vietnam (10.3% of GDP), Cambodia (8.3%) and the Philippines (5.9%), while Brunei, Laos and Myanmar stand at the bottom of the list.

According to the IMF, the measures rolled out by the governments and central banks could consist of one or more of the following main components : (1) liquidity support, (2) credit creation, (3) direct long-term lending, (4) equity support, (5) health and income support, (6) budget reallocation,

> ***"Fiscal stimulus was intended to boost the health, social and economic sectors, particularly in the hardest hit segments of population and industries."***

### Figure 3.1: AMS total stimulus amount (in USD billion) and share of 2019 GDP (in %)




Note: Total amount does not include component 6, 7 and 8 to avoid double counting.

### Figure 3.2: Breakdowns of stimulus measures by AMS (% to total package)




Source (Figure 3.1 and Figure 3.2): ADB, IMF [15, 16]

(7) central bank financing of government (through lending, bond purchases, etc.), (8) international assistance received, (9) international assistance provided, and (10) no breakdown [29,30]. As Figure 3.2 demonstrates, besides Brunei where all of the measures have gone to direct lending (measure-3), all other Member States have spent a fair to high amount on health and income support (measure-5).

A large part of the budget stimulus in AMS has been directed to support SMEs since they are more vulnerable compared to large firms. SMEs are subject to limited resources, capital and liquidity constraints, and hence were judged to be more likely to lay off workers and close down during the crisis. Across ASEAN, SMEs account for more than 90% of businesses and are responsible for a large share of total employment, ranging from 52% in Vietnam to 97% in Indonesia [31].

## MONETARY AND FINANCIAL MEASURES

Central banks across the region have taken measures to ease market liquidity and support financial institutions mostly through conventional policy instruments including policy rate cuts, reserve requirement

ratio reduction, open market operations, loan facilities, and asset purchases [15]. Loan rate cuts and additional credit have also been provided specifically to virus affected manufacturers, essential sectors, and medical product producers. Most monetary institutions also continued to encourage banks to support lending without undermining the soundness of the banking sector. Taken together, the measures are intended to maintain stability in the banking system and to boost liquidity and market confidence, aimed at steering the economy out of the crisis.

## INFRASTRUCTURE PROJECTS AS PART OF STIMULUS MEASURES

Infrastructure projects have typically been used as a tool to support the economy during crisis as they provide a strong boost to economic activities and have long-term impact [18,32]. Similarly, in the time of the pandemic, governments have continued infrastructure work as part of the stimulus measures as well as to help bridge the gap of supply chain disruptions in AMS:

- With sufficient fiscal space, **Cambodia** has been able to spend on infrastructure programs including a USD 100 million project for infrastructure development and rehabilitation investment in Preah Sihanouk Province, and a USD 150 million construction and improvement of 38 lines of road in Siem Reap Province during the last quarter of 2020 [28].
- **Indonesia** developed plans to start labor-intensive projects country-wide to preserve employment particularly for low-income workers.
- **Malaysia** continued large infrastructure works to support economic growth and at the same time allocated budget for small initiatives aimed at maintaining jobs, whereas the Philippines continued the 'build, build, build' project.

| AMS Central Bank | Monetary and financial measures |
|---|---|
| **National Bank of Cambodia** | • delayed additional increase in the capital conservation buffer for one year<br>• issued guidelines on loan structuring for borrowers experiencing financial difficulties in priority sectors [15]<br>• continued extension of forbearance to June 2021, taking into account the impacts of the recent flooding in Cambodia in addition to the pandemic [31] |
| **Bank of Laos** | • urged commercial lenders to restructure financing for affected borrowers, with one-year grace periods and lower interest rates as needed |
| **State Bank of Vietnam** | • encouraged banks and lenders to curb dividends and operating expenses<br>• urged banks to bring down settlement fees 50% through interbank electronic system, a measure taken to support sufficient supplies of capital |
| **Bank of Thailand** | • applied Corporate Bond Stabilization Fund by providing bridge financing to high-quality firms to ensure stability in the financial market<br>• set up a special facility to provide liquidity for mutual funds through banks<br>• purchased government bonds to support the functioning of the bond market |
| **Monetary Authority of Singapore** | • initiated efforts to address the financial institutions operational challenges<br>• adjusted specific regulatory requirements and supervisory programs to ease the financial system |

- **Singapore** committed to continue construction schemes after some delays due to travel restrictions and when COVID-19 cases first accelerated (in April 2020).
- **Thailand** reserved investment resources for community infrastructure as part of packages for stabilizing the economy.

Despite being a crucial measure to counter the severe economic impact of the pandemic, infrastructure construction has also been affected by social restrictions, while budgets are realigned for other stimulus funding. For instance, Indonesia has needed to reallocate funding from the capital plan to the pandemic response. However, as the lockdowns are lifted, large-scale infrastructure projects will work as a vital part of the recovery plan to revive economies.

## ASEAN COLLECTIVE RESPONSES

In addition to the measures by individual Member States, ASEAN has collectively responded to the crisis with a series of meetings and joint declarations among members, as well as with stakeholders and external partners, to strengthen coordination mechanisms and to mitigate the adverse impacts of the pandemic [26]. At the start of the crisis in January 2020, regional preparedness and response actions were launched by the ASEAN Health Sector with ASEAN-plus-three partners (China, Japan and the Republic of Korea), and the COVID-19 ASEAN Response Fund was subsequently established.

In addition to the health sector response, ASEAN declared it was keeping markets open and facilitating flows of food, medicine and medical supplies, and other essential goods. The ASEAN Economic Ministers (AEM) reaffirmed the commitment to promote regional economic resilience through the AEM statement on "Strengthening ASEAN's economic resilience in response to the outbreak of COVID-19", adopted at the 26th AEM Retreat in March 2020 [33]. According to the statement, the region commits to maintain ASEAN's open economic and integration policies, while [...exploring cooperation with external partners and the international community to enhance readiness and response measures to mitigate and eliminate the impact of the COVID-19] (p.2) [33]. Following this statement, an "ASEAN-Japan Economic Resilience Action Plan" and "Hanoi Plan of Action of Strengthening ASEAN Economic Cooperation and Supply Chain Connectivity in Response to the COVID-19 Pandemic" were subsequently adopted (in April and June 2020, respectively) to implement the AEM statement and to explore arrangements to preserve supply chain connectivity [34, 35].

> *"The ASEAN Economic Ministers (AEM) reaffirmed the commitment to promote regional economic resilience through the AEM statement on "Strengthening ASEAN's economic resilience in response to the outbreak of COVID-19""*

# ១.៦ សភានៅអឺរ៉ុបប្រឈមនឹងវិបត្តិកូវីដ-១៩

សភាអឺរ៉ុប និងសភាជាតិនៃរដ្ឋជាសមាជិកនៃសហភាពអឺរ៉ុបបានកំពុងធ្វើការយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងជំស្រួចស្រាវទៅនឹងជំងឺរាតត្បាតសកលកូវីដ-១៩ ដើម្បីព្យាយាមកាត់បន្ថយផលប៉ះពាល់ ការពារប្រជាពលរដ្ឋ និងសេដ្ឋកិច្ចរបស់ខ្លួន និងលើកកម្ពស់សាមគ្គីភាព។

សភាអឺរ៉ុបបានគាំទ្រសកម្មភាពទាំង ១០ ដែលបានធ្វើឡើងដោយគណៈកម្មការអឺរ៉ុបក្នុងការប្រយុទ្ធប្រឆាំងវីរុសកូរ៉ូណា ទោះបីជា យើងអាចចាំថា បើយោងតាមសន្ធិសញ្ញានានា បញ្ហាសុខភាពមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហភាពអឺរ៉ុបទេ[F]តែគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលនៃប្រទេសជាសមាជិក។ ទោះបីជាបែបនេះក្តី សហភាពអឺរ៉ុបបានរៀបចំនីតិវិធីជាបន្ទាន់ រួមទាំងការផ្ទេរអ្នកជំងឺឆ្លងព្រំដែន ដោយមានការសម្របសម្រួលរវាងមន្ទីរពេទ្យ (បារាំង អាល្លឺម៉ង់ និងលុចសំបួ)។ ជាការពិតជំងឺរាតត្បាតសកលនេះបានផ្តល់ផលវិបាកដែលប៉ះពាល់ហួសពីវិស័យសុខាភិបាល តែប៉ះពាល់ដល់វិស័យជាច្រើនទៀត ដែលស្ថិតនៅក្នុងដែនអំណាចដែលមាននៅក្នុងសហភាពអឺរ៉ុប (ការគាំទ្រផ្នែកហិរញ្ញវត្ថុពីធនាគារកណ្តាលអឺរ៉ុប ការបន្ធូរបន្ថយវិធានការរូបិយវត្ថុ និងការសម្របសម្រួលការគ្រប់គ្រងព្រំដែនខាងក្រៅ)។

អត្ថបទនេះបង្ហាញជាដំបូងពីវិធានការដែលចាត់ចែងដោយគណៈកម្មការសហភាពអឺរ៉ុប បន្ទាប់មកអនុសាសន៍របស់សភាសហភាពអឺរ៉ុប និងចុងក្រោយពីគំនិតផ្តួចផ្តើមដែលធ្វើឡើងរួមគ្នារវាងបារាំង និងអាល្លឺម៉ង់។

## សកម្មភាពទាំង ១០ ដែលចាត់វិធានការដោយសហភាពអឺរ៉ុប[៣៦]

### ព្រំដែន

ដើម្បីជួយទប់ស្កាត់ការចម្លងវីរុសនៅអឺរ៉ុបនិងនៅកន្លែងដទៃទៀត សហភាពអឺរ៉ុបបានបិទព្រំដែនខាងក្រៅរបស់ខ្លួនសម្រាប់ការធ្វើដំណើរដែលមិនចាំបាច់ តែធានាឲ្យមានការបន្តចរាចរណ៍ទំនិញសំខាន់ៗនៅក្នុងសហភាពអឺរ៉ុប តាមរយៈការដាក់ចេញនូវច្រកសុវត្ថិភាព (Green Lanes)។ ធនធានបន្ថែមត្រូវបានរៀបចំរួចរាល់សម្រាប់មជ្ឈមណ្ឌលអឺរ៉ុបគ្រប់គ្រង និងការពារជំងឺ ជាភ្នាក់ងារដែលមានភារកិច្ចផ្តល់ការវាយតម្លៃឆាប់រហ័សលើហានិភ័យ និងផ្តល់ព័ត៌មានបច្ចុប្បន្នភាពពីការផ្ទុះឡើងនៃរោគរាតត្បាតនេះ។

### ការផ្តល់ឧបករណ៍វេជ្ជសាស្ត្រ

បណ្តាប្រទេសក្នុងសហភាពអឺរ៉ុបមានស្តុកសម្ភារៈវេជ្ជសាស្ត្រដំបូងគេ RescEU ដែលអាចយកមកប្រើប្រាស់បានលឿន មានដូចជាឧបករណ៍ជួយការដកដង្ហើម និងម៉ាស់ការពារ ក្រោមយន្តការការពារជនស៊ីវិល។ លើសពីនេះទៀតសហភាពអឺរ៉ុបបានបង្កើតមូលនិធិអន្តរជាតិដ៏ធំមួយដែលអនុញ្ញាតឲ្យរដ្ឋជាសមាជិកធ្វើការទិញឧបករណ៍ និងថ្នាំរួមគ្នា ហើយកំពុងកៀរគរថវិកាចំនួន ៣,០៨ ពាន់លានអឺរ៉ូ ក្រោមជំនួយរបស់សហភាពអឺរ៉ុប ដើម្បីទិញឧបករណ៍ធ្វើតេស្តបន្ថែម និងជួយបុគ្គលិកពេទ្យដែលថែទាំអ្នកជំងឺ។ សហភាពអឺរ៉ុបក៏បានរៀបចំកម្មវិធីអែងគ្លាសប្រាក់តាមអ៊ិនធឺណែត ដើម្បីអែងគ្លាសថវិកាឲ្យបានចំនួនដំបូង ៧,៥ ពាន់លានអឺរ៉ូ សម្រាប់ការស្រាវជ្រាវវ៉ាក់សាំង ថ្នាំ និងការធ្វើរោគវិនិច្ឆ័យ ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺនេះទូទាំងសកលលោក។

### ការលើកកម្ពស់ការស្រាវជ្រាវ

កម្មវិធីស្រាវជ្រាវ Horizon ២០២០ របស់សហភាពអឺរ៉ុបផ្តល់ថវិកាដល់គម្រោងស្រាវជ្រាវចំនួន ១៨ និង១៥១ ក្រុម នៅទូទាំងទ្វីបអឺរ៉ុប ដើម្បីជួយស្រាវជ្រាវរកវ៉ាក់សាំង COVID-១៩ ឲ្យបានឆាប់រហ័ស។ គោលបំណងជាក់លាក់គឺធ្វើឲ្យប្រសើរឡើងនូវការធ្វើរោគវិនិច្ឆ័យ ការត្រៀមខ្លួនជាស្រេច ការគ្រប់គ្រងវេជ្ជសាស្ត្រ និងការព្យាបាល។

### ការជំរុញសាមគ្គីភាពអឺរ៉ុប

សភាអឺរ៉ុបបានគាំទ្រនូវវិធានថ្មី ដែលអនុញ្ញាតឲ្យរដ្ឋជាសមាជិកស្នើសុំជំនួយហិរញ្ញវត្ថុពីមូលនិធិសាមគ្គីភាពអឺរ៉ុប ដើម្បីគ្រប់គ្រងលើភាពអាសន្នផ្នែកសុខភាព។ ជាមួយនឹងវិសាលភាពថ្មីដែលត្រូវបានពង្រីកបន្ថែមនៃមូលនិធិនេះ ទឹកប្រាក់ រហូតដល់ចំនួន ៨០០លានអឺរ៉ូ នឹងត្រូវត្រៀមសម្រាប់រដ្ឋជាសមាជិកក្នុងឆ្នាំ២០២០ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរាតត្បាតជាសកលនៃវីរុសកូរ៉ូណានេះ។

### ការធានានូវការងើបឡើងវិញរបស់សហភាពអឺរ៉ុប

ដើម្បីជួយសហភាពអឺរ៉ុបឲ្យងើបឡើងវិញពីផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងសង្គម ដែលបណ្តាលមកពីកូវីដ-១៩ គណៈកម្មការអឺរ៉ុបត្រូវបានស្នើសុំឲ្យធ្វើបច្ចុប្បន្នភាពទៅលើផែនការថវិការយៈពេលវែងរបស់សហភាពអឺរ៉ុបសម្រាប់ឆ្នាំ ២០២១-២០២៧ ដែលក្នុងនោះរួមមានកញ្ចប់ដើម្បីជំរុញសន្ទុះសេដ្ឋកិច្ចផងដែរ។ សមាជិក សមាជិកានៃសភាអឺរ៉ុប (MEPs) បានអំពាវនាវឲ្យមានកញ្ចប់សម្រាប់ការស្តារ និង

ការស្តាបនាឡើងវិញដ៏ធំមួយដែលត្រូវបានផ្តល់ហិរញ្ញប្បទានពីកំណើនកញ្ចប់ថវិការយៈពេលវែងសម្រាប់សហភាពអឺរ៉ុប មូលនិធិសហភាពអឺរ៉ុបដែលមានស្រាប់ និងមធ្យោបាយហិរញ្ញវត្ថុ ក៏ដូចជាពីអ្វីដែលគេហៅថា ប័ណ្ណបំណុលសម្រាប់ការស្តារឡើងវិញ។ លើសពីនេះទៀតគណៈកម្មការបានបង្ហាញពីផែនទីបង្ហាញផ្លូវក្រោយការបិទប្រទេសរបស់ខ្លួនសម្រាប់ជាយុទ្ធសាស្ត្រត្រៀមឲ្យមានប្រសិទ្ធភាព និងមានការសម្របសម្រួល ដែលរួមបញ្ចូលទាំងការធ្វើតេស្តទ្រង់ទ្រាយធំ និងសម្ភារៈការពារសម្រាប់ប្រជាពលរដ្ឋ។

## ការគាំទ្រសេដ្ឋកិច្ច

សហភាពអឺរ៉ុបបានដាក់ចេញនូវកញ្ចប់ថវិកាគាំទ្រ ៥៤០ ពាន់លានអឺរ៉ូ ដើម្បីដោះស្រាយវិបត្តិ ជួយដល់កម្មករ ធុរកិច្ច និងរដ្ឋជាសមាជិក។ លើសពីនេះទៀត ធនាគារកណ្តាលអឺរ៉ុបកំពុងផ្តល់ប្រាក់ចំនួន ៧៥០ពាន់លានអឺរ៉ូ ដើម្បីសម្រាលបំណុលរដ្ឋាភិបាលក្នុងពេលមានវិបត្តិ ក៏ដូចជាការបញ្ចេញកញ្ចប់ថវិកាចំនួន ១២០ពាន់លានអឺរ៉ូសម្រាប់ទិញមូលប័ត្រ និងចំនួន ២០ពាន់លានអឺរ៉ូ សម្រាប់ការទិញបំណុល។ សមាជិក សមាជិកានៃសភាអឺរ៉ុបក៏បានបោះឆ្នោតគាំទ្រការអនុញ្ញាតឲ្យប្រទេសនៅសហភាពអឺរ៉ុបប្រើប្រាស់ទឹកប្រាក់ចំនួន ៣៧ពាន់លានអឺរ៉ូ នៃមូលនិធិអឺរ៉ុបសម្រាប់ការគាំទ្រសេដ្ឋកិច្ច និងកាត់បន្ថយវិសមភាពរវាងតំបន់នីមួយៗក្នុងអឺរ៉ុប (EU Strutural Fund) ដែលមានស្រាប់ ដើម្បីដោះស្រាយវិបត្តិវីរុសកូរ៉ូណា និងគាំទ្រសេវាកម្មថែទាំសុខភាព ធុរកិច្ច និងកម្មករ។

## ការការពារមុខរបរ

ដើម្បីធានាថា និយោជិកអាចរក្សាការងាររបស់ពួកគេបាន គណៈកម្មការបានស្នើឲ្យមានការគាំទ្រដល់ការងាររយៈពេលខ្លី (Sure) ដោយផ្តល់មូលនិធិសម្រាប់ក្រុមហ៊ុនដែលប្រឈមនឹងការថយចុះនៃតម្រូវការដោយសារតែវិបត្តិវីរុសកូរ៉ូណា។ គណៈកម្មការអឺរ៉ុបក៏បានដកប្រាក់ចំនួន ១ ពាន់លានអឺរ៉ូ ពីមូលនិធិអឺរ៉ុបសម្រាប់ការវិនិយោគយុទ្ធសាស្ត្រសម្រាប់ធានាដល់ការលើកទឹកចិត្តធនាគារ និងអ្នកផ្តល់ប្រាក់កម្ចីផ្សេងៗ ដោយផ្តល់ថវិកាដល់ទៅ ៨ពាន់លានអឺរ៉ូជាសាច់ប្រាក់ ដើម្បីគាំទ្រដល់ធុរកិច្ចចំនួន ១០០,០០០ នៅអឺរ៉ុប ។

## ការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋអឺរ៉ុប

ប្រជាពលរដ្ឋអឺរ៉ុបរាប់ម៉ឺននាក់ដែលជាប់នៅក្រៅប្រទេសនៅជុំវិញពិភពលោកដោយសារការផ្ទុះឡើងនៃជំងឺនេះ ត្រូវបានបញ្ជូនត្រឡប់ទៅផ្ទះវិញ ដោយសារយន្តការការពារជនស៊ីវិលអឺរ៉ុប។

## ការជួយប្រទេសកំពុងអភិវឌ្ឍន៍ដែលប្រឈមនឹងការរាតត្បាតសកល

គណៈកម្មាធិការអឺរ៉ុបបានបញ្ចេញទឹកប្រាក់ចំនួន ២០ ពាន់លានអឺរ៉ូ ដើម្បីជួយប្រទេសមិនមែនជាសមាជិកសហភាពអឺរ៉ុប ក្នុងការប្រយុទ្ធប្រឆាំងនឹងវិបត្តិនេះ ដែលជាផ្នែកមួយនៃកញ្ចប់ថវិកាសហភាពអឺរ៉ុបសម្រាប់ជួយសម្របសម្រួលការឆ្លើយតបជាសកលដើម្បីដោះស្រាយការរីករាលដាលនៃកូវីដ-១៩ ។

## ការធានានូវព័ត៌មានត្រឹមត្រូវ

ការផ្សព្វផ្សាយព័ត៌មានមិនត្រឹមត្រូវអំពីវីរុសកូរ៉ូណាធ្វើឲ្យកាន់តែមានគ្រោះថ្នាក់ចំពោះសុខភាពប្រជាពលរដ្ឋ។ សមាជិក សមាជិកាសភាអឺរ៉ុបបានអំពាវនាវឲ្យប្រភពព័ត៌មានអឺរ៉ុបទាំងអស់ធានាថា មនុស្សគ្រប់គ្នាអាចទទួលបានព័ត៌មានត្រឹមត្រូវ និងមានការផ្ទៀងផ្ទាត់តាមភាសារបស់ពួកគេ ហើយក៏បានស្នើសុំឲ្យក្រុមហ៊ុនបណ្តាញសង្គមដោះស្រាយចំពោះការផ្សព្វផ្សាយព័ត៌មានមិនពិត និងការប្រើពាក្យសម្តីនាំឲ្យមានការស្អប់ខ្ពើមគ្នា។

## សកម្មភាពរបស់សភាអឺរ៉ុប [៣៧]

នៅក្នុងសេចក្តីសម្រេចមួយដែលត្រូវបានអនុម័តនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ សភាអឺរ៉ុបបានស្វាគមន៍ចំពោះវិធានការសារពើពន្ធ និងការគាំទ្រជាសាច់ប្រាក់របស់សហភាពអឺរ៉ុប ដើម្បីដោះស្រាយជំងឺរាតត្បាតសកលនេះ។ សមាជិក សមាជិកាសភាក៏បានបញ្ជាក់ផងដែរថា ក្រៅពីអ្វីដែលបាននិងកំពុងធ្វើ អឺរ៉ុបក៏ត្រូវការកញ្ចប់ថវិកាសម្រាប់ការស្តារនិងកសាងឡើងវិញដ៏ធំមួយដែលផ្តល់ហិរញ្ញប្បទានដោយកំណើនកញ្ចប់ថវិការយៈពេលវែង (MFF) មូលនិធិសហភាពអឺរ៉ុបដែលមានស្រាប់ និងមធ្យោបាយហិរញ្ញវត្ថុ ក៏ដូចជា "ប័ណ្ណបំណុលសម្រាប់ការស្តារឡើងវិញ" ដែលធានាដោយកញ្ចប់ថវិការបស់សហភាពអឺរ៉ុប។ សមាជិក សមាជិកាសភាបានបញ្ជាក់ថា ទោះបីជាយ៉ាងណាក៏ដោយ ការឆ្លើយតបខាងសេដ្ឋកិច្ចទៅនឹងវីរុសនេះមិនគួរពាក់ព័ន្ធនឹងការចែករំលែកស្មើគ្នានូវបន្ទុកបំណុល ដែលមានស្រាប់នោះទេ ប៉ុន្តែគួរផ្តោតលើការវិនិយោគនាពេលអនាគត។ សមាជិក សមាជិកាសភាបានសង្កត់ធ្ងន់ថា កិច្ចព្រមព្រៀងបៃតងនៃសហភាពអឺរ៉ុប និងការផ្លាស់ប្តូរផ្នែកឌីជីថល គួរតែជាចំណុចស្នូលរបស់ខ្លួនដើម្បីជំរុញការចាប់ផ្តើមសេដ្ឋកិច្ច។

## ព្រំដែន

សមាជិក សមាជិកាសភាបានទទូចថា ព្រំដែននៅក្នុងសហភាពអឺរ៉ុបត្រូវតែរក្សាឲ្យបើកចំហ ដើម្បីធានាថា ឱសថ

ឧបករណ៍ការពារ បរិក្ខារវេជ្ជសាស្ត្រ ម្ហូបអាហារ និងទំនិញចាំបាច់នានាអាចចរាចរបាន។ ពួកគេបានទទួលស្គាល់ថា ទីផ្សាររួមតែមួយរបស់សហភាពអឺរ៉ុប គឺជាប្រភពនៃ «វិបុលភាពសមូហភាពរបស់យើង» និងជាគន្លឹះក្នុងការឆ្លើយតបបន្ទាន់ និងជាបន្តបន្ទាប់ទៅនឹងកូវីដ-១៩។

### ការការពារ

សភាអឺរ៉ុបបានអំពាវនាវឲ្យបង្កើតយន្តការឆ្លើយតបផ្នែកសុខភាពរបស់អឺរ៉ុប ដើម្បីធានាឲ្យមានការឆ្លើយតបប្រសើរជាងមុនចំពោះវិបត្តិសុខភាព ឬអនាម័យនាពេលអនាគត។ គេសង្ឃឹមថាឧបករណ៍ចាំបាច់ សម្ភារៈ និងស្តុកថ្នាំអាចប្រមូលបានឆាប់រហ័ស ដើម្បីជួយសង្គ្រោះជីវិតមនុស្ស។ ក្នុងករណីបន្ទាន់ សមាជិក សមាជិកាសភាក៏ចង់ឃើញមានថវិកាបន្ថែមរបស់សហភាពអឺរ៉ុបសម្រាប់គាំទ្រផ្នែកហិរញ្ញវត្ថុលើការស្រាវជ្រាវស្វែងរកវ៉ាក់សាំងផងដែរ។

### មូលនិធិសាមគ្គីភាពសហភាពអឺរ៉ុបសម្រាប់ប្រយុទ្ធប្រឆាំងនឹងវីរុសកូរ៉ូណា

សមាជិក សមាជិកានៃសភាអឺរ៉ុបក៏បានអំពាវនាវឲ្យមានជាអចិន្ត្រៃយ៍គម្រោងជានាភាពគ្មានការងារធ្វើរបស់អឺរ៉ុប ហើយសង្ឃឹមថា នឹងមានការបង្កើតមូលនិធិសាមគ្គីភាពសហភាពអឺរ៉ុបសម្រាប់ប្រយុទ្ធប្រឆាំងនឹងវីរុសកូរ៉ូណា ដែលមានទឹកប្រាក់យ៉ាងហោចណាស់ចំនួន ៥០ ពាន់លានអឺរ៉ូ។ មូលនិធិដែលបានស្នើឡើងនេះមានគោលបំណងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងផ្នែកហិរញ្ញវត្ថុ សម្រាប់យកមកអនុវត្តក្នុងវិស័យថែទាំសុខភាពនៅក្នុងរដ្ឋជាសមាជិកទាំងអស់ក្នុងពេលមានវិបត្តិ ក៏ដូចជាផ្តល់នូវការវិនិយោគនាពេលអនាគត ដើម្បីធ្វើឲ្យប្រព័ន្ធថែទាំសុខភាពទាំងនោះមានភាពធន់ និងផ្តោតការយកចិត្តទុកដាក់បន្ថែមទៅលើអ្នកដែលមានតម្រូវការបំផុត។

### ការផ្តល់អំណាចធំជាងមុនសម្រាប់សហភាពអឺរ៉ុបក្នុងការដោះស្រាយការគំរាមកំហែងសុខភាពឆ្លងព្រំដែន

សេចក្តីសម្រេចថ្ងៃសុក្រ ទី១៤ បានចែងថា ដំណោះស្រាយរួមរបស់អឺរ៉ុបដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលកូវីដ-១៩ គឺពិតជាមិនអាចខ្វះបាន។ សហភាពអឺរ៉ុបមិនត្រឹមតែត្រូវធ្វើខ្លួនឲ្យបានខ្លាំងជាងមុនដើម្បីងើបចេញពីវិបត្តិនេះនោះទេ តែស្ថាប័នអឺរ៉ុបនានាក៏គួរតែត្រូវបានផ្តល់អំណាចដើម្បីធ្វើសកម្មភាពនៅពេលដែលមានការគំរាមកំហែងសុខភាពឆ្លងព្រំដែនកើតឡើង។ ការណ៍នេះអាចឲ្យស្ថាប័នទាំងនោះសម្របសម្រួលការឆ្លើយតបនៅកម្រិតអឺរ៉ុបដោយមិនបង្អង់យូរនិងអាចនាំយកធនធានចាំបាច់ទៅកន្លែងដែលត្រូវការបំផុតមិនថាជាសម្ភារៈដូចជាម៉ាស់មុខ ឧបករណ៍ជួយដកដង្ហើម និងថ្នាំ ឬជំនួយហិរញ្ញវត្ថុនោះទេ។ សមាជិក សមាជិកានៃសភាអឺរ៉ុបក៏បានសម្តែងការគាំទ្ររបស់ពួកគេចំពោះការបង្កើនការផលិតសំខាន់ៗក្នុងសហភាពអឺរ៉ុប ដូចជា គ្រឿងផ្សំឱសថ បរិក្ខារ ឧបករណ៍ និងគ្រឿងប្រើប្រាស់វេជ្ជសាស្ត្រ ដើម្បីធានាថា អឺរ៉ុបបានរៀបចំខ្លួនដ៏ប្រសើរដើម្បីទប់ទល់នឹងវិបត្តិសកលនាពេលអនាគត។

### វិធីសាស្ត្រសម្របសម្រួលក្រោយការបិទប្រទេសដែលត្រូវការ

សមាជិក សមាជិកានៃសភាអឺរ៉ុបបានគូសបញ្ជាក់បន្ថែមនូវតម្រូវការឲ្យមានវិធីសាស្ត្រសម្របសម្រួលមួយ ក្រោយការបិទប្រទេសនៅសហភាពអឺរ៉ុប ដើម្បីចៀសវាងការរីករាលដាលឡើងវិញនៃវីរុស។ ពួកគេបានជំរុញឲ្យបណ្តាប្រទេសនៅសហភាពអឺរ៉ុបរួមគ្នាបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ការបញ្ឈប់ការធ្វើចត្តាឡីស័ក និងវិធានការណ៍បន្ទាន់នានាផ្សេងទៀត ហើយបានស្នើសុំឲ្យគណៈកម្មការអឺរ៉ុបដាក់ចេញនូវយុទ្ធសាស្ត្រត្រៀមដើម្បីងើបចេញពីវិបត្តិឲ្យមានប្រសិទ្ធភាពដែលរួមមានទាំងការធ្វើតេស្តទ្រង់ទ្រាយធំ និងឧបករណ៍ការពារផ្ទាល់ខ្លួន សម្រាប់ចំនួនប្រជាពលរដ្ឋច្រើនបំផុតតាមដែលអាចធ្វើទៅបាន។

### ប្រភពព័ត៌មានអឺរ៉ុបសម្រាប់ទប់ស្កាត់នឹងការផ្សព្វផ្សាយព័ត៌មានមិនពិត

ជាចុងក្រោយ សេចក្តីសម្រេចបានសង្កត់ធ្ងន់ថា ការផ្សព្វផ្សាយព័ត៌មានមិនពិតអំពីជំងឺកូវីដ-១៩ គឺជាកង្វល់សុខភាព សាធារណៈដ៏ធំមួយ។ ដូចនេះហើយ សមាជិកសមាជិកានៃសភាអឺរ៉ុបបានស្នើថា អឺរ៉ុបគួរតែបង្កើតប្រភពព័ត៌មានអឺរ៉ុប ដើម្បីធានាថា ប្រជាពលរដ្ឋទាំងអស់អាចទទួលបានព័ត៌មានត្រឹមត្រូវ និងព័ត៌មានដែលមានការផ្ទៀងផ្ទាត់ច្បាស់លាស់។ សមាជិក សមាជិកាសភាក៏បានអំពាវនាវដល់ក្រុមហ៊ុនបណ្តាញសង្គមនានាចាត់វិធានការប្រកបដោយបុរេសកម្ម ដើម្បីបញ្ឈប់ការរីករាលដាលនៃការផ្សព្វផ្សាយព័ត៌មានមិនពិត និងពាក្យសម្តីស្អប់ខ្ពើមដែលទាក់ទងទៅនឹងមេរោគនេះ។

### តួនាទីរបស់សភាជាតិ

ស្ថាប័ននីតិប្បញ្ញត្តិនៃរដ្ឋជាសមាជិកមួយចំនួនបានដោះស្រាយបញ្ហាមួយចំនួននៅថ្នាក់ជាតិ ទាក់ទងនឹងការរឹតត្បិតសេរីភាពបណ្តោះអាសន្ន ការតាមដានស្វែងរក និងការត្រួតពិនិត្យអ្នកដែលឆ្លងជំងឺ និងការត្រួតពិនិត្យរកព័ត៌មានពិត។

បារាំងជាប្រទេសនៃសហភាពអឺរ៉ុបតែមួយគត់ដែលតម្រូវឲ្យមានការបោះឆ្នោតដោយរដ្ឋសភានិងព្រឹទ្ធសភា មុនពេលរដ្ឋាភិបាលអាចប្រកាសនិងធ្វើសកម្មភាពលើស្ថានភាពអាសន្នផ្នែកសុខភាព [៣៨]។ បញ្ហាសំខាន់ៗមួយចំនួនដែលត្រូវបានពិភាក្សាក្នុងសភា គឺការទទួលខុសត្រូវរបស់អភិបាលក្រុងក្នុងការវិនិច្ឆ័យលើការបើកសាលារៀនឡើងវិញ និងដែនកំណត់នៃសេរីភាពក្នុងការធ្វើដំណើរ ដែលគិតត្រឹមពេលសរសេរអត្ថបទនេះ នៅតែត្រូវបានរឹតត្បិតត្រឹមនៅក្នុងកាំរង្វង់ចម្ងាយ១០០គីឡូម៉ែត្រជុំវិញ។

នៅប្រទេសអាល្លឺម៉ង់ បញ្ហាសំខាន់មួយគឺការចេញ «ប័ណ្ណបំណុលកូរ៉ូណា» ដើម្បីបង្កើតយន្តការមួយសម្រាប់ចែករំលែកបំណុលសាធារណៈរវាងរដ្ឋជាសមាជិកអឺរ៉ុប។ អធិការបតី Angela Markel បានសង្កត់ធ្ងន់លើចំណុចនេះទៅកាន់សភា Bundestag របស់ខ្លួនថា ជំហានបែបនេះ គឺជាមធ្យោបាយតែមួយគត់ដែលអាចជៀសវាងការដួលរលំនៃប្រព័ន្ធសេដ្ឋកិច្ច របស់សហភាពអឺរ៉ុប ("Systemabsturz")។

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០ លោកស្រី Angela Merkel និងប្រធានាធិបតីបារាំង Emmanuel Macron បានប្រកាសកិច្ចព្រមព្រៀងទ្វេភាគី ដើម្បីគាំទ្រដល់ការស្តារសេដ្ឋកិច្ចឡើងវិញតាមរយៈការជួយតំបន់និងវិស័យដែលខ្សោយបំផុតនៅក្នុងប្រទេសនៃសហភាពអឺរ៉ុបទាំង ២៧ (EU 27)។ កិច្ចព្រមព្រៀងនេះនឹងអនុញ្ញាតឲ្យគណៈកម្មការសហភាពអឺរ៉ុបខ្ចីប្រាក់រហូតដល់ ៥០០ពាន់លានអឺរ៉ូ ពីទីផ្សារហិរញ្ញវត្ថុ។ ជាការពិត ភាពខុសគ្នានៅតែមានក្នុងចំណោមប្រទេសនៃសហភាពអឺរ៉ុបទាំង ២៧ ទាក់ទងនឹងវិសាលភាព និងមធ្យោបាយនៃសាមគ្គីភាពអឺរ៉ុប ដូចជាការចែករំលែកបំណុល ប្រាក់កម្ចី ឬជំនួយឥតសំណង ដើម្បីជួយប្រទេសដែលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតពីកូវីដ-១៩ ដែលក្នុងនោះមានអ៊ីតាលី និងអេស្ប៉ាញជាប្រទេសអាទិភាព។

សរុបសេចក្តីមក សហភាពអឺរ៉ុបនៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំប្រកាន់យកពហុភាគីនិយមថា ជាមធ្យោបាយដ៏សក្តិសមតែមួយគត់ដើម្បីដោះស្រាយបញ្ហាប្រឈមរួមគ្នានេះ ដែលការក្រើនរំលឹកនេះដូចជាធ្ងន់ធ្ងរបន្តិចតែជាការល្អដែលរំលឹកយើងពីភាពកាន់តែកើនឡើងក្នុងការទាក់ទងគ្នាទៅវិញទៅមក។ ប្រជាពលរដ្ឋនៅអឺរ៉ុបបានឃើញវីរុសនេះជាលើកដំបូងនៅក្នុងតំបន់ឧស្សាហកម្ម ដែលមានទីតាំងនៅភាគខាងជើងនៃប្រទេសអ៊ីតាលី(Lombardy) និងនៅទីក្រុងបាវ៉ារៀ (Bavaria) ដែលមានទំនាក់ទំនងសេដ្ឋកិច្ច និងពេញនិយមជាមួយទីក្រុងវូហាននៃប្រទេសចិន។ វាទំនងជាឆ្លងចូលប្រទេសអេស្ប៉ាញតាមរយៈអ្នកគាំទ្រនៃក្លឹបបាល់ទាត់ Valencia ចំនួន ៣០០០ នាក់ ដែលបានទៅទីក្រុង Milan មើលការប្រកួតរវាងក្រុមរបស់ពួកគេនិងក្រុម Atalanta មកពី Lombardy។ ករណីដំបូងៗផ្សេងទៀតត្រូវបានគេតាមរកឃើញនៅរមណីយដ្ឋានជិះស្គីនៅតំបន់ភ្នំអាល់បារាំង (French Alps) ដែលទំនងជាឆ្លងពីជនជាតិអង់គ្លេសដែលត្រឡប់មកពីសន្និសីទនៅឯប្រទេសសិង្ហបុរី ដែលពួកគេបានបរិភោគអាហារពេលល្ងាចជាមួយអ្នកចូលរួមសន្និសីទមកពីវូហាន។ ការរីករាលដាលនៃ COVID-១៩ បានឆ្លុះបញ្ចាំងពីវិធីជាច្រើនដែលប្រជាពលរដ្ឋមកពីជុំវិញពិភពលោកនាពេលបច្ចុប្បន្នធ្វើការទាក់ទងគ្នាដូចជា ធុរកិច្ចពិភពលោក សិក្ខាសាលាអន្តរជាតិ ទេសចរណ៍ និងការជួបជុំខាងសាសនា កីឡា និងការធ្វើចំណាកស្រុកដើម្បីស្វែងរកការងារជាដើម។ នៅឆ្នាំ២០១៨ អ្នកដំណើរចំនួន ៤,៥ពាន់លាននាក់ បានធ្វើដំណើរតាមផ្លូវអាកាស។ មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ ការចម្លងកូវីដ-១៩ ក៏កើតឡើងតាមរយៈចរាចរណ៍ផ្លូវអាកាសសំខាន់ៗផងដែរ។ ទោះបីជាមានវិបត្តិនាពេលបច្ចុប្បន្នក៏ដោយ និន្នាការនៃការកើនឡើងអន្តរកម្មរវាងពលរដ្ឋនៃពិភពលោកហាក់ដូចជានៅតែបន្តទៅអនាគត។ ការសម្របសម្រួល និងការគ្រប់គ្រងតាមបទបញ្ញត្តិនូវពិភពលោកដែលមានភាពស្មុគស្មាញ និងមានការកើនឡើងនៃអន្តរទំនាក់ទំនង គឺជាការទទួលខុសត្រូវស្នូលរបស់សភា។

ក្នុងចំណោមរដ្ឋាភិបាល សភា និងពលរដ្ឋនៃទ្វីបអឺរ៉ុប ការឆ្លងកាត់បទពិសោធន៍រួមគ្នាក្នុងការប្រឈមទៅនឹងកូវីដ-១៩ បានកសាងជាថ្មីនូវជំនឿដ៏មុតមាំលើគុណតម្លៃនៃពហុភាគីនិយម ដែលជាឧបករណ៍មិនអាចខ្វះបានសម្រាប់ជួយក្នុងការដោះដូរទិន្នន័យវិទ្យាសាស្ត្រ ការសម្របសម្រួលការឆ្លើយតបចំពោះភាពអាសន្ននិងការបង្កើតវិធានរួមគ្នា។មានការសោកស្តាយយ៉ាងខ្លាំងផងដែរចំពោះជំហរឯកតោភាគីដ៏អកុសល ដែលត្រូវបានប្រកាន់យកដោយមហាអំណាចមួយចំនួន ជាពិសេសនៅចំពេលដែលមានការបញ្ជាក់ថាការធ្វើសកម្មភាពរួមគ្នា ពិតជាមានសារៈសំខាន់។ ជាការពិតការប្រឈមទៅនឹងវិបត្តិកូវីដ-១៩ រួមគ្នា និងការឆ្លើយតបស្របគ្នា បានបង្ហាញថា ពហុភាគីនិយមគឺជា ចម្លើយទាំងផ្នែកស្ថាប័ន និងនយោបាយតែមួយគត់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម និងឱកាសរួមនៃពិភពលោករបស់យើង ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកទាំងខាងសង្គមសេដ្ឋកិច្ច និងបច្ចេកវិទ្យា។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ១.៧ តើសភាអាចមានភាពនិម្មិតបានក្នុងកម្រិតណា?

ជំងឺរាតត្បាតសកលកូវីដ-១៩ បានជម្រុញឲ្យយើងផ្តោតការយកចិត្តទុកដាក់ទៅលើដំណើរការនៃប្រព័ន្ធនយោបាយរបស់យើង។ ក្នុងប្រទេសស្វីស បើនិយាយដោយឡែកយើងបានឃើញច្បាស់ថាទំនាក់ទំនងរវាងសភានិងរដ្ឋាភិបាលក្នុងអំឡុងពេលប្រឈមនឹងវិបត្តិនៅមិនទាន់ត្រូវបានកំណត់ពេញលេញនៅឡើយទេ ហើយម្យ៉ាងទៀតតួនាទីរបស់សភាក្នុងអំឡុងស្ថានភាពបច្ចុប្បន្ននៃវិបត្តិក៏នៅមិនច្បាស់លាស់សម្រាប់សមាជិកសមាជិកាសភាក៏ដូចជាសម្រាប់រដ្ឋាភិបាលដែរ។ ក្នុងប្រព័ន្ធប្រជាធិបតេយ្យ នយោបាយមិនអាចជាបញ្ហាផ្តាច់មុខរបស់រដ្ឋាភិបាលទេ ប៉ុន្តែគេនៅតែអាចចោទជាសំណួរឡើងថា៖ តើសភាពិតជាចាំបាច់ត្រូវជួបប្រជុំ បើទោះបីក្នុងអំឡុងពេលមានវិបត្តិដែរឬទេ? ដើម្បីជាជំនួយស្មារតីក្នុងការឈ្វេងយល់អំពីសំណួរនេះ អត្ថបទនេះនឹងផ្តល់សេចក្តីសង្ខេបគោលៗអំពី វិធីសាស្ត្រដែលប្រទេសស្វីសអនុវត្តក្នុងការទប់ទល់ទៅនឹងវិបត្តិកូវីដ ហើយជាពិសេសថាតើសំនួរអំពីសភានិយមលេចឡើងយ៉ាងដូចម្តេចនៅតំបន់ហ្ស៊ូរិច។

## ទិដ្ឋភាពទូទៅ [៣៩]

ដោយសារតែជំងឺរាតត្បាតសកលកូវីដ-១៩ ប្រទេសស្វីសបានដាក់ប្រទេសក្នុងភាពអាសន្នផ្នែកនយោបាយចាប់ពីខែមីនា ដល់ខែឧសភា ឆ្នាំ២០២០។ ផ្អែកតាមបទបញ្ញត្តិស្តីពីភាពអាសន្ន (មាត្រា ១៨៥(៣) នៃរដ្ឋធម្មនុញ្ញសហព័ន្ធ) រដ្ឋាភិបាលស្វីស (ក្រុមប្រឹក្សាសហព័ន្ធ) បានធ្វើសេចក្តីសម្រេចចិត្តជាច្រើនលើរឿងរ៉ាវនានាពីពាក់កណ្តាលខែមីនាឆ្នាំ២០២០ រួមមាន ការបិទសាលានិងហាងពីថ្ងៃទី១៧ខែមីនា ការហាមប្រាមការជួបជុំមនុស្សចាប់ពី៥នាក់ឡើងទៅការប្រកាន់យកវិធានការណ៍ពិសេសដើម្បីផ្តល់ប្រយោជន៍ដល់និយោជិត និយោជក និងក្រុមហ៊ុន ដូចជាការកាត់បន្ថយម៉ោងការងារ ការផ្តល់សំណងចំពោះការបាត់បង់ប្រាក់ចំណូល ច្បាប់ស្តីពីការរឹតបន្តឹងបំណុល និងការក្ស័យធន។ ក៏មានផងដែរនូវការដាក់ចេញក្រឹត្យអាសន្នលើវិស័យអប់រំនិងវប្បធម៌។ បទបញ្ញត្តិអាសន្នទាំងនេះមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះដោយក្នុងនោះភាគច្រើនមានសុពលភាពត្រឹមដំណាច់ខែសីហា ឆ្នាំ២០២០។

សេចក្តីសម្រេចចិត្តទាំងនេះធ្វើឡើងដោយអត្តនោម័តិពីសំណាក់រដ្ឋាភិបាលស្វីស។ យ៉ាងហោចណាស់ ក្នុងអំឡុង៤សប្តាហ៍ដំបូង សេចក្តីសម្រេចចិត្តទាំងនេះទទួលបានការគាំទ្រខ្លាំងក្លាពីបណ្តាគណបក្សនយោបាយ អ្នកនយោបាយនិងប្រជាពលរដ្ឋដោយពុំមានការរិះគន់ឬបាតុកម្មឡើយ។ ផ្អែកលើកិច្ចប្រឹងប្រែងរបស់ខ្លួនរដ្ឋាភិបាលអាចកសាងបាននូវទំនុកចិត្តយ៉ាងច្រើន។សង្គមស្វីសបានបង្ហាញនូវភាពធន់នឹងបញ្ហាហើយបានដោះស្រាយវិបត្តិយ៉ាងល្អ។ប្រជាពលរដ្ឋគ្រប់ជំនាន់ (ក្មេងនិងចាស់) បានជួយយកអាសារគ្នាទៅវិញទៅមក ហើយប្រជាពលរដ្ឋបានប្រកាន់ខ្ជាប់នូវវិន័យ បើទោះបីជាពុំមានការដាក់បម្រាមលើការដើរហើរជាសាធារណៈក៏ដោយ។ ប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាគណបក្សនយោបាយក៏បានសាមគ្គីគ្នាក្នុងការគាំទ្រវិធានការណ៍ទាំងនេះ។ ជារួមក្រុមប្រឹក្សាសហព័ន្ធត្រូវបានផ្តល់ឲ្យនូវបណ្ណរបាយការណ៍ល្អ (good report card) ក្នុងការគ្រប់គ្រងវិបត្តិ។ ក្នុងពេលជាមួយគ្នានេះ ស្ថិតក្រោមសម្ពាធនៃជំងឺរាតត្បាតសកលកូវីដ-១៩ សភាសហព័ន្ធបានបិទបញ្ចប់សម័យប្រជុំ រដូវផ្ការីករបស់ខ្លួននៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។ កិច្ចការសភាក្នុងសម័យប្រជុំពេញអង្គត្រូវបានផ្អាករហូតដល់សម័យប្រជុំវិសាមញ្ញពីថ្ងៃទី៤ ដល់ទី៧ ខែឧសភា ឆ្នាំ២០២០។

សភាពការណ៍មានភាពប្រហែលគ្នានៅកម្រិតរដ្ឋនីមួយៗ។ រដ្ឋាភិបាលនៃតំបន់នីមួយៗបានកោះប្រជុំក្រុមជំនាញទាក់ទងនឹងវិបត្តិរៀងៗខ្លួនដោយបន្ទាន់ ស្របពេលដែលសភានៃរដ្ឋចំនួន១៦ ក្នុងចំណោម២៦ បានលុបចោលកិច្ចប្រជុំនានាដែលបានកំណត់។ ក្នុងតំបន់ហ្ស៊ូរិច មានការខ្វែងយោបល់គ្នាទាក់ទងនឹងកម្រិតនៃអំណាចដែលរដ្ឋាភិបាលមាន និងថាតើរដ្ឋាភិបាលអាចរារាំងសភាមិនឲ្យជួបប្រជុំដោយផ្អែកលើហេតុផលគោលនយោបាយសុខភាពបានដែរឬទេ។ ដូចដែលយើងបានដឹង សភាហ្ស៊ូរិចមានសមាជិក១៨០រូប ដែលលើសពីចំនួនកំណត់១០០រូបសម្រាប់សភា ដែលកំណត់ដោយក្រុមប្រឹក្សាសហព័ន្ធ។ ក៏ប៉ុន្តែគណៈកម្មាធិការប្រតិបត្តិនៃសភាហ្ស៊ូរិចបានបញ្ឈប់កិច្ចពិភាក្សាទាំងនេះនៅពេលដែលគណៈកម្មាធិការនេះបានសម្រេចភ្លាមៗឲ្យមានការប្រជុំសភា។ បើមើលលើជ្រុងម្ខាងការសម្រេចនេះបានរក្សានូវតថភាពដែលបង្ហាញថា សភាជាអង្គដែលបង្កើតដោយរដ្ឋធម្មនុញ្ញ ហេតុដូច្នេះដោយផ្អែកតាមរដ្ឋធម្មនុញ្ញ សភាចាំបាច់ត្រូវអនុម័តបទបញ្ញត្តិអាសន្នរបស់រដ្ឋាភិបាល ក្នុងអំឡុងពេលនៃវិបត្តិ។ តែបើមើលលើជ្រុងម្ខាងទៀត សភាក៏ចាំបាច់ត្រូវមានភាពជាគំរូដល់ប្រជាពលរដ្ឋផងដែរ។ បើទោះបីស្ថិតក្នុងអំឡុងពេលនៃវិបត្តិ សភាចាំបាច់ត្រូវប្រកាន់ខ្ជាប់ដោយសុទ្ធចិត្តនូវតួនាទីរបស់ខ្លួន

និងជានាទ្យបាននូវធម្មានរូបភាពបែបប្រជាធិបតេយ្យនៃការសម្រេចចិត្តរបស់រដ្ឋនីមួយៗ។ លើសពីនេះគ្មានរដ្ឋាភិបាលណាមួយនៅប្រទេសស្វ៊ីសមានសិទ្ធិតាមរដ្ឋធម្មនុញ្ញក្នុងការបញ្ជាទៅសភាថា ត្រូវជួបប្រជុំនៅពេលណា ក្នុងហេតុផលណា ឬនៅទីកន្លែងណាឡើយ។ ដូច្នេះ សភារបស់តំបន់ហ្ស៊ូរិចបានដើរតួនាទីត្រួសត្រាយផ្លូវក្នុងប្រទេស ដោយបានផ្លាស់ប្ដូរទីតាំងពីអគារសភាដែលមានតម្លៃជាប្រវត្តិសាស្ត្រដែលមានទំហំតូចចង្អៀតសង់តាំងពីឆ្នាំ១៦៩៨ ទៅកាន់សាលពិព័រណ៍ដ៏ទំនើបនៅជាយក្រុងហ្ស៊ូរិច ដើម្បីរៀបចំសម័យប្រជុំសភាស្របទៅតាមបទបញ្ញត្តិអនាម័យរបស់ការិយាល័យសហព័ន្ធផ្នែកសុខភាពសាធារណៈ និងស្របតាមអនុសាសន៍ស្ដីពីគម្លាតសុវត្ថិភាពសង្គម។ ជាសរុបសភាហ្ស៊ូរិចបានជួបប្រជុំបីដង រហូតដល់ការបន្តនូវប្រតិបត្តិការប្រចាំសប្ដាហ៍ជាទៀងទាត់ឡើងវិញ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២០។ ស្របតាមរដ្ឋធម្មនុញ្ញរបស់តំបន់ សភាហ្ស៊ូរិចបានអនុម័តបទបញ្ញត្តិអាសន្នបីដែលស្នើដោយអង្គនីតិប្រតិបត្តិ បំពេញបន្ថែមបទបញ្ញត្តិមួយជាមួយនឹងបទបញ្ជាទៅកាន់រដ្ឋាភិបាល និងព្យួរបទបញ្ញត្តិមួយ។ បន្ថែមលើនេះ សភាបានបោះឆ្នោតលើគ្រប់បញ្ហាទាំងឡាយដែលត្រូវការអនុម័ត ជាពិសេសសេចក្ដីសម្រេចចិត្តទាក់ទងនឹងហិរញ្ញវត្ថុ។ គណៈកម្មាធិការសភាក៏បានជួបប្រជុំម្ដងទៀត ហើយផែនការទូទៅមួយត្រូវបានដាក់ចេញដើម្បីចរចានិងដោះស្រាយកិច្ចការរដ្ឋាភិបាលដែលមានច្រើនក្នុងវេលាសមស្រប។សភាហ្ស៊ូរិចបានសម្រេចថា ខ្លួននឹងបន្តជួបប្រជុំនៅក្នុងសាលពិព័រណ៍ក្នុងប៉ុន្មានខែដែលនៅសេសសល់ក្នុងឆ្នាំ២០២០។

ក្នុងអំឡុងពេលច្របូកច្របល់នេះនៅពេលដែលទំនួលខុសត្រូវនានាចាំបាច់ត្រូវបញ្ជាក់ឲ្យបានច្បាស់ សំណួរសំខាន់ខ្លះៗបានលេចឡើងភ្លាមៗអំពីសភា៖ ហេតុអ្វីបានជាសម័យប្រជុំសភាមិនអាចរៀបចំបានតាមរយៈវីដេអូ? ហើយតើសមាជិក សមាជិកាសភាទាំងឡាយដែលជាអ្នកតំណាងឲ្យក្រុមប្រជាពលរដ្ឋងាយរងគ្រោះគួរត្រូវបានទទួលការជួយសម្រួលដោយរបៀបណាខ្លះ? រដ្ឋធម្មនុញ្ញនៅប្រទេសស្វ៊ីសផ្តល់ចម្លើយច្បាស់ៗទៅកាន់សំណួរទាំងនេះ។ សភាអាចធ្វើការពិភាក្សានិងធ្វើសេចក្ដីសម្រេចចិត្តដែលមានសុពលភាពដរាបណាមានវត្តមានសមាជិក សមាជិកាសភាភាគច្រើន។ រដ្ឋធម្មនុញ្ញបានចែងផងដែរពី ការជួបប្រជុំដោយផ្ទាល់។ ក៏ប៉ុន្តែនេះមិនទាន់ឆ្លើយទៅនឹងសំណួរពិតប្រាកដឬក៏បញ្ជាក់ថាតើសំណួរត្រូវបានចោទសួរត្រឹមត្រូវឬទេ៖ ផ្អែកលើទស្សនៈសេរីប្រជាធិបតេយ្យ គេគួរសួរជំនួសវិញថា តើសភាគួរ ឬមិនគួរជួបប្រជុំក្នុងអំឡុងពេលមានវិបត្តិ? តើសភាមិនមានមតិផ្នែកនយោបាយក្នុងអំឡុងពេលមានវិបត្តិទេឬ? តើកិច្ចពិភាក្សាប្រជាធិបតេយ្យមិនសំខាន់ទេឬក្នុងអំឡុងពេលមានវិបត្តិ?

វាហាក់ដូចជាមិនទំនងបើសិនជានរណាម្នាក់ហ៊ានសន្និដ្ឋានថា ខ្លួនមានចម្លើយទៅកាន់គ្រប់សំណួរទាំងនេះ។ អ្វីដែលយើងដឹងនៅពេលនេះគឺថា មិនទាន់មានដំណោះស្រាយជាក់ស្ដែងចំពោះបញ្ហាដែលគេលើកឡើងទាំងអស់នោះទេ ខណៈដែលគ្រោះអាសន្ននៅខាងមុខនេះ គឺច្បាស់ណាស់អាចនៅក្បែរៗនេះ។ វាអាចនឹងមិនមែនជាជំងឺរាតត្បាតទេ តែអាចជាបញ្ហាកង្វះថាមពល ឬកង្វះទឹក វិបត្តិសេដ្ឋកិច្ច គ្រោះទឹកជំនន់ ឬខ្យល់ព្យុះជាដើម ហើយសង្ឃឹមថា វាមិនមែនជាឧប្បត្តិហេតុនុយក្លេអ៊ែរទៅចុះ។ ប្រសិនបើមានឧប្បត្តិហេតុនុយក្លេអ៊ែរ ទោះបីជាមានសម័យប្រជុំសភាតាមរយៈសន្និសីទតាមវីដេអូក៏ដោយ ក៏នឹងមិនមានផលប្រយោជន៍អ្វីដែរ។ ដើម្បីឆ្លើយសំណួរទាំងនេះ ច្បាស់ណាស់ថា ចាំបាច់ត្រូវមានការផ្លាស់ប្ដូរវប្បធម៌ ស្របពេលយើងនឹងពិនិត្យមើលពីគំនិតជាក់ស្ដែងរបស់សភាក្នុងប្រព័ន្ធប្រជាធិបតេយ្យ។

## គំនិតរបស់ "សភា"

"រដ្ឋាភិបាលដោយផ្អែកលើការពិភាក្សា" គឺជាពាក្យស្លោកដែល "កត់សម្គាល់ពីសមិទ្ធផលពិតប្រាកដនៃប្រព័ន្ធសភានិយម ហើយក៏ជាចរិតលក្ខណៈនៃប្រជាធិបតេយ្យរបស់ប្រព័ន្ធនេះដែរ" [៤០]។ សភាជាស្ថាប័នដែលជួយឲ្យមានវិធាននយោបាយស្របច្បាប់ក្នុងក្របខ័ណ្ឌនៃសមត្ថភាព និងឆន្ទៈ ការចរចា និងការជជែកដេញដោល [៤១]។ វាជានីតិវិធីតាមលំដាប់លំដោយ អនុលោមតាមវិធានរបស់គូភាគី ដែលចូលទៅគ្រប់គ្រងកិច្ចពិភាក្សាដោះស្រាយទំនាស់ដើម្បីដាក់ចេញនូវសេចក្ដីសម្រេចចិត្តរបស់រដ្ឋ ដើម្បីធ្វើឲ្យគូភាគីក្នុងជម្លោះស្រុះស្រួលគ្នា [៤២]។ សភាក្នុងនាមជាវេទិកាសម្រាប់សង្គម គឺជាជាឆាកនយោបាយដែលតំណាងពិពិធភាពនៃមតិនៅក្នុងសហជីព និងជានិមិត្តរូបដែលប្រជាពលរដ្ឋស្វ៊ីសនិយមហៅថា "ឆន្ទៈនៃប្រជាជាតិ"។

គន្លឹះមួយនៃមុខងារតំណាងក្នុងដំណើរការនយោបាយគឺទំនុកចិត្ត។ សភាអនុវត្តតាមអ្វីដែលមាត្រា២នៃក្រមរដ្ឋប្បវេណីស្វ៊ីសតម្រូវឲ្យពលរដ្ឋគ្រប់រូបត្រូវធ្វើក្នុងជីវិតប្រចាំថ្ងៃ គឺ "ការធ្វើអំពើដោយសុចរិត" [G] មិនត្រឹមតែក្នុងជីវិតជាសាធារណៈ តែក្នុងរាល់ទំនាក់ទំនងរវាងមនុស្ស ឧទាហរណ៍ រវាងក្រុមទទួលប្រយោជន៍ ក្រុមនយោបាយ និងសមាជិក សមាជិកាសភា [H][43]។ មូលដ្ឋានគ្រឹះប្រជាធិបតេយ្យនៃភាពជាតំណាង គឺទំនុកចិត្តពីប្រជាពលរដ្ឋទៅលើការ

សម្រេចចិត្តរបស់សភា ជាពិសេសទៅភាពច្បាស់លាស់អាចយល់បាន។ មូលដ្ឋានគ្រឹះនេះអាចរក្សាឲ្យឋិតថេរបានលុះត្រាតែតួអង្គពាក់ព័ន្ធក៏ត្រូវមានការទុកចិត្តគ្នាទៅវិញទៅមកដែរ។ ឧទាហរណ៍ជាច្រើនពីអតីតកាលនៃនយោបាយរបស់ប្រទេសស្វីសបានគូសបញ្ជាក់ពីសារៈសំខាន់នៃការផ្តល់សេចក្តីទុកចិត្តពីអ្នកដែលត្រូវបានគេតំណាងដល់ស្ថាប័ននយោបាយ៖ សាធារណជនមានការមិនពេញចិត្ត និងមានកំហឹងនៅពេលដែលសភាស្វីសអាចអនុវត្តបានតែចំណុចខ្លះៗនៃការផ្តួចផ្តើមធ្វើច្បាប់ពីរដែលបានអនុម័តដោយប្រជាពលរដ្ឋ [៤៤, ៤៥] ទីមួយទាក់ទងនឹងការដាក់កម្រិតលើការពង្រីកទីក្រុងទៅតំបន់ដែលមានដង់ស៊ីតេប្រជាជនទាប និងទំហំនៃលំនៅឋានទីពីរ (ជាពិសេសសំដៅលើលំនៅឋានសម្រាកវិសមកាល) ក្នុងប្រទេសស្វីស និងទីពីរត្រូវបានគេហៅថា "ការប្រឆាំងនឹងអន្តោប្រវេសន៍ទ្រង់ទ្រាយធំ" ដែលធ្វើឡើងដើម្បីតម្រង់គោលនយោបាយមូលដ្ឋានអន្តោប្រវេសន៍ស្វីស ដែលអាចប៉ះពាល់ដល់ទំនាក់ទំនងគ្រឹះជាមួយសហភាពអឺរ៉ុប។ ទោះជាបែបនេះក្តី ប្រជាពលរដ្ឋបានទទួលយកសំណើនានារបស់សភាសម្រាប់ការអនុវត្ត ហើយបានសម្រេចចិត្តមិនធ្វើប្រជាមតិទាក់ទងនឹងបញ្ហាទាំងនោះទៀតឡើយ [I] [៤៦art.១៤៣]។ការទទួលយកនេះអាចមានឫសគល់ចេញពីទំនុកចិត្តរបស់អ្នកបោះឆ្នោតដែលមានទៅលើអ្នកនយោបាយ។ សមាជិក សមាជិកានៃសភាសហព័ន្ធទទួលបានទំនុកចិត្តនេះ ដោយសារមានការបង្ហាញជា សាធារណៈពីដំណើរការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយតម្លាភាព និងមានភាពងាយយល់។ ពួកគេបានពន្យល់ទៅកាន់ប្រជាពលរដ្ឋថាសំណើសម្រាប់ការអនុវត្តទាំងនោះគឺជាការសម្របសម្រួលដែលចាំបាច់ ដោយសារតែជំហរគោលនយោបាយការបរទេសរបស់ស្វីសដែលមានយូរលង់មកហើយ។ ផ្ទុយមកវិញ ការរៀបចំដោយសម្ងាត់នៃក្រុមសភាបី ដែលសម្រេចមិនបោះឆ្នោតជ្រើសរើសសមាជិកពីររូបនៃរដ្ឋាភិបាលសហព័ន្ធម្តងទៀតបានបង្កឲ្យមានផលប៉ះពាល់ជាអវិជ្ជមាន និងយូរអង្វែងចំពោះកិត្តិនាមនៃសភាសហព័ន្ធ។ ការបោះឆ្នោតមួយចំនួនទៀតត្រូវបានរៀបចំឡើងប្រកបដោយតម្លាភាព ដើម្បីទទួលបានទំនុកចិត្តជាសាធារណៈឡើងវិញចំពោះដំណើរការជ្រើសរើស និងដំណើរការបោះឆ្នោត។

ឧទាហរណ៍ទាំងពីរនេះបង្ហាញថា ស្ថាប័នរបស់សភាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្កើត ឬស្តារឡើងវិញនូវអត្តសញ្ញាណ ការធ្វើសមាហរណកម្ម និងការកសាងទំនុកចិត្ត ជាពិសេសដោយមានការរួមផ្សំនឹងប្រជាធិបតេយ្យដោយផ្ទាល់។ ក្រោយពីមានការតស៊ូយ៉ាងជូរចត់ដើម្បីទទួលបានការបោះឆ្នោតពីប្រជាពលរដ្ឋលើច្បាប់ប្រជាមតិ និងសំណើអនុវត្តរបស់រដ្ឋាភិបាលតុល្យភាពរវាងក្រុមនយោបាយនៅតែមិនអាចបង្កើតបាន។ ក៏ប៉ុន្តែក្នុងសភា ការសម្រុះសម្រួលគ្នាអាចចរចាបាន។ ដូច្នេះគំនិតដែលថា សភាជាស្ថាប័នប្រជាធិបតេយ្យ គឺសំដៅលើមុខងារបង្កើតសន្តិភាពនេះឯង។ គូបដិបក្ខនយោបាយមានកាតព្វកិច្ចក្នុងការចូលរួមក្នុងដំណើរការបង្កើតសេចក្តីសម្រេចចិត្តប្រកបដោយតម្លាភាព និងសណ្តាប់ធ្នាប់។ នៅជ្រុងមួយ សភាបង្កើតជាចំណុចប្រសព្វដែលនៅទីនោះនយោបាយត្រូវបានប្រែក្លាយទៅជាសកម្មភាពរបស់រដ្ឋ ហើយនៅជ្រុងមួយទៀត សភាជាចំណុចភ្ជាប់រវាងសកម្មភាពរដ្ឋ និងនយោបាយ[៤៧]។ និយាយដោយខ្លី ស្ថាប័នសភាជាទីកន្លែងដែលជួយឲ្យអ្នកនយោបាយមានការស្រុះស្រួលលើភាពខុសគ្នារបស់ពួកគេ ដោយចំហ តម្លាភាព ងាយយល់ និងដោយសន្តិវិធី។

សភា និងប្រជាធិបតេយ្យដោយផ្ទាល់កើតមានព្រមគ្នានៅប្រទេសស្វីស [៤៨]។ ប្រជាធិបតេយ្យដោយផ្ទាល់នឹងមិនអាចធ្វើទៅបានទេ បើសិនជាគ្មានការសម្រុះសម្រួលដែលសម្របសម្រួលដោយសភា មិនថាពេលមុនឬពេលក្រោយទេ។ ក្នុងករណីប្រទេសស្វីស សភានិងប្រជាធិបតេយ្យដោយផ្ទាល់ជួយពង្រឹងគ្នាទៅវិញទៅមក[៤៩]។ បើសិនជាសភាមិនទទួលបានបរិយាបន្ន នោះក្តីស្រមៃបែបប្រជាភិថុតនឹងក្លាយជាការពិត ហើយពេលនោះរដ្ឋាភិបាលនឹងអាចធ្វើសកម្មភាពនានាដោយផ្ទាល់ជាមួយនឹងប្រជាពលរដ្ឋដោយប្រើអំណាចគ្មានការបែងចែកនិងគ្មានដែនកំណត់។ ការប្រមូលផ្តុំអំណាចបែបនេះជារឿងមិនត្រូវបានគេស្វាគមន៍ឡើយនៅប្រទេសស្វីស ដោយសារមុំទាំងបីគឺ "ប្រជាពលរដ្ឋ សភា និងរដ្ឋាភិបាល" បានបង្កើតឲ្យមាននូវតុល្យភាពប្រជាធិបតេយ្យចម្រុះ ប៉ុន្តែរឹងមាំ ដែលនាំឲ្យមានសមាហរណកម្ម ទំនុកចិត្ត និងសន្តិភាព។

ទំនាក់ទំនងរវាងបុគ្គល និងរដ្ឋមានសារៈសំខាន់ខ្លាំងណាស់។ មុខងារទាំងឡាយនៃអំណាចរដ្ឋទាំងបួន (ប្រជាពលរដ្ឋ សភា រដ្ឋាភិបាល និងតុលាការ) ចូលរួមចំណែករួមគ្នាជានា និងអភិវឌ្ឍប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស៖ តុលាការវិនិច្ឆ័យបញ្ហាទាំងឡាយណាដែលមិនអនុលោមទៅតាមបទបញ្ញត្តិច្បាប់ ចំណែកប្រជាពលរដ្ឋធានាថា សិទ្ធិមនុស្សត្រូវបានអង្កេតតាមដាន[៥០ទំ.៧]រីឯសភាមានតួនាទីជាអន្តរការីរវាងប្រជាពលរដ្ឋនិងរដ្ឋាភិបាលឬរដ្ឋបាល[៥០ទំ. ៦]។ រដ្ឋាភិបាលតំណាងរដ្ឋក្នុងវិស័យការបរទេស ចំណែកសភាតំណាងប្រជាពលរដ្ឋនៅក្នុងប្រទេស [៤៦ art. ១៨៤ និង art. ១៤៨] ដែលតទល់ទៅនឹងរដ្ឋាភិបាលដោយការផ្តួចផ្តើមធ្វើច្បាប់ និងប្រជាមតិ[៥១]។ តុល្យភាពនេះបណ្តាលធ្វើឲ្យ

សភាក្លាយជាប្រភពនៃការឆ្លើយតបរហ័ស និងប្រកបដោយប្រសិទ្ធិភាពខ្ពស់ក្នុងការជម្រុញទឹកចិត្ត និងធ្វើឲ្យមានការផ្តួចផ្តើមផ្នែកនយោបាយ[៥២]។

ដោយសារហេតុផលនេះ ក្រុមជនភាគតិចនៅប្រទេសស្វីសតែងតែប្រើប្រាស់នីតិវិធីសភាដើម្បីបញ្ចេញមតិយោបល់របស់ពួកគេជាសាធារណៈ។ តាមរយៈយន្តការនានារួមមានដូចជា ការដាក់ញត្តិជាដើម បញ្ហានានាអាចត្រូវបានលើកទៅដល់វេទិកានយោបាយតាមរយៈសមាជិក សមាជិកាសភា ហើយដែលបញ្ហាទាំងនោះអាចនឹងបាត់ក្នុងដំណើរនីតិវិធីនយោបាយធំៗ ដូចជាសិទ្ធិផ្តួចផ្តើមធ្វើច្បាប់និងប្រជាមតិនីតិវិធីពិគ្រោះយោបល់ ឬការតវ៉ាជាសមូហភាពជាដើម។ កិច្ចការអាចធ្វើទៅរួចក៏ដោយសារតែវិន័យគណបក្សនៅប្រទេសស្វីសមិនត្រូវបានអង្កេតតាមដានតឹងតែងដូចក្នុងបណ្តាប្រទេសប្រជាធិបតេយ្យសភានិយមជាច្រើនផ្សេងទៀតទេ។ ដោយការយល់ពីភាពជាតំណាងជាលក្ខណៈបុគ្គល និងដោយសមាជិក សមាជិកាសភានាំយកផលប្រយោជន៍តំបន់ និងសហគមន៍ ឬផលប្រយោជន៍របស់សមាគមមកបន្ថែមលើផលប្រយោជន៍របស់គណបក្សនយោបាយ សភាបានផ្តល់ជាការរួមចំណែកដ៏សំខាន់ដោយធ្វើឲ្យមានសមាហរណកម្មនៃជនភាគតិច និងភាពស្អិតរមួតក្នុងសង្គម។

ដូច្នេះ សភាបង្កើតបាននូវអត្តសញ្ញាណ និងទំនុកចិត្ត ហើយជានាបាននូវពិពិធភាពនិងការចូលរួម។ អំណាចនយោបាយស្ថិតនៅត្រង់សភានិងសមត្ថភាពរបស់សភាក្នុងការដោះស្រាយបញ្ហាជម្លោះនានា ដោយពឹងផ្អែកលើភាពច្បាស់លាស់ក្នុងការធ្វើសេចក្តីសម្រេចចិត្តពីរបៀបគ្រប់គ្រងដំណើរការ និងតើនរណាដែលពាក់ព័ន្ធក្នុងការចរចា។ រាល់ការសម្រុះសម្រួលដែលធ្វើឡើងនៅក្នុងសភាត្រូវបានសម្រេចឡើងតាមនីតិវិធីបែបប្រជាធិបតេយ្យ។ វាជានីតិវិធីដែលមានសមាជិក សមាជិកាសភាចូលរួម និងមានទំនាក់ទំនងដោយផ្ទាល់ជាមួយមនុស្ស ដែលអាចឲ្យមានតុល្យភាពរវាងអំណះអំណាង ការពិត ទ្រឹស្តី និងវោហារស័ព្ទ។ តាមវិធីនេះ សភាធានាបាននូវការចាប់ផ្តើមការពិភាក្សានិងការជជែកវែកញែកអំពីរាល់បញ្ហានយោបាយ [៤៦ art. ១៥១-១៥៣ ៤៩]។

តថភាពនៃសភានេះបញ្ជាក់នូវការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់នៃពេលវេលានិងទីកន្លែង "នៅទីនេះ និងនៅពេលនេះ" ដែលជាតថភាពសភាក្នុងនយោបាយ។ គោលការណ៍នៃការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់នេះទាមទារនូវសមាសភាគសំខាន់ដែលលើសពីនិយមន័យទូទៅរបស់គោលការណ៍នេះ។ វាមិនមែនគ្រាន់តែជាគោលការណ៍បែបនីតិវិធីធម្មតាប៉ុណ្ណោះទេ តែជាគោលការណ៍ដែលរួមបញ្ចូលនូវមុខងារនយោបាយរបស់សភាដែលបានរៀបរាប់ខាងលើ។ គោលការណ៍នេះត្រូវបានផ្តល់និយមន័យទៅតាមរបៀបសភានិងនីតិវិធីរបស់សភា ដែលមានឥទ្ធិពលរួមគ្នា ដែលជានាទូវអត្តសញ្ញាណនៃពិពិធភាពនយោបាយ និងដែលធ្វើឲ្យនយោបាយស្ថិតនៅក្រោមឥទ្ធិពលដោយផ្ទាល់របស់សភា និងអាចចរចាបាននៅនឹងកន្លែងផ្ទាល់។

បើប្រជាពលរដ្ឋចង់លើកឡើងថា សភាគ្មានអ្វីពិសេសលើសពីប្រជាពលរដ្ឋធម្មតានោះ វាជារឿងត្រឹមត្រូវណាស់។ សភាមិនអាច និងមិនគួរជាអ្វីលើសពីប្រជាពលរដ្ឋនោះទេ។ សភាគួរតែជាតំណាង ជារូបភាពឆ្លុះបញ្ចាំងពីសង្គមនូវរាល់ទិដ្ឋភាព។ នីតិវិធីនេះបង្ហាញពីគំនិតរបស់សភា ហើយធ្វើឡើងក្នុងទម្រង់នៃសកម្មភាពដោយផ្ទាល់នៃតួអង្គរបស់ខ្លួន។

## ទំនុកចិត្តទាមទារការផ្តល់ឲ្យ

ពេលនេះ គេអាចនឹងមានទំនោរនិយាយថា ការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់នៃការចរចាសភាអាចនឹងត្រូវបានបង្កើតឡើងនៅក្នុងសន្និសីទតាមវីដេអូ ដោយសារប្រធានបទត្រូវពិភាក្សា និងសម្រេចត្រូវយកទៅចរចាជាមួយភាគីពាក់ព័ន្ធទាំងឡាយក្នុងពេលតែមួយ។ មានតែការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់ក្នុងប្រទេសទេដែលអាចជំនួសបានដោយទីកន្លែងនិម្មិត។ វាជាការវែកផ្លូវទៅកាន់ ការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់បែបនិម្មិត។ ការភ្ជាប់ទំនាក់ទំនងគ្នាដោយបន្ទាន់បែបនិម្មិតមិនមានភាពស៊ីសង្វាក់គ្នានឹងនីតិវិធីសភាដែលមានពីយូរលង់ដែលកំពុងប្រើសព្វថ្ងៃនេះទេ ព្រោះសភាមានទំនោរយ៉ាងច្បាស់ទៅរកការជួបប្រជុំដោយផ្ទាល់នៅនឹងកន្លែង[៤១, ៤៩]។

សន្មត់ថា មានឧបករណ៍ប្រាស្រ័យទាក់ទងមួយអាចបំពេញរាល់តម្រូវការនៃការជជែកដេញដោលរបស់សភា ដូចជា អាចធ្វើការបង្ហាញជាបន្តបន្ទាប់ពីអត្តសញ្ញាណរបស់សមាជិក សមាជិកាសភាក្នុងអំឡុងពេលប្រជុំ ជានាបាននូវបណ្តាញតភ្ជាប់ដោយមិនរអាក់រអួល ប្រព័ន្ធសំឡេងបោះឆ្នោតនិងការបោះឆ្នោតដែលអាចផ្តល់ជូនទៅបេក្ខជនបាន អាចបង្កើតនិងប្រគល់ជូនសំណើនានា ក៏ដូចជាឱកាសសម្រាប់ការចូលរួមពីសាធារណជនជាដើម។ បើទោះបីជាចំណុចទាំងអស់នេះអាចធ្វើបានក៏ដោយហើយបើទោះបីជាអាចធ្វើទៅរួច ឧទាហរណ៍ មានមនុស្ស៦០០នាក់ នៅក្នុងក្រុមប្រឹក្សាពីរក្នុងពេលតែមួយក៏ដោយ ក៏នៅតែមានសំណួរចោទសួរថា តើមុខងារអត្តសញ្ញាណស្ថាប័នរបស់សភាអាចបង្កើតឡើងយ៉ាងដូចម្តេច បើសិនវាមិនអាចកាត់ផ្តាច់ពីទីកន្លែងរូបវន្តបានផងនោះ។

គ្មានមន្ទិលសង្ស័យអ្វីទេថាក្នុងរយៈពេល៥ឬ ១០ឆ្នាំខាងមុខទៀតសភាដែលផ្អែកលើប្រព័ន្ធសន្និសីទតាមវីដេអូនឹងអាចបំពេញមុខងាររបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាពយ៉ាងល្អ។ បច្ចេកវិទ្យា ជាពិសេសមធ្យោបាយទំនាក់ទំនងរវាងអ្នកប្រើប្រាស់ និងប្រព័ន្ធកុំព្យូទ័រនឹងបន្តរីកចម្រើន ដែលអាចនាំឲ្យមានការបង្កើតនូវទីតាំងនិម្មិត។ ហើយប្រហែលជាយើងអាចចូលរួមបានដោយមិនចាំបាច់ប្រើឧបករណ៍អ្វីផងក៏ថាមិនត្រូវ។ ហេតុនេះវាពិតជាមានសារៈសំខាន់ ដែលក្នុងពេលបច្ចុប្បន្នពេលបង្កើតគម្រោងទាំងឡាយ ត្រូវគិតដោយយកចិត្តទុកដាក់ពីការអនុវត្តរបស់សភាបែបឌីជីថល [៥០]។ក៏ប៉ុន្តែ ក្នុងពេលបច្ចុប្បន្ននេះមិនទាន់មានឧបករណ៍បែបនេះនៅឡើយទេ ហើយការដាក់មុខងារសភាដែលបានពិពណ៌នាខាងលើទៅក្នុងលំហនិម្មិតមួយនឹងទាមទារកិច្ចប្រឹងប្រែងខ្លាំង ក៏ដូចជាការព្រាងគោលការណ៍សណ្តាប់ធ្នាប់សភាថ្មី ក្នុងចំណោមកិច្ចការជាច្រើនទៀត។

ក៏ប៉ុន្តែគួរកត់សម្គាល់ផងដែរថា មុខងារអត្តសញ្ញាណ និងពិធីភាពពេញលេញរបស់សភាអាចនឹងពិបាកយកមកតំណាងក្នុងសន្និសីទតាមវីដេអូ។ ជំនួសមកវិញ អ្នកដែលសម្របសម្រួលសន្និសីទ និងដែលលេចមុខឥតដាច់នៅផ្ទៃខាងមុខអេក្រង់នឹងដើរតួជាជនបង្គោលមួយនិងជាអ្នកបង្កើតអត្តសញ្ញាណ។ ប្រធានសភានឹងក្លាយជាតួអង្គដែលគេអាចមើលឃើញជាអត្តសញ្ញាណបន្តបន្ទាប់ ឯសភាទាំងមូលនឹងត្រូវរុញទៅជាផ្ទៃខាងក្រោយនៃអេក្រង់។ ប្រព័ន្ធនេះពិតជាមិនស៊ីសង្វាក់គ្នាទាល់តែសោះជាមួយនឹងក្បួនទម្លាប់របស់សភា។ តាមក្បួនទម្លាប់ប្រធានក្រុមប្រឹក្សាជាអ្នកផ្តល់នូវអព្យាក្រិតភាពប្រកបដោយសុភវិនិច្ឆ័យ និងមិនចេញមុខលេចធ្លោខ្លាំងទេ។ ភាពនិម្មិតនេះធ្វើឲ្យប៉ះពាល់ដល់តុល្យភាពនៃប្លង់អង្គប្រជុំរូបវន្ត ជាពិសេសនៅពេលដែលគេមិនអាចមើលឃើញសភាទាំងមូលក្នុងពេលតែមួយបាន។ នៅប្រទេសស្វីសមានបញ្ហាមួយទៀតត្រង់ថា ប្រធានសភាត្រូវបោះឆ្នោតជ្រើសតាំងឲ្យកាន់មុខតំណែងតែរយៈពេលមួយឆ្នាំប៉ុណ្ណោះ ដែលជាបញ្ហាប្រឈមបន្ថែមទៀតទាក់ទងនឹងមុខងារអត្តសញ្ញាណ។

ដោយសារសភាចាំបាច់ត្រូវរក្សាលទ្ធភាពរបស់ខ្លួនក្នុងការបំពេញការងារអំឡុងពេលមានជំងឺរាតត្បាតសកលដើម្បីធ្វើសេចក្តីសម្រេចចិត្តចាំបាច់នានា ឬក៏រៀបចំការបោះឆ្នោតក្នុងករណីបន្ទាន់ខ្លាំង សន្និសីទតាមវីដេអូអាច យកមកជំនួសកិច្ចប្រជុំផ្ទាល់បាន តែជាបណ្តោះអាសន្នប៉ុណ្ណោះ។ នេះក៏ដោយសារចំណុចស្នូលនៃមុខងារសភាគឺ ពឹងផ្អែកលើទំនាក់ទំនងដោយផ្ទាល់រវាងមនុស្សនិងមនុស្ស ដែលជួយបង្កើតតុល្យភាពរវាងកម្លាំង និងអំណះអំណាងផ្នែកនយោបាយ ក្នុងស្មារតីប្រកបដោយការទុកចិត្ត។ ប្រហែលជាកត្តានេះមិនអាចកើតឡើងបានទេក្នុងលំហនិម្មិតមួយ ដោយសារការភ្ជាប់ទំនាក់ទំនងបន្ទាន់ដែលជួយបង្កើនទំនុកចិត្តតាមរយៈការប្រាស្រ័យទាក់ទងរវាងមនុស្ស ដែលជាផ្នែកដ៏សំខាន់នៃប្រជាធិបតេយ្យត្រូវបាត់បង់។ អត្តសញ្ញាណរួមរបស់សភាអាចត្រូវផ្អែកទៅលើបុគ្គលដោយឡែករៀងៗខ្លួននៃសមាជិកសមាជិកាក្រុមប្រឹក្សា។ នេះអាចជាទម្រង់ថ្មីមួយនៃប្រព័ន្ធសភានិយម តែវានឹងមិនងាយមានភាពទាក់ទាញនិងមានគុណភាពដូចគ្នាទេ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ១.៨ វិធីបែបអាស៊ានឆ្ពោះទៅរកពហុភាគីនិយម ដើម្បីសន្តិភាព សន្តិសុខ និងវិបុលភាព

## វិធីបែបអាស៊ានឆ្ពោះទៅរកពហុភាគីនិយម

នៅក្នុងពេលដំណាលគ្នាដែលពហុភាគីនិយមទូទាំងសាកលលោកកំពុងស្ថិតក្រោមភាពតានតឹងយ៉ាងខ្លាំង ពហុភាគីនិយមនៅអាស៊ីអាគ្នេយ៍បែរជាកំពុងមានកម្លាំង និងឥទ្ធិពល។ វឌ្ឍនភាពនេះកើតមានឡើង ដោយសារមានការអភិវឌ្ឍបទដ្ឋាន និងគំនិតផ្តួចផ្តើមមួយចំនួនដែលជំរុញឲ្យមានការចូលរួម និងមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ។ ការរីកចម្រើននេះភាគច្រើន គឺដោយសារសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ទទួលបានភាពល្បីល្បាញពីអន្តរជាតិ តាមរយៈកិច្ចប្រឹងប្រែងការទូតរបស់ខ្លួនដើម្បីស្វែងរកដំណោះស្រាយនយោបាយគ្រប់ជ្រុងជ្រោយមួយចំពោះជម្លោះអូសបន្លាយ ដែលប្រទេសកម្ពុជាបានប្រឈមក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០។ ចាប់តាំងពីពេលនោះមក អាស៊ានត្រូវបានគេស្គាល់ថា ជាប្រភពដែលនាំឲ្យមានស្ថិរភាពក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលជាលទ្ធផលនៃកិច្ចសហប្រតិបត្តិការនិម្មាបនកម្មសន្តិសុខ (cooperative security Architectures) និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការទូលំទូលាយជាងមុនជាមួយនឹងមហាអំណាចធំៗ ជាមួយនឹងតំបន់អាស៊ីខាងកើត និងជាមួយប្រទេសផ្សេងៗក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។

យោងទៅតាម «វិធីបែបអាស៊ាន» មេដឹកនាំអាស៊ានចូលចិត្តប្រើនីតិវិធីក្រៅផ្លូវការ ព្រោះអាស៊ានជឿជាក់ទៅលើបរិយាកាសដែលគ្មានការគំរាមកំហែងក្នុងការការស្វែងរកវិធីដោះស្រាយបញ្ហា។ ដូច្នេះ នៅក្នុងការចូលរួមរបស់អាស៊ានក្នុងការពិគ្រោះយោបល់ស្តីពី សន្តិសុខពហុភាគី គឺអាស៊ានតែងតែសង្កត់ធ្ងន់ជានិច្ចពីសារៈសំខាន់នៃ"កម្រិតផាសុខភាព" របស់អ្នកចូលរួម ដោយបានអះអាងថា បញ្ហាណាដែលចម្រូងចម្រាសគួរតែដកចេញពីរបៀបវារៈ ជាជាងទុកនៅដែលអាចនាំឲ្យមានហានិភ័យដែលបង្កឲ្យមានភាពតានតឹង។ ជាឧទាហរណ៍ជាក់ស្តែងនៃអភិក្រមនេះ គឺវេទិកាតំបន់អាស៊ាន(ARF) ដែលមើលឃើញពហុភាគីនិយម ថាជាយន្តការសម្រាប់ដោះស្រាយបញ្ហាដើម្បីការពារ និងទប់ស្កាត់កុំឲ្យមានហានិភ័យនៃភាពគ្មានសណ្តាប់ធ្នាប់ក្នុងតំបន់។

អាស៊ានឈានទៅចាប់យកពហុភាគីនិយម តាមបែបបទដោយឡែកនៃតំបន់និយមរបស់ខ្លួន។ អភិក្រមនេះបាននាំឲ្យមានការវិវត្តនៃក្រុមនិងវេទិកាចម្រុះតែមិនមានលក្ខណៈដូចសហភាពអឺរ៉ុប ដែលធ្វើឲ្យមានបរិយាប័នស្ថាប័ននានាជាទ្រង់ទ្រាយធំ ដូចស្ថាប័នផ្សេងៗដែលបានបង្កើតនៅអឺរ៉ុបនោះទេ។ ពហុភាគីនិយមបែបអាស៊ានជាទូទៅពឹងផ្អែកលើការឯកភាពបែបកុងសង់ស៊ីស និងមិនចងកាតព្វកិច្ចទេ។ លក្ខណៈនេះ គឺផ្ទុយទៅនឹងអភិក្រមរបស់លោកខាងលិចចំពោះពហុភាគីនិយម ដែលច្រើនតែនិយមស្ថាប័នីយកម្ម និងការចងកាតព្វកិច្ចចំពោះអង្គការក្នុងតំបន់របស់ខ្លួន។ "វិធីបែបអាស៊ាន" ចំពោះពហុភាគីនិយមច្រើនជំរុញដោយដំណើរការ ជាជាងដោយតួអង្គណាមួយ ដោយបញ្ហាប្រឈម ឬដោយព្រឹត្តិការណ៍ជាក់លាក់ណាមួយ។ ក្នុងន័យនេះ អាស៊ានប្រាថ្នាចង់អភិវឌ្ឍនីតិវិធីទាំងឡាយឲ្យស្របទៅនឹងបទដ្ឋាន និងការអនុវត្តដែលមានស្រាប់ក្នុងតំបន់របស់ខ្លួន។ វិធីនេះធ្វើឲ្យអ្នកដែលចូលរួមអាចធ្វើអន្តរកម្មជាមួយគ្នាប្រកបដោយផាសុកភាព ដែលនេះជាហេតុជួយជំរុញឲ្យមានអន្តរកម្មនៃពហុភាគី ពង្រឹងតម្លាភាព ភាពទុកចិត្តគ្នាទៅវិញទៅមក និងជួយឲ្យអាចដោះស្រាយបញ្ហាចម្រូងចម្រាសបានដោយសន្តិវិធី និងប្រកបដោយការស្តាបនា។

ចាប់ពីដែលបានបង្កើតឡើងនៅ ឆ្នាំ១៩៦៧ មក ដំណើរការតាមបែបតំបន់និយមរបស់អាស៊ានត្រូវបានប្រើដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរឹងមាំក្នុងតំបន់ ឈានដល់ការពង្រីកកិច្ចសហប្រតិបត្តិការជាមួយតំបន់អាស៊ីខាងកើត ក្នុងពេលជាមួយគ្នាឈានទៅពង្រឹងទំនាក់ទំនងពហុភាគីជាមួយបណ្តាមហាអំណាចទាំងជិតនិងឆ្ងាយ។ អាស៊ានធ្វើបែបនេះ ដោយបានបន្តពង្រឹងវេទិកាតំបន់អាស៊ាន(ARF) (ចាប់ផ្តើមឡើងក្នុងឆ្នាំ១៩៩៤ ដោយមានសមាជិក២៧ប្រទេស) អាស៊ានបូកបី (ក្នុងឆ្នាំ១៩៩៧ បានរួមបញ្ចូលអាស៊ានទាំងដប់ បូកនឹងចិន ជប៉ុន និងកូរ៉េខាងត្បូង) កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (សមាជិក១៨ប្រទេស រួមមាន ១៣ប្រទេសនៃអាស៊ានបូកបី ជាមួយនឹងឥណ្ឌា អូស្ត្រាលី នូវែលសេឡង់ រុស្ស៊ី និងសហរដ្ឋអាមេរិក ដែលបានជួបគ្នាលើកដំបូងនៅខែធ្នូ ឆ្នាំ២០០៥) និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិបូក (ADMM-Plus) (បានបង្កើតឡើងនៅខែតុលា ឆ្នាំ២០១០ មានសមាជិកអាស៊ាន រួមនឹងប្រទេសដែលមានអំណាចប្រាំបីទៀតគឺ៖ អូស្ត្រាលី ចិន ឥណ្ឌា ជប៉ុន នូវែលសេឡង់ សាធារណរដ្ឋកូរ៉េ រុស្ស៊ី និងសហរដ្ឋអាមេរិក)។

ការប្រកាន់ខ្ជាប់នូវពហុភាគីនិយមជួយការពារវិបាក និងបទដ្ឋាននានាដែលមានស្រាប់របស់សមាគម ក៏ដូចជាជួយការពារតំបន់ទប់ទល់នឹងការមើលស្រាលពីមហាអំណាចធំៗ។ "វិធីបែបអាស៊ាន" ឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការសន្តិសុខពហុភាគី គឺជាការដាក់រាល់ការបារម្ភស្តីពីសន្តិសុខនៅលើតុដើម្បីពិភាក្សា ដោយអនុវត្តវិធីរបស់អាស៊ានក្នុងការកិច្ចសន្ទនា កិច្ចពិគ្រោះយោបល់ និងក្នុងស្ថាប័ន ដើម្បីបញ្ចៀសការសង្ស័យ ហើយបង្កើតឲ្យមានការយោគយល់គ្នាកាន់តែប្រសើរកសាងបាននូវទំនុកចិត្តរវាងគ្នា និងសម្របសម្រួលឲ្យមានការដោះស្រាយតាមអភិក្រមសន្តិវិធី ដើម្បីជៀសវាងនូវជម្លោះតំបន់ ការគំរាមកំហែង និងការប្រើប្រាស់កម្លាំង។ នេះហើយជាវិធីដែលអាស៊ានទាំងមូលអាចធ្វើឲ្យចិនចូលរួមជាលក្ខណៈពហុភាគីបាន ខណៈពេលដែលរដ្ឋជាសមាជិកនៅបន្តទទួលបានផលប្រយោជន៍ដោយឡែកៗពីវត្តមានដ៏រឹងមាំរបស់សហរដ្ឋអាមេរិកនៅក្នុងផ្នែកមួយនេះនៃពិភពលោក។

## បញ្ហាប្រឈមចំពោះតំបន់និយមរបស់អាស៊ាន

ទោះបីជាអាស៊ានទទួលបានជោគជ័យក្នុងការរក្សាទំនាក់ទំនងវិជ្ជមានជាមួយចិន និងសហរដ្ឋអាមេរិកក៏ដោយ ក៏បញ្ហាប្រឈមធំបំផុតចំពោះកិច្ចសហប្រតិបត្តិការពហុភាគីគឺនៅតែជាការព្រួយបារម្ភជុំវិញជម្លោះដែលអាចនឹងកើតមានក្នុងចំណោមមហាអំណាចធំៗ និងការខ្វះនូវយន្តការដើម្បីរារាំងឬជួយគ្រប់គ្រងឥរិយាបថរបស់មហាអំណាចទាំងនោះ។ ទោះបីសហរដ្ឋអាមេរិកជាប្រធានស្ថាបនិកនៃសណ្តាប់ធ្នាប់អន្តរជាតិដែលកើតក្រោយពីសង្គ្រាមលោកលើកទី២ក៏ដោយ ក៏អ្វីដែលបាននឹងកំពុងរីកដុះដាលនៅក្នុងសង្គមអាមេរិកចាប់តាំងពីប្រធានាធិបតីត្រាំឡើងកាន់តំណែងពីខែមករា ឆ្នាំ២០១៧មក គឺជាការឆ្លុះបង្ហាញឲ្យឃើញច្បាស់នូវការកើនឡើងនៃការផ្តាច់ខ្លួនរបស់ប្រជាជាតិនេះពីពិភពលោក។ ដោយផ្តោតលើ "America First" អាមេរិកហាក់ដូចជាបានបោះបង់ចោលនូវសណ្តាប់ធ្នាប់អន្តរជាតិ ដែលបានដឹកនាំដោយសហរដ្ឋអាមេរិកផ្ទាល់។ ក្នុងការព្យាយាម "ធ្វើឲ្យអាមេរិកក្លាយជាអស្ចារ្យម្តងទៀត" សហរដ្ឋអាមេរិកឥឡូវនេះកំពុងតែបដិសេធថាសាកលភាវូបនីយកម្មមិនមែនជាកម្លាំងវិជ្ជមានមួយ។ ជាមួយនឹងទស្សនៈជាតិនិយមដ៏ខ្លាំងក្លា និងការឆ្ពោះទៅរកគាំពារនិយម សព្វថ្ងៃនេះ សហរដ្ឋអាមេរិកគឺ កំពុងតែបោះបង់នូវតួនាទីដឹកនាំរបស់ខ្លួនលើសណ្តាប់ធ្នាប់អាស្រ័យច្បាប់បែបពហុភាគី ដែលធ្លាប់ជាចំណុចស្នូលមួយនៃគោលនយោបាយការបរទេសរបស់អាមេរិក និងប្រភពនៃអនុត្តរភាពរបស់អាមេរិក។

ការងើបឡើងដ៏អស្ចារ្យនិងភ្ញាក់ផ្អើលរបស់ចិន គឺមិនមែនផ្តល់ភាពតានតឹងតិចតួចដល់អាស៊ាននោះទេ។ ប្រកបដោយទំនុកចិត្ត និងកម្លាំងកាន់តែខ្លាំងក្លា ចិនបានតាមទាន់ជាមួយលោកខាងលិចទាក់ទងនឹងផ្នែកសេដ្ឋកិច្ច ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពការពារមួយចំនួន និងបានធ្វើសមាហរណកម្មខ្លួនទៅក្នុងសេដ្ឋកិច្ចសាកលលោក។ ប៉ុន្តែចិនមិនបានយកតាមនូវទ្រឹស្តីសណ្តាប់ធ្នាប់អាស្រ័យច្បាប់របស់លោកខាងលិច ឬគុណតម្លៃណាមួយរបស់លោកខាងលិចដូចជា ប្រជាធិបតេយ្យតំណាង និងសិទ្ធិមនុស្សជាសកលនោះទេ។នៅពេលដែលចិនត្រូវការពារអត្ថប្រយោជន៍ស្នូលរបស់ខ្លួន ដូចជាបញ្ហាទាក់ទងនឹងសមុទ្រចិនខាងត្បូង ចិនមានភាពស៊ីសង្វាក់និងភាពច្បាស់លាស់ពីជំហរដែលខ្លួនចង់បាន ពោលគឺប្រើការរចរចាទ្វេភាគីជាមួយនឹងភាគីពាក់ព័ន្ធផ្ទាល់ ជាជាងពឹងផ្អែកលើការរៀបចំបែបពហុភាគី ដូចជាតាមរយៈតុលាការអន្តរជាតិជាដើម។ ទ្វេភាគីនិយមផ្តល់នូវក្របខ័ណ្ឌមួយដែលអាចបត់បែនបានច្រើនសម្រាប់កិច្ចសហប្រតិបត្តិការ ហើយផ្តល់ឲ្យចិននូវឥទ្ធិពលកាន់តែខ្លាំងលើសម្ព័ន្ធមិត្តរបស់ខ្លួន។

បញ្ហាប្រឈមមួយផ្សេងទៀត គឺជាឌីអិនអេ (DNA) ផ្ទាល់របស់អាស៊ាន។ បទដ្ឋានដែលបានចាក់ឫសយ៉ាងជ្រៅគឺការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុង និងការធ្វើសេចក្តីសម្រេចចិត្តផ្អែកលើការឯកភាពបែបកុងសង់ស៊ីស អាចកម្រិតការចូលរួមរបស់សមាគមនេះលើការទទួលបន្ទុកដោះស្រាយបញ្ហាបន្ទាន់ផ្នែកសន្តិសុខ និងភូមិសាស្ត្រនយោបាយក្នុងតំបន់។ ការប្រកាន់ខ្ជាប់យ៉ាងរឹងមាំទៅនឹងគោលការណ៍ទាំងនេះ ក្នុងពេលនេះធ្វើឲ្យអាស៊ានបាត់ឱកាសក្នុងការបោះជំហានឲ្យបានវែង និងទទួលបានការគោរពបន្ថែមទៀតពីប្រទេសជាសមាជិក និងដៃគូខាងក្រៅ ជាពិសេសដើម្បីពង្រឹងតួនាទីរបស់ខ្លួនឲ្យបានត្រឹមត្រូវ ក្នុងនាមជាអ្នកដែលជំរុញឲ្យមានសន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។ ឧទាហរណ៍មួយនៃយន្តការកិច្ចសហប្រតិបត្តិការពហុភាគីដ៏សំខាន់របស់អាស៊ាន ដែលរួមមានដូចជា វេទិកាតំបន់អាស៊ាន (ARF) នៅតែខ្វះសមត្ថភាពពង្រឹងក្របខ័ណ្ឌសម្រាប់ "ច្បាប់នៃអាកប្បកិរិយាដែលអាចទទួលយកបាន"។

បញ្ហាប្រឈមផ្ទៃក្នុងអាស៊ាន រួមមានល្បឿនយឺតនៃដំណើរការសមាហរណកម្មរបស់ខ្លួនដើម្បីកាត់បន្ថយគម្លាតខុសគ្នានៃសេដ្ឋកិច្ច និងវិសមភាពរវាងរដ្ឋសមាជិក។ ចំពោះការគ្រប់គ្រងសន្តិសុខតាមព្រំដែន អាស៊ានត្រូវតែស្វែងរកវិធីសាស្ត្រច្បាស់លាស់បន្ថែមទៀត ដើម្បីជួយសម្របសម្រួល និងដោះស្រាយជម្លោះរវាងសមាជិកនៃសមាគម។ អាស៊ានក៏អាចជំរុញស្មារតីយកចិត្តទុកដាក់ និងឆន្ទៈរបស់ខ្លួនក្នុង

> អាស៊ានត្រូវតែរកវិធីច្បាស់លាស់ ដើម្បីជួយផ្សះផ្សារ និងដោះស្រាយទំនាស់រវាងសមាជិករបស់សមាគម

ការជួយរដ្ឋជាសមាជិកដែលមានការលំបាកដោយសារបញ្ហាផ្ទៃក្នុងប្រទេស។ ដូច្នេះការគិតគូរសមរម្យឡើងវិញអំពី គោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង និងដំណើរនៃការធ្វើសេចក្តីសម្រេចចិត្តដែលមានលក្ខណៈឆ្លើយតបទាន់ពេលវេលា ក៏ដូចជាអភិក្រមដែលសកម្មជាងមុនលើបញ្ហាដូចជាអភិបាលកិច្ចល្អ សិទ្ធិមនុស្ស ប្រជាធិបតេយ្យ គណនេយ្យភាព និងតម្លាភាព គួរសិក្សាបន្ថែមទៀត។

ចំណែកឯបញ្ហាប្រឈមខាងក្រៅសម្រាប់អាស៊ាន គឺមានដូចជាភាពលំបាករបស់អាស៊ានក្នុងការពិភាក្សាគ្នាដោយស្រុះស្រួល ពីបញ្ហាសន្តិសុខដែលមិនមានការគំរាមកំហែងផ្នែកយោធាដែលធ្វើឲ្យបាត់នូវ“មជ្ឈភាពអាស៊ាន”។ការណ៍នេះបានជះផលប៉ះពាល់ដល់មុខមាត់ និងកេរ្តិ៍ឈ្មោះរបស់សមាគម ដែលជានិច្ចជាកាលមានការរិះគន់មួយចំនួនដែលថា អាស៊ានជាវេទិកាមួយដែល “សម្រាប់តែនិយាយ និងមិនមានសកម្មភាពគ្រប់គ្រាន់”។ អាស៊ានត្រូវតែចាត់វិធានការណ៍ឲ្យបានស៊ីជម្រៅជាជាងធ្វើសកម្មភាពសើរៗ ទៅលើបញ្ហាទាំងឡាយនាពេលសព្វថ្ងៃ ដូចជាការរំសាយអាវុធនុយក្លេអ៊ែរនៅឧបទ្វីបកូរ៉េ ជម្លោះសមុទ្រចិនខាងត្បូង វិបត្តិមនុស្សធម៌នៅរដ្ឋរ៉ាឃីនដែលពោរពេញដោយបញ្ហា ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងការវាយប្រហារតាមប្រព័ន្ធទូរគមនាគមន៍ និងបញ្ហាសន្តិសុខមិនមែនប្រពៃណីផ្សេងទៀត។ នៅក្នុងន័យនេះ ARF ត្រូវតែឈានទៅមុខលើសពីតួនាទីរបស់ខ្លួន ដែលគ្រាន់តែជាវេទិកានិយាយដើម្បីដោះស្រាយស្ថានការណ៍សន្តិសុខដ៏ស្មុគស្មាញនាពេលបច្ចុប្បន្ន។ ចក្ខុវិស័យបីដំណាក់កាលឆ្ពោះទៅមុខរបស់ARF រួមមាន៖ ទីមួយ ត្រូវដើរទៅឲ្យហួសពីការកសាងភាពជឿជាក់និងទំនុកចិត្ត, ទីពីរ ទប់ស្កាត់ជម្លោះតាមរយៈការទូតបែបទប់ស្កាត់ជម្លោះ (Preventive Diplomacy) និងទីបី បញ្ចប់ជម្លោះតាមរយៈការដោះស្រាយជម្លោះ។

## ដំណើរឆ្ពោះទៅមុខសម្រាប់អាស៊ាន ដើម្បីលើកកម្ពស់ពហុភាគីនិយម សម្រាប់ផលប្រយោជន៍សន្តិភាព សន្តិសុខ និងវិបុលភាព

ពហុភាគីនិយមតាមបែបអាស៊ាន មានប្រវត្តិដ៏យូរលង់នៅក្នុងតំបន់ ដោយផ្សារភ្ជាប់ទៅនឹងវិធីពិសេសរបស់អាស៊ានក្នុងកិច្ចពិគ្រោះយោបល់និងការៀបចំជាសមូហភាពក្នុងវិស័យសេដ្ឋកិច្ច នយោបាយ និងសន្តិសុខ។ ទោះបីជាវិធីបែបអាស៊ាន គឺយកការឯកភាពបែបកុងសង់ស៊ីសជាជាងយកមតិភាគច្រើន ប៉ុន្តែការប្តេជ្ញាចិត្តអនុវត្តតាមគោលការណ៍មិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសដទៃ និងការធ្វើសេចក្តីសម្រេចចិត្តតាមរយៈរចនាសម្ព័ន្ធក្រៅផ្លូវការ និងភាពជាគំរូ បានដំណើរការយ៉ាងល្អនៅក្នុងអាស៊ានក្នុងអំឡុងពេល ៥០ឆ្នាំកន្លងមកក៏ដោយ ក៏មានមតិខ្លះអះអាងថា “អាស៊ាននៅតែជាស្ថាប័ននយោបាយមួយដែលមានកម្រិតដែលនៅមានភាពស្ទាក់ស្ទើរក្នុងការដោះស្រាយកង្វល់ទាក់ទងនឹងបញ្ហាសន្តិសុខក្រោយសង្គ្រាមត្រជាក់” [៥៦]។

ដើម្បីឲ្យពហុភាគីនិយមបែបអាស៊ានធ្វើបានជោគជ័យ និងអាចដោះស្រាយបញ្ហាសន្តិសុខធំៗបាន រដ្ឋជាសមាជិកអាស៊ានទាំងអស់ត្រូវស្រមៃថា កិច្ចសហប្រតិបត្តិការពហុភាគីមិនមែនគ្រាន់តែជាការដោះស្រាយលំហាត់ធម្មតានៃការគ្រប់គ្រងបញ្ហាភាពគ្មានសណ្តាប់ធ្នាប់នៅក្នុងតំបន់នោះទេ។ ដើម្បីមានភាពបុរេសកម្មក្នុងការរក្សាសន្តិភាព និងធ្វើសកម្មភាពឆ្ពោះទៅមុខសំដៅលើកកម្ពស់វិបុលភាព អាស៊ានត្រូវពិចារណាលើចំណុចដូចខាងក្រោម៖

- ត្រូវមានកិច្ចប្រឹងប្រែងបន្ថែមជាចាំបាច់ដើម្បីទាក់ទាញចិនក្នុងន័យស្ថាបនា។ ប្រទេសចិនមិនត្រឹមតែស្ថិតនៅចំកណ្តាលនៃបញ្ហាថាតើរបៀបវារៈសន្តិសុខក្នុងតំបន់ត្រូវវិវត្តបែបណាទេ ប៉ុន្តែក៏ជាចំណុចស្នូលនៃលទ្ធភាពឈានទៅរកភាពជោគជ័យនៃការបង្កើតក្របខ័ណ្ឌសន្តិសុខណាមួយផងដែរ។ អាស៊ានគប្បីទទួលស្គាល់ការពិតនេះ។
- អាស៊ានត្រូវខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីអាចទទួលបានចំណាប់អារម្មណ៍ និងការចូលរួមយូរអង្វែងពីសហរដ្ឋអាមេរិក ព្រោះថា ស្ថានភាពសន្តិសុខក្នុងតំបន់កាន់តែមានភាពប្រែប្រួលជាងពេលណាៗទាំងអស់។ សហរដ្ឋអាមេរិក នៅតែមានផលប្រយោជន៍ច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយវត្តមានបន្តរបស់សហរដ្ឋអាមេរិកនៅក្នុងតំបន់អាចជួយទប់ស្កាត់ជម្លោះក្នុងតំបន់ និងការប៉ុនប៉ងត្រួតត្រាពីមហាអំណាចខាងក្រៅ។
- អាស៊ានមិនត្រូវលំអៀងទេ ប៉ុន្តែត្រូវរក្សាឲ្យបាននូវគោលការណ៍អព្យាក្រឹតរបស់ខ្លួន ដើម្បីកុំឲ្យមានឧបសគ្គក្នុងការសម្រេចឲ្យបាននូវការរៀបចំសន្តិសុខ ដែល

អាចជួយកាត់បន្ថយភាពតានតឹងដែលបណ្តាលមកពីការប្រកួតប្រជែងក្នុងចំណោមមហាអំណាច។ អាស៊ានត្រូវតែបញ្ជាក់ឲ្យច្បាស់ថា អាស៊ីអាគ្នេយ៍គ្មាននរណានៅពីក្រោយទេ ហើយគ្មានអំណាចមកពីក្រៅណាមួយដែលត្រូវបានអនុញ្ញាតឲ្យយកមកប្រើលើកិច្ចការណាមួយ ដែលអាចបង្កគ្រោះថ្នាក់ដល់ប្រយោជន៍រួមនៅក្នុងតំបន់ឡើយ។ ជម្រើសរបស់អាស៊ាននឹងមានតិច ប្រសិនបើសមាគមនេះពឹងផ្អែកលើមហាអំណាចតែមួយ។ ហេតុដូច្នេះ អាស៊ានត្រូវបន្តទាក់ទាញគ្រប់មហាអំណាចខាងក្រៅឲ្យចូលរួមដោយភាពស្មោះត្រង់ និងប្រកបដោយស្មារតីស្ថាបនា។

- អាស៊ានគប្បីបន្តនូវការព្យាយាមរបស់ខ្លួនក្នុងការធ្វើឲ្យសហរដ្ឋអាម៉េរិក និងចិនបន្តចូលរួម តាមរយៈក្របខ័ណ្ឌដែលមានស្រាប់ដូចជា ARF បើទោះជាអ្វីដែលអាចសម្រេចបាននៅមានកំរិតក៏ដោយ។ ទីក្រុងវ៉ាស៊ីនតោន និងប៉េកាំងមានចំណាប់អារម្មណ៍ក្នុងការបំពេញចិត្តអាស៊ាន និងផ្តល់ការយកចិត្តទុកដាក់បំពេញតាមបំណងប្រាថ្នារបស់អាស៊ាននៅពេលរៀបចំគោលនយោបាយរបស់គេរៀងៗខ្លួន។ អាស៊ានមានឥទ្ធិពលយ៉ាងណាចំពោះបញ្ហានេះ គឺអាស្រ័យលើសមត្ថភាពអាស៊ានខ្លួនឯង ក្នុងការធ្វើឲ្យមានការរួបរួម និងមានមជ្ឈភាព ដូច្នេះការជំរុញដំណើរការរបស់ ARF កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិបូកឲ្យឈានទៅមុខ គឺជាការចាំបាច់ដែលអាស៊ានត្រូវធ្វើដោយយកចិត្តទុកដាក់។
- ដើម្បីឲ្យអាស៊ានអាចក្លាយជា “ជើងឯក” នៃពហុភាគីនិយម អាស៊ានត្រូវតែពង្រឹងខ្លួនឡើងវិញ ហើយសម្របសម្រួលស្ថាប័នដែលមានស្រាប់ទៅនឹងនិន្នាការថ្មីៗ ដើម្បីធានាឲ្យបានថា កិច្ចសហប្រតិបត្តិការតំបន់ និងពហុភាគីអាចដំណើរការបានដោយត្រឹមត្រូវក្នុងការដោះស្រាយបញ្ហាតំបន់។ ជាពិសេសទៀតអាស៊ានត្រូវព្យាយាមធ្វើឲ្យមានតុល្យភាពរវាងកិច្ចសហប្រតិបត្តិការពហុភាគីដែលមានរចនាសម្ព័ន្ធទន់ខ្សោយ ដែលសង្កត់ធ្ងន់តែលើការពង្រឹងឯកភាពបែបកុងសង់ស៊ីស ទៅនឹងការអនុវត្តតាមបែបផ្សេងទៀតនៃពហុភាគីនិយមដែលធ្វើឡើងតាមរបៀបរបស់អឺរ៉ុប គឺការប្តេជ្ញាចិត្តដែលចងកាតព្វកិច្ចដោយច្បាប់ នៅក្នុងរចនាសម្ព័ន្ធស្ថាប័នទូលំទូលាយ។
- ដោយតថភាពជាក់ស្តែងនៃអំណាចនយោបាយអាចមានឥទ្ធិពលអវិជ្ជមានដល់ពហុភាគីនិយមបែបអាស៊ាន តែវាប្រហែលជាអាចនឹងមានផលប្រយោជន៍បើអាស៊ានអាចធ្វើតាមគំរូរបស់សហភាពអឺរ៉ុបនៃ “ពហុភាគីនិយមប្រកបដោយប្រសិទ្ធភាព” (ជាសណ្តាប់ធ្នាប់អាស្រ័យលើច្បាប់មួយ ដែលសង្កត់ធ្ងន់លើការចែករំលែកនូវអធិបតេយ្យភាព ការដោះស្រាយបញ្ហារួម និងមានសកម្មភាពដូចគ្នា ដើម្បីសម្រេចបានសន្តិភាព សន្តិសុខ និងវិបុលភាព)។ អាស្រ័យហេតុនេះ អាស៊ានគប្បីប្រឹងប្រែងកសាងភាពជាដៃគូជាមួយសហភាពអឺរ៉ុបឲ្យកាន់តែខ្លាំងក្លាឡើង។ ក្នុងនាមជាដៃគូ អាស៊ាននិងសហភាពអឺរ៉ុបអាចប្រមូលឆន្ទៈនយោបាយ ដែលចាំបាច់ដើម្បីកែសម្រួល និងបង្កើតនូវសណ្តាប់ធ្នាប់ថ្មីមួយនៃពហុភាគីនិយមដើម្បីបញ្ចៀសនូវគ្រោះថ្នាក់នៃជម្លោះ និងការប៉ះទង្គិចដោយកម្លាំងរវាងរដ្ឋដែលមានអំណាច។ សម្រាប់ផ្នែករបស់ខ្លួន សហភាពអឺរ៉ុបគប្បីទទួលស្គាល់នូវការចូលរួមចំណែកដ៏មានអត្ថន័យរបស់អាស៊ានឆ្ពោះទៅរកពហុភាគីនិយមដែលកំពុងវិវត្តទៅមុខនេះ។

ទោះបីជាមានចំណុចខ្វះចន្លោះក៏ដោយ ក៏អាស៊ានបានទទួលជោគជ័យគួរឲ្យកត់សម្គាល់ ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការតំបន់តាមរយៈកិច្ចសន្ទនាបែបកុងសង់ស៊ុស។ អភិក្រមនេះបានជួយបង្កើតនូវសណ្តាប់ធ្នាប់តំបន់ក្រោយពីសង្គ្រាមត្រជាក់ ដែលមានលក្ខណៈខុសប្លែកទាក់ទងទៅនឹងវិធីដែលស្ថាប័នពហុភាគីបានរៀបចំដើម្បីអាចមានអត្ថិភាពរួមគ្នា តែមិនមែនជំនួសគ្នាទេ ក្នុងការរៀបចំសន្តិសុខតាមបែបប្រពៃណី ដូចជាការបង្កើតសម្ព័ន្ធមិត្ត រចនាសម្ព័ន្ធពិភពលោកធំទូលាយ ឬរចនាសម្ព័ន្ធទ្វេភាគីតូចចង្អៀតសម្រាប់អភិបាលកិច្ច សេដ្ឋកិច្ច ឬការរៀបចំសន្តិសុខបែបប្រពៃណីទូលំទូលាយផ្សេងទៀតជាដើម។ ដូច្នេះ វិធីបែបអាស៊ានគួរតែទទួលបាននូវការស្វាគមន៍មួយបន្ថែមទៅលើការកសាងអនាគតនៃពហុភាគីថ្មីមួយ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ១.៩ បុរេសកម្មសភា ដើម្បីសន្តិភាព សន្តិសុខ និង វិបុលភាពរួម៖ ទស្សនៈបែបអាស៊ី

លាតសន្ធឹងលើផ្ទៃដី ៣០ ភាគរយនៃផ្ទៃដីពិភពលោកទាំងមូល និងជាទីស្នាក់អាស្រ័យនៃប្រជាពលរដ្ឋជាង ៤ ពាន់លាននាក់[៥៧]អាស៊ីជាទ្វីបប្រកបដោយពិពិធភាពផ្នែកនយោបាយ សេដ្ឋកិច្ច និងវប្បធម៌។ នេះក៏ដោយសារតែទំហំដ៏ធំល្វឹងល្វើយ ភាពស្មុគស្មាញនៃប្រជាសាស្ត្រ និងកេរដំណែលប្រវត្តិសាស្ត្រដែលបង្កឲ្យមានបរិយាកាសភូមិសាស្ត្រនយោបាយមួយប្រកបដោយថាមវន្ត និងបញ្ហាច្រើនក្នុងពេលជាមួយគ្នា។ អ្វីដែលគួរឲ្យកត់សម្គាល់នោះគឺ ទ្វីបអាស៊ីមានអនុតំបន់ធំៗជាច្រើនដូចជា អាស៊ីបូព៌ា អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង អាស៊ីកណ្ដាល និងមជ្ឈិមបូព៌ា ដែលជាទីប្រជុំប្រទេសមានអំណាចធំៗដែលទន្ទឹមនឹងសហការគ្នាក៏ប្រកួតប្រជែងគ្នាយ៉ាងស្រួចស្រាវលើវិស័យសេដ្ឋកិច្ច និងយោធា។ ការណ៍ទាំងនេះជម្រុញឲ្យមានការកើនឡើងនូវបញ្ហាសន្តិសុខសហសម័យ ទាំងសន្តិសុខបែបប្រពៃណី និងមិនមែនប្រពៃណី ដែលអាចគំរាមកំហែងយ៉ាងធ្ងន់ធ្ងរលើសន្តិភាព សន្តិសុខ និងវិបុលភាពរួមមិនត្រឹមតែរបស់អាស៊ីខ្លួនឯង តែក៏ពាក់ព័ន្ធដល់ដៃគូខាងក្រៅរបស់អាស៊ីដូចជាសហរដ្ឋអាម៉េរិក អឺរ៉ុប និងបណ្ដាប្រទេសសម្ព័ន្ធមិត្តរបស់ពួកគេ។

## ស្ថានភាពសន្តិសុខសហសម័យនៅអាស៊ី

បញ្ហាសន្តិសុខបែបប្រពៃណីដែលកំពុងកើតមាននៅទ្វីបអាស៊ីមានចាប់តាំងពី ជម្លោះក្នុងដែនសមុទ្រចិនខាងត្បូងរវាងចិន និងរដ្ឋដើមបណ្ដឹងជាសមាជិកអាស៊ានមួយចំនួនដែលបង្កការរំខានដល់សេរីភាពនាវាចរណ៍ ប៉ះពាល់ដល់សណ្ដាប់ធ្នាប់ បទដ្ឋាន និងច្បាប់អន្តរជាតិ ហើយជាវិញ្ញាសារសោកល្បងសាមគ្គីភាពរបស់អាស៊ានទាំងមូល រហូតដល់បញ្ហាទំនាក់ទំនងនយោបាយការទូតរវាងចិន និងតៃវ៉ាន់ដែលរឹងរឹតតែស្មុគស្មាញឡើងដោយសារតែ "ភាពស្រពេចស្រពិលជាយុទ្ធសាស្ត្រ" របស់សហរដ្ឋអាម៉េរិក [៥៨]។ បន្ថែមលើនេះ បញ្ហាលុបបំបាត់កម្មវិធីអាវុធនុយក្លេអ៊ែរនៅឧបទ្វីបកូរ៉េបានបង្កការគំរាម កំហែងជាពិសេសដល់សន្តិសុខរបស់សម្ព័ន្ធមិត្តសហរដ្ឋអាម៉េរិកតួយ៉ាង កូរ៉េខាងត្បូង និងជប៉ុន ខណៈដែលជម្លោះក្នុងដែនសមុទ្រចិនខាងកើតបាន និងកំពុងរុញមហាអំណាចសេដ្ឋកិច្ចពិភពលោកទី២ (ចិន) ឲ្យប្រឈមនឹងមហាអំណាចសេដ្ឋកិច្ចពិភពលោកទី៣ (ជប៉ុន)។ មិនតែប៉ុណ្ណោះ វិបត្តិសង្គ្រាមស៊ីវិលនៅស៊ីរីបន្តបញ្ឆេះភាពតានតឹងរវាងសហរដ្ឋអាម៉េរិក និងរុស្ស៊ី នេះមិនទាន់គិតពីបញ្ហាលំហូរនៃជនភៀសខ្លួនទៅកាន់អឺរ៉ុបផង។ ក្នុងពេលជាមួយគ្នានេះ ការខកខានមិនអាចធ្វើបានតាមកិច្ចព្រមព្រៀងនុយក្លេអ៊ែរអ៊ីរ៉ង់កាន់តែធ្វើឲ្យរាំងស្ទះដល់ដំណើរការរក្សាស្ថិរភាព និងសន្តិភាពតំបន់ ក៏ដូចជារាំងស្ទះដល់ការផ្គត់ផ្គង់ប្រេងជាសកលផងដែរ។

ម្យ៉ាងទៀត អាស៊ីក៏នៅតែបន្តប្រឈមនឹងជម្លោះព្រំដែនអន្តរជាតិដែលមិនទាន់ដោះស្រាយទាក់ទងនឹងរដ្ឋនៅអាស៊ីអាគ្នេយ៍ ជម្លោះព្រំដែនរវាងឥណ្ឌា និងប៉ាគីស្ថាន ហើយនៅមានជម្លោះរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន ក៏ដូចជាចលនាបំបែករដ្ឋប្រដាប់អាវុធនៅភាគនិរតីមីយ៉ាន់ម៉ា និងភាគខាងត្បូងថៃ។ បើគ្មានការតាមដានត្រួតពិនិត្យហ្មត់ចត់ និងវិធានការណ៍ត្រឹមត្រូវ និងទាន់ពេលវេលាទេ បញ្ហាទាំងនេះអាចបង្កគ្រោះធ្ងន់ធ្ងរដល់ទំនុកចិត្តក្នុងតំបន់ក្នុងចំណោមរដ្ឋអាស៊ីដែលពាក់ព័ន្ធ និងដៃគូខាងក្រៅរបស់ខ្លួន ក៏ដូចជាផលប៉ះពាល់ដោយផ្ទាល់លើសន្តិសុខតំបន់ជារួមដែរ។

ទន្ទឹមនឹងនេះ បញ្ហាសន្តិសុខមិនមែនប្រពៃណីមួយចំនួនដែលកំពុងរាលដាលសព្វថ្ងៃនេះប្រៀបបានដូចជាដាវមុខពីរ ដោយម្យ៉ាងបាន និងកំពុងបំផ្លាញកាន់តែច្រើនឡើងនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសន្តិសុខមនុស្សជាតិក្នុងទ្វីបអាស៊ី ហើយម្យ៉ាងទៀតក៏ជម្រុញរដ្ឋដែលពាក់ព័ន្ធទាំងឡាយឲ្យស្វះស្វែងរកវិធានការណ៍ឆ្លើយតបរួមគ្នា។ ឧទាហរណ៍ដូចជា អំពើភេរវកម្ម ជាពិសេសការផ្ទុះឡើងនៃចលនាក្រុមរដ្ឋអ៊ីស្លាមជ្រុលនិយម អាយស៊ីស (ISIS) នៅមជ្ឈិមបូព៌ា និងផ្នែកខ្លះនៅអាស៊ីអាគ្នេយ៍ បានបង្កវិនាសកម្មរូបវ័ន្ត និងគ្រោះមហន្តរាយផ្នែកមនុស្សធម៌យ៉ាងធ្ងន់ធ្ងររួមមានលំហូរជនភៀសខ្លួនទ្រង់ទ្រាយធំទាំងក្នុងតំបន់ និងអន្តរតំបន់។ ការដួលរលំនៃពួក ISIS ក្នុងឆ្នាំ២០១៩ បានបង្វែរឥទ្ធិពលមកកាន់ក្រុមអាល់កៃដា (Al-Qaeda) និងបង្កើតភាពភ័យខ្លាចអំពីការវិលត្រឡប់នៃក្រុមភេរវកម្មបរទេសរបស់ ISIS មកកាន់ស្រុកកំណើតវិញដែលរួមបញ្ចូលទាំងនៅអាស៊ីអាគ្នេយ៍ផងដែរ [៥៩]។

លើសពីនេះ ជំងឺឆ្លង ឬជំងឺរាតត្បាតសកល ជាពិសេសការផ្ទុះរីករាលដាលនៃជំងឺកូវីដ-១៩ (Covid-19) នៅ

ប្រទេសចិននៅដើមឆ្នាំ២០២០ បាននាំឲ្យមានចត្តាឡីស័កទ្រង់ទ្រាយធំក្នុងប្រទេស និងក្នុងទ្វីបជាច្រើន ការកើនឡើងនៃការរើសអើងពូជសាសន៍ និងភាពអាក់រអួលផ្នែកសេដ្ឋកិច្ចគួរឲ្យកត់សម្គាល់។ បញ្ហានេះបានបន្ថែមភាពធ្ងន់ធ្ងរទាក់ទងនឹងការគំរាមកំហែងក្នុងតំបន់មកលើសន្តិសុខមនុស្សជាតិ និងបន្ថែមបន្ទុកថ្មីមួយទៀតពីលើបន្ទុកដែលមានស្រាប់ក្នុងបញ្ជីបញ្ហាសន្តិសុខមិនមែនប្រពៃណីដូចជា បម្រែបម្រួលអាកាសធាតុ ការបំផ្លាញបរិស្ថាន ការជួញដូរថ្នាំញៀន និងមនុស្ស ការទន្ទ្រានធនធានធម្មជាតិ សន្តិសុខស្បៀង និងថាមពល គ្រោះមហន្តរាយធម្មជាតិ និងសង្គ្រាមតាមប្រព័ន្ធទូរគមនាគមន៍ រួមទាំងការផ្សព្វផ្សាយព័ត៌មានមិនពិត។

## និម្មាបនកម្មសន្តិសុខបច្ចុប្បន្នរបស់អាស៊ី

ក្នុងបរិបទបច្ចុប្បន្ននេះ ច្បាស់ណាស់ដែលថាគ្មានរដ្ឋណាមួយអាចទប់ទល់នឹងភាពចាក់ស្រេះនៃបញ្ហាសន្តិសុខទាំងបែបប្រពៃណី និងមិនមែនប្រពៃណីបានតែឯកឯងទេ ដូច្នេះយន្តការនៃកិច្ចសហប្រតិបត្តិការរួមគ្នាជារឿងមិនអាចខ្វះបានឡើយ។ ហេតុនេះ បញ្ហាប្រឈមរួមទាំងនេះអាចដើរតួរជាបុរេលក្ខខណ្ឌជម្រុញឲ្យមានការបង្កើតឡើងនូវនិម្មាបនកម្មសន្តិសុខអាស៊ីប្រកបដោយបរិយាបន្ន[៦០]ដែលរួមមានដូចជា វេទិកាតំបន់អាស៊ាន (ARF) កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM) កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិអាស៊ានបូក (ADMM+) កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) និងគំនិតផ្តួចផ្តើមពាក់ព័ន្ធដទៃទៀតដែលបង្កើតឡើងដើម្បីដោះស្រាយបញ្ហាសន្តិសុខតំបន់ទាំងបែបប្រពៃណី និងមិនមែនប្រពៃណី។ ស្ថាប័នទាំងនេះធ្វើប្រតិបត្តិការមិនត្រឹមតែក្នុងកម្រិតរដ្ឋាភិបាល (Track I) ប៉ុណ្ណោះទេ តែក៏តាមរយៈក្រុមមន្ត្រីជំនាញ (Track II) ផងដែរ ហើយដែលប្រតិបត្តិការទាំងនេះអាចត្រូវបានជួយលើកកម្ពស់បន្ថែមដោយការគាំទ្រពីសំណាក់សភាដែលត្រូវបានពិភាក្សានៅចំណុចខាងក្រោម។ គួរឲ្យកត់សម្គាល់និម្មាបនកម្មដែលមានស្រាប់ក្នុងពេលបច្ចុប្បន្នស្ទើរទាំងអស់មានជាប់ពាក់ព័ន្ធជាមួយនឹងរដ្ឋដែលនៅអមសងខាងមហាសមុទ្រប៉ាស៊ីហ្វិច ដោយហេតុថា អនុតំបន់ដទៃទៀតក្នុងទ្វីបអាស៊ីពុំទាន់ឈានទៅបង្កើត ឬសម្រេចបាន គំនិតផ្តួចផ្តើមតំបន់ដែលមានលក្ខណៈជាក់ស្តែងនៅឡើយ។

## ទស្សនវិស័យរបស់អាស៊ីលើបញ្ហាសន្តិសុខ៖ វិធីបែបអាស៊ីចំពោះពហុភាគីនិយកម្ម

ខណៈដែលពហុភាគីនិយមមានសារៈសំខាន់ចំពោះសន្តិសុខតំបន់ គេមិនគួរបណ្តោយឲ្យវាប៉ះពាល់ដល់មជ្ឈភាពអាស៊ីឡើយ។ តួនាទីក្នុងការកំណត់ជោគវាសនារបស់ខ្លួន និងអធិបតេយ្យភាពនៅតែមានភាពសំខាន់ខ្លាំងបំផុត ដែលជាតម្លៃដក់ជាប់ជ្រៅក្នុងសរសៃឈាមនយោបាយរដ្ឋអាស៊ីទាំងអស់។ឧទាហរណ៍ចម្បងមួយគឺមជ្ឈភាពអាស៊ាន[៦១] ដែលក្នុងនោះវិធីបែបអាស៊ាន (សង្កត់ធ្ងន់លើការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង កិច្ចពិគ្រោះយោបល់ និងការសម្រេចចិត្តដោយការឯកភាពបែបកុងសង់ស៊ីស) ជាគោលការណ៍គ្រឹះសម្រាប់ស្ថាប័នពហុភាគីជាច្រើនក្នុងតំបន់ដូចជា អាស៊ានបូកបី (APT) កិច្ចប្រជុំអាស៊ីអឺរ៉ុប (ASEM) វេទិកាសន្តិសុខអាស៊ាន (ARF) និង កិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) ជាដើម។មជ្ឈភាពអាស៊ីអាចសម្រេចទៅបានលុះត្រាតែមានការប្រកាន់ខ្ជាប់នូវគោលការណ៍គម្រោងតំបន់ដែលមានលក្ខណៈ "ក្រៅផ្លូវការ" ឬ "ទន់" ដែលបង្កប់នូវលក្ខណៈជាក់លាក់មួយចំនួនដូចជា ការប្រកាន់យកអធិបតេយ្យភាពរដ្ឋធំជាងអំណាចស្ថាប័នតំបន់ ការយល់ពីគ្នាទៅវិញទៅមក និងភាពបត់បែន រួមទាំងភាពមានកម្រិតនៃកាតព្វកិច្ចផ្លូវច្បាប់ ដែលទាំងនេះផ្ទុយពីគម្រោងដែលមានលក្ខណៈ "ផ្លូវការ" ឬ "រឹង" របស់លោកខាងលិច[៦២]។ក្នុងន័យនេះ ការតាក់តែងគោលការណ៍ស្ថាប័នតំបន់គួរតែផ្សារភ្ជាប់ទៅនឹង "លក្ខខណ្ឌដែលត្រូវនឹងតំបន់" ឬអ្វីទៅដែលត្រូវនឹងតថភាពរបស់អាស៊ី ជាជាង "ការប្រៀបធៀបតំបន់ និងតំបន់" ដែលព្យាយាមប្រៀបធៀបវិធីបែបអាស៊ីទៅនឹងវិធីបែបលោកខាងលិច។ ប្រតិបត្តិការដ៏ប៉ិនប្រសព្វនៃប្រព័ន្ធពហុភាគីនិយមដែលសក្តិសមសម្រាប់អាស៊ីនេះ ជារឿងដ៏សំខាន់ដើម្បីឲ្យអាស៊ីអាចបត់បែនយ៉ាងប្រុងប្រយ័ត្នក្នុងចន្លោះមហាអំណាច ជាពិសេសសហរដ្ឋអាមេរិក និងចិនដើម្បីទាញយកប្រយោជន៍ជាតិ និងតំបន់ជាអតិបរិមា និងកាត់បន្ថយហានិភ័យក្នុងការក្លាយជារដ្ឋរណបជាអប្បបរមា ហើយស្របពេលជាមួយគ្នាចាំបាច់ត្រូវសង្កត់ធ្ងន់លើច្បាប់ និងបទដ្ឋាននានាដែលជាគន្លឹះក្នុងការរក្សាសណ្តាប់ធ្នាប់អន្តរជាតិ។

## តួនាទីបុរេសកម្មរបស់សភាក្នុងបរិបទ សន្តិភាព សន្តិសុខ និងវិបុលភាពរួម

ក្នុងនាមជាស្ថាប័នឯករាជ្យមួយដែលមានទំនួលខុសត្រូវលើផ្នែកនីតិកម្ម ការត្រួតពិនិត្យការអនុវត្តច្បាប់និងគោលនយោបាយ និងក្នុងភាពជាតំណាង សភាមានតួនាទីដ៏សំខាន់ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពរួម។ ក្នុងបរិបទនៃការគំរាមកំហែងសន្តិសុខបែបប្រពៃណី និងមិនមែនប្រពៃណីបច្ចុប្បន្នដែលប្រកបដោយថាមវន្ត និងភាពស្មុគស្មាញ វាជាពេលដ៏សំខាន់ដែលសភានៅអាស៊ីត្រូវមានភាពបុរេសកម្ម ដែលសំដៅដល់ការគ្រប់គ្រងស្ថានការណ៍ជាជាងប្រតិកម្មទៅនឹងស្ថានការណ៍ តាមរយៈការពង្រឹងតួនាទីដែលមានស្រាប់របស់ខ្លួន និងក្រសោបយកតួនាទីថ្មីៗបន្ថែម។

ទីមួយ សភានៅអាស៊ីមានភារកិច្ចចម្បងៗជាច្រើនដែលអាចរួមចំណែកក្នុងការកសាងគំរូនិម្មាបនកម្មសន្តិសុខ និងសមាហរណកម្មសេដ្ឋកិច្ចតំបន់។ ឧទាហរណ៍ សភាមានតួនាទីផ្តល់សច្ចាប័ន និងត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិ (ដែលឆ្លុះបញ្ចាំងពីផលប្រយោជន៍ជាតិរៀងៗខ្លួន) ត្រួតពិនិត្យការអនុវត្តគោលនយោបាយការបរទេស និងអនុម័តកញ្ចប់ថវិកាជាតិជាដើម។សភាក៏ទទួលខុសត្រូវក្នុងការធ្វើសេចក្តីស្នើច្បាប់ ពិនិត្យ និងអនុម័ត ច្បាប់ (ក្នុងនោះកម្រិតនៃសមត្ថកិច្ចមានភាពខុសៗគ្នាទៅតាមរដ្ឋ) ដើម្បីធានាសន្តិភាព និងស្ថិរភាពជាតិក្នុងប្រទេស ដែលអាចមានផលទាក់ទងខ្លាំងទៅដល់សន្តិសុខតំបន់។ ហេតុនេះ ដើម្បីមានភាពបុរេសកម្ម សភានៅអាស៊ីចាំបាច់ត្រូវពង្រឹងតួនាទីដែលមានស្រាប់ទាំងនេះតាមរយៈការកសាងសមត្ថភាពដើម្បីឈានទៅគ្រប់គ្រង និងកំណត់បរិយាកាសសន្តិសុខតំបន់ក្នុងកម្រិតខ្ពស់បំផុតតាមដែលអាចទៅរួច ជាជាងគ្រាន់តែឆ្លើយតបនឹងការគំរាមកំហែងដែលកើតឡើងរួចហើយ។

ទីពីរ ដើម្បីមានភាពបុរេសកម្ម សភានៅអាស៊ីក៏ត្រូវបន្សាំខ្លួនទៅនឹងតួនាទីថ្មីៗរួមមាន ការចូលរួមកាន់តែផុសផុលក្នុងការទូតសភា [៦៣] ដែលជាសកម្មភាពការទូតនានានៃសភាដើម្បីបំពេញបន្ថែមលើការទូតរបស់ស្ថាប័ននីតិប្រតិបត្តិ។ តាមរយៈវិធីនេះ សភាដែលមានភាពបុរេសកម្មអាចជ្រោមជ្រែងបណ្តាញការទូតបែបប្រពៃណីបានច្រើនដោយការប្រើប្រាស់បណ្តាញវេទិកាអន្តរសភាដែលកំពុងលូតលាស់ខ្លាំងដូចជា របស់សហភាពអន្តរសភា (IPU) អន្តរសភា អាស៊ាន (AIPA) និង សភាក្នុងតំបន់អាស៊ី (APA) ជាដើម។

## ពិពិធភាពនៃសភានៅអាស៊ី៖ សមត្ថភាព សមាសភាព និងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ

ពុំមានរដ្ឋណាមួយមានសភាពដូចគ្នាទៅនឹងរដ្ឋដទៃទេ ហើយសភានៅអាស៊ីក៏ដូច្នោះដែរ។ ពិពិធភាព ជាពាក្យដែលគេអាចប្រើដើម្បីពិពណ៌នាស្ថានភាពបច្ចុប្បន្នរបស់សភាក្នុងតំបន់នេះដោយផ្អែកលើកត្តាចំនួនបីគឺ សមត្ថភាព សមាសភាព និងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ។ ទីមួយ សភានៅអាស៊ីមានភាពខុសគ្នាបើផ្អែកលើកត្តាសេដ្ឋកិច្ចរបស់រដ្ឋរៀងៗខ្លួន ហើយគម្លាតសេដ្ឋកិច្ចទាំងនេះមានផលទាក់ទងទៅនឹងគម្លាតសមត្ថភាពរវាងសភានីមួយៗ ដោយហេតុថា សមត្ថភាពក្នុងការអនុម័តកញ្ចប់ថវិកាដោយសភាក្នុងគោលនយោបាយណាមួយពឹងផ្អែកដោយផ្ទាល់លើសមត្ថភាពសេដ្ឋកិច្ចរបស់រដ្ឋខ្លួន។ ទីពីរ សមាសភាពនៃគណបក្សនយោបាយក្នុងសភានីមួយៗក៏ខុសគ្នាអាស្រ័យទៅលើប្រព័ន្ធនយោបាយផ្សេងៗគ្នានៃរដ្ឋនីមួយៗ។ រដ្ឋខ្លះមានការបោះឆ្នោតសកលដែលបង្ហាញពីភាពចម្រុះនៃគណបក្សប្រកួតប្រជែងគ្នាច្រើន ឯរដ្ឋខ្លះមានការបោះឆ្នោតសកលដែលគ្របដណ្តប់ដោយបក្សតែមួយខណៈដែលរដ្ឋខ្លះទៀតពុំមានការបោះឆ្នោតសកលទេដោយមានបក្សតែមួយប៉ុណ្ណោះ។ ចុងក្រោយ សភានៅអាស៊ីក៏អាចបែងចែកទៅតាមក្របខ័ណ្ឌនៃរដ្ឋធម្មនុញ្ញដែលរួមមានប្រព័ន្ធប្រធានាធិបតីនិយម និងប្រព័ន្ធសភានិយម [៦៤]។ ប្រព័ន្ធប្រធានាធិបតីនិយមមានការបោះឆ្នោតពីរផ្សេងគ្នា ក្នុងនោះមួយសម្រាប់ជ្រើសរើសប្រមុខរដ្ឋាភិបាល និងមួយទៀតសម្រាប់សភា ដែលប្រព័ន្ធបែបនេះអាចបំបែកអំណាចរវាងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័ននីតិបញ្ញត្តិ។ ចំណែកប្រព័ន្ធសភានិយមវិញមានការបោះឆ្នោតតែមួយសម្រាប់សភា ហើយសភានោះនឹងធ្វើការបោះឆ្នោតជ្រើសតាំងប្រមុខរដ្ឋាភិបាលដែលមានទំនួលខុសត្រូវផ្ទាល់ចំពោះមុខសភា។

តាមអ្វីដែលគេអាចសន្និដ្ឋានបាន ភាពខុសគ្នាខាងលើដែលទាក់ទងនឹងសមត្ថភាព សមាសភាព និងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញ អាចបង្កឲ្យមានភាពខុសគ្នាចំពោះកម្រិតអំណាចឬសមត្ថកិច្ចសភាក្នុងការព្រាងពិនិត្យ និងអនុម័តច្បាប់។ ថាតើសភាអាចមានភាពបុរេសកម្មកម្រិតណា វាពឹងផ្អែកទៅលើកម្រិតនៃភាពខុសគ្នាទាំងនេះ។ សភាទាំងឡាយណាដែលស្ថិតក្នុងរដ្ឋដែលមានសេដ្ឋកិច្ចអភិវឌ្ឍខ្លាំងនឹងទទួលបានលក្ខខណ្ឌអំណោយផលច្រើនក្នុងអំណាចអនុម័តថវិកាជាតិរបស់ខ្លួន ខណៈសភាទាំងឡាយណាដែលស្ថិតក្នុងរដ្ឋប្រកាន់របបប្រធានាធិបតីនិយម និងប្រព័ន្ធបោះឆ្នោតពហុ

បក្សអាចមានតួនាទីកាន់តែសំខាន់ក្នុងនីតិកម្ម។ ភាពខុសគ្នាទាំងនេះ ដែលជាលទ្ធផលនៃកេរដំណែលនយោបាយ និងប្រវត្តិសាស្ត្ររបស់រដ្ឋនីមួយៗ ចាំបាច់ត្រូវលើកយកមកពិចារណានៅក្នុងកិច្ចពិភាក្សាអំពីពិធភាពនៃអភិក្រមដែលសភាអាចប្រើប្រាស់ក្នុងការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាពរួម។



ស្ពានមិត្តភាពឡាវ ថៃទី៣ ខេត្តណាខនប៉ាថុម សហគមន៍សេដ្ឋកិច្ចអាស៊ាន
Peemakon Rattanon

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ១.១០ បញ្ហាប្រឈមសន្តិសុខនៅអាស៊ី៖ ទស្សនៈបែបអឺរ៉ុប

នៅក្នុងបទវិចារណកថាផ្ទាល់ខ្លួនមួយចេញផ្សាយកាលពីខែឧសភា ឆ្នាំ២០១៨ ដោយ Federica Mogherini ដែលកាលនោះជាតំណាងជាន់ខ្ពស់នៃសហភាពអឺរ៉ុបទទួលបន្ទុកកិច្ចការបរទេស និងគោលនយោបាយសន្តិសុខ បានសរសេរថា “អឺរ៉ុប និងអាស៊ីមិនដែលជិតស្និទ្ធនឹងគ្នាដូចពេលនេះទេ [...] សន្តិសុខរបស់យើង គឺមានអន្តរទំនាក់ទំនងនឹងគ្នាទៅវិញទៅមក៖ ពួកយើងជួបប្រទះនឹងបញ្ហាប្រឈមដូចគ្នា ពួកយើងប្រឈមនឹងការគំរាមកំហែងស្រដៀងគ្នា ហើយពួកយើងក៏មានចំណាប់អារម្មណ៍រួមគ្នាក្នុងការថែរក្សាសន្តិភាពក្នុងតំបន់របស់យើង និងក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិជាសកលផងដែរ”[៦៥]។ លោកស្រីបានសំដៅលើការរីកចម្រើននៃកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខរវាងសហភាពអឺរ៉ុប និងអាស៊ី ជាពិសេសការកើនឡើងនៃភាពកាន់តែស្រដៀងគ្នា ក៏ដូចជាការរីកចម្រើននូវអន្តរទំនាក់ទំនងនៅក្នុងវិស័យសន្តិសុខ។

ជាយូរអង្វែងមកហើយ បញ្ហាសន្តិសុខដ៏រ៉ាំរ៉ៃនៅតំបន់អាស៊ីបូព៌ា និងជាពិសេសនៅតំបន់អាស៊ីអាគ្នេយ៍ មិនត្រូវបានគេផ្តល់សារៈសំខាន់ខ្លាំងទេនៅក្នុងយុទ្ធសាស្ត្រពិភពលោក។ ទោះបីជាពេលនេះ បញ្ហានេះត្រូវបានឯកភាពគ្នាយ៉ាងសុខដុមក្នុងការយកមកដាក់ជាបញ្ហាស្នូលនៅក្នុងកិច្ចពិភាក្សាស្តីពី សន្តិសុខរបស់អាស៊ី អឺរ៉ុបក៏ដោយ ក៏បញ្ហានេះនៅតែជាបញ្ហាតូចតាចតែប៉ុណ្ណោះសម្រាប់ការពឹងផ្អែកគ្នាទៅវិញទៅមករវាងអឺរ៉ុប និងអាស៊ី។ ជាមួយនឹងការងើបឡើងរបស់ចិន ដែលចិនកាន់តែមានអំណាចជាងមុន បញ្ហាទាក់ទងនឹងផលប្រយោជន៍ក៏មានកាន់តែខ្ពស់។ ការប្រែប្រួលនៃស្ថានការណ៍សង្គម និងសេដ្ឋកិច្ចបច្ចុប្បន្ននៅអាស៊ីអាចនឹងមានផលប៉ះពាល់មិនត្រឹមតែនៅតំបន់អាស៊ីប៉ុណ្ណោះទេ តែក៏ប៉ះពាល់ដល់សណ្តាប់ធ្នាប់ពិភពលោក ដែលជាហេតុធ្វើឲ្យមានការជះឥទ្ធិពលដល់ក្របខ័ណ្ឌដែលកំពុងដំណើរការនៅអឺរ៉ុប នៅអាស៊ី និងនៅទីកន្លែងផ្សេងទៀត។ ដូច្នេះ ដូចដែលត្រូវបានបង្ហាញនៅក្នុងបញ្ហាដ៏ពិបាកនិងស្មុគស្មាញនៃជម្លោះដែនសមុទ្រចិនខាងត្បូង “បញ្ហាសន្តិសុខនៅអាស៊ីលែងជាបញ្ហារបស់អាស៊ីតែម្នាក់ឯងទៀតហើយ”។ ការគ្រប់គ្រងបញ្ហានៅតែស្ថិតក្រោមទំនួលខុសត្រូវរបស់អាស៊ី ប៉ុន្តែអឺរ៉ុបត្រូវតែចាំមើល ហើយនៅពេលណាដែលអាចធ្វើទៅបាន នោះសហភាពអឺរ៉ុបនឹងចូលរួមចំណែកដើម្បីកាត់បន្ថយបញ្ហាសន្តិសុខទាំងនេះនៅអាស៊ី។

## ស្វ័យភាពរបស់អាស៊ីក្រោមជម្រកយុទ្ធសាស្ត្ររបស់អាមេរិក

បញ្ហាសន្តិសុខចម្បងៗនៅអាស៊ី ស្ទើរតែមិនបានផ្លាស់ប្តូរចាប់តាំងពីចប់សង្គ្រាមត្រជាក់មក។ ភាពងាយរងគ្រោះនៃសេដ្ឋកិច្ច ភាពផុយស្រួយផ្នែកនយោបាយ និងភាពមិននឹងនរនៃអភិបាលកិច្ច រួមជាមួយនឹងបញ្ហាជនជាតិភាគតិចជាដើម តែងតែប៉ះពាល់ដល់ផ្នែកធំៗនៃអាស៊ី ហើយនិងស្ថិរភាពក្នុងតំបន់ ជាក់ស្តែងដូចឃើញច្បាស់ពីបញ្ហាភេរវកម្ម ការបំបែកខ្លួននិងការបះបោរប្រដាប់អាវុធ ចោរសមុទ្រនិងការបំផ្លាញធនធានធម្មជាតិ និងសូម្បីតែការជួញដូរគ្រឿងញៀន។ ស្រដៀងគ្នានេះ បញ្ហាជម្លោះព្រំដែនក៏មិនមែនជាបញ្ហាថ្មីសម្រាប់តំបន់ដែរ [J]។ ទាំងអស់នេះនៅតែចាត់ទុកជាជាបញ្ហាតូចតាច ដរាបណាបញ្ហាទាំងនេះត្រូវបានទុកដោះស្រាយតែត្រឹមកម្រិតក្នុងប្រទេសនៅអាស៊ីអាគ្នេយ៍។ បញ្ហាទាំងនេះមិនបានធ្វើឲ្យរាំងស្ទះទេ តែពេលខ្លះបានជួយជម្រុញដល់ដំណើរការធ្វើសមាហរណកម្មតំបន់។ បញ្ញវន្តអាម៉េរិក Marvin C. Ott បានសង្កេតឃើញថា “រដ្ឋនៅអាស៊ីអាគ្នេយ៍បាននឹងកំពុងអភិវឌ្ឍស្ថាប័នតំបន់ និងគំរូអន្តរកម្មដែលបានធ្វើឲ្យតំបន់នេះកាន់តែមានភាពស៊ីសង្វាក់គ្នា ហាក់ដូចជាស្ថាប័ននយោបាយ សេដ្ឋកិច្ច និងសន្តិសុខតែមួយ ដែលលើសឆ្ងាយពីកម្រិតដែលមាននៅកន្លែងដទៃ ក្នុងពិភពអាហ្វ្រិក-អាស៊ី” [៦៦]។ នៅអាស៊ីអាគ្នេយ៍ដែលជាតំបន់មិនធ្លាប់ជួបប្រទះនឹងការគំរាមកំហែងពីបញ្ហាសន្តិសុខធំៗទាំងពីខាងក្នុងឬពីខាងក្រៅតំបន់តាំងពីពេលចប់សង្គ្រាមត្រជាក់ រាល់ជម្លោះដែលកើតឡើងត្រូវបានដោះស្រាយតាមរយៈយន្តការគ្រប់គ្រងដោយសន្តិវិធី។ វេទិកាតំបន់អាស៊ាន (ARF) បានបង្កើតឡើងនៅឆ្នាំ ១៩៩៤ ហើយអស់រយៈកាលដ៏យូរមកហើយ ដែលស្ថាប័នសន្តិសុខរបស់អាស៊ានមួយនេះមានគោលដៅចម្បងគឺ “ការជំរុញកិច្ចសន្ទនានិងកិច្ចពិគ្រោះយោបល់ប្រកបដោយការស្ថាបនាលើបញ្ហានយោបាយ និងសន្តិសុខ ដែលជាប្រយោជន៍និងជាកង្វល់” និងដើរតួក្នុងការរួមចំណែកកសាងទំនុកចិត្ត និងការទូតបែបការពារក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក [៦៧]។ សហរដ្ឋអាម៉េរិកបានធានាឲ្យមានសណ្តាប់ធ្នាប់តំបន់ដែលនឹងផ្តល់ឲ្យអាស៊ីនូវបរិយាកាសនយោបាយ និងស្វ័យភាពក្នុងការធ្វើសកម្មភាពដោះស្រាយបញ្ហាសន្តិសុខមិនមែនយុទ្ធសាស្ត្រដោយខ្លួនឯង។

## ចាប់ពីតំបន់ដល់សកលលោក៖ ការងើបឡើងរបស់ចិន និងអន្តរជាតូនីកម្មបញ្ហាសន្តិសុខរបស់អាស៊ី

ការកើនឡើងនៃអំណាចរបស់ចិនមិនបាននាំឲ្យមានការកែសម្រួលស្ថាប័នតំបន់ទេ ប៉ុន្តែបាននាំឲ្យមានការផ្លាស់ប្តូរទាំងស្រុង (ទោះបីជាបន្តិចម្តងៗ) នូវបរិបទនៃដំណើរការប្រតិបត្តិ។ ទសវត្សរ៍ដំបូងនៃសតវត្សរ៍ទី២១ គេឃើញមានការធ្វើអន្តរជាតូនីយកម្មបន្តិចម្តងៗនូវបញ្ហាសន្តិសុខដែលជាការបារម្ភរបស់តំបន់។ ភាពកាន់តែមានទំនុកចិត្ត និងក្លាហានរបស់ចិនបាននាំឲ្យចិនឈានទៅទាមទារអធិបតេយ្យភាពរបស់ខ្លួននៅលើដែនសមុទ្រចិនខាងត្បូងស្ទើរតែទាំងមូលដែលធ្វើឲ្យដើមបណ្តឹងដែលជាគូប្រកួតប្រជែង (ប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន កោះតៃវ៉ាន់និងវៀតណាម) មានការខឹងសម្បារ។ ការកើតមានជម្លោះដែនទឹកទ្វេភាគីនៅក្នុងអាស៊ានមិនបានបញ្ចប់នោះទេប៉ុន្តែត្រូវបានគេបញ្ចូលទៅជាបញ្ហាធំមួយដែលប្រឆាំងនឹងចិន និងបណ្តារដ្ឋជាសមាជិកអាស៊ានមួយចំនួន។

ម៉្យាងទៀត ការដាក់មូលដ្ឋានទ័ពនៅកោះ Paracel និងSpratly ដែលចិនបានបោះទីតាំងចំនួន២០ និង ៧ រៀងគ្នានៅទីនោះ [៦៨] បានធ្វើឲ្យកាន់តែរីកសាយភាយនូវសក្តានុពលនៃជម្លោះនេះ និងបានធ្វើឲ្យមានការជំរុញបញ្ហានេះទៅក្នុងការដោះស្រាយកំរិតអន្តរជាតិក្នុងពេលតែមួយ។ ចិនមិនត្រឹមតែជំទាស់នឹងការបកស្រាយនៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS) លើបញ្ហានានាដូចជាការគ្រប់គ្រងកម្លាំងយោធានៅក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) ឧទាហរណ៍នៅពេលដែលគេផ្តល់និយមន័យចង្អៀតនៃ “សេរីភាពក្នុងការធ្វើនាវាចរណ៍” ប៉ុណ្ណោះទេ ប៉ុន្តែចិនក៏ប្រឆាំងផងដែរទៅនឹង គោលការណ៍គ្រឹះនៃច្បាប់អន្តរជាតិ ឧទាហរណ៍ដូចជាការលើកឡើងនូវ “សិទ្ធិជាប្រវត្តិសាស្រ្ត”។ នៅក្នុងដំណើរការនេះ ចិនបានបង្កើតនូវភាពមិនប្រាកដប្រជា ចំពោះអ្វីដែលធ្លាប់តែអាចដឹងមុនបានតាមរយៈនីតិរដ្ឋ។ ភាពមិនប្រាកដប្រជានេះបានកើតមានឡើងនៅគ្រប់ទីកន្លែង រួមទាំងនៅអឺរ៉ុបផងដែរ។

> “ អន្តរជាតូនីយកម្មនៃបញ្ហាសន្តិសុខដែលជាការព្រួយបារម្ភរបស់តំបន់បានកើតមានឡើងសន្សឹមៗនៅក្នុងទសវត្សរ៍ដំបូងនៃសតវត្សរ៍ទី២១ ។ ”

បញ្ហាសន្តិសុខនៅអាស៊ីលែងត្រូវបានកម្រិតនៅត្រឹមតែបញ្ហានៅក្នុងអាស៊ីទៀតហើយ។

## បញ្ហាប្រឈមចំពោះពហុភាគីនិយម និងការបែកចែកប៉ូលម្ខាងម្នាក់ខាងចិន និងអាម៉េរិក (SINO-US POLARIZATION)៖ អាស៊ីបាត់បង់ភាពម្ចាស់ការអនាគតយុទ្ធសាស្រ្តរបស់ខ្លួន

កត្តាបន្ថែមលើសពីនេះទៀតគឺ ជាពិសេសទាក់ទងនឹងភាពផ្ទុយគ្នារវាងចិន និង អាម៉េរិក (SINO-US) និងបញ្ហាប្រឈមរួមនៃពហុភាគីនិយមដែលឥឡូវកំពុងរួមចំណែកក្នុងការធ្វើអន្តរជាតូបនីយកម្មនៃបញ្ហាសន្តិសុខរបស់អាស៊ី និងធ្វើឲ្យអាស៊ីបាត់បង់នូវសិទ្ធិគ្រប់គ្រងយុទ្ធសាស្រ្តអនាគតរបស់ខ្លួន។ ការប្រជែងគ្នារវាងស៊ីណូ-អាម៉េរិកកំពុងកើនឡើង ហើយភាពផ្ទុយពីគ្នាក្នុងតំបន់បន្តិចម្តងៗកំពុងតែបង្វែរគ្រប់បញ្ហាទាំងអស់ទៅជាល្បែងដែលមានតែឈ្នះ និងចាញ់ (zero-sum game) ដែលគ្រប់តួអង្គនីមួយៗត្រូវបានបង្ខំចិត្តធ្វើការសម្រេចចិត្តជ្រើសរើសគាំទ្រភាគីមួយណាដែលស្ថានភាពនេះធ្វើភាពស្អិតរមួតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ចុះខ្សោយ និងបង្កើតឲ្យមានភាពតានតឹងប្រឈមទៅនឹងអាទិភាពរៀងៗខ្លួនរបស់ប្រទេសនីមួយៗ។

ភាពផ្ទុយគ្នាក្នុងតំបន់នៅចន្លោះរវាងផលប្រយោជន៍ចិន និងសហរដ្ឋអាម៉េរិក គឺបានធ្វើឲ្យកាន់តែមានបញ្ហាប្រឈមចំពោះពហុភាគីនិយម៖ តាមរបៀបផ្សេងៗគ្នា មហាអំណាចយក្សទាំងពីរនៃតួអង្គក្នុងទំនាក់ទំនងអន្តរជាតិកំពុងធ្វើឲ្យស្ថាប័នពហុភាគីនិយមចុះខ្សោយយ៉ាងឆាប់រហ័ស។ សហរដ្ឋអាម៉េរិកបានព្រងើយកន្តើយទៅនឹងអាស៊ាន និងស្ថាប័នអាស៊ាន[K] ហើយព្យាយាមប្រើទំនាក់ទំនងទ្វេភាគី ដែលអាម៉េរិកអាចទទួលបានផលប្រយោជន៍ដោយសារអតុល្យភាពនៃអំណាច។ ដោយឃើញដូច្នេះ ចិនកាន់តែមានភាពសកម្មចំពោះទំនាក់ទំនងជាមួយអាស៊ាន។ ក្រុងប៉េកាំងបានវិនិយោគក្នុងទំនាក់ទំនងជាមួយស្ថាប័នអាស៊ាន និងកំពុងទាញយកផលចំណេញសេដ្ឋកិច្ចពីការវិនិយោគរបស់ខ្លួននៅក្នុងរដ្ឋសមាជិកអាស៊ានមួយចំនួន ធ្វើឲ្យសមាគមនេះលែងមានភាពសំខាន់ ដើម្បីបែងចែកតំបន់នេះតាមន័យនយោបាយ និងដើម្បីកម្រិតសមត្ថភាពអាស៊ានក្នុងការប្រឆាំងនឹងគោលនយោបាយចិន និងខិតខំប្រឹងប្រែងធ្វើឲ្យតំបន់នេះក្លាយជាតំបន់ថាមវន្តគំរូទៅតាមបំណងប្រាថ្នារបស់ខ្លួន។

លើសពីនេះទៀត ចំណុចទំនាញកណ្ដាលរបស់អាស៊ីអាគ្នេយ៍កំពុងតែរំកិលបន្តិចម្ដងៗចេញក្រៅតំបន់។ ជាលទ្ធផល ករណីនេះនាំឲ្យមានការប៉ះពាល់ជាអវិជ្ជមានធ្ងន់ធ្ងរដល់មជ្ឈភាពអាស៊ានដែលត្រូវបានគេយល់ឃើញថាជាយន្តការសម្រេចចិត្តមួយដែលពឹងផ្អែកលើការឯកភាពតាមបែបកុងសង់ស៊ីសរបស់អាស៊ាន ដែលយន្តការនេះបាននាំឲ្យមានការបញ្ឈប់យ៉ាងមានប្រសិទ្ធិភាពនូវគំនិតប៉ុនប៉ងធ្វើអនុត្តរភាពទាំងអស់ក្នុងតំបន់។ អាទិភាពផ្នែកសន្តិសុខរបស់អាស៊ី និងនម្មាបនកម្មសន្តិសុខត្រូវបានធ្វើស្ថាបនីយកម្មបន្ថែមក្នុងអំឡុងពេលតែមួយជាមួយនឹងការបង្កើតកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (EAS) [L] ក្នុងឆ្នាំ២០០៥ និងបន្ទាប់មកការបង្កើតកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការពារជាតិបូក (ADMM Plus)[M] នៅឆ្នាំ២០១០។ ប៉ុន្តែស្ថាប័នថ្មីទាំងនេះកំពុងក្លាយជាចំណាប់ខ្មាំងរបស់ការប្រកួតប្រជែងឥទ្ធិពលពិភពលោករវាងសហរដ្ឋអាម៉េរិក និងចិន។

ការជជែកដេញដោលជុំវិញទស្សនាទានអំពី ឥណ្ឌូ-ប៉ាស៊ីហ្វិក បានបង្ហាញពីភាពលំបាកដែលប្រទេសនៅអាស៊ីបូព៌ាកំពុងប្រឈមនាពេលបច្ចុប្បន្ន និងភាពមានកម្រិតនៃមធ្យោបាយដែលអាចអោយពួកគេគេចចេញពីភាពលំបាកនេះបាន។ ដោយត្រូវរងសម្ពាធក្នុងការជ្រើសរើសរវាងចិន និងសហរដ្ឋអាម៉េរិក ប្រទេសនៅអាស៊ីបូព៌ាបានគាំទ្រទស្សនាទានអំពី ឥណ្ឌូ-ប៉ាស៊ីហ្វិក ដើម្បីរក្សានូវទំនាក់ទំនងជាមួយអាម៉េរិក ប៉ុន្តែត្រូវបកស្រាយទៅតាមវិធីបរិយាបន្នផ្ទាល់របស់ពួកគេ ដើម្បីជៀសវាងការប្រឆាំងនឹងចិន និងការពារខ្លួនទប់ទល់នឹងផលប៉ះពាល់ជាអវិជ្ជមាននានាពីការប្រកួតប្រជែងរវាងស៊ីណូ-អាម៉េរិក។ ទោះជាយ៉ាងណា យុទ្ធសាស្ត្រឥណ្ឌូ-ប៉ាស៊ីហ្វិកទាំងអស់ស្ថិតនៅដំណាក់កាលដំបូងនៅឡើយ ហើយផលប៉ះពាល់មកលើថាមវន្តតំបន់ក៏មិនទាន់ច្បាស់លាស់ដែរ។

## តើបញ្ហាសន្តិសុខបរិស្ថាន គឺជាកត្តានាំឲ្យមានការផ្លាស់ប្តូរចម្បង និងនាំងស្រុងឬ?

នៅក្នុងបរិបទនេះ លក្ខណៈថ្មី និងសំខាន់របស់សន្តិសុខមានដូចជាសន្តិសុខបរិស្ថានអាចផ្ដល់ឲ្យអាស៊ីវិញនូវភាពប្រកបដោយបរិយាបន្នដែលខ្លួនកំពុងតែបាត់បង់។ បម្រែបម្រួលអាកាសធាតុជាឧទាហរណ៍នៃមេគុណនៃការគំរាមកំហែងមន្ថែម។ បញ្ហានេះបាននាំឲ្យមានការរៀបចំផែនទីឡើងវិញ ធ្វើឲ្យមានបម្លាស់ទីលំនៅប្រជាពលរដ្ឋ បង្កើតប្រភពថ្មីនៃភាពតានតឹង និងធ្វើឲ្យផលប៉ះពាល់យ៉ាងខ្លាំងដល់ហេដ្ឋារចនាសម្ព័ន្ធ។ ការគំរាមកំហែងដល់ ជីវចម្រុះបរិស្ថានសមុទ្រ ឬការបង្កដោយផ្ទាល់ និងដោយប្រយោលសុទ្ធតែផ្ដល់នូវផលវិបាកស្រដៀងគ្នា។ ពិតណាស់ ការគំរាមកំហែងដល់សន្តិសុខបរិស្ថានប៉ះពាល់ដល់គ្រប់ផ្នែកទាំងអស់នៃសន្តិសុខ។ ជាឧទាហរណ៍អ្នកជំនាញទទួលស្គាល់ថា ទ្វីបអាស៊ីនឹងស្ថិតក្នុងចំណោមតំបន់ដែលរងផលប៉ះពាល់ខ្លាំងបំផុតពីបម្រែបម្រួលអាកាសធាតុ។ ទីក្រុងនៅតាមបណ្ដាយឆ្នេរសមុទ្រទាបៗនៅប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ជាច្រើន និងប្រជាជនរាប់លាននាក់ដែលរស់នៅទីនោះ គឺងាយរងគ្រោះជាពិសេស។

ទោះបីជាយ៉ាងណាក៏ដោយ ក៏បញ្ហាសន្តិសុខបរិស្ថានតែងតែជាបញ្ហាឆ្លងដែន ហើយដំណោះស្រាយ គឺជាកិច្ចខិតខំប្រឹងប្រែងរួម។ ការការពារបរិស្ថានសមុទ្រ(MEP) គឺជាឧទាហរណ៍មួយ។ មានការប៉ាន់ស្មានថា ស្ថានភាពនៃអត្រាសឹករិចរិលនៃថ្មប៉ប្រះទឹកក្នុងសមុទ្រចិនខាងត្បូងដែលជាប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណៈចម្រុះជាងគេនៅលើពិភពលោក និងផ្ដល់ជម្រកដល់ទៅ៧៦% នៃប្រភេទសត្វសមុទ្រលើពិភពលោក និង៣៧% នៃប្រភេទត្រីប៉ប្រះទឹក នឹងនាំឲ្យរដ្ឋដែលនៅជាប់សមុទ្រអាចនឹងខាតបង់សក្ដានុពលសេដ្ឋកិច្ចប្រហែល ៥,៧ពាន់លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ[៦៩]។ ផែនការគោលឆ្នាំ២០២៥ នៃសហគមន៍សង្គម-វប្បធម៌អាស៊ាន បានលើកទឹកចិត្តរដ្ឋសមាជិក “លើកកម្ពស់កិច្ចសហប្រតិបត្តិការដើម្បីការពារ ស្តារឡើងវិញ និងប្រើប្រាស់តំបន់ឆ្នេរសមុទ្រ និងបរិស្ថានសមុទ្រប្រកបដោយចីរភាព...”[៧០] ប៉ុន្តែនៅតែគ្មានការយកគោលការណ៍នេះទៅបញ្ចូលក្នុងស្ថាប័ន ដែលនិយាយពីរបៀបទាក់ទងរបស់អាស៊ានជាមួយដៃគូពាក់ព័ន្ធសំខាន់ៗ ដូចជាចិន ដើម្បីអនុវត្តផែនការនេះទេ។ ទោះបីការការពារបរិស្ថានសមុទ្រគឺជាទិដ្ឋភាពសំខាន់សម្រាប់ការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុក៏ដោយក៏នៅមិនទាន់មានអនុសញ្ញា ឬស្ថាប័នកំរិតតំបន់ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងបរិស្ថានសមុទ្ររួមគ្នានៅឡើយទេ ទោះបីមានយន្តការកិច្ចសហប្រតិបត្តិការពហុភាគីក្នុងតំបន់ជាច្រើនហើយក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ការការពារសន្តិសុខបរិស្ថានបានផ្ដល់ឲ្យមាននូវឱកាសក្នុងការអនុវត្តអភិក្រមនៃកិច្ចសហប្រតិបត្តិការដែលមិនមានលក្ខណៈនយោបាយដើម្បីដោះស្រាយបញ្ហាសមុទ្រចិនខាងត្បូង ដោយពឹងផ្អែកលើមូលដ្ឋានបច្ចេកទេស និងនៅតែជាអ្វីដែលមានតម្លៃសម្រាប់ការធ្វើបន្តទៅមុខទៀត។

## តួនាទីរបស់សភា

សភាមានទំនួលខុសត្រូវរបស់ខ្លួនក្នុងការគិតគូរពីនម្មាបនកម្មសន្តិសុខនៅអាស៊ី។ តួនាទីដំបូងបង្អស់របស់សភាគឺត្រូវធានាថា កិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាដោយរដ្ឋាភិបាលនឹងអនុលោមទៅតាមផលប្រយោជន៍ជាតិ និងកាតព្វកិច្ចអន្តរជាតិ។ សភាក៏មានតួនាទីគ្រប់គ្រង និងត្រួតពិនិត្យលើការអនុវត្តគោលនយោបាយការបរទេស និងគោលនយោបាយសន្តិសុខដែលអនុវត្តដោយរដ្ឋាភិបាលតាមរយៈគណៈកម្មការកិច្ចការការបរទេស និងការពារជាតិរបស់សភាដែរ។សម្រាប់គោលដៅនេះ សភាមានឧបករណ៍ក្នុងដៃដ៏មានអំណាចមួយគឺការអនុម័តកញ្ចប់ថវិកាសម្រាប់ក្រសួងពាក់ព័ន្ធ។

សភាក៏មានតួនាទីក្នុងការអប់រំដល់គណបក្សនយោបាយធំអំពី កិច្ចការការបរទេស និងបញ្ហាសន្តិសុខ។ ការជជែកដេញដោលអំពី នយោបាយជាសាធារណៈបានជួយឲ្យគេអាចយល់កាន់តែច្បាស់ពីចំណុចគន្លឹះនៅក្នុងគោលនយោបាយការបរទេសជាតិ និងបានចូលរួមផ្តល់ព័ត៌មានបន្ថែមដល់សង្គមអំពី បញ្ហាដែលប៉ះពាល់ដល់សន្តិសុខជាតិ និងតំបន់ក៏ដូចស្ថានភាពពាក់ព័ន្ធនឹងការឆ្លើយតបរបស់រដ្ឋាភិបាលទៅលើបញ្ហាទាក់ទងនឹងគោលនយោបាយការបរទេស និងសន្តិសុខ។ ធ្វើដូចនេះ សភាក៏នឹងមានសមត្ថភាពក្នុងការសម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនៅថ្នាក់ជាតិផងដែរ។ អាស្រ័យហេតុនេះ ក្នុងករណីអាស៊ី និងអាស៊ានជាពិសេស សភាក៏អាចមានសមត្ថភាពសម្របសម្រួលការធ្វើសមាហរណកម្មតំបន់តាមរយៈការអនុវត្តសេចក្តីថ្លែងការណ៍និងកិច្ចព្រមព្រៀងនានាផងដែរ។តំណាងសភាមានភាពជាកាន់តែចម្រុះ នោះសភាកាន់តែខិតជិតប្រជាពលរដ្ឋ និងមានលទ្ធភាពអភិវឌ្ឍអភិក្រមនានាដែលពាក់ព័ន្ធគោលនយោបាយការបរទេសបានកាន់តែមានប្រសិទ្ធភាព។

ជាចុងក្រោយ សភាក៏អាចធ្វើការទូតដោយខ្លួនឯងផ្ទាល់ផងដែរ។ ការទូតសភាគឺ “ជាឧបករណ៍បំពេញបន្ថែមដែលផ្តល់សក្តានុពលសម្រាប់សម្រេចលទ្ធផលដែលមើលទៅទំនងពិបាកសម្រេចបានតាមរយៈការទូតបែបប្រពៃណីឬតាមបណ្តាញការទូតធម្មតា” [៧១] ដូចដែលបានគូសបញ្ជាក់នៅមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤០ (AIPA)។ ការទូតសភាអាចបង្កើតដៃគូរឹងមាំដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងតំបន់ ជាពិសេសការពារការបែកបាក់នៃនម្មាបនកម្មសន្តិសុខអាស៊ាន។និយាយឲ្យចំការទូតសភា គឺជាការទូតនៃឥទ្ធិពល។ តាមរយៈបណ្តាញជាច្រើនផ្សេងៗ សមាជិក សមាជិកាសភាអាចប្រាស្រ័យទាក់ទងគ្នាពីសារ និងលើកកម្ពស់ផលប្រយោជន៍ជាតិនៃរដ្ឋនីមួយៗរៀងៗខ្លួន។ អាស្រ័យហេតុផលនេះ ការទូតសភាគួរតែជាឧបករណ៍ដែលគួរជ្រើសរើសមកប្រើដើម្បីដោះស្រាយជាមួយបញ្ហាសន្តិសុខបរិស្ថាន។

ដូច្នេះសភាអាចដើរតួយ៉ាងសំខាន់ក្នុងការថែរក្សាការឯកភាព និងភាពចូលរួម ក៏ដូចជាពហុភាគីនិយម ដែលអាស៊ីនៅមិនទាន់យកមកអនុវត្តបានស៊ីជម្រៅនៅឡើយ។ ដូច្នេះសភា គឺជាដៃគូសម្របសម្រួលដែលអឺរ៉ុបមិនអាចព្រងើយកន្តើយបានតែត្រូវបន្តពូនជ្រុំបន្ថែម។ ទោះបីជាភាពជាតំណាងសភាដ៏ស្មោះត្រង់របស់ប្រជាពលរដ្ឋខុសគ្នាពីប្រទេសមួយទៅប្រទេសមួយកម្រិតណាក៏ដោយ ក៏សភានៅតែជាឧបករណ៍ដ៏មានអំណាចមួយសម្រាប់រដ្ឋាភិបាលដើម្បីទប់ទល់នឹងសម្ពាធនៅចំកណ្តាលនៃមហាអំណាចដូចដែលអាស៊ីកំពុងជួបប្រទះដែរ។ ដូច្នេះហើយសភាអាចចូលរួមយ៉ាងសំខាន់ដើម្បីសន្តិសុខតំបន់ និងពិភពលោក។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានសភាកម្ពុជា (PIC)។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ ៖ https://www.pcasia.org ។

# ១.១១ ការត្រួតពិនិត្យរបស់សភាទៅលើការប្រើប្រាស់កម្លាំង និងកងកម្លាំងប្រដាប់អាវុធ

> “ គោលបំណងនៃសង្គ្រាម (ដែលជាសកម្មភាពនៃការប្រយុទ្ធប្រឆាំងគ្នាដោយប្រើសព្វាវុធ) គឺតែងតែមានពាក់ព័ន្ធនឹងរឿងនយោបាយ។ ដោយសារតែអត្ថន័យនៃពាក្យសង្គ្រាមមិនអាចត្រូវកំណត់បានជាក់លាក់ អត្ថន័យរបស់វាត្រូវបានទាញយកចេញពីតក្កវិជ្ជានៃគោលនយោបាយ ឬកំលាំងចលករពីខាងក្រៅ [៧២]។ ”

## សេចក្តីផ្តើម

គ្រប់សង្គ្រាមទាំងអស់គឺមានពាក់ព័ន្ធនឹងរឿងនយោបាយ។ សង្គ្រាមរវាងរដ្ឋនិងរដ្ឋ និងសង្គ្រាមផ្ទៃក្នុងតែងតែធ្វើឡើងដោយហេតុផល គោលដៅ និងគោលបំណងនយោបាយ។ គោលការណ៍ចម្បងមួយនេះនៃសង្គ្រាម ត្រូវបានកត់ត្រាទុកតាំងពីប្រវត្តិសាស្ត្រដំបូង និងនៅបន្តមានសុពលភាពរហូតដល់សព្វថ្ងៃនេះ [៧៣]។ ដោយសារសង្គ្រាមមានពាក់ព័ន្ធនឹងរឿងនយោបាយ ដូច្នេះវាអាចប៉ះពាល់ដល់ប្រជាពលរដ្ឋ និងប្រជាជាតិទាំងមូល។ ប្រហែលជាធ្លាប់មានពេលវេលាពិសេសណាមួយដែលស្តេច និងអ្នកកាន់អំណាចអាចធ្វើសង្គ្រាម ដោយគ្មានការគាំទ្រពីប្រជាពលរដ្ឋរបស់ខ្លួន ហើយក៏ប្រហែលជាធ្លាប់មានពេលណាមួយដែលសង្គ្រាមមិនបានបំផ្លាញដល់ប្រទេសជាតិទាំងមូលឡើយ។ សង្គ្រាមក្នុងសម័យឧស្សាហកម្មទំនើប និងផលប៉ះពាល់នៃសាកលភាវូបនីយកម្ម បានផ្លាស់ប្តូរផលប៉ះពាល់ទាំងនោះ ហើយប្រជាជាតិទាំងមូលកំពុងរងគ្រោះច្រើនជាងពីមុនដោយសារសង្គ្រាម និងជម្លោះអន្តរជាតិ។ ដូច្នេះការជះឥទ្ធិពលតាមបែបប្រជាធិបតេយ្យទៅលើការសម្រេចចិត្តប្រកបដោយយុទ្ធសាស្ត្រ និងការគ្រប់គ្រងលើកងកម្លាំងប្រដាប់អាវុធជាតិជារឿងមួយដ៏ចាំបាច់។

## ករណីនៃការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ

តាមការគិតបែបរំពឹងខ្ពស់បំផុត តួនាទីរបស់សភាគួរតែពង្រីក «ទៅគ្រប់វិស័យទាំងអស់នៃសកម្មភាពរបស់រដ្ឋាភិបាល ជាពិសេសពាក់ព័ន្ធនឹងការវិភាជថវិកា» រួមទាំងការផ្តល់អំណាចសំខាន់ៗក្នុងនាមជាសភា ដែលកើតឡើងពីការបោះឆ្នោត ដែលត្រូវមានអំណាចក្នុងការបោះឆ្នោតនិងអនុម័តច្បាប់ដែលស្នើដោយរដ្ឋាភិបាល។ នៅក្នុងន័យនេះ រដ្ឋាភិបាលមួយ «ដំណើរការក្រោមការត្រួតពិនិត្យពីសភា» [៧៤]។ ស្ថាប័នជាប់ឆ្នោតជាតំណាងរបស់ប្រជាពលរដ្ឋ ដូច្នេះហើយត្រូវដើរតួជំនួសប្រជាពលរដ្ឋ និងត្រូវបំពេញតួនាទីឲ្យមានតុល្យភាពអំណាចជាមួយដៃគូនីតិប្រតិបត្តិ។ អាស្រ័យហេតុនេះ ស្ថាប័ននីតិប្រតិបត្តិត្រូវរក្សាគណនេយ្យភាពចំពោះមុខសភានិងត្រូវបានត្រួតពិនិត្យដោយសភា។

ការធ្វើឲ្យមានតុល្យភាពនេះ គឺជាចំណុចស្នូលមួយនៃលទ្ធិប្រជាធិបតេយ្យ និងអាចចាត់ទុកជារឿងសំខាន់នៅពេលដែលត្រូវការប្រើប្រាស់កម្លាំងយោធា។ ប្រសិនបើគ្មានការត្រួតពិនិត្យបែបប្រជាធិបតេយ្យនេះទេ ស្ថាប័ននីតិប្រតិបត្តិអាចនឹងមានអំណាចលើគ្រប់រឿង និងអាចងាយធ្វេសប្រហែសមិនបានពិនិត្យទស្សនៈនិងយោបល់របស់ប្រជាពលរដ្ឋ រួមទាំងរបស់គណបក្សប្រឆាំងផងដែរ។ ដូច្នេះ បើគ្មានការត្រួតពិនិត្យពីសភា នោះប្រជាធិបតេយ្យសេរីពហុនិយមនឹងប្រឈមការគំរាមកំហែងនានាដែលកំពុងកើតមានឡើង។

ទោះបីជាបញ្ហាពាក់ព័ន្ធនឹងសន្តិសុខជាតិ «អាចមានលក្ខណៈពិសេស» [៧៥] ក៏ដោយ ក៏បញ្ហានេះនៅតែបង្ហាញច្បាស់ថា សភាគួរតែមានឥទ្ធិពលទៅលើទំនាក់ទំនងការបរទេសរបស់រដ្ឋ និងលើបញ្ហាទាក់ទងនឹងសន្តិសុខ និងការការពារជាតិ។

កាលពីអតីតកាល ស្តេច និងមេដឹកនាំផ្តាច់ការ គឺជាមេបញ្ជាការកំពូលរបស់កងកម្លាំងយោធា [៧៦]។ ហេតុនេះកងកម្លាំងទាំងនោះមានភាពស្មោះស្ម័គ្រចំពោះស្តេច មិនមែនចំពោះប្រជាពលរដ្ឋទេ។ ហេតុដូចនេះ កងកម្លាំងយោធាក៏ជាអ្នកដែលផ្តល់គ្រោះថ្នាក់ដល់ប្រជាពលរដ្ឋក្នុង

ស្រុកដែរ។ នេះជាហេតុផលដែល Machiavelli ដែលជាអ្នកវិភាគកិច្ចការនយោបាយនៃសម័យចន្លោះមជ្ឈឹមសម័យ និងសម័យទំនើប (Renaissance) បានលើកឡើងថា ជាតិមួយគប្បីលុបបំបាត់កងទ័ពឯកជន និងកងទ័ពស៊ីឈ្នួល ហើយជំនួសមកវិញដោយការបង្កើតកងទ័ពរបស់ប្រជាពលរដ្ឋ [៧៧]។ នៅសម័យទំនើបដែលមានការរីករាលដាលនៃរបបប្រជាធិបតេយ្យ និងការកើនឡើងនៃជំនឿចូលរួមក្នុងកិច្ចការនយោបាយ គេមិនគួរពឹងផ្អែកលើព្រះរាជានុវង្ស ក្រុមផ្តាច់ការ និងឥស្សរជន ជាអ្នកសម្រេចថាតើគួរប្រើប្រាស់កងកម្លាំងយោធា និងកងកម្លាំងប្រដាប់អាវុធរបៀបណា ឬថាតើគួរប្រើប្រាស់ ឬមិនប្រើប្រាស់នោះទេ។ ផ្ទុយទៅវិញ ការសំខាន់ គឺត្រូវឲ្យតំណាងរាស្ត្រដែលកើតឡើងពីការបោះឆ្នោតចូលរួមក្នុងសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការប្រើប្រាស់កម្លាំង និងកងទ័ព។

## ឧត្តមភាពនៃនយោបាយ

យោងទៅតាមអ្នកយុទ្ធសាស្ត្រដ៏ល្បីឈ្មោះ Colin S. Gray «គ្មាននរណាអាចជំទាស់អំពីឧត្តមភាពនៃនយោបាយលើបញ្ហាយោធានោះទេ»[៧៨]។ នេះមានន័យថា ប្រតិបត្តិការយោធា គឺធ្វើឡើងក្រោមគោលដៅ និងទិសដៅធំរបស់នយោបាយ។ ដូច្នេះកងកម្លាំងយោធាត្រូវរៀបចំទៅតាមរបៀបដែលឆ្លុះបញ្ចាំងពីគោលដៅ និងគោលបំណងនយោបាយដូចគ្នា។ មានសម័យកាលមួយនៅក្នុងប្រវត្តិសាស្ត្រ ដែលអ្នកនយោបាយត្រូវបានរំពឹងថា នឹងប្រគល់ការគ្រប់គ្រងកិច្ចការសង្គ្រាម និងការធ្វើសង្គ្រាមទៅឲ្យអ្នកជំនាញយោធា ដើម្បីឲ្យអ្នកជំនាញយោធាទាំងនោះអាចបំពេញប្រតិបត្តិការរបស់ពួកគេក្នុងបែបផែន «មិនពាក់ព័ន្ធនយោបាយ»។ ដោយសារគំនិតបែបនេះហើយទើបសង្គ្រាមក្នុងដើមសតវត្សរ៍ទី២០បានក្លាយជាការកាប់សម្លាប់ដោយគ្មានគោលបំណងច្បាស់លាស់ពោលគឺ«គ្មានគោលបំណងនយោបាយ» [៧៩]។

វាអាចជារឿងសមហេតុផលក្នុងការអះអាងថា សង្គ្រាម គឺជាបញ្ហាស្មុគស្មាញ និងតម្រូវឲ្យមានអ្នកជំនាញធ្វើការសម្រេចចិត្តទាក់ទងនឹងការរៀបចំ និងការប្រើប្រាស់កងកម្លាំងសន្តិសុខ និងយោធា។ វាក៏ប្រហែលជារឿងធម្មតា ដែលមនុស្សភាគច្រើនដែលចូលរួមបញ្ចេញគំនិតក្នុងការរៀបចំយុទ្ធសាស្ត្រយោធា គឺជាអ្នកជំនាញយោធា មិនមែនជាប្រជាពលរដ្ឋស៊ីវិល។ ទន្ទឹមនឹងនេះ អ្នកបញ្ញវន្តផ្នែកយុទ្ធសាស្ត្រ (បើសិនយើងអាចហៅដូច្នោះបាន) ដែលទទួលខុសត្រូវក្នុងការបង្កើតយុទ្ធសាស្ត្រគោលសម្រាប់ប្រទេសជាតិ ភាគច្រើនជាប្រជាពលរដ្ឋស៊ីវិល [៨០]។

តាមរយៈការធានាឲ្យបានថា កងកម្លាំងប្រដាប់អាវុធ និងសង្គ្រាមស្ថិតក្រោមការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ នោះគោលបំណងនយោបាយនៃសង្គ្រាមអាចត្រូវគ្រប់គ្រងបានយកមកប្រើដើម្បីប្រយោជន៍ផ្សេងៗ ដូច្នេះសន្តិសុខនៃប្រជាជាតិនឹងមិនចាំបាច់ឬប្រុងប្រយ័ត្នពីការគំរាមកំហែងទេ។ វាពិតជាមានសារៈសំខាន់ក្នុងការគ្រប់គ្រង(និងដាក់កម្រិត) លទ្ធភាពដែលអាចបង្កើតសង្គ្រាមបាន ដើម្បីរក្សាប្រជាជាតិមួយមិនឲ្យធ្លាក់ចូលក្នុងជម្លោះដោយសារតែអារម្មណ៍របស់បុគ្គលដែលជាអ្នកដឹកនាំ។

## ស្ថាប័ននីតិប្រតិបត្តិគួរដំណើរការក្រោមក្របខ័ណ្ឌគតិយុត្តិ

នៅឆ្នាំ១៩៨៣ ក្រោយពីការទម្លាក់គ្រាប់បែកនៅស្ថានទូតអាម៉េរិកប្រចាំទីក្រុង Beirut នៃប្រទេសលីបង់ ជាកន្លែងដែលកងកម្លាំងយោធាអាម៉េរិកច្រើនជាង២២០នាក់ត្រូវបានសម្លាប់ លោកប្រធានាធិបតី Ronald Reagan និងក្រុមសន្តិសុខជាតិរបស់គាត់បានពិភាក្សាពីការបន្តវត្តមាននៃកងកម្លាំងរបស់អាម៉េរិកនៅប្រទេសនោះ។ ទោះបីជាប្រធានាធិបតីរូបនេះមានការខឹងសម្បារលើការទម្លាក់គ្រាប់បែកនោះ រហូតដល់គាត់បានកត់ត្រាក្នុងកំណត់ហេតុប្រចាំថ្ងៃអំពីអារម្មណ៍របស់គាត់នៅពេលនោះថា «ស្អប់មនុស្សដែលអាចប្រព្រឹត្តអំពើដ៏ឃោរឃៅ ប៉ុន្តែកំសាកបែបនេះ» [៨១] គាត់មិនបានជ្រើសរើសធ្វើការសងសឹកដោយឯកតោភាគីទេ ប៉ុន្តែបានយកករណីនេះទៅសភាដើម្បីសុំការសម្រេច។ នៅក្នុងសៀវភៅកត់ត្រាប្រចាំថ្ងៃរបស់គាត់ លោកប្រធានាធិបតី Reagan បានសំដៅជាពិសេសដល់ច្បាប់ស្តីពីអំណាចសង្គ្រាម[៨២] និងរបៀបដែលគាត់ស្វែងរក «ការសម្រេចពីសភា ដើម្បីដាក់ពង្រាយទ័ពជើងទឹកនៅលីបង់»[៨៣]។ ទោះបី ជាប្រធានាធិបតីអាម៉េរិក ជាមេបញ្ជាការកំពូលនៃកងទ័ពយោធាអាម៉េរិកក៏ដោយ ក៏គាត់មិនមានអំណាចដូចស្តេចនិងមេដឹកនាំផ្តាច់ការកាលពីអតីតកាល ដើម្បីធ្វើសង្គ្រាមដោយមិនឆ្លងកាត់ការត្រួតពិនិត្យ និងតាមចិត្តនោះទេ[៨៤]។

ផ្ទុយទៅវិញ រដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាម៉េរិក បានចាត់ទុកការសម្រេចពីសភា មិនត្រឹមតែជាការទាមទារទេ តែជាកិច្ចការចាំបាច់បំផុតមុននឹងប្រធានាធិបតីអាម៉េរិកអាចដាក់ពង្រាយកងទ័ព និងប្រើកម្លាំងប្រដាប់អាវុធនៅបរទេសបាន [៨៥]។ នៅសហរដ្ឋអាម៉េរិក ការអនុវត្តបែបនេះ គឺត្រូវបានគេចាត់ទុកថាជាការត្រួតពិនិត្យរបស់សភា និងជាយន្តការផ្លូវការមួយក្រោមការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ។ប្រទេសប្រជាធិបតេយ្យទំនើបភាគច្រើនមានយន្តការស្រដៀងគ្នាក្នុងការអនុវត្តផងដែរ។

## ដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត និងការធ្វើផែនការយុទ្ធសាស្ត្រល្អបំផុត

ដើម្បីការពារការត្រួតពិនិត្យតាមបែបប្រជាធិបតេយ្យលើកម្លាំងយោធា និងការប្រើប្រាស់កងកម្លាំងយោធា សមាជិក សមាជិកាសភា ត្រូវតែជាផ្នែកមួយនៃដំណើរការក្នុងការធ្វើផែនការយុទ្ធសាស្ត្រ។ សមាជិក សមាជិកាសភាមិនត្រឹមតែគួរត្រូវបានអញ្ជើញចូលរួមក្នុងការធ្វើផែនការទេ តែថែមទាំងគួរធ្វើជាដៃគូចាំបាច់ និងជាអ្នកពាក់ព័ន្ធក្នុងដំណើរការនេះ។

អំណះអំណាងខ្លះបានលើកឡើងប្រឆាំងថាដំណើរការគ្រប់គ្រងកម្លាំងយោធាត្រូវធ្វើជាសម្ងាត់ ហើយយុទ្ធសាស្ត្រនេះជាបញ្ហាស្មុគស្មាញដែលអ្នកមិនមានជំនាញយោធាមិនអាចយល់បានឡើយ កុំថាឡើយដល់គ្រប់គ្រងលើបញ្ហានេះ។ ប៉ុន្តែទីមួយ បើទោះជាមានតម្រូវការច្បាស់លាស់ថា ផ្នែកណាមួយនៃយុទ្ធសាស្ត្រត្រូវការរក្សាការសម្ងាត់ក៏ដោយ តែមិនត្រូវយកចំណុចនេះជាលេសមិនឲ្យតំណាងរាស្ត្រដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋដឹងឮនោះទេ។ ផ្ទុយទៅវិញ ការរក្សាការសម្ងាត់នេះហើយដែលធ្វើឲ្យការត្រួតពិនិត្យបែបប្រជាធិបតេយ្យកាន់តែចាំបាច់។ ដើម្បីធានាបានថា ការធ្វើផែនការយុទ្ធសាស្ត្រនេះត្រូវបានរក្សាការពារបានល្អ អ្នកដែលចូលរួមក្នុងដំណើរការនេះត្រូវតែទទួលបានការត្រួតពិនិត្យ ដោយហេតុផលសន្តិសុខ។ ទីពីរ និងប្រហែលជាអំណះអំណាងធំបំផុតសម្រាប់ភាពជាតំណាងតាមបែបប្រជាធិបតេយ្យ នៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តនោះ គឺ «យុទ្ធសាស្ត្រមិនអាចត្រូវបានគូសវាសដោយពឹងផ្អែកតែទៅលើកត្តាយោធាទាំងស្រុងទេ» [៨៦]។ ជាការពិត ប្រជាពលរដ្ឋស៊ីវិលចាំបាច់ត្រូវចាត់ទុកជាអ្នកគ្រប់គ្រងលើយោធាដោយឥតលក្ខខណ្ឌ [៨៧]។ នេះពាក់ព័ន្ធទៅនឹងទំនាក់ទំនងដែលយើងលើកឡើងខាងលើថាសង្គ្រាមមានពាក់ព័ន្ធនឹងរឿងនយោបាយ។ មុខងារនយោបាយនៃសង្គ្រាមត្រូវតែនៅពីមុខជានិច្ច។

ភាពជាតំណាងតាមបែបប្រជាធិបតេយ្យនៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្តអាចប្រព្រឹត្តទៅបានក្នុងរបៀប ខុសប្លែកគ្នា ប៉ុន្តែមិនត្រូវទទួលបានការមើលស្រាលទេ។ ឧទាហរណ៍៖ គួរតែមានគណៈកម្មាធិការ ឬគណៈរដ្ឋមន្ត្រីពិសេសមួយដែលមានសមាសភាពពីបុគ្គលដែលជាប់ឆ្នោតដើម្បីតំណាងឲ្យសភាតំណាងរាស្ត្រ ឬសភាជាតិ។ នៅក្នុងគណៈកម្មាធិការនោះ គ្រប់បញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងគោលនយោបាយការពារជាតិ និងយុទ្ធសាស្ត្រជាតិត្រូវតែយកមកជជែកដេញដោល។ ទោះបីជាពេលនោះមានទម្រង់ទីពីរ ឬទីបី នៃការធ្វើសេចក្ដីសម្រេចចិត្តពាក់ព័ន្ធនឹងការប្រើប្រាស់កងកម្លាំងទ័ពជាក់ស្ដែង ឬទោះបីជាគណៈកម្មាធិការអាចជាផ្នែកមួយដែរនោះឬមិនអាច ការជជែកដេញដោលត្រូវតែធ្វើឡើងដូចគ្នា។ អ្វីដែលសំខាន់គឺ ការបង្កើតគោលនយោបាយក៏ដូចជាការសម្រេចចិត្តពាក់ព័ន្ធនឹងការប្រើប្រាស់កងកម្លាំង ត្រូវធ្វើឡើងដោយមានការចូលរួមពីបុគ្គលជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យ។

## សេចក្ដីបញ្ចប់

សង្គ្រាមប្រហែលជារឿងដ៏អាក្រក់បំផុតដែលអាចកើតឡើងលើប្រជាជាតិណាមួយ ហើយសង្គ្រាមស៊ីវិលអាចនឹងអាក្រក់ជាងសង្គ្រាមអន្តរជាតិទៅទៀត។ ដូច្នេះរាល់ការសម្រេចចិត្តពាក់ព័ន្ធនឹងការធ្វើសង្គ្រាម ឬប្រើប្រាស់កម្លាំងទ័ពចាំបាច់ត្រូវត្រួតពិនិត្យឲ្យបានច្បាស់លាស់ និងឆ្លងកាត់ការពិភាក្សាជាច្រើនដំណាក់កាល។ ទីមួយ ការប្រើប្រាស់កម្លាំងត្រូវតែធ្វើស្របទៅនឹងច្បាប់ដែលបានចែងទាំងច្បាប់អន្តរជាតិ និងច្បាប់ជាតិ។ ទីពីរ នៅពេលណាដែលប្រជាជាតិមួយគ្មានជម្រើសអ្វីក្រៅពីការប្រើប្រាស់កម្លាំងទ័ព ដំណើរការនោះត្រូវធ្វើឡើងតាមបែបប្រជាធិបតេយ្យដោយអនុញ្ញាតឲ្យមានការជជែកវែកញែកនយោបាយលើសារៈសំខាន់នៃការធ្វើសង្គ្រាម ក៏ដូចជាការពិភាក្សាអំពីគ្រប់ជម្រើសយុទ្ធសាស្ត្រទាំងអស់ដែលមានក្នុងដៃ។ ការសម្រេចចិត្តដែលនាំឲ្យប្រជាជាតិ និងប្រជាពលរដ្ឋធ្លាក់ចូលក្នុងជម្លោះប្រដាប់អាវុធ ដោយឯកតោភាគីពីសំណាក់ស្ថាប័ននីតិប្រតិបត្តិ គឺមិនអាចទទួលយកបានឡើយ។

ការត្រួតពិនិត្យត្រូវធ្វើឡើងដោយសភា ដែលកើតឡើងពីការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ និងសមាជិក សមាជិកាសភា។ សមាជិក សមាជិកាសភាទាំងនេះត្រូវតែចូលរួមក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការរៀបចំផែនការយុទ្ធសាស្ត្រនិងយោធា គោលនយោបាយ ក៏ដូចជាគ្រប់ដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត។ ការធ្វើសង្គ្រាម និងជម្លោះអន្តរជាតិគឺជាបញ្ហាដែលពាក់ព័ន្ធនឹងនយោបាយ ដូច្នេះហើយអ្នកគ្រប់គ្រងបញ្ហាទាំងនេះត្រូវតែជាប្រជាពលរដ្ឋស៊ីវិល។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ១.១២ ROLE OF WOMEN IN CONFLICT RESOLUTION AND PEACEBUILDING IN ASEAN

## 1. BACKGROUND

Several studies show that when women are included in conflict resolution and peacebuilding, outcomes improve significantly (in terms of successful peace negotiations, impact of humanitarian assistance, sustainability of peace, and economic recovery) [88, 91, 94, 96, 97]. Yet an analysis of 1,500 peace and political agreements adopted between 2000 and 2016 found that only 25 even mention the role of women [98]. And despite growing recognition of their critical role as peacemakers, through broadening the scope of issues discussed in the negotiation process, increasing "community-buy in" and the chances that root causes of the conflict will be addressed, and greater pressure on the involved parties to reach an agreement, women continue to be underrepresented at the global, regional, and national levels. Globally, from 1990 to 2019, women made up just 6% of mediators, 13% of negotiators, and 6% of witnesses and signatories worldwide [99]. As of December 2020, 336 peacekeepers were women from the ASEAN region, as shown in Figure 1.

Additionally, whereas analysis found that increased female participation in parliament reduces the risks of civil war and of human rights abuses and that when the percentage of women in parliament increases by 5% a state is 5 times less likely to use violence when faced with an international crisis [88], ASEAN has been classified as having insufficient representation of women in parliaments (See Figure 2).

Figure 1: Peacekeeping Contributions by ASEAN Member States (AMS)

| EMA | Contribution des femmes | Homme | Femme | Total |
|---|---|---|---|---|
| **Brunei** | Contingent (0) | 30 | 0 | 30 |
| **Cambodia** | Contingent (71), experts (1), staff (1) | 684 | 92 | 776 |
| **Indonesia** | Contingent (107), experts (3), FPU (29), police (13), staff (7) | 2663 | 164 | 2827 |
| **Lao PDR** | N/A | 0 | 0 | 0 |
| **Malaysia** | Contingent (34), experts (3), staff (1) | 801 | 44 | 845 |
| **Myanmar** | N/A | 0 | 0 | 0 |
| **Philippines** | Experts (5), police (3), staff (0) | 16 | 11 | 27 |
| **Singapore** | N/A | 0 | 0 | 0 |
| **Thailand** | Contingent (0),experts (1), police (9), staff (1) | 288 | 13 | 301 |
| **Viet Nam** | Contingent (10), experts (1), staff(1) | 64 | 12 | 76 |

Source: UN Peacekeeping December 2020

### Figure 2: Women Representative in Parliaments by AMS

| ASEAN Countries | National Parliament | |
|---|---|---|
| | Lower House | Upper House |
| **Brunei** | 9.1% | - |
| **Cambodia** | 20.% | 16% |
| **Indonesia** | 20.3% | - |
| **Lao PDR** | 27.5% | - |
| **Malaysia** | 14.4% | 19.1% |
| **Myanmar** | 11.1% | - |
| **Philippines** | 28% | 29.2% |
| **Singapore** | 24.0% | - |
| **Thailand** | 16.2% | 10.4% |
| **Viet Nam** | 26,7% | - |

Source: UN Women/IPU, Data as of March 2020

Finally, despite evidence that women in police forces are more likely to de-escalate tensions and to report gender-based violence and are less likely to use excessive force, law enforcement in the ASEAN region is predominantly male, with a women severely underrepresented in the police and military: even if ASEAN Member States (AMS) have undertaken programs to recruit women into police and military service, women comprise only between 6 and 20% of law enforcement workforces [95].

While a number of AMS are post conflict societies undergoing rebuilding, far more needs to be done to engage women's participation in sustaining peace and to track the achievements of women in contributing to peacebuilding and conflict resolution. In a context in which women and girls suffer disproportionately from impacts of conflicts, women's participation in peace and security matters are important to ensure respect for women's rights and to uphold international commitments. It is also fundamental to build a solid foundation for peaceful and just societies. The aim of this article is to underline the roles of ASEAN Parliaments in promoting women in conflict resolution and peacebuilding, by highlighting some relevant AMS good practices as well as the way MPs can develop and lobby on topics related to women, peace and security (WPS).

## 2. INTERNATIONAL AND REGIONAL WPS FRAMEWORKS

### 2.1 At the international level

In 2000, the Role of Women in Conflict Resolution and Peacebuilding became part of the international agenda with the United Nations Security Council (UNSC) Resolution 1325. This resolution recognizes for the first time that the "full participation of women in the peace process can significantly contribute to the maintenance and promotion of international peace and security". In this regard, UNSCR 1325 identifies four pillars of the women, peace and security agenda (See Figure 3).

Resolution 1325 has been reinforced in several legally binding international resolutions. They can be divided into two categories: women's participation in peace building, namely resolutions 1889 (2009), 2122 (2013), 2242 (2015) and 2493 (2019); and prevention and fight against conflict-related sexual violence, with resolutions 1820 (2008), 1888 (2009), 1960 (2010), 2106 (2013) and 2467 (2019). [ ]

### 2.2. At the regional level

In 2017, AMS collectively issued the Joint Statement on Promoting Women, Peace and Security in ASEAN. The 2017 Joint Statement identifies the following four key areas to support the region's realization of the WPS agenda.

**Illustration 3 : Les quatre piliers de la résolution 1325 du Conseil de sécurité des Nations sur les femmes, la paix et la sécurité**

| | |
|---|---|
| **Participation** | Calls for increased participation of women at all levels of decision-making, including in mechanisms for the prevention, management, and resolution of conflict as well as in peace negotiations & operations. |
| **Protection** | Calls specifically for the protection of women and girls from sexual and gender-based violence, including in emergency and humanitarian situations. |
| **Prevention** | Calls for improving intervention strategies in the prevention of violence against women, including by prosecuting those responsible for violations of international law; strengthening women's rights under national law; and supporting local women's peace initiatives and conflict resolution processes. |
| **Relief and Recovery** | Calls for advancement of relief and recovery measures to address international crises through a gendered lens, including by respecting the civilian and humanitarian nature of refugee camps, and considering the needs of women and girls in the design of refugee camps and settlements. |

Source: ASEAN Regional Study on Women, Peace and Security

- **Participation:** Explicitly referencing the importance of women's participation in the political, security, and justice sectors, and in peace processes.
- **Peace Agents:** Reference to the need to recognize and support the role of women as peacebuilding negotiators, mediators, and first responders.
- **Prevention:** Identifying gender inequality as a root cause of conflict and a contributing factor in the risk of violent extremism.
- **Recovery:** Disaster management (presumably including natural and man-made disasters and pandemics).

In April 2018, the first ASEAN-Australia WPS Dialogue was conducted. Under the ASEAN Institute for Peace and Reconciliation (AIPR), ASEAN established on December 13 of the same year the ASEAN Women for Peace Registry (AWPR), a pool of experts who provide capacity building for women as peacebuilders and support the integration of gender perspectives in conflict prevention and peacebuilding strategies.

In 2019, three important agendas emerged, including the adoption of a Joint Statement on Promoting the WPS Agenda at the ASEAN Regional Forum (ARF); the first AWPR Meeting as part of the first Regional Symposium on Implementing the WPS

Agenda, held in Phnom Penh; and the ASEAN Women Interfaith Dialogue, held in Jakarta.

In 2020, the Southeast Asia Network of Women Peace Negotiators and Mediators was set up. The 53rd ASEAN Foreign Ministers' Meeting on 10 September 2020 included an ASEAN Ministerial Dialogue on Strengthening Women's Role for Sustainable Peace and Security where the Ministers "took note of the need to develop a regional plan of action to synergize efforts at the national, regional and global level" [95]. They also encouraged intersectoral collaboration across the three ASEAN community pillars of the Political Security Community, Economic Community, and Socio-Cultural Community.

Finally, the year 2021 marks a significant step in advancing the WPS agenda as ASEAN prepares to commence the development of the Regional Action Plan (RAP) on WPS.

Each of these efforts demonstrates the consistent advance of the WPS agenda in ASEAN. However, there are still only two ASEAN countries with National Action Plans (NAPs) for implementing UNSCR 1325 : the Philippines and Indonesia. A huge gap remains between the effort of ASEAN to promote the WPS agenda and the policies of ASM.

## 3. THE ROLES OF ASEAN PARLIAMENTARIANS IN WPS

### 3.1. Legislation to implement the WPS agenda

ASEAN Parliaments have an instrumental role in ensuring that laws concerning issues related to WPS are discussed and adopted. The Philippines - the first Southeast Asian nation to ratify the Convention on the Elimination of Discrimination against Women (CEDAW) – offers a unique opportunity to examine how Parliaments can adopt laws in conformity with the WPS agenda and adopt quotas to promote girls and women's participation in peacebuilding and conflict resolution.

The Philippines has passed two pieces of legislation that encourage increased participation of women in peacebuilding and their protection against gender-based violence in armed conflicts, namely Republic Act 7192 and the Magna Carta for Women. Additionally, the Bangsamoro Organic Law – which was adopted in 2018 after 70 congresses involving more than 2700 women - specifically called for rehabilitation

**Figure 4: The Three Iterations of Philippines National Action Plans for WPS**

**2009 - 2016:** First National Action Plan was launched in March 2010 (Executive Order 865), and created the implementing infrastructure of the NAP, the National Steering Committee on Women, Peace and Security (NSC WPS).

**2014 - 2017:** The Philippines launched a review of the first NAP, and in 2014, aftera series of consultation meetings, further streamlined the Action Points and Indicators for the second-generation NAP WPS or the 2014 NAP WPS.

**2017 – 2022:** The Philippines launched its Second official NAP, The National Action on Women, Peace and Security (NAPWPS), 2017-2022, through the NSC WPS Technical Working Group (TWG).

Source: ASEAN Regional Study on Women, Peace and Security

programs to address the needs of fighters, including the decommissioned women's auxiliary force, as well as those of internally displaced persons, including widows, as part of a more general commitment to "observe, promote, and ensure gender-responsiveness in all aspects of security and peace building" [97].

Under the Philippine NAP on UNSCR 1325, the government committed to a 10 % quota for female law enforcement officers. Despite early success, the need to increase this quota became evident. On the one hand, this quota left a shortage of female police officers to staff Women and Children Protection Desks within all police departments nationally. On the other hand, increased reports of police brutality and sexual violence pointed to an urgent need to recruit more women to law enforcement. Additionally, female police officers have been deployed to post-disaster refugee camps to ensure protection of women and children from sexual violence and abuse. In 2018, media commentators and women's organizations began placing greater pressure on the Filipino government to increase the quota. In February 2019, the government approved a bill to increase the quota to 20%. In addition, the Philippine NAP established Women and Children Protection Desks in all police stations around the country.

The case of the Philippines reveals the importance of developing a WPS NAP informed by a legislative needs-analysis. In this framework, MPs or parliamentary committees can identify laws or amendments needed to advance the WPS agenda as well as the most critical areas requiring legislative attention. In addressing the WPS agenda, the Philippines is also paving the way for women's participation in peace building and peacekeeping through promoting their role as negotiators, mediators, and peacekeepers (by recruiting female police officer and establishing women's police desks).

### 3.2. Budgeting for WPS implementation

In 2012, the Indonesian government put in place a National Strategy for Gender Mainstreaming Acceleration through Gender-Responsive Budgeting. This strategy provided training for officials and local level bodies as well as proposed budgetary reforms. In subsequent years, after Indonesia launched its first NAP in 2014 for the period 2014-2019, this work has been continually re-evaluated, with the Ministry of Finance and Ministry of National Development Planning tracking the work being done, including capacity checks and training for local officials. Civil society organizations have also been active on these issues, engaging in gender-responsive budgeting training and implementation within their own organizations, especially in the post-conflict areas as well as in the regions most heavily affected by natural disasters. The insights of local women and local communities have, in turn, been fed back into government approaches [97].

The case of Indonesia reveals the importance of analyzing the gendered impact of budgetary allocations, with the aim of expanding the resources dedicated to promoting gender equality. In this framework, MPs or parliamentary committees can be involved in the development, implementation, publicizing and monitoring of a budgeted plan of action for the implementation of resolution 1325. They can, for example, engage with and gather information from their constituents on whether and how government programs have been useful in advancing the WPS agenda or use Question Time to ask whether and how WPS issues will be funded when the draft national budget is tabled in the legislature. Committees responsible for reviewing budgets or public finances can also ask the parliamentary secretariat to undertake an analysis to identify how existing budgets could be targeted more effectively to address WPS, or hold hearings

with representatives from relevant ministries to ask them about what funds they have allocated towards implementation of the WPS agenda and whether and how they have set performance indicators to assess the impact of such funds.

### 3.3. Parliamentary role in public representation

Although the average rate of women's participation in peace processes around the world remains low, the Philippines is an outlier. In 2014 peacemaking negotiations between the Philippines government and the Moro Islamic Liberation Front (MILF), women comprised 40% of the peace negotiators, 69% of the secretariat, and 60% of the legal team, showing that near gender parity can be achieved [94]. More precisely, 33% of the negotiators were women (2 of the 4 government negotiators and 1 of the 5 MILF negotiators), and 50% of the government's negotiating team and 25% of the signatories were women, with the first female panel chair (Professor Miriam Colonel-Ferrer) and the first female chief negotiator to sign a major peace accord (Teresita Quintos-Deles). As a result, 16 articles of the final peace accord mentioned women's rights (the most gender-sensitive peace agreements to date) [97].

ទន្ទឹមនឹងនេះដែរ ប្រទេសជាច្រើននៅអាស៊ីបានបន្តអនុវត្តកិច្ចផ្តួចផ្តើមសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងអន្តរតំបន់។ កិច្ចផ្តួចផ្តើមប្រភេទនេះដំបូងគេគឺ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយនិងវឌ្ឍនភាពសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP) ដែលជាគំនិតផ្តួចផ្តើមសមាហរណកម្មពាណិជ្ជកម្ម និងសេដ្ឋកិច្ចឆ្លងតំបន់ (ដែលរួមមានប្រទេសចំនួន ១១ ជុំវិញពិភពលោក ដូចជាជប៉ុន ម៉ាឡេស៊ី សិង្ហបុរី វៀតណាម ព្រុយណេ អូស្ត្រាលី នូវែលសេឡង់ កាណាដា ស៊ីលី ប៉េរូ និងម៉ិកស៊ិក) បន្ទាប់ពីអាម៉េរិកដកខ្លួនចេញពីភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP) ដែលមាន ១២ ប្រទេសជាសមាជិក ភ្លាមៗក្រោយលោកប្រធានាធិបតីត្រាំចូលកាន់តំណែងនៅខែមករា ឆ្នាំ២០១៧។ កិច្ចព្រមព្រៀង CPTPP ត្រូវបានចុះហត្ថលេខានៅខែមីនា ឆ្នាំ២០១៨ ហើយត្រូវបានផ្តល់សច្ចាប័នពីសមាជិកភាគច្រើន។ កិច្ចព្រមព្រៀងនេះបានចូលជាធរមាននៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨។ ប្រទេសកូរ៉េខាងត្បូងត្រូវបានគេមើលឃើញថា នឹងអាចក្លាយជាសមាជិកនាពេលអនាគតរបស់ CPTPP ខណៈដែលថ្មីៗនេះ ប្រទេសថៃ និងកូឡុំប៊ីបានបង្ហាញចំណាប់អារម្មណ៍ក្នុងការចូលរួមផងដែរ។

ថ្មីៗនេះ ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ដែលជាភាពជាដៃគូសេដ្ឋកិច្ចក្នុងតំបន់ និងមាន

សមាជិកចំនួន ១៦ ដែលរួមមានសមាជិកអាស៊ានទាំង ១០ បូកនឹងជប៉ុន ចិន កូរ៉េខាងត្បូង អូស្ត្រាលី នូវែលសេឡង់ និងឥណ្ឌា កំពុងឈានដល់ដំណាក់កាលចុងក្រោយ។ ប្រទេសជាសមាជិកទាំងអស់ លើកលែងឥណ្ឌា មានបំណងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះនៅឆ្នាំ២០២០ និងចាប់ផ្តើមអនុវត្តនៅដើមឆ្នាំ២០២១។ គំនិតផ្តួចផ្តើម RCEP បានចាប់ផ្តើមនៅឆ្នាំ២០១២ ដើម្បីធ្វើសមាហរណកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងប្រទេសសមាជិកអាស៊ាន និងដៃគូពាណិជ្ជកម្មសំខាន់ៗរបស់ខ្លួនទៅជាកិច្ចព្រមព្រៀងរួមមួយ ដែលនឹងក្លាយជាកិច្ចព្រមព្រៀងពាណិជ្ជកម្មធំបំផុតរបស់ពិភពលោក បើគិតពីចំនួនប្រជាជន និងប្រាក់ចំណូល។

RCEP មានសក្តានុពលធំធេងក្នុងការបង្កើនប្រាក់ចំណូលសកល (Reinsch et. al., ២០១៩)។ ការសិក្សាមួយរបស់វិទ្យាស្ថានប្រ៊ូកឃីង (Brookings Institute) ដែលជាក្រុមអ្នកផ្តល់យោបល់មួយនៅសហរដ្ឋអាម៉េរិកបានប៉ាន់ប្រមាណថា RCEP មានសក្តានុពលក្នុងការបង្កើនប្រាក់ចំណូលសកលចំនួន ២៨៥ ប៊ីលានដុល្លារអាម៉េរិកជារៀងរាល់ឆ្នាំ ដែលបើគិតក្នុងតម្លៃជាក់ស្តែងជាចំខាត វាស្មើនឹងទ្វេដងនៃចំណូលដែលត្រូវបានគេប៉ាន់ស្មានថានឹងបានពី CPTPP (ដកស្រង់ពីក្នុង Reinsch et. al., ២០១៩)។ កិច្ចព្រមព្រៀងនេះធ្វើឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ក្នុងការដោះស្រាយវិធាននៃប្រភពដើមទំនិញ (rules of origin) កម្មសិទ្ធិបញ្ញា និងការកាត់បន្ថយពន្ធគយ ខណៈពេលដែលនៅមានភាពខ្វះខាតនៅក្នុងផ្នែកផ្សេងទៀតដូចជាផ្នែកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច។ ក្នុងអំឡុងពេលនៃការចរចាចុងក្រោយ មានឧបសគ្គកើតឡើងនៅពេលដែលឥណ្ឌាដកខ្លួនចេញពីកិច្ចព្រមព្រៀង។ ទោះជាការចាកចេញរបស់ឥណ្ឌាមិនគួរឲ្យនឹកស្មានដល់ក៏ដោយ តែវាមិនបានប៉ះពាល់ដល់វឌ្ឍនភាពរបស់ RCEP ឡើយ។

បទបញ្ញត្តិរបស់ RCEP ដែលបញ្ជាក់ដោយឡែកពីការចូលរួមរបស់ឥណ្ឌានឹងត្រូវផ្អាក ហើយការផ្លាស់ប្តូរតិចតួចមួយចំនួនអាចនឹងត្រូវធ្វើឡើងសម្រាប់ការចាកចេញរបស់ឥណ្ឌា។ RCEP នឹងនៅតែបើកចំហសម្រាប់ឥណ្ឌាចូលរួមម្តងទៀតនៅពេលណាមួយ (RCEP ក៏មានបទបញ្ញត្តិសម្រាប់ការចូលរួមជាទូទៅផងដែរ) ប៉ុន្តែការដែលឥណ្ឌានឹងពិចារណាចូលរួម RCEP ម្តងទៀតហាក់ដូចជាមិនអាចទៅរួចមុនពេលដែលមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។

## សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ស្ទើរតែគ្រប់ប្រទេសនៅអាស៊ីទាំងអស់បានទទួលផលប្រយោជន៍យ៉ាងច្រើនពីប្រព័ន្ធពាណិជ្ជកម្មពហុភាគីក្រោយសង្គ្រាម និងស្ថាប័នអភិបាលកិច្ចសំខាន់របស់ប្រព័ន្ធនេះ ពោលគឺអង្គការពាណិជ្ជកម្មពិភពលោក។ របបពាណិជ្ជកម្មពិភពលោកដែលបើកចំហ និងអាស្រ័យច្បាប់បានធ្វើឲ្យប្រទេសមួយហើយមួយទៀតនៅអាស៊ីអនុវត្តតាមគោលនយោបាយពាណិជ្ជកម្មដែលឆ្ពោះទៅខាងក្រៅ (ដែលផ្តោតលើការនាំចេញ) និងធ្វើសមាហរណកម្មទៅក្នុងទីផ្សារពិភពលោកដ៏ធំ។ លទ្ធផលមានដូចជាការកើនឡើងនៃការនាំចេញ ការបង្កើតការងាររាប់លាននៅក្នុងប្រទេស និងការអភិវឌ្ឍដែលកើនឡើងជាលំដាប់។ ប្រទេសចិនប្រហែល គឺជាឧទាហរណ៍ច្បាស់មួយនៃវឌ្ឍនភាពនេះ ដោយទទួលបានអត្ថប្រយោជន៍តាមរយៈការអនុវត្តយុទ្ធសាស្ត្រកំណើនដោយផ្អែកលើការនាំចេញចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០។

ជាការដោះដូរ អ្នកប្រើប្រាស់នៅអឺរ៉ុប សហរដ្ឋអាម៉េរិក និងតំបន់ផ្សេងទៀតទទួលបានផលប្រយោជន៍ពីទំនិញ និងសេវាកម្មទាំងឡាយដែលនាំចូលពីអាស៊ីក្នុងតម្លៃទាបជាងបើផលិតនៅក្នុងប្រទេស។ ប្រព័ន្ធពាណិជ្ជកម្មពហុភាគីផ្តល់ផលប្រយោជន៍ដូចគ្នាដល់ប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ នៅពេលដែលមានការប៉ះទង្គិចខាងផ្នែកពាណិជ្ជកម្មរវាងប្រទេសនិងប្រទេស ការដោះស្រាយអាចធ្វើបានតាមរយៈប្រព័ន្ធដោះស្រាយវិវាទពហុភាគីអាស្រ័យច្បាប់ក្រោមកិច្ចព្រមព្រៀងទូទៅ ស្តីពីពន្ធគយនិងពាណិជ្ជកម្ម ឬអង្គការពាណិជ្ជកម្មពិភពលោក។ ទោះជាយ៉ាងណាការតម្លើងពន្ធជាឯកតោភាគីដោយអាម៉េរិកដែលចាប់ផ្តើមនៅឆ្នាំ២០១៨ និងការដកសមាជិកភាពរបស់ខ្លួនចេញពីស្ថាប័នឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក បានបង្ហាញពីភាពតានតឹងយ៉ាងខ្លាំងលើប្រព័ន្ធពាណិជ្ជកម្មពហុភាគី។ ក្នុងពេលជាមួយគ្នានេះដែរ អ្នកសង្កេតការណ៍ជាច្រើនបានកត់សម្គាល់ថា ចិនក៏បានដាក់ចេញនូវគោលនយោបាយដែលអាចបង្កបញ្ហា និងមានទំនោរធ្វើឲ្យខូចខាតដល់របបពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់។

សហគមន៍អន្តរជាតិមានចំណាប់អារម្មណ៍ចង់ឲ្យចិន និងអាម៉េរិកដោះស្រាយជម្លោះពាណិជ្ជកម្មរបស់ខ្លួនប្រកបដោយមេត្រីភាពនិងឆាប់រហ័ស ដើម្បីធ្វើឲ្យប្រព័ន្ធពាណិជ្ជកម្មពហុភាគីក្រោយសង្គ្រាមដែលទទួលបានការថែរក្សាយ៉ាងយកចិត្តទុកដាក់បំផុតក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមក នឹងវិលត្រលប់ទៅរកស្ថានភាពល្អប្រសើរវិញ។ បណ្តា

ប្រទេសនៅអាស៊ីភាគច្រើនបានឆ្លើយតបជាមួយនឹងអភិក្រមផ្លូវពីរ (dual-track approach) ក្រោយពីមានជម្លោះពាណិជ្ជកម្មរវាងអាមេរិក និងចិន។ ខណៈដែលប្រទេសនៅអាស៊ីទាំងនេះបានប្រកាសពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះប្រព័ន្ធពាណិជ្ជកម្មពហុភាគី ពួកគេក៏បានសម្របសម្រួលសេរីភាវូបនីយកម្មពាណិជ្ជកម្មតាមរយៈគំនិតផ្តួចផ្តើមសមាហរណកម្មអន្តរតំបន់ និងក្នុងតំបន់ដូចជា CPTPP និង RCEP។ ទស្សនៈផ្លូវពីររបស់អាស៊ីនេះហាក់ដូចជាការឆ្លើយតបសមស្របទៅនឹងការប្រេះស្រាំដែលបន្តប្រែប្រួលនៅក្នុងប្រព័ន្ធពាណិជ្ជកម្មពហុភាគីបច្ចុប្បន្ន។ អភិក្រមផ្លូវពីរនេះគួរតែពង្រឹងការធ្វើសមាហរណកម្មពាណិជ្ជកម្មពិភពលោកតាមមធ្យោបាយមួយ ឬផ្សេងទៀត។

ផែនទី ១៖ ពាណិជ្ជកម្មអឺរ៉ុប-អាស៊ី




*ប្រភព: DG Trade ឆ្នាំ២០១៩*

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ២.៣ ប្រព័ន្ធពាណិជ្ជកម្មពហុភាគី៖ ទស្សនៈមួយបែបអឺរ៉ុប

## មូលដ្ឋានប្រវត្តិសាស្ត្រ

> "ខណៈពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីមិនសូវមានភាពស្មុគស្មាញ ប្រទេសដែលចូលរួមក្នុងកិច្ចព្រមព្រៀងនោះនៅតែប្រឈមមុខនឹងភាពតានតឹងជាមូលដ្ឋានរវាងអធិបតេយ្យភាព និងគោលការណ៍នៃសាកលភាវូបនីយកម្ម។"

ប្រព័ន្ធទំនើបនៃពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់បានចាប់ផ្តើមនៅឆ្នាំ១៩៤១ ក្នុងអំឡុងពាក់កណ្ដាលសង្គ្រាមលោកលើកទី២នៅពេលដែលលោកChurchillនិងលោក Roosevelt បានជួបគ្នានៅ Newfoundland ហើយបានធ្វើសេចក្តីថ្លែងការណ៍រួមមួយ ដែលក្រោយមកត្រូវបានគេស្គាល់ថាជាធម្មនុញ្ញអាត្លង់ទិក [១០]។ បើទោះជាមានបញ្ហាក្នុងសម័យសង្គ្រាមក៏ដោយ មាត្រាចំនួន២ ក្នុងចំណោមមាត្រាទាំង៨ (មាត្រា៤ និងមាត្រា៥) នៃធម្មនុញ្ញនេះបានផ្តោតសំខាន់លើពាណិជ្ជកម្ម [១១] ហើយធម្មនុញ្ញនេះបានធ្វើឲ្យមានការផ្តួចផ្តើមបង្កើតស្ថាប័ន ឆ្លងដែនមួយចំនួនរួមមានកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម (GATT) និងប្រព័ន្ធ Bretton Woods [១២]។

ក្រោយសង្គ្រាម អឺរ៉ុបមានសមាហរណកម្មជាមួយគ្នាកាន់តែខ្លាំងឡើង ដោយផ្តើមដំបូង ដោយការបង្កើតសហគមន៍ធ្យូងថ្មនិងដែកថែបអឺរ៉ុបនៅឆ្នាំ១៩៥០ និងបន្ទាប់មកការបង្កើតសហគមន៍សេដ្ឋកិច្ចអឺរ៉ុប (European Economic Community) ក្នុងឆ្នាំ១៩៥៧។ ទោះយ៉ាងណា កិច្ចព្រមព្រៀងទាំងនេះ មិនគ្រាន់តែជាឯកសារសេដ្ឋកិច្ចដែលផ្តោតលើការដោះដូរពាណិជ្ជកម្មតែមួយមុខប៉ុណ្ណោះទេ តែវាក៏បង្ហាញពីគុណតម្លៃនយោបាយ និងសីលធម៌មូលដ្ឋានរបស់អឺរ៉ុប និងទំនាក់ទំនងអឺរ៉ុបជាមួយប្រជាជាតិដទៃទៀតផងដែរ។ សេចក្តីប្រកាស Schuman (ដែលនាំឲ្យមានការបង្កើតសហគមន៍ធ្យូងថ្ម និងដែកថែបអឺរ៉ុប) បានលើកឡើងថា"ការអភិវឌ្ឍទ្វីបអាហ្វ្រិក"ជា"ភារកិច្ចដ៏សំខាន់" មួយរបស់អឺរ៉ុប [១២] និងសន្ធិសញ្ញារ៉ូម (ដែលបានបង្កើត EEC) មានផ្នែកមួយទាំងមូល (ផ្នែក ៤) ដែលផ្តោតលើ "ប្រទេស និងទឹកដីនៅបរទេស" [១៣]។

ភស្តុតាងបន្ថែមដែលបង្ហាញថាមានកត្តាផ្សេងទៀតក្រៅពីកត្តាសេដ្ឋកិច្ចបានចូលរួមក្នុងការស្ថាបនាសហភាពអឺរ៉ុប នោះគឺ សហរដ្ឋអាម៉េរិកបានគាំទ្រយ៉ាងខ្លាំងក្នុងការបង្កើត EEC ទោះបីជាសហព័ន្ធគយ (customs union) មួយនេះនឹងបង្កការខាតបង់ផ្នែកសេដ្ឋកិច្ចដល់ជំនួញអាម៉េរិកខណៈពេលដែលខ្លួនគ្មានវត្តមាននៅក្នុងនោះក៏ដោយ។ យោងតាមអគ្គនាយករងអង្គការពាណិជ្ជកម្មពិភពលោកបច្ចុប្បន្នលោក Wolff បានលើកឡើងថា អាម៉េរិក (ដោយផ្នែក) បានគាំទ្រដល់សហគមន៍សេដ្ឋកិច្ចអឺរ៉ុបដើម្បី "បង្កើតជាកម្លាំងសេដ្ឋកិច្ចប្រឆាំងនឹងការរីកលូតលាស់របស់សហភាពសូវៀត" [១៤] នេះបញ្ជាក់ឲ្យឃើញថា ឧត្តមគតិនយោបាយមានឥទ្ធិពលជាងការ គិតគូរផ្នែកសេដ្ឋកិច្ច។ ខណៈពេលដែលសហភាពអឺរ៉ុបមានការលូតលាស់ទាំងទំហំ និងសេដ្ឋកិច្ចក្នុងរយៈពេលប៉ុន្មាន ទសវត្សរ៍នេះ គុណតម្លៃនយោបាយនិងសីលធម៌នៅតែជាមូលដ្ឋាននៃទស្សនវិជ្ជាពាណិជ្ជកម្មភាគច្រើនរបស់ខ្លួន។ ជាក់ស្តែងកំណើនសេដ្ឋកិច្ចរបស់សហភាពអឺរ៉ុបបានពង្រឹងបន្ថែមនូវ "ទស្សនាទាននៃតួនាទីរបស់ខ្លួនដែលជាអំណាចបែប "បទដ្ឋាន" និងឈានមុខគេ" [១៥,ទំ.៧៣]។ សហភាពអឺរ៉ុបអនុវត្តអំណាចនេះ ទាំងនៅក្នុងអង្គការ ពាណិជ្ជកម្មពិភពលោកក៏ដូចជាតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគីផងដែរ។

> "ខណៈពេលដែលសហភាពអឺរ៉ុបមានការលូតលាស់ទាំងទំហំនិងសេដ្ឋកិច្ចក្នុងរយៈពេលប៉ុន្មានទសវត្សរ៍នេះគុណតម្លៃនយោបាយនិងសីលធម៌នៅតែជាមូលដ្ឋាននៃទស្សនវិជ្ជាពាណិជ្ជកម្មភាគច្រើនរបស់ខ្លួន។"

## អង្គការពាណិជ្ជកម្មពិភពលោក

សហភាពអឺរ៉ុប (ក៏ដូចជារដ្ឋជាសមាជិកទាំងអស់របស់ខ្លួន) គឺជាសមាជិករបស់អង្គការពាណិជ្ជកម្ម ពិភពលោក និងចាត់ទុកថាអង្គការពាណិជ្ជកម្មពិភពលោកជាអ្វីដែល "មិនអាចខ្វះបានក្នុងការធានាឲ្យមានពាណិជ្ជកម្មសេរី និងយុត្តិធម៌" [១៦,ទំ.១]។ សហភាពអឺរ៉ុបចាត់ទុកប្រព័ន្ធអាស្រ័យច្បាប់រឹងមាំ ជាបុរេលក្ខខណ្ឌ សម្រាប់កំណើនប្រកបដោយចីរភាព ពីព្រោះសេដ្ឋកិច្ចសហភាពអឺរ៉ុបបានចូលរួមយ៉ាងស៊ីជម្រៅទៅក្នុងខ្សែសង្វាក់ តម្លៃពិភពលោក (global value chains) ដែលទាមទារឲ្យមានស្ថិរភាព និងភាពដែលអាចព្យាករណ៍បាន [១៦]។ សក្ខីកម្មមួយដែលបង្ហាញពីសមត្ថភាពរបស់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់ក្នុងការបង្កើតឲ្យមានស្ថិរភាពនោះគឺវិបត្តិហិរញ្ញវត្ថុពិភពលោកឆ្នាំ២០០៨-២០០៩ មិនបាននាំឲ្យមានសង្គ្រាមពាណិជ្ជកម្ម ឬឈានដល់ ការកើនឡើងនៃវិធានការណ៍គាំពារនិយម ដូចវិបត្តិកាលពីទសវត្សរ៍ឆ្នាំ១៩៣០ ឡើយ [១៦, ១៧, ១៨]។

ទោះជាយ៉ាងនេះក៏ដោយ មួយទសវត្សរ៍ក្រោយមក ប្រព័ន្ធពាណិជ្ជកម្មពហុភាគីអាស្រ័យលើច្បាប់ហាក់ ដូចជាកំពុងប្រឈមនឹងបញ្ហា ជាមួយនឹងការកើនឡើងនូវការគំរាមកំហែងនៃវិធានការណ៍បែបគាំពារនិយម ឯកតោភាគី ដូចជាសង្គ្រាមពាណិជ្ជកម្មរវាងអាម៉េរិកនិងចិន និងការគំរាមកំហែងពីអាម៉េរិកក្នុងការដកខ្លួនចេញពី អង្គការពាណិជ្ជកម្មពិភពលោក [១៦, ១០]។ ប្រព័ន្ធដោះស្រាយវិវាទ (Dispute Settlement System) ដែល សហភាពអឺរ៉ុបចាត់ទុកថាជា "ត្បូងនៃមកុដ" របស់អង្គការពាណិជ្ជកម្មពិភពលោក [១៩, ទំ.២] កំពុងប្រឈមនឹងការ ដួលរលំនៅពេលដែលអាម៉េរិកកំពុងរាំងការតែងតាំងតំណាងថ្មីទៅកាន់ស្ថាប័នឧទ្ធរណ៍ (Appellate Body) ដែល បានបង្កើតឲ្យមានភាពជាប់គាំង [១៩]។ ការរាំងពីសំណាក់អាម៉េរិកនេះគឺដោយសារតែកង្វល់មួយចំនួន ដែលខ្លួនមានចំពោះអង្គការពាណិជ្ជកម្មពិភពលោក និង"អភិក្រមសកម្មនៃស្ថាប័នឧទ្ធរណ៍" (activist approach of the Appellate Body)

> "សហភាពអឺរ៉ុបចាត់ទុកប្រព័ន្ធអាស្រ័យច្បាប់រឹងមាំជាបុរេលក្ខខណ្ឌសម្រាប់កំណើនប្រកបដោយចីរភាពពីព្រោះសេដ្ឋកិច្ចសហភាពអឺរ៉ុបបានចូលរួមយ៉ាងស៊ីជម្រៅទៅក្នុងខ្សែសង្វាក់តម្លៃពិភពលោកដែលទាមទារឲ្យមានស្ថិរភាព និងភាពដែលអាចព្យាករណ៍បាន។"

[២០, ទំ.២៨] ដែលក្នុងនោះចំណុចសំខាន់ (និងស្មុគស្មាញបំផុត) គឺទាក់ទងនឹងភាពតានតឹង រវាងអធិបតេយ្យភាពរបស់អាម៉េរិក និងយុត្តាធិការជាសកលរបស់អង្គការពាណិជ្ជកម្មពិភពលោក។ អាម៉េរិកជំទាស់ ការដែលស្ថាប័នឧទ្ធរណ៍ពិនិត្យច្បាប់ក្នុងស្រុករបស់ខ្លួនឡើងវិញ និងការដែលស្ថាប័នឧទ្ធរណ៍ចាត់ទុករបាយការណ៍ របស់ខ្លួនជាគំរូសម្រាប់ការអនុវត្តទៅថ្ងៃអនាគត [២០]។

បន្ថែមលើបញ្ហាជាមួយស្ថាប័នឧទ្ធរណ៍ ការជាប់គាំងដែលបានកើតឡើងបន្ទាប់ពីរបៀបវារៈអភិវឌ្ឍន៍ដូហា (ឬហៅថា កិច្ចចរចា Doha Round ឆ្នាំ២០០១ តទៅក្នុងឯកសារនេះហៅកាត់ថា DDA) បាននាំឲ្យមានការកើនឡើងទ្វេភាគីនិយម នៅពេលដែលសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ព្យាយាមបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មក្រៅប្រព័ន្ធពហុភាគីរបស់អង្គការពាណិជ្ជកម្មពិភពលោក [១៩]។ ផ្នែកមួយនៃហេតុផលសម្រាប់ការជាប់ គាំងបច្ចុប្បន្នគឺ "អភិក្រមអនុវត្តទាំងស្រុង (Single Undertaking Approach)" របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលមានន័យថាកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក (ដូចជា DDA) ត្រូវតែអនុម័តទាំងស្រុង បើមិនដូច្នេះទេ គឺមិនអនុម័តតែម្តង ហើយក៏គ្មានជម្រើសក្នុងការជ្រើសអនុម័តតែបទបញ្ញត្តិជាក់លាក់ ណាមួយឡើយ [២១]។ ការពន្យល់មួយទៀតលើការបរាជ័យនៃ DDA គឺជាការបែងចែកភាគខាងជើង-ខាងត្បូង ដោយប្រទេសអភិវឌ្ឍន៍នៅភាគខាងជើងមើលឃើញថា ការផ្តល់ទីផ្សារជាហានិភ័យសេដ្ឋកិច្ចដែលគួរតែមានការសម្របសម្រួលពីអ្នកទទួលផល តែប្រទេសកំពុងអភិវឌ្ឍន៍នៅភាគខាងត្បូងស្តីបន្ទោសផ្នត់គំនិតបែបពាណិជ្ជកម្មនេះ ហើយផ្ទុយទៅវិញមើលឃើញថា DDA ជាផ្លូវមួយដើម្បីផ្លាស់ប្តូរច្បាប់មិនយុត្តិធម៌មានស្រាប់ដែលកំណត់ដោយ ប្រទេសអភិវឌ្ឍន៍ [១៨]។ បញ្ហានេះកាន់តែស្មុគស្មាញដោយសារតែទស្សនាទានចាស់របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលយល់ថាប្រទេសចែកចេញជាប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍន៍ (ឬមានការអភិវឌ្ឍតិចតួចបំផុត) កំពុងក្លាយជាទស្សនៈដែលហួសសម័យ ស្របពេលប្រទេស BRIC [A] រីកចម្រើនរហូតធ្វើឲ្យប្រទេស អភិវឌ្ឍន៍លែងចង់ផ្តល់សម្បទាននានា ដែលមិនទទួលបានអ្វីតបស្នងពីប្រទេសទាំងនោះវិញសោះ [១៧]។

ខណៈពេលដែលសភាអឺរ៉ុបនៅតែចាត់ទុកអង្គការពាណិជ្ជកម្មពិភពលោកជាជម្រើសល្អបំផុតសម្រាប់ពាណិជ្ជកម្មអន្តរជាតិ [១៩] សហភាពអឺរ៉ុបកំពុងព្យាយាមកែទម្រង់អង្គការនេះ ក្នុងនោះរួមមានតាមរយៈការពង្រឹងយន្តការ

អនុវត្តការផ្តល់អំណាចបន្ថែមឲ្យគណៈកម្មាធិការនានាដើម្បីផ្លាស់ប្តូរវិធាន និងការដោះស្រាយកង្វល់ របស់អាម៉េរិក អំពីស្ថាប័នឧទ្ធរណ៍ [១៦]។ ទោះយ៉ាងណា ខណៈពេលដែលអាម៉េរិកបាននិងកំពុងធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTAs) មួយចំនួនរបស់ខ្លួន សហភាពអឺរ៉ុបមិនបានអង្គុយស្ងៀមនោះទេ ផ្ទុយទៅវិញនៅក្នុងឆ្នាំ២០០៦ សហភាពអឺរ៉ុបបានបំពានការហាមឃាត់របស់ខ្លួនក្នុងការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មី ហើយបានបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាច្រើន ដែលក្នុងនោះមួយចំនួនធ្វើជាមួយប្រទេសអភិវឌ្ឍន៍[១៧]។“ពាណិជ្ជកម្មសម្រាប់ទាំងអស់គ្នា” (Trade for All) គឺជាឯកសារគោលនយោបាយពីឆ្នាំ២០១៥ធ្វើដោយស្នងការពាណិជ្ជកម្មអឺរ៉ុប(ឬពីមុនហៅថា Cecilia Malmström) បានបញ្ជាក់ថាកិច្ចព្រមព្រៀងពាណិជ្ជកម្ម សេរីត្រូវតែជាការចាំបាច់ អមជាមួយនឹងកិច្ចព្រមព្រៀងពហុភាគីរបស់អង្គការពាណិជ្ជកម្មពិភពលោក។ កិច្ចព្រមព្រៀងពហុភាគីអាចមានឥទ្ធិពលធំជាងនេះ ប៉ុន្តែក៏មានលក្ខណៈស្មុគស្មាញផងដែរ ហើយគណៈកម្មការអឺរ៉ុបជឿជាក់ថា ការបង្រួបបង្រួមបទប្បញ្ញត្តិធ្វើឲ្យមានភាពងាយស្រួលក្នុងការសម្រេចបានតាមរយៈការចរចាទ្វេភាគី [២២]។ ទស្សនវិជ្ជានេះហាក់ដូចជាបានអនុវត្តនៅក្នុងអាស៊ាន ប៉ុន្តែអំឡុងពេលដែលមានការចរចាទ្វេភាគីរវាងតំបន់ ជាមួយអាស៊ាន ការចរចានោះក្លាយជាមានភាពស្មុគស្មាញខ្លាំងទៅវិញ។ ចាប់តាំងពីពេលនោះមក សហភាពអឺរ៉ុប បានធ្វើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយសិង្ហបុរីនិងវៀតណាម ហើយកំពុងចរចាជាមួយសមាជិក អាស៊ានទាំងអស់ (លើកលែងអនាគតសមាជិក-ទីម័រខាងកើត)។ សេរីភាវូបនីយកម្មពាណិជ្ជកម្ម ហាក់មានភាព បន្ទាន់និងមានសារៈសំខាន់ខ្លាំង ដែលសហភាពអឺរ៉ុបហាក់មិនអាចរង់ចាំរហូតដល់បញ្ហានៃប្រព័ន្ធអង្គការ ពាណិជ្ជកម្មពិភពលោកត្រូវបានដោះស្រាយ [១៥]។

## អធិបតេយ្យភាព និងពិភពពាណិជ្ជកម្មបែបថ្មី

បញ្ហាមួយចំនួននៃអង្គការពាណិជ្ជកម្មពិភពលោកបានផ្តើមចេញពីភាពតានតឹងរវាងតម្រូវការរបស់រដ្ឋនានាដើម្បីរក្សាអធិបតេយ្យភាព និងតម្រូវការនៃប្រព័ន្ធពហុភាគីដែលមានច្បាប់ដើម្បីគ្រប់គ្រងពាណិជ្ជកម្មរវាងប្រទេស។ យោងតាមគំរូរដ្ឋប្រជាជាតិ Westphalian ប្រទេសមានអធិបតេយ្យភាពពេញលេញទាំងស្រុងលើអ្វី ដែលកើតឡើងក្នុងព្រំដែនរបស់ខ្លួន។ គំរូនេះកាន់តែពិបាកក្នុងការរក្សានៅក្នុងពិភពសកលភាវូបនីយកម្ម ដែលផលិតផលត្រូវបានផលិតនៅក្នុងប្រទេសប្រាំឬប្រាំមួយផ្សេងគ្នា (ដោយក្រុមហ៊ុនដែលចុះឈ្មោះនៅក្នុងប្រទេសតែមួយរួមគ្នា)។ ខណៈពេលដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីមិនសូវមានភាពស្មុគស្មាញ ប្រទេសដែលចូលរួមក្នុងកិច្ច ព្រមព្រៀងនោះនៅតែប្រឈមមុខនឹងភាពតានតឹងជាមូលដ្ឋានរវាងអធិបតេយ្យភាព និងគោលការណ៍សាកលភាវូបនីយកម្ម។

លោក Pascal Lamy អតីតអគ្គនាយកនៃអង្គការពាណិជ្ជកម្មពិភពលោក និងជាអតីតស្នងការសហភាព អឺរ៉ុបសម្រាប់ពាណិជ្ជកម្មបានចាត់ទុក ហើយហៅបញ្ហានេះជា “ពិភពពាណិជ្ជកម្មចាស់” ធៀបនឹង “ពិភពពាណិជ្ជកម្មថ្មី” ដោយពិភពលោកបច្ចុប្បន្នកំពុងស្ថិតក្នុងដំណាក់កាលផ្លាស់ប្តូររវាងពិភពទាំងពីរ [១៧, ២៣, ២៤]។

នៅក្នុងទស្សនាទាននេះ “ពិភពលោកបែបចាស់” គឺជាទស្សនាទានដែលអ្នកបង្កើតគោលនយោបាយ ព្យាយាមការពារផលិតករក្នុងស្រុកពីការប្រកួតប្រជែងពីខាងក្រៅតាមរយៈវិធានការណ៍គាំពារនិយម (ដូចជាពន្ធ គយនិងកូតាជាដើម)។នៅក្នុងពិភពលោកបែបនេះ ការចរចាពាណិជ្ជកម្មគឺមានអត្ថន័យដោយត្រង់ៗ ពោលគឺការធ្វើពាណិជ្ជកម្មបែបបើកចំហមានន័យថា កាត់បន្ថយឬដកចេញនូវវិធានការណ៍គាំពារនិយមដែលអាចផ្តល់នូវសម្បទានទៅវិញទៅមកណាមួយ (ប្រសិនបើប្រទេស A កាត់បន្ថយពន្ធគយលើផលិតផល X នោះប្រាសមក វិញប្រទេស B អាចកាត់បន្ថយពន្ធគយលើផលិតផល Y) ហើយគោលដៅចុងក្រោយគឺពន្ធគយស្មើសូន្យ (ឧទាហរណ៍ដូចជាមិនមានពន្ធគយឬកូតាជាដើម)។ ផ្ទុយមកវិញនៅក្នុង “ពិភពលោកបែបថ្មី” ការគាំពារនិយម គឺ មិនមានប្រយោជន៍ទេ ព្រោះវាធ្វើឲ្យប៉ះពាល់ដល់សង្វាក់ផលិតកម្មពិភពលោកដែលផលិតករក្នុងស្រុកជាផ្នែកមួយក្នុងនោះផងដែរ។ ការគាំពារនិយមនេះត្រូវបានជំនួសដោយការប្រុងប្រយ័ត្ន ពោលគឺអ្នករៀបចំគោលនយោបាយ ព្យាយាមការពារអ្នកប្រើប្រាស់ (ជាជាងអ្នកផលិត) ដោយកំណត់បទបញ្ញត្តិនិងបទដ្ឋានរបស់ទំនិញនិងសេវាកម្ម ដែលដាក់លក់នៅលើទីផ្សារក្នុងស្រុក។ ការលុបបំបាត់ភាពខុសគ្នានៅក្នុងបទបញ្ញត្តិ គឺជាផ្នែកសំខាន់មួយនៃការធ្វើពាណិជ្ជកម្មបើកចំហនៅក្នុងពិភពលោកបែបថ្មីនេះ។ ទោះយ៉ាងណាបទបញ្ញត្តិមិនអាចត្រូវដោះដូរបានងាយស្រួលដូចពន្ធគយនោះទេ ដោយហេតុថា ប្រទេសមួយចំនួនទំនងជាមិនបន្ទាបបទប្បញ្ញត្តិសុខភាព និងសុវត្ថិភាព ដើម្បីជាថ្នូរនឹងដៃគូពាណិជ្ជកម្មឡើយ។ ការចរចាពាណិជ្ជកម្មនៅក្នុងពិភពលោកបែបចាស់គឺទាញ (ការគាំពារនិយម) ឲ្យធ្លាក់ចុះ ឯនៅក្នុងពិភពលោកបែបថ្មីគឺ ទាញ (ការប្រុងប្រយ័ត្ន) ឲ្យកើនឡើង [២៣, ២៤]។

វិធីនកោរផ្សើពាណិជ្ជកម្មបបែទំនឹបនេះនឹងពន្ធយល់ពីភាពស្មុគស្មាញនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់។ ខណៈពេលដែលបណ្ដាប្រទេសអាចបន្ទាបបទដ្ឋាន (ហើយអ្នកផលិតប្រហែលជាគាំទ្រលើការអនុវត្តបែបនេះ) អ្នកប្រើប្រាស់ និងក្រុមការពារអ្នកប្រើប្រាស់នឹងជំទាស់បះបោរ ដូចនេះគ្មានប្រទេសណាអាចធ្វើបែបនេះទេ បើខ្លួនចង់រក្សាធម្មានុរូបភាពតាមបែបប្រជាធិបតេយ្យ។ ពន្ធគយនិងកូតាមិនមានគុណតម្លៃជាបទដ្ឋានទេ ប៉ុន្តែវិធានការណ៍បង្ការទុកជាមុន (ឧទាហរណ៍ដូចជាបទប្បញ្ញត្តិជាដើម) គឺជាការគ្រប់គ្រងហានិភ័យនិងជាការទទួលយកគុណតម្លៃជំផេង (value-laden) [២៣, ២៤]។ ដោយសារគុណតម្លៃទទួលឥទ្ធិពលពីវប្បធម៌ ហើយប្រទេសផ្សេងគ្នាមានវប្បធម៌ខុសៗគ្នា ការធ្វើពាណិជ្ជកម្មបើកចំហនៅក្នុងពិភពលោកថ្មី (ឧទាហរណ៍ដូចជាការធ្វើសុខដុមនីយកម្មនៃបទប្បញ្ញត្តិជាដើម) បានក្លាយជាបញ្ហាដ៏លំបាកមួយ (Gordian knot) [១៧]។

សារៈសំខាន់នៃធម្មានុរូបភាពតាមបែបប្រជាធិបតេយ្យត្រូវបានកត់សម្គាល់ដោយសហភាពអឺរ៉ុបក្នុងអំឡុងពេលនៃកិច្ចចរចាភាពជាដៃគូពាណិជ្ជកម្មនិងវិនិយោគអាត្លង់ទិក (Transatlantic Trade and Investment Partnership, TTIP)។ គោលបំណងនៃ TTIP គឺការរួមបញ្ចូលគ្នានៃក្របខ័ណ្ឌគតិយុត្តិរបស់សហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិក ប៉ុន្តែទោះបីភាគីទាំងពីរមានបទដ្ឋានខ្ពស់រួចហើយក៏ដោយ ក៏វាហាក់បញ្ជាក់ឲ្យឃើញថា មានភាពស្មុគស្មាញខ្លាំងនៅក្នុងការចុះសម្រុងគ្នា។ លើសពីនេះទៀតពលរដ្ឋអឺរ៉ុបជាច្រើនយល់ឃើញថា TTIP ជាការគំរាមកំហែងដល់គំរូបទបញ្ញត្តិរបស់សហភាពអឺរ៉ុប ដែលត្រូវបានប្រើក្នុងសុន្ទរកថាជាសាធារណៈនៃការតវ៉ាប្រឆាំង"ការសម្អាតមាន់ដោយប្រើទឹកក្លរ" (chlorinated chicken) ដែលមានការអនុញ្ញាតិឲ្យលក់នៅសហរដ្ឋអាមេរិក តែត្រូវបានហាមឃាត់នៅសហភាពអឺរ៉ុប [២៥]។ ឯកសារគោលនយោបាយ "ពាណិជ្ជកម្មសម្រាប់ទាំងអស់គ្នា" ដែលបានរៀបរាប់ខាងលើបានចេញផ្សាយនៅឆ្នាំ២០១៥ ប៉ុន្តែដោយសារការរិះគន់ជាសាធារណៈអំពី TTIP កំពុងឡើងដល់កម្រិតកំពូល បានធ្វើឲ្យការចរចារបស់ TTIP ឈានទៅរកការជួលលំ (ការចរចាបានបញ្ចប់ក្នុងឆ្នាំ២០១៦ ហើយក្រុមប្រឹក្សាសហភាពអឺរ៉ុបបានចេញសេចក្តីណែនាំថាការចរចានេះផុតកំណត់នៅឆ្នាំ២០១៩ [២៦])។ នៅក្នុង "ពាណិជ្ជកម្មសម្រាប់ទាំងអស់គ្នា" គណៈកម្មការសហភាពអឺរ៉ុបបានលើកឡើងពីអ្វីដែលបានរៀនពីបញ្ហានេះ ហើយបានប្ដេជ្ញាថា នឹងមានតម្លាភាពថែមទៀតក្នុងការចរចាពាណិជ្ជកម្មនាពេលអនាគតដោយធ្វើសេចក្តីណែនាំស្តីពីការចរចា និងលទ្ធផលជាសាធារណៈឲ្យទាន់ពេលវេលា [២២]។

## គុណតម្លៃ និងភាពអនុគ្រោះរបស់សហភាពអឺរ៉ុប

ដូចដែលបានបញ្ជាក់ខាងលើសហភាពអឺរ៉ុបបានដាក់បញ្ចូលគ្នានូវគោលនយោបាយពាណិជ្ជកម្មជាមួយនឹងអំណាចបទដ្ឋាន និងបំណងក្នុងការអភិវឌ្ឍពិភពលោក។ ឧទាហរណ៍នៃគោលការណ៍នេះគឺ "ប្រព័ន្ធអនុគ្រោះទូទៅ" (General System of Preferences) ដែលកាត់បន្ថយឬដកពន្ធគយលើការនាំចូលផលិតផលពីបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ ក៏ដូចជាប្រព័ន្ធអនុគ្រោះពន្ធគ្រប់មុខទំនិញលើកលែងតែសព្វាវុធ (Everything But Arms) ដែលដកចេញនូវកាតព្វកិច្ចនិងកូតាទាំងអស់ (លើកលែងតែសព្វាវុធ) សម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួចបំផុតចំនួន៤៩ [១៧]។ ឯកសារគោលនយោបាយអឺរ៉ុបបានលើកឡើងយ៉ាងច្បាស់ពីសារៈសំខាន់នៃការអនុវត្ត "យុត្តិធម៌សង្គម ការគោរពសិទ្ធមនុស្ស បទដ្ឋានការងារខ្ពស់ និងបរិស្ថាន និងការការពារសុខភាពនិងសុវត្ថិភាព" តាមរយៈគោលនយោបាយពាណិជ្ជកម្ម [២២, ទំ.២២]។

អ្នកសិក្សាខ្លះបានជំទាស់ថាភាសាដែលជាបទដ្ឋាននៅក្នុងឯកសារគោលនយោបាយរបស់សហភាពអឺរ៉ុប គឺគ្រាន់តែជាកិច្ចសន្ទនាដែលគ្មានខ្លឹមសារជាមួយនឹងការរំលេចពីតថភាពតិចតួចដែលប្រែប្រួលឡើងឬចុះ អាស្រ័យលើអ្នកណាជាស្នងការសហភាពអឺរ៉ុបសម្រាប់ពាណិជ្ជកម្ម[១៥]។ ទោះយ៉ាងណា នៅក្នុងគណៈកម្មការសហភាពអឺរ៉ុប កិច្ចសន្ទនាអំពី "ការតម្រង់គោលនយោបាយពាណិជ្ជកម្មជាមួយនឹងគុណតម្លៃរបស់អឺរ៉ុប" [២២, ទំ.២៤] ហាក់ដូចជាមានឥទ្ធិពលពិតប្រាកដនៅក្នុងអាស៊ាន។ ការចូលរួមរបស់សហភាពអឺរ៉ុបក្នុងគំនិតផ្ដួចផ្ដើម ដើម្បីលើកកម្ពស់សិទ្ធិការងារ និងការអនុវត្តការងារជាមូលដ្ឋាននៅប្រទេសមីយ៉ាន់ម៉ាត្រូវបានលើកឡើងនៅក្នុង "ពាណិជ្ជកម្មសម្រាប់ទាំងអស់គ្នា" ដែលជាមធ្យោបាយនៃ "ការគ្រប់គ្រងប្រកបដោយទំនួលខុសត្រូវលើខ្សែសង្វាក់ផ្គត់ផ្គង់ជាសកល" [២២] ។ ការដកផ្នែកខ្លះនៃប្រព័ន្ធអនុគ្រោះពន្ធ EBA សម្រាប់កម្ពុជាបន្ទាប់ពីគណៈកម្មការសហភាពអឺរ៉ុបបានសម្រេចថា រាជរដ្ឋាភិបាលកម្ពុជាមិនបានអនុវត្តគ្រប់គ្រាន់ដើម្បីបន្ធូរបន្ថយ "កង្វល់ធ្ងន់ធ្ងរ" លើករណីមិនទាន់ដោះស្រាយដែលពាក់ព័ន្ធនឹងសហជីពកម្មករ [២៨] គឺជាឧទាហរណ៍មួយរបស់សហភាពអឺរ៉ុបដែលប្រើប្រាស់គោលនយោបាយពាណិជ្ជកម្មជាឧបករណ៍នយោបាយ។

ទោះជាយ៉ាងណា គោលនយោបាយបែបនេះហាក់មិនសូវមានប្រសិទ្ធភាព នៅពេលដែលពិភពលោកឈានទៅរកការធ្វើពាណិជ្ជកម្មនៃពិភពលោកមួយដែល លោក Lamy ឲ្យឈ្មោះថា“ពិភពលោកបែបថ្មី”ហើយប្រព័ន្ធអនុគ្រោះពន្ធ EBA និងប្រព័ន្ធអនុគ្រោះផ្សេងទៀត (ឬការបដិសេធមិនផ្តល់ប្រព័ន្ធទាំងនេះ) កាន់តែពិបាកបង្ហាញឲ្យឃើញថាសមហេតុផល នៅក្នុងពិភពលោកបែបថ្មីនេះ។ គេមិនអាចផ្តល់អត្ថប្រយោជន៍នៃបទបញ្ញត្តិដល់អ្នកផលិតមកពីប្រទេសមួយចំនួន និងមិនផ្តល់ដល់អ្នកផលិតមកពីប្រទេសដទៃទៀតទេ ព្រោះវានឹងធ្វើឲ្យផ្ទុយគោលបំណងទាំងមូលនៃបទបញ្ញត្តិជាប្រព័ន្ធ (ឧទាហរណ៍ដូចជាការគ្រប់គ្រងហានិភ័យសម្រាប់អ្នកប្រើប្រាស់ជាដើម) [២៣,២៤]។ ជាលទ្ធផលខណៈដែលកិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងអស់របស់សហភាពអឺរ៉ុបក្នុងទសវត្សរ៍ចុងក្រោយមានជំពូកមួយស្តីពី “ការអភិវឌ្ឍប្រកបដោយចីរភាព” [១៥] សម្ពាធបទដ្ឋានខាងក្រៅ (external normative pressure) ធ្វើឲ្យពិបាកក្នុងការអនុវត្តគោលនយោបាយពាណិជ្ជកម្ម ហើយជំពូកទាំងនោះមានហានិភ័យក្នុងការក្លាយជាកិច្ចសន្ទនាដែលមិនអាចប្រតិបត្តិបាន។

## តួនាទីរបស់សហភាពអឺរ៉ុបនាពេលអនាគតក្នុងពាណិជ្ជកម្មដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន

សហភាពអឺរ៉ុបនឹងនៅតែជាអ្នកគាំទ្រយ៉ាងខ្លាំងនៃប្រព័ន្ធពាណិជ្ជកម្មពហុភាគីអាស្រ័យច្បាប់ដ៏រឹងមាំ។ សេដ្ឋកិច្ចរបស់សហភាពអឺរ៉ុបត្រូវបានធ្វើសមាហរណកម្មយ៉ាងស៊ីជម្រៅទៅក្នុងខ្សែសង្វាក់តម្លៃជាសកល ដែលធ្វើឲ្យខ្លួនមិនអាចមិនគាំទ្រប្រព័ន្ធនេះបាន។ ទោះជាយ៉ាងណា ដរាបណាអង្គការពាណិជ្ជកម្មពិភពលោកនៅតែស្ថិតក្នុងជំហរជាប់គាំងមួយដែលខ្លួនមិនអាចអភិវឌ្ឍកិច្ចព្រមព្រៀងថ្មី ឬតែងតាំងសមាជិកថ្មីទៅកាន់ស្ថាប័នឧទ្ធរណ៍ សហភាពអឺរ៉ុបទំនងជានឹងនៅតែបន្តពង្រីកកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីនិងពហុភាគី។

លើសពីនេះទៀតខណៈពេលដែលគុណតម្លៃបទដ្ឋាននៅតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងរាល់កិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មីរបស់សហភាពអឺរ៉ុប ការអនុវត្តទិដ្ឋភាពបទដ្ឋាននៃកិច្ចព្រមព្រៀងនេះក៏ប្រហែលជាការអនុវត្តតែខាងក្រៅប៉ុណ្ណោះ។

ទីបំផុត (អំឡុងពេលសរសេរអត្ថបទនេះ) ការចរចា Brexit ដែលកំពុងបន្តនិងការរះឡើងនៃការរិះគន់លើសហភាពអឺរ៉ុបនិងសមាហរណកម្មរបស់ខ្លួន (Euroscepticism) (ក្រុមសមាជិកសភាដែលរិះគន់លើសហភាពអឺរ៉ុប “អត្តសញ្ញាណនិងប្រជាធិបតេយ្យ” ពេលនេះមាន ៧៦ ក្នុងចំណោម ៧០៥ អាសនៈនៅក្នុងសភានៃសហភាពអឺរ៉ុប បន្ទាប់ពីសមាជិកសភាអង់គ្លេសបានចាកចេញ) ធ្វើឲ្យជំហររបស់សហភាពអឺរ៉ុបមានភាពមិនច្បាស់លាស់។ សហភាពអឺរ៉ុបទំនងជាចង់រក្សាចក្រភពអង់គ្លេសនៅក្នុងបរិវេណបទប្បញ្ញត្តិរបស់ខ្លួន។ ស្របពេលនេះដែរ ដូចដែលកំហឹងសាធារណៈជុំវិញ TTIP បានបង្ហាញថា សហភាពអឺរ៉ុបមិនមានលទ្ធភាពបង្កើតកិច្ចព្រមព្រៀងទ្វេភាគី ដែលត្រូវការការកែទម្រង់បទប្បញ្ញត្តិដោយគ្មានតម្លាភាពនិងការចូលរួមតាមបែបប្រជាធិបតេយ្យទេ ប្រសិនបើចង់ឲ្យការរិះគន់លើសហភាពអឺរ៉ុបនិងសមាហរណកម្មនៅនឹងមួយកន្លែង។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានសភាកម្ពុជា (PIC)។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ ៖ https://www.pcasia.org ។

# ២.៤ REFORMING THE WORLD TRADE ORGANIZATION: TOWARDS A SUSTAINABLE AND EFFECTIVE MULTILATERAL TRADING SYSTEM

## THE WTO MATTERS BUT IT IS IN CRISIS.

According to the EU Commission [29], World trade has expanded 300-fold since the foundation of the multilateral system in 1947 and today contributes more than 60% of global GDP, supporting jobs, growth and investments, partly thanks to successive reductions in tariffs negotiated through the multilateral system. Today the world's applied tariffs stand at an average of 9%, made possible by the stability the system provides. The WTO's most-favored nation principle (MFN) limits discrimination between goods and services from different trading partners.

The WTO framework provides a stable floor of economic openness whereby 60% of EU trade is conducted on MFN terms, including trade with the United States, China, Russia and India. The rules of the WTO protect the interests of all trading nations against discriminatory, behind-the-border action and ensure that contingent trade protection is based on multilaterally agreed mechanisms. Though more needs to be done, the WTO has also contributed to global sustainable development. The economic openness it has guaranteed has helped many developing countries into the world economy, lifting hundreds of millions of people out of poverty.

The EU Commission found that, the current crisis affecting the WTO affects all three of its functions: negotiations have failed to modernize its rules, the dispute settlement system has made a de facto return to the days of the General Agreement on Tariffs and Trade (GATT) where panel reports can be blocked, and the monitoring of trade policies has become ineffective.

> *"The rules of the WTO protect the interests of all trading nations against discriminatory, behind-the-border action and ensure that contingent trade protection is based on multilaterally agreed mechanisms."*

In addition, the trade relationship between the US and China, two of the three largest WTO members, is currently managed outside of WTO mechanisms. A key driver of the crisis is that China's accession to the Organization has not led to its transformation into a market economy. The level at which China has opened its markets does not correspond to its weight in the global economy, and the state continues to exert a decisive influence on China's economic environment that results in competitive distortions that cannot be sufficiently addressed by current WTO rules.

But the WTO has not been able to negotiate new rules to tackle this or other pressing issues, such as digital trade and sustainability. Reaching consensus among 164 members against the backdrop of today's diffuse global balance of power is a huge challenge. Negotiations are also held back by disagreements about flexibilities for developing countries. The current situation is not sustainable, where two thirds of the membership - including some of the world's most significant economies – insist on special and differential treatment.

> *Not only is trade vital for its connected economy, but promoting rules-based international cooperation is the very essence of the European project.*

Further, the WTO's monitoring and deliberative function is being seriously challenged by insufficient transparency about members' trade legislation and practices, and the fact that topics such as environmental degradation, climate change and decent working conditions are considered taboo. Last but certainly not least, the dispute settlement system was effectively paralyzed at the end of 2019 due to the full-scale obstruction of appointment of Appellate Body members by the United States.

## THE URGENT NEED FOR REFORM

The current context presents unique problems for an organization that seems to have lost its sense of common purpose, but a stable trading environment with the WTO at its centre is more essential than ever to address the challenges before us, starting with the economic recovery from the pandemic. The EU has a fundamental strategic interest in ensuring the effectiveness of the WTO. Not only is trade vital for its connected economy, but promoting rules-based international cooperation is the very essence of the European project. The EU must therefore play a leading role in building the momentum for meaningful WTO reform.

## SEVERAL OBJECTIVES SHOULD BE PURSUED

Restoring trust and a sense of common purpose: the WTO's contribution to sustainable development

- Concluding the negotiations on fisheries subsidies would be an important step towards solidifying the WTO's contribution to sustainability.
- The EU has presented together with the Ottawa Group a trade and health initiative covering regulations on export restrictions and several trade facilitating measures and steps to facilitate transparency.
- Many SDGs relate to protection of the environment (and biodiversity), and as such the WTO should seek to align its rules with their achievement.
- The EU views sustainability as part of the necessary green transition of economies, and so will work to see this reflected in the WTO's work across the board. To this end, the EU will soon present an initiative on trade and climate in the WTO.

## HOW CAN TRADE CONTRIBUTE TO DEVELOPMENT?

There is a need for a forward-looking approach to special and differential treatment. One of the founding objectives of the WTO is to ensure that developing countries, and especially the least developed among them, secure a share of the benefits of international trade commensurate with the needs of their economic development. 'Special and differential treatment' (SDT) is meant to enable developing countries to make the best use of the opportunities for development that WTO membership offers.

The EU is a strong supporter of SDT but believes its use must be guided by the underlying economic reality that trade

> *"Those developing economies that have seen the most consistent growth are those that have focused their efforts on integrating into the global economy and progressively opening their markets to greater competition."*

is a driver of development, rather than a threat. Those developing economies that have seen the most consistent growth are those that have focused their efforts on integrating into the global economy and progressively opening their markets to greater competition. The great development challenge for the WTO is how the Organization can effectively assist the efforts of those developing countries that are not yet sufficiently integrated into the global economy.

In terms of process, an 'agreement-by-agreement' approach appears to be the most likely to deliver real progress on SDT. While it would be desirable that all WTO members agreed on crosscutting criteria for SDT, it is more realistic to try to find convergence in specific negotiations. Still, the EU's approach will be guided by some overall considerations. The EU would strongly support SDT provisions that effectively respond to the capacity constraints of most developing countries. At the same time, the EU expects full commitments in ongoing negotiations and future agreements from a) OECD members (including OECD accession candidates); b) countries classified as 'high income' by the World Bank; and c) countries that represent a sufficiently high share of global exports in general or in the sectors concerned by a particular negotiation. Due to its weight in the system, China should lead by example and not claim SDT in any ongoing negotiations.

## RESTORING A FULLY FUNCTIONING WTO DISPUTE SETTLEMENT SYSTEM WITH A REFORMED APPELLATE BODY

The most urgent of WTO reforms is finding an agreed basis to restore a functioning dispute settlement system and to proceed to the appointment of the members of the Appellate Body. This task should be addressed as a priority and not be linked to the other aspects of WTO reform. In the absence of a functioning dispute settlement system, it is difficult to see what the motivation for countries could be to modernize and fill gaps in the rules.

## TOWARDS A MORE EFFECTIVE NEGOTIATING FUNCTION

At the heart of the crisis in the WTO lies the failure of its negotiating function. WTO reform should therefore aim at restoring the effectiveness and credibility of the WTO as a forum for the negotiation of trade rules and further liberalization. WTO rules need to be brought into line with the economic and trade realities of the 21st century.

On substance, the priority should be to modernize the rules of the WTO on e-commerce, investment facilitation, domestic regulation of services, and on the role of the state in the economy, including on subsidies. Once rules are modernized, consideration could also be given to advancing liberalization regarding goods and services in a manner that ensures a better balance of commitments. As for the method for negotiations, where a single undertaking approach has failed to deliver, progress can be best achieved through different processes, including open, plurilateral agreements. In parallel to substantive negotiations, WTO members should reflect on ways of better integrating plurilateral agreements into the WTO framework.

> *Many WTO members are of the view that China's market access and other commitments do not sufficiently reflect its growth, and that further liberalization by China would confer greater legitimacy on its role in the organization.*

The last challenges are to reinforce the monitoring and deliberative functions of the WTO and to achieve WTO reform through building alliances and engaging in discussions with China and India on the different aspects of the WTO reform agenda. China's per capita GDP has increased by a factor of 10 since its WTO accession, and China has become the WTO's largest exporter during just two decades. Many WTO members are of the view that China's market access and other commitments do not sufficiently reflect its growth, and that further liberalization by China would confer greater legitimacy on its role in the organization. India has a highly dynamic economy and is a leading player in the G20, although its overall level of development and competitiveness cannot be compared to that of China. Both countries are indispensable partners for substantive WTO reform discussions.

Discussions with China and India should help to better understand the respective perspectives of WTO members, including on the issues for which progress should be achieved at the 12th Ministerial Conference (MC12) scheduled to take place from 30 November to 3 December 2021 in Geneva, Switzerland. Three areas where work should intensify prior to MC12 are trade and health, fisheries subsidies, and the reform of the dispute settlement system.

In addition, the following outcomes could be achieved by MC12:

- An agreement reached to reinvigorate WTO work on trade and environment in view of mainstreaming sustainability issues in the WTO's work. Ideally, this should be done multilaterally, although certain elements may only be pursued by subgroups of interested WTO members, such as liberalization regarding selected climate-mitigating goods and environmental services.
- Work launched amongst interested countries on the development of rules on competitive neutrality, including modernized rules on industrial subsidies.
- Substantial progress recorded on the plutilateral initiatives on e-commerce and investment facilitation and the conclusion of the Joint Statement Initiative on domestic regulation of services.
- The renewal of the multilateral e-commerce and TRIPS moratoria.
- Improvements to the WTO's regular work function, through agreements on the horizontal transparency in notifications and trade concerns proposals.
- On agriculture, agreement reached on a package of transparency improvements across the board and on export restrictions. The initiative on the exemption of the World Food Programme humanitarian purchases from export restrictions could also be part of such an outcome. The EU is open to discuss how to progress after MC12 on the main aspects of the negotiations, on trade distorting domestic support.

# ២.៥ ASEAN PREPARING FOR A POST-PANDEMIC RESILIENT RECOVERY

As ASEAN and its Member States work towards recovery from COVID-19, governments must balance between health protection and economic costs, as a long-term recovery plan is vital for the region to build back better and emerge stronger. A sustainable and resilient path to economic and social recovery is thus a key priority for ASEAN as a whole as well as for individual members.

While production activity is resuming as lockdowns are eased and vaccination campaigns are rolled-out in many ASEAN Member States (AMS), uncertainty remains as weak global demand and unemployment are likely to prevail, of particular concern to the informal sector, tourism, and manufacturing where value chains have been highly disrupted. Despite the challenges, the region could seize upon the opportunities that have arisen. For instance, the disruptions may lead to the promotion of skills advancement as economies upgrade toward digitalization, e-commerce and technology creation [33].

It is, therefore, crucial that governments continue to provide support to ensure that businesses are able to return to their pre-crisis production and employment levels while maximizing absorption capacity. There is now an important nexus between production networks, digitalization, skills upgrades, and other cross-cutting issues to be addressed with more resilient and forward-looking policies that will help ASEAN to kick-start the regional economic recovery.

The "ASEAN Comprehensive Recovery Framework", formed by the mandate of the 37th ASEAN Summit in November 2020, has been developed to lay the foundation for sustainable recovery

[B] [35]. The framework covers a three phase-approach, outlined in Figure 4.1, starting first with "Reopening", the specifics of which will vary for each Member State, the "Recovery," when activity picks up and where support is needed for severely affected sectors or groups, and finally

**Figure 4.1: The three phase-approach of the recovery strategy for ASEAN**

| | |
|---|---|
| **Re-opening** | • A period of differing states of epidemological status<br>• Close cross-sectoral coordination is required for a safe reopening<br>• In this phase, economies re-open safely, while minizing the risk of resurgence of the virus |
| **Recovery** | • The timeframe for this phase will last until a full recovery is achieved<br>• Focus on assisting sectors/groups that have been adversely affected by the pandemic<br>• At the end of this phase, economic activities will be back to pre-COVID levels |
| **Resilience** | • A period of converging with the longer-term ASEAN's shared vision<br>• Focus on contributing towards long-term regional resilience<br>• The phase is cognizant of the new trends and emerging challenges and the risk of future pandemic (s) |

Source: ASEAN Secretariat (2020), ASEAN Comprehensive Recovery Framework, p18 [35]

"Resilience", preparation for emerging trends and future crises towards long-term sustainability.

## IMPLICATIONS FOR ASEAN SUPPLY CHAINS IN ECONOMIC RECOVERY

The three-stage approach framework is accompanied by an implementation plan that outlines a series of broad strategies, in which Broad Strategy 3: "Maximizing the potential of intra-ASEAN market and economic integration" focuses on enhancing supply chains and trade facilitation. The overall strategy, consisting of key priorities and initiatives in enhancing manufacturing supply chains in ASEAN, is summarized below.

**Strengthening supply chain connectivity:** It is important for ASEAN to have sustained connectivity across the region given the experience of supply chain challenges. The purposes of sustained connectivity are to maintain regional production networks and to reduce the high dependency of supplies from specific external markets. This can be achieved through resilient infrastructure [36], with priorities on ensuring connectivity of both hard and soft infrastructure to facilitate movement of goods, services and labor, deepening and widening the connection among producers and suppliers to reduce costs of global value chains (GVCs), and promoting public-private partnerships. This priority is compatible with the Master Plan for ASEAN Connectivity 2025, which aims to enhance regional outlets that cover a set of five strategies: sustainable infrastructure, digital innovation, seamless logistics, regulatory excellence, and people mobility [37]. To alleviate governments' budget pressure after the pandemic, public-private partnerships can help to facilitate infrastructure development through private sector investment [31]. Other initiatives may include supporting and clustering smallholder businesses to increase productivity and market access (particularly in Cambodia, Laos, Myanmar and Vietnam), connecting small producers and large enterprises, developing trade routes to address key checkpoint barriers, and exploring the possibility of establishing a database for ASEAN manufacturers and exporters for essential goods to avoid delays in the paperwork process [35].

**Diversification of supply networks:** While strengthening regional connectivity is important, this should not limit the opportunity for the region to diversify production networks and expand market potential to scale up trade routes across the GVCs [36]. The pandemic has been a signal for manufacturers and businesses in the region to reduce reliance in sourcing inputs from particular countries, and diversify the supply sources to a range of destinations, taking into consideration geographical locations and costs of distribution. In addition, greater relocation of production away from China to ASEAN is seen in the experience of the US-China trade war, when producers relocated or created new factories in ASEAN to avoid paying higher import tariffs when exporting goods to the US. Analysis of the Production Relocation Index identified Vietnam, Malaysia and Singapore as the countries most benefiting from the diversion of production and FDI from China during the trade war period [38]. The plan to relocate or establish new investment to ASEAN can be repeated as businesses look at diversifying the source of production after the pandemic. Therefore, it is important for ASEAN to identify and reap the advantage of the relocation opportunities and prepare itself to attract new businesses [32].

**Investment in technology and digitalization:** As AMS start to reopen the economy, adoption of new technology particularly as seen in Industrial Revolution 4 (such as artificial intelligence, Internet of Things)






will give firms the opportunity to secure and gradually increase production when demand picks up [39]. Empowering businesses including SMEs to adopt digital connectivity can help set the foundation for longer-term productivity, competitiveness and sustainability [30]. In addition, while companies consider shifting their production back to their countries, reshoring of production might be more economical due to labor and relocation costs, the shifts made possible by technology and automation of manufacturing where people can work remotely without worrying about supply disruptions and health risks [32].

Digital connectivity is essential to facilitate not only e-commerce activity, but also overall economic digitalization. ASEAN as a whole is one of the world's fastest-growing online markets, with e-commerce expected to grow by 25%-35% on average per year during the 2020s [40]. While ASEAN has a generally satisfactory quality of infrastructure, the development of technological-related infrastructure is uneven, both between and within countries. As digital connectivity is a broad topic, a policy brief by Chen and Ruddy (2020) proposes a framework of three basic components: data, logistics and financial connectivity. Figure 4.2 shows their relationship, suggesting that "how effectively they intersect with one another depends on seamless links between the cyberspace and physical networks, which then determines the overall quality of digital connectivity for e-commerce" [40]. To streamline these connections, the region-wide priorities may include the following efforts [40]:

- Collaborating on national and regional rule-setting for connectivity which covers traditional trade issues and new issues such as cross-border information flow, data localization and protection.

- Enhancing digital-related infrastructure (through public investment and public-private partnership), and establishing a digital-friendly environment to ensure accuracy and fairness of information access, payments and competition.
- Promoting value-added in the service sector to ensure that connectivity is speedy, reliable and transparent, and to support the inclusion of SMEs.

**Trade and investment facilitation and liberalization:** Further opening the ASEAN market is important to attract multinational enterprises as they are seeking to relocate their production base given the interruptions of GVCs. Supportive policy actions include minimizing non-tariff measures and reducing market distorting policies (refers to any interventions, such as price ceilings and tax subsidies, imposed by a governing body that constrains the market in reaching optimal market prices) which would contribute to greater intra-ASEAN trade and investment. Establishing a conducive investment regulatory environment is an important instrument to facilitate investment and encourage large enterprises to balance their investment portfolios which could ensure sufficient supply [39]. The ASEAN Comprehensive Recovery Framework also proposes the following initiatives: 1) ensuring smooth customs procedures by leveraging digital technology to keep goods moving while limiting unnecessary human interaction, 2) applying financial technologies to facilitate cross-border trade and transactions, and 3) working towards wider acceptance of digital documents to facilitate seamless trade in the region so that traders do not have to maintain both digital and paper-based documents for customs clearance [33,35].

Building a competitive ASEAN single market: As ASEAN could be seen as potential alternative sites for international firms seeking to diversify their production base, the region must expedite trade integration and push toward a competitive single market to better compete with the larger markets of China and India. However, it should be recognized that while relocating a final production base, firms themselves may be dependent on raw material supplies and sub-assembly components from those larger markets, which could hinder the relocation process [32]. As such, it is vital that ASEAN collectively coordinate and defend rules-based trading and foster regional trade agreements. For example, the Regional Comprehensive Economic Partnership (RCEP) can serve as a multilateral mechanism to push for outward-looking trade and guard against protectionism, helping to bolster ASEAN and give it stronger negotiation powers [32].

Investment in human capital, skills development and social protection: Investment in human capital is essential to allow citizens to participate in economic activities, move to a more innovative and productive livelihood, and share the full benefits of the recovery process [34]. This inclusive goal can be achieved through strengthening social protection to increase access to better public services including health care and skills enhancement. Funding of social services helps protect the most vulnerable households from falling into poverty while providing support to informal workers. Skills training can be done online within countries as well as across the region on general topics such as communication, or on specific professional skill sets such as accounting [35].

## PARLIAMENTS' ROLE IN SUPPORTING SUPPLY CHAIN CONNECTIVITY

Through their functions of legislation, representation and oversight, Parliaments can accelerate and expand regional connectivity

for a resilient recovery from COVID-19. Through legislative power, parliaments can initiate or propose measures necessary to mitigate the impacts of the pandemic on the economy and citizens. Relevant legislation may deal with such subjects as trade and investment agreements, taxation and customs-excise regimes, infrastructure and digital technology projects, all of which would link closely to budget bills. Many parliaments in the region, for example, have adopted emergency stimulus packages for this purpose during 2020. Alternative agreements with external partners could also be sought, such as in the case of the Comprehensive and Progressive Agreement for the Trans-Pacific Partnership [C] and the Regional Comprehensive Economic Partnership [D] in which members of ASEAN have integrated into both cross-regional and intra-regional trade agreements.

Production networks can also be strengthened through digital infrastructure and technology supported by parliaments. For instance, as part of the legislative mandate, the International Trade Committee of the European Parliament has adopted a report on blockchain technology to promote global value chains and trade, as blockchain stimulates collaboration, promotes transparency and reduces the procedural costs of paperwork [42].

Parliaments also play a significant role in overseeing, monitoring and communicating executive actions to help ensure fair and inclusive support for a sustainable re-opening and recovery processes. Parliaments may conduct public hearings and have discussions with the executive branch on COVID-19 impacts and plans for improved supply chain connectivity. Through this mechanism, parliament can follow up and conduct oversight over the government to ensure the executive's accountability and transparency. For example, Singapore's Members of Parliament questioned the Minister of Trade and Industry in 2020 on how the accelerating shifts of the global supply chain due to supply disruption would affect Singapore's economy and what measures would be taken by the executive branch on this issue [43].

Efforts could also be taken in cooperation with business and citizens to represent and address concerns on employment, skills upgrading and social protection to better enable them to participate and benefit from growth. Research and educational services may be utilized to provide information on relevant industrial sector issues, while outreach and media workshops could be used at the local level to disseminate information on policy actions to the public.

At the regional level, the ASEAN Inter-Parliamentary Assembly (AIPA) as an institution has provided a platform for Member Parliaments to share and discuss collective actions, together with external parliaments such as those from other countries in Asia and the EU [41]. The promotion of regional supply chains is not a new topic for AIPA, which has championed the concept through its support for ASEAN economic integration, ASEAN trade liberalization, ASEAN Connectivity 2025 and ASEAN Economic Community 2025.

# ២.៦ EUROPEAN UNION RECOVERY PLAN (NEXT GENERATION EUROPE)

## THE POST-COVID-19 ECONOMY

According to François Villeroy de Galhau, Governor of the Bank of France [44, p.2],

> The European economy following the COVID-19 pandemic should integrate three improvements: greener, more digital and more resilient. In so doing, it can contribute to meeting the strong expectations of the rising generations, who vigorously demand an economy with more respect for the planet that is more sensible and ethical, and respects social justice. This challenge is fundamentally very encouraging, and it is our very European values that are driving it. We Europeans can be the champions of a social and sustainable market economy. I write with this conviction - enough of a Europe that lurks in the shadows! The chaotic world of 2021 needs a Europe that leads with its hope and ambition [E].

## THE EUROPEAN RECOVERY PLAN (NEXT GENERATION EU)

The recovery plan decided at the European Council in July 2020 includes €750 billion in loans and grants that will be distributed through the Recovery and Resilience Fund (RRF). To have access to it, States must submit to the Commission national recovery plans presenting the related reforms and public investments. Member countries must have the objectives of creating jobs, supporting growth, increasing economic and social resilience, and promoting digital and green transitions. The European/EU funds will be combined with national plans already established in mid-2020 to alleviate the recessionary effects of the pandemic crisis.

Recovery plans must also present flagship initiatives in seven areas: clean and renewable energies, building renovation, access to the recharging networks, connectivity, digitalization of the public sector (including health and justice), industrial data storage and digital education. In each, 37% of funds must contribute to the climate transition and at least 20% to the digital transition [44, pp.2-3].

The European Commission has firmly framed the national proposals by indicating its priorities of ecological transition and digitization of activities. Most beneficiary countries rightly emphasize structural reforms (administration, health, education). Their implementation is highly dependent on sustained political support provided to the governments responsible for them. In other countries, the recovery plan provides a fiscal supplement to policies aimed at achieving a low-carbon economy.

At the sectoral level, the renovation of buildings (Germany, France) and transport systems (Belgium, Portugal), the all-out development of alternative energies hydro-wind, hydrogen, solar), the strengthening of health systems and the immense field of digitization (particularly in education and in SMEs) are clearly shared and sustainable priorities that deserve the attention of investors in the long term [44, p.11].

### Schedule

EU countries have already presented their national recovery plans to the European Commission, in April 2021. After examination

by the Commission, they were submitted to the European Council. Disbursement of funds from the Recovery and Resilience Facility will be spread over three years, between 2021 and 2023, of which 70% will be for the first two years, with 13% of funds available during the summer of 2021.

Over this period, each country will receive a different allowance, defined according to three criteria: population, gross domestic product per capita and unemployment rate over the period 2015-2019. The remaining 30% will be paid in 2023 (with a criterion linked to the decline in GDP observed in 2020 and 2021). By 2023, two new instruments will be introduced: a mechanism for carbon adjustment at borders and a digital tax.

Other avenues mentioned are the use of the carbon market (trading system of the emissions quotas) possibly extended to air and maritime transport, as well as a tax on financial transactions. In 2028 the European recovery plan loans begin to be repaid, over 30 years, until 2058 [44, p.3].

## THE EUROPEAN UNION INNOVATES: A CARBON TAX AT THE BORDERS

According to Les Échos [45],

> The EU wants to put the world's first carbon border tax on track by which the European Commission wants to gradually subject the most polluting imports to the EU to the same rules as those imposed on local producers. The idea had been put forward in France at the end of the 2000s but no country had yet dared to implement it, when the European Commission presented a plan for its major border carbon tax project. More precisely, the EU wants to make this "carbon adjustment mechanism at the borders" one of the flagship tools in the fight against global warming.
>
> The principle is simple: impose a carbon price on certain imported products manufactured by companies outside Europe, in countries with less stringent environmental standards. A form of customs duty aimed at having the same climate change mitigation cost for national/regional production and imports is a world's first.
>
> The sectors of cement, steel and iron, aluminum, fertilizer and electricity - the most emitting - will be targeted. They represent 170 million tons of imported emissions. Importers to the EU will gradually be forced to purchase "emission certificates", based on the carbon price they would have had to pay if the goods had been produced in the European Union. From 2026, the date of entry into force of the system, importers will have to declare the quantity of emissions contained in the goods received.

The objective is threefold. First, to avoid relocating production and therefore the emission of greenhouse gases, called "carbon leaks", which threaten with the tightening of legislation. Second is to generate income, as the tool could bring in up to €10 billion per year which will go into the EU budget, in particular to finance the post-COVID recovery plan. Third, Europe hopes to encourage countries outside of the EU to reduce their emissions. The Commission's objective is very clear- to put a mechanism in place so that international climate action progresses to the extent that it never needs to be activated.

## FOOTNOTES

A. BRIC countries (Brazil, Russia, India, and China; i.e. countries on the brink of becoming developed countries)

B. The objectives of the Framework are: 1) to articulate and guide ASEAN sectors to assess, realign or expedite work and priorities, and 2) to outline a reference for cross-pillar engagement with and contribution from broader stakeholders.

C. This initiative includes 11 countries: Japan, Malaysia, Singapore, Vietnam, Brunei, Australia, New Zealand, Canada, Chile, Peru and Mexico.

D. This partnership consists of ASEAN members plus Japan, China, South Korea, Australia, New Zealand, and India.

E. Retrouver confiance en l'économie, Odile Jacob, 2021

## REFERENCES

1. WTO. (N/A). What is the WTO [Online]. Geneva: WTO. Available at: https://www.wto.org/english/thewto_e/whatis_e/whatis_e.htm [Accessed 15 Jan 2020].

2. Economic Online. (N/A). Why do countries trade? [Online]. Economics Online. Available at: http://www.economicsonline.co.uk/Global_economics/Why_do_countries_trade.html [Accessed 07 Jan 2020].

3. ASEAN. (N/A). ASEAN Economic Community [Online]. ASEAN. Available at: https://asean.org/asean-economic-community/ [Accessed 07 Jan 2020].

4. WTO, (2019). World Trade Statistical Review 2019. Geneva: WTO, Available at: https://www.wto.org/english/res_e/statis_e/wts2019_e/wts2019_e.pdf.

5. WTO. (2019). WTO Lowers Trade Forecast as Tensions Unsettle Global Economy [Online]. Geneva: WTO. Available at: https://www.wto.org/english/news_e/pres19_e/pr840_e.htm [Accessed 07 Jan 2020].

6. Harte, R., (2018). Multilateralism in international trade. Reforming the WTO. European Parliament

7. Inter-Parliamentary Union. (2018). 2018 Annual Session of the parliamentary Conference on the WTO. Highlight of the Session. WTO: The Way Forward. Geneva.

8. Basedow, R. (2018) „Strengthening the World Trade Organisation„, Bertelsmann Stiftung, Gütersloh.

9. Panagariya, Arvind (2018). President Donald Trump's Trade War: Multilateralism at Risk, Working Paper no. 2018-03, Columbia University (Deepak and Neera Raj Center on Indian Economic Policies (SIPA), 23 August.

10. Nottage, H. (2018). Trade in War's Darkest Hour: Churchill and Roosevelt's Daring 1941 Atlantic Meeting that Linked Global Economic Cooperation to Lasting Peace and Security. Victoria University of Wellington Law Review, 49(4), pp. 595-606, Available at: https://doi.org/10.26686/vuwlr.v49i4.5342 [Accessed 27 February 2020].

11. Atlantic Charter. (1941). [online] Available at: https://www.unmultimedia.org/searchers/yearbook/page.jsp?volume=1946-47&page=37&searchType=advanced [Accessed 27 February 2020].

12. The Schuman Declaration. (1950). [online] Available at: https://europa.eu/european-union/about-eu/symbols/europe-day/schuman-declaration_en [Accessed 27 February 2020].

13. Treaty of Rome. (1950). [online]. CM3/NEGO, opened for signatire 25 March 1957, entered into force 1 January 1958. Available at: https://www.europarl.europa.eu/about-parliament/en/in-the-past/the-parliament-and-the-treaties/treaty-of-rome [Accessed 27 February 2020].

14. Wolff, A. (2018). DDG Wolff: Trade and foreign policy have always been intertwined. [online] Available at: https://www.wto.org/english/news_e/news18_e/ddgra_09feb18_e.htm [Accessed 27 February 2020].

15. Orbie, J. and Martens, D. (2016) EU Trade Policy and Developing Countries: Towards a more Ethical Agenda? In: P. Garcia-Duran and M. Millet, ed., Different Glances at EU Trade Policy, Barcelona: CIDOB, pp. 73-82.

16. EU Commission (2018). EU concept paper on WTO reform. [online] Available at: https://trade.ec.europa.eu/doclib/docs/2018/september/tradoc_157331.pdf [Accessed 27 February 2020].

17. Jara, A. (2016) EU Trade Policy in the Multilateral Trading System. In: P. Garcia-Duran and M. Millet, ed., Different Glances at EU Trade Policy, Barcelona: CIDOB, pp. 11-22.

18. Cho, S. (2010). The Demise of Development in the Doha Round Negotiations. Texas International Law Journal, 45, pp. 573-601.

19. Edward, R. and Harte, N. (2018) Multilateralism in international trade: Reforming the WTO. [online] European Parliamentary Research Service. Available at: https://www.europarl.europa.eu/thinktank/en/document.html?reference=EPRS_BRI(2017)603919 [Accessed 27 February 2020].

20. US Trade Representative (2018) The President's Trade Policy Agenda. [online] US Trade Representative (USTR). Available at: https://ustr.gov/sites/default/files/files/Press/Reports/2018/AR/2018%20Annual%20Report%20I.pdf [Accessed 27 February 2020].

21. Dickinson, E.M. (2013). The Doha Development Dysfunction: Problems of the WTO Multilateral Trading System. Global Business Law Review, 3(2), pp. 229-250.

22. European Commission (2015). Trade for All: Towards a more responsible trade and investment policy. [online] European Union. Available at: https://trade.ec.europa.eu/doclib/docs/2015/october/tradoc_153846.pdf [Accessed 27 February 2020].

23. Lamy, P. (2015). The new world of trade: The third Jan Tumlir Lecture, Jan Tumlir Policy Essays, No. 01/2015, Brussels: European Centre for International Political Economy(ECIPE). Available at: http://hdl.handle.net/10419/174861 [Accessed 27 February 2020].

24. Lamy, P. (2015). Colloquium on Business and Society: A Conversation with Pascal Lamy, Former Director General World Trade Organization. [video] Yale School of Management. Available at: https://www.youtube.com/watch?v=QOOBQhTE57o [Accessed 27 February 2020].

25. Lawrence, F. (2020). Why chlorinated chicken is centre of the table in UK-EU talks. The Guardian, [online]. Available at: https://www.theguardian.com/politics/2020/feb/25/why-chlorinated-chicken-is-centre-of-the-table-in-uk-eu-talks [Accessed 27 Feb 2020].

26. Council of the European Union (2019). COUNCIL DECISION authorising the opening of negotiations with the United States of America for an agreement on the elimination of tariffs for industrial goods. 6052/19. Available at: https://www.consilium.europa.eu/media/39180/st06052-en19.pdf [Accessed 27 Feb 2020].

27. Fontaine, P. (2014) Europe in 12 lessons. Brussels: European Commission.

28. European Commission, (2020). Trade/Human Rights: Commission decides to partially withdraw Cambodia's preferential access to the EU market. [online] Available at: https://ec.europa.eu/commission/presscorner/detail/en/ip_20_229 [Accessed 27 February 2020].

29. EUROPEAN Commission. (2021). Communication from the Commission to the European Parliament, the Council, the European Economic and Social Committee and the Committee of the Regions Empty: Trade Policy Review - An Open, Sustainable and Assertive Trade Policy. [online] Brussels: EUR-Lex, Available at: https://eur-lex.europa.eu/legal-content/EN/TXT/?uri=CELEX:52021DC0066&qid=1614007663855 [Accessed 16 Sep.2021].

30. Zulkhibri, M., Blessilda, J. (2020). Assessing Asean Economic Policy Responses in a Pandemic, ASEAN Policy Brief No.2 [No.2] Jakarta: ASEAN Integration Monitoring Directorate and Community Relations Devision The ASEAN Secretariat.

31. ERIA. (2020). COVID-19 and Southeast and East Asian Economic Integration: Understanding the Consequences for the Future. Policy Brief. [No.2020-01] Jakarta, Indonesia: Economic Research Institute for ASEAN and East Asia.

32. CARI. (2020). How COVID-19 Will Transform Global Supply Chains and How ASEAN Must Respond. [Online]. CARI ASEAN RESEARCH AND ADVOCACY. Available at: https://www.cariasean.org/news/how-covid-19-will-transform-global-supply-chains-and-how-asean-must-respond/#.X0cT2jWlaUn [Accessed 10-Mar-2021.

33. ASEAN Secretariat. (Nov, 2020). ASEAN Rapid Assessment: The impact of Covid-19 on livelihoods acress ASEAN. Jakarta: Community Relations Divisions of the ASEAN Secretariat, 135.

34. ASEAN Secretariat. (2020). ASEAN Economic Integration Brief No. 07. [No.7] Jakarta, Indonesia. : ASEAN Integration Monitoring Directorate and Community Relations Devision The ASEAN Secretariat.

35. ASEAN Secretariat. (2020). ASEAN Comprehensive Recovery Framework. Jakarta: Community Relations Devision (CRD) of the ASEAN Secretariat.

36. ASEAN. (2020). Enhancing ASEAN Connectivity for Post-Covid 19 Recovery. Regional efforts related to ASEAN connectivity. [Online]. Jakarta: ASEAN Secretariat. Available at: https://connectivity.asean.org/resource/enhancing-asean-connectivity-for-post-covid-19-recovery/ [Accessed 12 Aug. 2020].

37. ASEAN Secretariat. (2016). Master Plan on ASEAN Connectivity 2025. Jakarta: Community Relations Devision (CRD) of the ASEAN Secretariat.

38. Nomura. (2018). US-Sino trade friction: not all a lose-lost outcome for Asia [Online]. Nomura. Available at: https://www.nomuraconnects.com/focused-thinking-posts/us-sino-trade-friction-not-all-a-lose-lose-outcome-for-asia/ [Accessed 01-03-2021.

39. Nishimura, H. (2020). Understanding the Consequences of the Covid-19 pandemic for the furture of south and east Asian economic integration [Online]. Jakarta: Economic Research Institute for ASEAN and East Asia (ERIA) Available at: https://www.eria.org/news-and-views/understanding-the-consequences-of-the-covid-19-pandemic-for-the-future-of-southeast-and-east-asian-economic-integration/ [Accessed 06 Oct 2020].

40. Chen, L., and Lydia, R. (2020). Improving Degital Connectivity: Policy Priority for ASEAN Degital Transformation. P. [No. 2020-07] Jakarta, Indonesia.

41. Canada Parliament. (2017). The 38th General Assembly ASEAN Inter-Parliamentary Assembly, Philippines, 14th-20th September 2017: Appendix C. Report [Online]. Senate Parliament of Canada Available at: https://www.parl.ca/DocumentViewer/en/IIA/visit-report/9154091/page-21 [Accessed 22 Mar 2021].

42. Inter-Parliamentary Union. (2018). 2018 Annual Session of the parliamentary Conference on the WTO. Highlight of the Session. WTO: The Way Forward. Geneva.

43. Koh, F. (2020). Parliament: Supply chain shifts due to Covid-19 will impact economy but also present opportunities, says Chan Chun Sing [Online]. Singapore The Straits Times. Available at: https://www.straitstimes.com/singapore/supply-chains-shifts-due-to-covid-19-will-impact-economy-but-also-present-opportunities [Accessed 26-Agu-2020 2020].

44. CFJC. (2021). Les priorités nationales des bénéficiaires du plan de relance européen. [pdf] Paris: Compagnie Financière Jacques Cœur (CFJC), Available at: https://cfjc.fr/wp-content/uploads/2021/06/CFJC-LEclaireur-2-Plan-de-relance-europeen.pdf [Accessed 01 Sep.2021].

45. Muryel, J. and Derek, P. (2021). L'UE veut mettre sur les rails la première taxe carbone aux frontières au monde [online]. Paris: Les Echos. Available at: https://www.lesechos.fr/monde/europe/lue-veut-mettre-sur-les-rails-la-premiere-taxe-carbone-aux-frontieres-au-monde-1332177 [Accessed 1 Sep. 2021].

## BIBLIOGRAPHY

Inter-Parliamentary Union. (2001). For a free, just and equitable multilateral trading system: Proving a Parliamentary Dimension. Parliamentary Meeting. Revised annotated provision agenda. Geneva, Available at: http://archive.ipu.org/splz-e/tr-agenda.pdf [Accessed 7 February 2020 ].

Organization – Critical Demands for Imperative Success, Global Economic Dynamics, Bertelsmann-Stiftung, 27 April (https://www.bertelsmann-stiftung.de/fileadmin/files/BSt/Publikationen/GrauePublikationen/MT_Strengthening_the_WTO.pdf

Reinsch, William Alan, Jack Caporal and Lydia Murray (2018). At Last, An RCEP Deal, Center for Strategic and International Studies (CSIS), 3 December (Link: http://www.csis.org/analysis/least-rcep-deal)



ទួរប៊ីនដើរដោយខ្យល់ជាផ្នែកមួយនៃការបញ្ចូលគ្នារបស់ប្រព័ន្ធថាមពលកកើតឡើងវិញ
SSUAphotos

ជំពូកទី

# ០៣

# ការដោះស្រាយបញ្ហាអន្តរកម្មនៃសន្តិសុខទឹក ថាមពល និងស្បៀងក្រោមឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ


ទំ.១០៤ | ៣.១ សន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុ៖ ទស្សនៈពីប្រទេសសិង្ហបុរី
*ដោយ ឯកអគ្គរដ្ឋទូត តាំង យុក ចូវ*

ទំ.១០៨ | ៣.២. បណ្តាទីក្រុងនៅអាស៊ានប្រឈមនឹងហានិភ័យបរិស្ថាន និងការប្រែប្រួលអាកាសធាតុ
*ដោយ សាស្ត្រាចារ្យ មីហ្សែល ហ្វូសហ្សេ*

ទំ.១១៤ | ៣.៣ ការប្រែប្រួលអាកាសធាតុ និងការការពារតំបន់ព្រៃធម្មជាតិ៖ ទស្សនៈពីខាងតំបន់អាស៊ីអាគ្នេយ៍
*ដោយ បណ្ឌិត គឹម សុធន*

ទំ.១១៨ | ៣.៤ ប្រសិទ្ធភាពនៃច្បាប់ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ
*ដោយ លោក មូសារ អ៊ីស្សាម*

ទំ.១២៥ | ៣.៥. សន្តិសុខថាមពលអឺរ៉ុប៖ បញ្ហាប្រឈមក្នុងការធ្វើ ពិពិធកម្ម និងការបំបែកកាបូនឌីអុកស៊ីតចេញពីរបាយឥន្ធនៈ
*ដោយ បណ្ឌិត ឡុតហ្ស៍ ម៉េហ្ស៍*

ទំ.១៣០ | ៣.៦ សហភាពអឺរ៉ុប និងបញ្ហាប្រឈមទៅនឹងការប្រែប្រួលអាកាសធាតុ៖ អំណាចកំពូលក្នុងការចេញបទបញ្ញត្តិ
*ដោយ សាស្ត្រាចារ្យ មីហ្សែល ហ្វូសហ្សេ*

ទំ.១៣៣ | ៣.៧ Climate Legislation from Asia and Europe: EU Fit-for-55 and China's Carbon Market *By Laura KIM YEAT*

ទំ.១៤០ | ៣.៨ On Biodiversity: Updates on the UN Biodiversity Conference (COP15) *By Hisham MOUSAR*

# ៣.១ សន្តិសុខស្បៀង និងការប្រែប្រួលអាកាសធាតុ៖ ទស្សនៈពីប្រទេសសិង្ហបុរី

ការប្រែប្រួលអាកាសធាតុ ជាពិសេសកម្តៅភពផែនដី និងផលប៉ះពាល់ដែលមិនអាចទប់ស្កាត់បានបង្កឲ្យមានបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរសម្រាប់ប្រទេសជាច្រើន។ កំណើននីវ៉ូទឹកសមុទ្រ គឺជាបញ្ហាស្លាប់រស់សម្រាប់ ប្រទេសជាកោះតូចៗដូចជាសិង្ហបុរី។ ហេតុនេះហើយ ប្រទេសសិង្ហបុរីបានធ្វើការយ៉ាងសកម្ម ដើម្បីឲ្យមានការមូលមតិជាអន្តរជាតិ ដែលក្រោយមកត្រូវបានសម្រេចក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដើម្បីឲ្យភាគីប្រទេស នីមួយៗធ្វើ «សកម្មភាពដើម្បីអាកាសធាតុ» និងដើម្បីកាត់បន្ថយការបញ្ចេញនូវឧស្ម័នផ្ទះកញ្ចក់។ ប្រទេសសិង្ហបុរីបានដើរតួក្នុងការព្យាយាមកាត់បន្ថយជាតិកាបូន និងបង្កើននិរន្តរភាពលើគ្រប់វិស័យទាំងអស់ រាប់ពីសម្ភារៈប្រើប្រាស់ក្នុងផ្ទះ និងការដឹកជញ្ជូនរហូតដល់ឧស្សាហកម្ម ធុរកិច្ច និងក្នុងគ្រួសារ៖ វាជាកិច្ចប្រឹងប្រែងដែលទាមទារការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់។ បច្ចេកវិទ្យាអាចជាកម្លាំងចលករក្នុងការផ្លាស់ប្តូរស្ថានការណ៍ប្រទេសសិង្ហបុរី ដោយមិនត្រឹមតែបង្កើនប្រសិទ្ធិភាពថាមពលដែលខ្ពស់ស្រាប់ និងការប្រើប្រាស់ថាមពលកកើត ឡើងវិញរបស់ខ្លួននោះទេ ប៉ុន្តែថែមទាំងជួយដល់ការរំកិលខ្លួនទៅកាន់សេដ្ឋកិច្ចវិលជុំដែលមិនមានកាកសំណល់ (Zero waste) ដោយការប្រើប្រាស់ឡើងវិញ (Re-using) គ្រប់សម្ភារៈ និងធនធាននៅពេលណាមួយដែលអាចធ្វើបាន។

ក្នុងរបាយការណ៍ជាបន្តបន្ទាប់ ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) បានចេញផ្សាយការវាយតម្លៃបន្ទាន់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើភពផែនដីយើង។ របាយការណ៍ចុងក្រោយរបស់ពួកគេមិនបានផ្តល់សញ្ញាល្អសម្រាប់តំបន់អាស៊ីអាគ្នេយ៍នោះទេ ដែលជាហេតុនាំឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក អាន់តូនីញ៉ូ ហ្គូទែរ៉េស (Antonio Guterres) ថ្លែងនៅក្នុង សុន្ទរកថាបើករបស់លោកនៅឯកិច្ចប្រជុំកំពូលអាស៊ាន-យូអិន (ASEAN-UN) នាថ្ងៃទី៣ ខែវិច្ឆិកាឆ្នាំ២០១៩ នៅទីក្រុងបាងកកថា៖ «ភាពអាសន្ននៃអាកាសធាតុ គឺជាបញ្ហាកំណត់ជោគវាសនានៃយុគសម័យរបស់យើង។ប្រទេសចំនួន៤ក្នុងចំណោមប្រទេសទាំង១០ ដែលរងផលប៉ះពាល់ខ្លាំងបំផុតពីការប្រែប្រួលអាកាសធាតុ គឺជាប្រទេសដែលជាសមាជិកអាស៊ាន។ តំបន់នេះគឺជាតំបន់ងាយរងផលប៉ះពាល់ ខ្ពស់ដោយសារកំណើននីវ៉ូ ទឹកសមុទ្រ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សហគមន៍ដែលនៅតំបន់ទាបៗ។

## ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុចំពោះសន្តិសុខស្បៀងពិភពលោក

ការសិក្សាជាច្រើនបានបង្ហាញថា ត្រឹមតែការកើនឡើងកម្តៅតែមួយមុខក៏អាចនឹងបង្កឲ្យមានការធ្លាក់ ចុះទិន្នផលស្រូវ (យោងតាមការប្រមូលផលនាពេលបច្ចុប្បន្ននេះ) ក្នុងប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និង វៀតណាម រហូតដល់ ៥០% ដោយចាប់គិតពីឆ្នាំ១៩៩០ ដល់ឆ្នាំ២១០០។ ដោយសារសកម្មភាពកសិកម្ម សំខាន់ធ្វើឡើងក្នុងតំបន់ទាបៗ ក្នុងនោះមានដូចជាតំបន់ដីសណ្តមេគង្គ និងតំបន់មាត់សមុទ្រដែលងាយទទួលរងនូវទឹកជំនន់ និងការឡើងជាតិប្រៃដែលកើតចេញពីកំណើននីវ៉ូទឹកសមុទ្រ ដូច្នេះផលិតផលដំណាំស្រូវ និងផលិតផលផ្សេងៗអាចនឹងងាយរងផលប៉ះពាល់ផងដែរ។ អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) និងក្រុមការងារអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) បានប៉ាន់ស្មានថាការប្រែប្រួល អាកាសធាតុអាចនឹងបង្កឲ្យមានការធ្លាក់ចុះទិន្នផលស្រូវពី១០-១៥% ត្រឹមឆ្នាំ២០៥០។ ការធ្លាក់ចុះទិន្នផលដ៏គួរឲ្យកត់សម្គាល់នេះនឹងក្លាយជាការគំរាមកំហែងយ៉ាងខ្លាំងចំពោះសន្តិសុខស្បៀងពិភពលោក ដែលកំពុងរងសម្ពាធស្រាប់ពីការកើនឡើងនៃចំនួនប្រជាជននៅលើពិភពលោក ដែលអាចកើនឡើងដល់ ១០ប៊ីលាន ត្រឹមឆ្នាំ២០៥០ ពីចំនួន ៧.៣ប៊ីលាន នាពេលបច្ចុប្បន្ននេះ។

## អភិក្រមរបស់ប្រទេសសិង្ហបុរីចំពោះសន្តិសុខស្បៀង

ប្រទេសសិង្ហបុរី គឺជាទីក្រុងស៊ីវិល័យ និងជាឋានសួគ៌ចំណីអាហារដែលគេអាចរកបានអាហារសឹងតែគ្រប់ប្រភេទ និងគ្រប់តម្លៃទាំងអស់។ សន្ទស្សន៍សន្តិសុខស្បៀងពិភពលោកដែលបានចេញផ្សាយដោយអង្គភាពស៊ើបការណ៍សេដ្ឋកិច្ច (Economist Intelligence Unit) បានចាត់ចំណាត់ថ្នាក់សិង្ហបុរីថា ជាប្រទេសដែល មានសន្តិសុខស្បៀងខ្ពស់ជាងគេក្នុងឆ្នាំ២០១៨ និង២០១៩។ ដូច្នេះយើងអាចយល់បានថា ប្រជាពលរដ្ឋសិង្ហបុរីជាច្រើនមិនបារម្ភអំពីរឿងការទទួលបានអាហារនោះទេ។ ទោះយ៉ាងណាក៏ដោយអ្នកធ្វើគោលនយោបាយមិនអាចមិនខ្វល់ពីការគំរាមកំហែងជាក់ស្តែងលើសន្តិសុខស្បៀងរបស់សិង្ហបុរី

នាពេលអនាគតនោះទេ។ ក្រោយពីបានដើរចេញពីវិស័យកសិកម្មតាំងពីមួយជំនាន់មុន ដើម្បីងាកទៅប្រើប្រាស់ដី និងធនធាន ដែលមានកម្រិតរបស់ខ្លួនឲ្យមានផលិតភាពសេដ្ឋកិច្ចជាងមុន ប្រទេសសិង្ហបុរី បច្ចុប្បន្ននេះកំពុងធ្វើការស្វែងរកយ៉ាងយកចិត្តទុកដាក់នូវវិធីសាស្ត្រ ដែលមានប្រសិទ្ធភាពក្នុងតម្លៃសមស្រប និងប្រកបដោយនិរន្តរភាព ដើម្បីផលិតចំណីអាហារ មិនត្រឹមតែសម្រាប់ផ្គត់ផ្គង់ទីក្រុងរបស់ខ្លួនប៉ុណ្ណោះទេតែក៏អាចចូលរួមចំណែកក្នុងការផលិតចំណីអាហារសម្រាប់ផ្គត់ផ្គង់ពិភពលោកផងដែរ។ ស្របពេលជាមួយគ្នានេះដែរ វិធីសាស្ត្ររបស់សិង្ហបុរីអាចនឹងជួយឲ្យប្រជាពលរដ្ឋពាក់កណ្ដាលពិភពលោក ដែលបច្ចុប្បន្នរស់នៅក្នុងតំបន់ទីប្រជុំជន អាចចូលរួមចំណែកក្នុង ការកាត់បន្ថយកង្វះសន្តិសុខស្បៀងពិភពលោកនាពេលអនាគត។

នៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩ សភាសិង្ហបុរីបានអនុម័តច្បាប់មួយ ដើម្បីបង្កើតក្រុមប្រឹក្សាស្របច្បាប់ថ្មីមួយដែលមានឈ្មោះថា ភ្នាក់ងារស្បៀងសិង្ហបុរី (Singapore Food Agency) ដែលស្ថិតនៅក្រោមឱវាទក្រសួងបរិស្ថាន និងធនធានទឹកសិង្ហបុរី (Singapore's Ministry of the Environment and Water Resources)។ បេសកកម្មរបស់ភ្នាក់ងារស្បៀងសិង្ហបុរី (SFA)នេះ គឺដើម្បីធានា និងរក្សាឲ្យបានការផ្គត់ផ្គង់ចំណីអាហារសុវត្ថិភាពសម្រាប់ប្រទេសសិង្ហបុរី។ ជាការប្រមូលផ្ដុំមុខងារពាក់ព័ន្ធនឹងចំណីអាហារ ដែលពីមុនគ្រប់គ្រងដោយភ្នាក់ងារជាច្រើនមកធ្វើការរួមគ្នាតាមវិធីសាស្ត្រគ្រប់ជ្រុងជ្រោយដើម្បីពង្រឹងសុវត្ថិភាព និងសន្តិសុខស្បៀង នាពេលនេះភ្នាក់ងារស្បៀងសិង្ហបុរី (SFA) ដែលមានអំណាចអនុញ្ញាតដោយច្បាប់ក្នុងការត្រួតពិនិត្យខ្សែសង្វាក់ផលិតកម្មចំណីអាហារទាំងមូល «ចាប់ពីការផលិតទិន្នផលកសិកម្មរហូតដល់ការប្រើប្រាស់ (from farm to fork)»។ ទីភ្នាក់ងារនេះកំពុងធ្វើការជាមួយដៃគូធុរកិច្ច ដើម្បីប្រែក្លាយឧស្សាហកម្ម កសិម្ហូបអាហារជាតិ និងដើម្បីបង្កើតការងារល្អៗសម្រាប់ជនជាតិសិង្ហបុរី។ ដើម្បីពង្រឹងភាពរឹងមាំនៃការផ្គត់ផ្គង់ ចំណីអាហាររបស់ប្រទេសសិង្ហបុរី ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) កំពុងតែព្យាយាមសម្រេចគោលដៅ «៣០ គុណ ៣០» ដើម្បីផលិតឲ្យបាន ៣០% នៅក្នុងស្រុកនូវផលិតផលអាហារូបត្ថម្ភដែលជាតម្រូវការរបស់ប្រទេសសិង្ហបុរីត្រឹមឆ្នាំ២០៣០ ដែលនឹងធ្វើឲ្យមានការកើនឡើងច្រើនដងនូវផលិតភាពក្នុងស្រុកបើប្រៀបនឹងកម្រិតបច្ចុប្បន្ន។ ដើម្បីសម្រេចគោលដៅ ៣០ គុណ ៣០ ឧស្សាហកម្មកសិម្ហូបអាហារត្រូវមានការស្រាវជ្រាវ និងអភិវឌ្ឍន៍ (R&D) ក្នុងការបង្កើតនូវដំណោះស្រាយសម្រាប់ជំនះឧបសគ្គផ្នែកធនធាន បង្កើនផលិតភាព និងពង្រឹងភាពធន់នឹងអាកាសធាតុ។

ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) ធ្វើការលើកទឹកចិត្តកសិដ្ឋានក្នុងស្រុកដែលមានស្រាប់ឲ្យធ្វើនវានុវត្តន៍ និងធ្វើការអភិវឌ្ឍខ្លួនឯង (ឧទាហរណ៍៖ ការធ្វើសមាហរណកម្មការទៅក្នុងដំណើរការពីការគ្រប់គ្រងអាកាសធាតុ និងការប្រើម៉ាស៊ីនស្វ័យប្រវត្តិ) ដើម្បីបង្កើនផលិតភាព។ ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) បានលើកទឹកចិត្តឲ្យមានកសិដ្ឋាននៅក្នុងអគារបែបទាន់សម័យ (state-of-art indoor farms) ដែលជួយធ្វើឲ្យរុក្ខជាតិ លូតលាស់បានកាន់តែប្រសើរ និងបង្កើនទិន្នផលបានកាន់តែឆាប់រហ័ស តាមរយៈមធ្យោបាយដែលមានបច្ចេកវិទ្យាខ្ពស់ ដូចជាការប្រើប្រាស់ពន្លឺ អិល អ៊ី ឌី (LED) និងការគ្រប់គ្រងអាកាសធាតុជាដើម។ ដោយគ្រប់គ្រងការលូតលាស់ពីកត្តាផ្សេងៗ កសិដ្ឋានទាំងនេះមានភាពធន់នឹងអាកាសធាតុ និងអាចរក្សាស្តង់ដារ គុណភាពបានខ្ពស់។ ស្រដៀងគ្នានេះដែរ ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) ក៏បានលើកទឹកចិត្តឲ្យមានកសិដ្ឋានចិញ្ចឹមត្រីដែលមានភាពធន់មាននិរន្តរភាពជាងមុន និងអាចផ្ដល់ផលិតផលកាន់តែច្រើនពីព្រោះកសិដ្ឋានចិញ្ចឹមត្រីបែបប្រពៃណីដែលប្រើសំណាញ់ហ៊ុំព័ទ្ធ ងាយនឹងរងគ្រោះដោយសារឧប្បត្តិហេតុពីខាងក្រៅក្នុងនោះរួមមាន៖ ឆាប់មានស្លែលើផ្ទៃទឹក និងងាយរងផលប៉ះពាល់ពីការកំពប់ប្រេងជាដើម។ ក្រុមហ៊ុនមួយឈ្មោះថា បច្ចេកវិទ្យា វារីវប្បកម្មសិង្ហបុរី (Singapore Aquaculture Technologies) បានប្រើប្រាស់ប្រព័ន្ធបែបបិទជិតចាប់តាំងពីឆ្នាំ២០១២ ក្នុងការចិញ្ចឹមត្រីដូចជា ត្រីស្តង់ស(baramundi) ត្រីស្តង់ (sea bass) និងត្រីអាំងកឹយក្រហម(red snapper)។

## ដំណើរឆ្ពោះទៅរកនិរន្តរភាព

ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) កំពុងធ្វើការជាមួយស្ថាប័នសិក្សាជាន់ខ្ពស់ជាច្រើនក្នុងការផ្ដល់នូវចំណេះដឹង និងជំនាញទៅឲ្យក្មេងជំនាន់ក្រោយឲ្យក្លាយខ្លួនជាអ្នកបច្ចេកទេសកសិកម្ម និងវារីវប្បកម្ម អ្នកជំនាញផ្នែកកសិដ្ឋានបែបទីក្រុង និងអ្នកស្រាវជ្រាវ។ អង្គភាពនេះក៏ផ្ដល់ការគាំទ្រដល់អ្នកដែលមានចំណាប់អារម្មណ៍ ក្នុងការធ្វើកសិដ្ឋានបែបទីក្រុងដោយប្រើប្រាស់កន្លែងទំនេរដូចជា រានហាល និងលើដំបូលដើម្បីធ្វើការដាំដុះ។ គម្រោងបែបនេះជួយប្រមូលផ្ដុំសហគមន៍ធ្វើឲ្យប្រជាពលរដ្ឋចូលរួមដោយផ្ទាល់ក្នុងការផលិតកម្មម្ហូបអាហារ បង្កើនការយល់ដឹងពីបញ្ហាសន្តិសុខស្បៀង ជួយកែផ្នត់គំនិតឲ្យចេះផ្ដល់តម្លៃទៅលើអាហារ និងចេះកាត់បន្ថយសំណល់អាហារ។ ដោយសារតែអាហារងាយនឹងផ្អូមឬរលួយ ចំនួនអាហារមួយចំនួនធំត្រូវបានបាត់បង់ក្នុងខ្សែ ចង្វាក់តម្លៃសកលមុនពេលដែលអាហារទាំងនោះបានទៅដល់អតិថិជន។ អង្គការស្បៀង និងកសិកម្មនៃអង្គការ

សហប្រជាជាតិ (FAO) បានប៉ាន់ប្រមាណថា ប្រហែល ១/៣ នៃអាហារដែលបានផលិតរួចត្រូវបានបាត់បង់ ឬខ្ជះខ្ជាយទៅក្នុងខ្សែសង្វាក់តម្លៃកសិម្ហូបអាហារសកលដែលចំនួននេះកើនឡើងបន្តិចម្តងៗ ក្នុងខណៈពេលដែលភាពអត់ឃ្លាននៅតែបន្តប៉ះពាល់ដល់មនុស្សជាច្រើននៅលើពិភពលោក។

ការកាត់បន្ថយការបាត់បង់ និងសំណល់អាហារច្បាស់ណាស់ គឺជាវិធីសាស្ត្រដែលមានប្រសិទ្ធិភាព បំផុតក្នុងការកាត់បន្ថយជានកាបូនក្នុងវិស័យកសិម្ហូបអាហារដោយមិនមានការខាតបង់អ្វីទាំងអស់។ ទោះបីជាបរិមាណនៃការខូចខាតអាហារ ឬសំណល់អាហារនៅក្នុងប្រទេសសិង្ហបុរីមានកម្រិតទាបជាងចំនួនជាមធ្យម ក៏ដោយ ដែលតាមការប៉ាន់ស្មានមានចំនួនប្រមាណ២០% តែតួលេខនេះគឺ នៅតែជាកម្រិតមួយខ្ពស់ខ្លាំង។ អតិថិជនទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យទិញ ចំអិន និងបរិភោគអាហារក្នុងបរិមាណល្មម ខណៈពេលដែល សៀវភៅមគ្គុទ្ទេសក៏ស្តីពីការបង្កើតអាហារគ្រប់មុខ ការបង្កើតរោងចក្រផលិតចំណីអាហារ និងផ្សារទំនើបត្រូវ បានចេញផ្សាយ និងផ្សព្វផ្សាយដល់គ្រប់ឧស្សាហកម្មតាំងពីឆ្នាំ២០១៤។ កិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើងក្នុងការប្រមូល និងចែកចាយឡើងវិញនូវស្បៀងអាហារដែលនៅសេសសល់ និងលក់មិនដាច់។ ចំពោះការខូចខាតស្បៀង ការសិក្សាមួយបានបង្ហាញថា ស្បៀងអាហារចំនួន ៧.២ % ដែលប្រទេសសិង្ហបុរីនាំចូលតាមរយៈការដឹកជញ្ជូនគិតជាតោនក្នុងមួយឆ្នាំត្រូវបានបាត់បង់ (ឧទាហរណ៍.ដោយសារការរលួយ/ខូច) នៅតាមផ្លូវមកកាន់ប្រទេសសិង្ហបុរី និងក្នុងពេលចែកចាយក្នុងប្រទេសសិង្ហបុរីធ្វើឲ្យស្បៀងបាត់បង់ចំនួន ៥.៥% ថែមទៀត។ ការផលិតស្បៀងអាហារក្នុងស្រុកនឹងមិនត្រឹមតែពង្រឹងសន្តិសុខស្បៀងសម្រាប់ប្រទេសសិង្ហបុរីដោយផ្តល់ជាស្តុកក្នុងពេលមានវិបត្តិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយកាត់បន្ថយចម្ងាយក្នុងការដឹកជញ្ជូនស្បៀងដែលត្រូវប្រើប្រាស់ក្នុងប្រទេសសិង្ហបុរីផងដែរ។ ម្យ៉ាងវិញទៀត ខ្សែសង្វាក់ផ្គត់ផ្គង់ខ្លីក្នុងស្រុក ចាប់ពីការផលិត ទិន្នផលកសិកម្មរហូតដល់ការប្រើប្រាស់ (from farm to fork) ធ្វើឲ្យស្បៀងអាហារអាចទៅដល់អតិថិជនស្រស់ៗ និងជៀសវាងការខូចខាត ដែលមុខជានឹងកើតឡើង បើឆ្លងកាត់ខ្សែសង្វាក់តម្លៃអាហារនាំចូលដែលមានចម្ងាយឆ្ងាយ។

ដូចគ្នានឹងវិស័យផ្សេងៗក្នុងប្រទេសសិង្ហបុរី វិស័យកសិម្ហូបអាហារកំពុងតែផ្តោតទៅរកនិរន្តរភាព។ ការបង្កើតឲ្យមានភ្នាក់ងារស្បៀងសិង្ហបុរី (SFA) ជាផ្នែកមួយរបស់ក្រសួងបរិស្ថាន និងធនធានទឹកសិង្ហបុរី (MEWR) បានជួយសម្របសម្រួលឲ្យមាន "គ្រួសារបរិស្ថាន" ដោយប្រើប្រាស់នូវអភិក្រមរួបរួមគ្នាក្នុងការគ្រប់គ្រងទឹក ស្បៀង ប្រសិទ្ធិភាពនៃថាមពល និងការប្រើប្រាស់ភាពរួមគ្នារវាងទំនាក់ទំនងនៃថាមពល-ស្បៀង-ទឹក-កាកសំណល់។ ដោយភ្នាក់ងារស្បៀងសិង្ហបុរី (SFA) មានតួនាទីពង្រឹងសន្តិសុខស្បៀងសម្រាប់ប្រទេសសិង្ហបុរី អង្គភាពនេះគាំទ្រជានិច្ចនូវអភិក្រមសេដ្ឋកិច្ចវិលជុំលើផលិតកម្មកសិម្ហូបអាហារ ដើម្បីធានាឲ្យមានការប្រើប្រាស់ធនធានឲ្យអស់លទ្ធភាព កាត់បន្ថយការបាត់បង់និងកាកសំណល់អាហារ និងជំរុញការកែច្នៃ (ឧទាហរណ៍ បំលែង) កាកសំណល់អាហារឲ្យទៅជាសារធាតុដើម្បីផលិតថាមពលក្នុងវិស័យកសិកម្ម ឬកែច្នៃធ្វើជីជាដើម។ អ្វីដែលជាកាកសំណល់នៅក្នុងវិស័យមួយជាទូទៅអាចប្រើប្រាស់ឡើងវិញ ឬបំលែងឲ្យទៅជាអ្វីផ្សេងសម្រាប់ប្រើប្រាស់ក្នុងវិស័យមួយទៀតបាន។

កសិដ្ឋានក្នុងស្រុកខ្លះបានប្រើប្រាស់គោលការណ៍សេដ្ឋកិច្ចវិលជុំនេះរួចហើយ។ កសិដ្ឋានក្នុងអាគារមួយកន្លែងមានឈ្មោះថា ស៊ុស្ទីនីនា (Sustenir) កំពុងប្រើប្រាស់ឧស្ម័នកាបូនិក ដើម្បីបង្កើនទិន្នផលបន្លែរបស់ខ្លួន។ កសិដ្ឋានចិញ្ចឹមមាន់មួយបានអនុវត្តបច្ចេកទេសបំបែកជីវសាស្ត្រដោយយកកាកសំណល់ពីមាន់ដែលខ្លួនចិញ្ចឹមដើម្បីផលិតឲ្យទៅជាថាមពលក្នុងការសម្ងួតផលិតផលបន្ទាប់បន្សំ ដែលចេញពីឧស្សាហកម្មចំណីអាហារដើម្បីផលិតទៅជាចំណីមាន់។ ពងសត្វល្អិតខ្លះដូចជារុយ (Black Soldier Fly) ជាដើម ផ្សំជាមួយនឹងកាកសំណល់កសិម្ហូបអាហារអាចផលិតទៅជាជីខណៈពេលដែលពងសត្វល្អិតដែលលូតលាស់អាចធ្វើជាចំណីសម្រាប់ត្រី ឬមាន់បាន។

ការអភិវឌ្ឍបច្ចុប្បន្នក្នុងការផលិតអាហារថ្មីៗមានដូចជាជម្រើសក្នុងការចំរាញ់ប្រូតេអ៊ីនចេញពីរុក្ខជាតិរហូតដល់ពីសាច់សត្វ វិធីងាយស្រួលសម្រាប់ផលិតទឹកដោះគោ និងស៊ុតសម្រាប់លក់ និងការធ្វើកសិដ្ឋានបណ្តុះស្លែ និងចិញ្ចឹមសត្វល្អិត ដើម្បីធ្វើជាប្រភពផ្សេងៗនៃប្រូតេអ៊ីន អាចបើកផ្លូវប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសសិង្ហបុរីក្នុងការធ្វើពិពិធកម្មប្រភពប្រូតេអ៊ីន ដើម្បីឈានទៅសម្រេចកាន់គោលដៅ ៣០ គុណ ៣០ របស់ខ្លួន។ ដោយការផលិតអាហារសំបូរទៅដោយប្រូតេអ៊ីនដែលផ្អែកលើសណ្តែកគ្រាប់ធញ្ញជាតិ ស្រូវសាលី ម៉េមរុក្ខជាតិបញ្ចេញជានកាបូនទាបជាងផលិតកម្មចេញពីសាច់មកពីកសិដ្ឋានចិញ្ចឹមសត្វ វាប្រហែលជាអាចជួយស្តារឡើងវិញនូវឧស្សាហកម្មប្រូតេអ៊ីនសកល ដែលកំពុងជួបប្រទះបញ្ហាកាន់តែច្រើនឡើងៗចំពោះនិរន្តរភាពបរិស្ថានរបស់ខ្លួន។

## ការស្រាវជ្រាវ និងអភិវឌ្ឍ (R&D) រកដំណោះស្រាយប្រកបដោយនវានុវត្តន៍ និងស្បៀងអាហារនាពេលអនាគត

ដើម្បីពន្លឿនការស្រាវជ្រាវ និងអភិវឌ្ឍ (R&D) ក្នុងការរកដំណោះស្រាយបែបបច្ចេកវិទ្យាសម្រាប់វារីវប្បកម្មបែបត្រូពិច និងកសិកម្មបែបទីក្រុងក្នុងប្រទេសសិង្ហបុរី ភ្ជាប់ជាមួយនឹងគោលដៅផ្សេងៗរួមមាន៖ ពង្រឹងការគ្រប់គ្រងសុខភាព និងជំងឺ (ឧទាហរណ៍. តាមរយៈការពង្រឹងសេនេទិចនៃប្រភេទដំណាំត្រូពិច និងពូជសំខាន់ៗជាមួយនឹងផេណូទីបដែលបន្សាំសម្រាប់កសិដ្ឋានក្នុងអាគារ) ភ្នាក់ងារស្បៀងសិង្ហបុរី (SFA) បានចេញប្រកាសនៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩ ចំពោះការដាក់សំណើស្រាវជ្រាវដែលពាក់ព័ន្ធ។ គោលដៅ គឺដើម្បីបង្កើនផលិតភាពរបស់អ្នកផលិតអាហារក្នុងស្រុកឲ្យហួសពីអ្វីដែលអាចសម្រេចបានតាមបច្ចេកវិទ្យាដាច់គេនាពេលបច្ចុប្បន្ននេះ ដោយគិតផងដែរពីប្រសិទ្ធភាពនៃថ្លៃចំណាយ ចីរភាពបរិស្ថាន និងភាពធន់នឹងអាកាសធាតុ។ ស្របពេលនេះដែរ ទីភ្នាក់ងារវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្រាវជ្រាវបានចាប់ផ្តើមបើកគម្រោងផ្តល់ថវិកាសម្រាប់ការស្រាវជ្រាវពាក់ព័ន្ធនឹងការបង្កើតអាហារសម្បូរប្រូតេអ៊ីន ដើម្បីដោះស្រាយនូវបញ្ហាប្រឈមជាមូលដ្ឋាននានា ទាក់ទងនឹងជម្រើសផលិតប្រូតេអ៊ីនពីប្រភពផ្សេងៗ។ កត្តានេះត្រូវបានគេសង្ឃឹមថានឹងនាំឲ្យមានអភិក្រមនៃការស្រាវជ្រាវ និងអភិវឌ្ឍដ៏ថ្មីស្រឡាង និងបេកគំហើញបច្ចេកវិទ្យា «ដើម្បីអភិវឌ្ឍដំណោះស្រាយ និងបច្ចេកវិទ្យាដែលផ្អែកទៅលើភស្តុតាង និងទស្សនាទានដែលមានសម្អាង» សម្រាប់សុវត្ថិភាពស្បៀង ជីវជាតិរសជាតិ ថាមពលនិងប្រសិទ្ធិភាព និរន្តរភាពនិងការពិចារណាជាក់ស្តែងក្នុងពិភពលោកផ្សេងៗទៀត។

## ការផលិតថ្មី៖ ផលិតកម្មកសិផ្ទុបអាហារ

ទោះបីជាវិស័យកសិកម្មត្រូវបានជំនួសដោយឧស្សាហកម្មនៅប្រទេសសិង្ហបុរីតាំងពីកាលពី ៣០-៤០ឆ្នាំ មុនក៏ដោយ បច្ចេកវិទ្យាកំពុងតែបំលែងការធ្វើកសិដ្ឋាន និងផលិតកម្មចំណីអាហារឲ្យត្រលប់មកវិញ ជាប្រភេទផ្សេងមួយនៅក្នុងការផលិត ជាមួយនឹងកសិករធ្វើជំនួញបែបបច្ចេកវិទ្យា (techno-preneur farmers) និងអ្នកបង្កើតនវានុវត្តន៍នៃអាហារ (novel food innovator-creators)។ ភាពជោគជ័យរបស់ប្រទេសសិង្ហបុរីនៅក្នុងវិស័យដ៏សកម្មក្នុងការពង្រឹងនូវសន្តិសុខស្បៀងតាមរយៈដំណោះស្រាយអាហារបែបទីក្រុងនឹងត្រូវចែករំលែកជាមួយប្រទេសដទៃ ដោយចាប់ផ្តើមពីទីក្រុងជិតខាងក្នុងអាស៊ីអាគ្នេយ៍ ដើម្បីឲ្យប្រទេសដទៃទៀតអាចធ្វើពិសោធន៍ក្នុងសកម្មភាពវិវត្តន៍ថ្មីស្រដៀងគ្នានេះ ក្នុងការពង្រឹងនូវសន្តិសុខស្បៀងក្នុងស្រុក ស្របពេលដែលជួយពង្រឹងការផ្គត់ផ្គង់ស្បៀងជាសកល។



សួនបន្លែនៅលើដំបូលផ្ទះនិងចំណតរថយន្តនៃក្រុមប្រឹក្សាភិបាលអភិវឌ្ឍន៍ និងលំនៅដ្ឋាន នៅទីក្រុងយូស៊ីនប្រទេសសិង្ហបុរី
Olivia Choong / https://tendergardener.com

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ៣.២ បណ្ដាទីក្រុងនៅអាស៊ានប្រឈមនឹងហានិភ័យ បរិស្ថាននិងការប្រែប្រួលអាកាសធាតុ

## ការរកឃើញ

នៅក្នុងឆ្នាំ២០១១ ផ្នែកមួយនៃទន្លេចៅប្រាយ៉ាដែលហូរកាត់ទីក្រុងបាងកកមានទឹកហូរជោរជន់ ដែលបង្កឲ្យមានទឹកជំនន់លិចទីក្រុងលើផ្ទៃដី ៤០% ។ តំបន់ជិតខាងទាំងមូលត្រូវបានកកស្ទះរយៈពេលជាច្រើនថ្ងៃ ដែលនាំឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចយ៉ាងខ្លាំង។ ទឹកជំនន់នេះបានបង្កឲ្យមានការចំណាយថវិកាជាង ៤៦ ប៊ីលានដុល្លារអាមេរិក ដើម្បីជួសជុល និងស្ដារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ ក្នុងនោះទីក្រុងបាងកកតែមួយត្រូវការចំណាយចំនួន ៨ ប៊ីលានដុល្លារអាមេរិក។ កាន់តែធ្ងន់ធ្ងរជាងនេះ រាជធានីរបស់ប្រទេសថៃអាចនឹងស្រុតចុះក្នុងជម្រៅ ១,៨ ម៉ែត្រ គិតពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៥។

ហ្សាការតាដែលជារដ្ឋធានីដ៏ធំរបស់ប្រទេសឥណ្ឌូនេស៊ីទទួលរងការស្រុតចុះពី ៧,៥ស.មទៅ១០ស.ម ក្នុងមួយឆ្នាំ និង ៤០% នៃទីក្រុងដ៏ប្រជុំជនមួយនេះស្ថិតនៅក្រោមនីវ៉ូទឹកសមុទ្រ។ ការស្រុតចុះនេះបានធ្វើឲ្យប៉ះពាល់ភាគខាងជើងនៃរាជធានី កំពង់ផែ មូលដ្ឋាននាវាចរ ផ្សារត្រី និងផ្សារទំនើបធំៗជាច្រើន។ ដើម្បីជាការឆ្លើយតប លោកប្រធានាធិបតី ចូកូ វីដូដូ (Joko Widodo) បានផ្ដួចផ្ដើមផែនការនាខែមេសា ឆ្នាំ២០១៩កន្លងទៅនេះ ក្នុងការផ្លាស់ប្ដូររដ្ឋធានីនេះទៅកាន់ឆ្នេរខាងកើតនៃទីក្រុងបូនេអូ។

ទីក្រុងហូជីមិញកំពុងទទួលរងការស្រុតចុះ ៨ស.ម ក្នុងមួយឆ្នាំ។ ក្នុងឆ្នាំ២០០៩ ក្រសួងបរិស្ថាន និងធនធានធម្មជាតិរបស់ប្រទេសវៀតណាមបានផ្ដល់ដំណឹងដល់សាធារណជនថា ៦% នៃផ្ទៃលើរបស់ទីក្រុងត្រូវបានស្ថិតនៅក្រោមការគំរាមកំហែងពីការស្រុតចុះនេះ។ នៅប្រទេសហ្វីលីពីន មួយផ្នែកនៃទីក្រុងម៉ានីលដែលមានប្រជាពលរដ្ឋរស់នៅប្រមាណ១៣លាននាក់ កំពុងប្រឈមមហន្តរាយដែលជិតមកដល់ដោយសារការស្រុតចុះនៃទីក្រុងចំនួន ៤,៥ស.ម ក្នុងមួយឆ្នាំ។

ជាមួយនឹងប្រជាពលរដ្ឋចំនួន ៥៤% ដែលរស់នៅក្នុងតំបន់ជិត ឬក្រោមនីវ៉ូទឹកសមុទ្រ និងជាពិសេសក្នុងបណ្ដាទីក្រុងធំៗ ទ្វីបអាស៊ីបានក្លាយជាកន្លែងដែលងាយរងគ្រោះងាយទទួលរងការគំរាមកំហែងពីការស្រុតដី និងកំណើននីវ៉ូទឹកសមុទ្រ ។

## កំណើនទីក្រុងប្រជុំជននៅអាស៊ីអាគ្នេយ៍

ក្នុងឆ្នាំ២០១៩ បណ្ដាទីក្រុងនៅអាស៊ីអាគ្នេយ៍ដែលធ្លាប់មានប្រជាពលរដ្ឋរស់នៅជាង ២លាននាក់ បច្ចុប្បន្ននេះមានចំនួនប្រជាពលរដ្ឋបញ្ចូលគ្នាសរុប ១៦៧លាននាក់ នៃចំនួនប្រជាពលរដ្ឋសរុបចំនួន ៦៦៤លាននាក់។ ចំនួននេះស្មើនឹង ២៦,៣%។

**តារាង ១៖** ទីក្រុង និងទីក្រុងធំៗមានចំនួនប្រជាពលរដ្ឋដូចខាងក្រោម៖

| | |
|---|---|
| ចាបូដេតាតិក(ហ្សាការតា,បូហ្គ័រ, ដេប៉ុក,តាងហ្គឺរ៉ាង និង បេកាស៊ី) | ៣៥លាន |
| មេត្រូម៉ានីល | ២៤លាន |
| បាងកក (ក្រុងថេបមហាណាកន) | ១៨,៩លាន |
| ហូជីមិញ | ១៣,៦លាន |
| បានឌុង | ៨,៧លាន |
| គូឡាឡាំពួ | ៨,២លាន |
| សិង្ហបុរី | ៨,១លាន |
| ហាណូយ | ៧,៤លាន |
| យ៉ាងហ្គូន | ៧,៤លាន |
| ស៊ូរ៉ាកាតា | ៦លាន |
| មេតាន | ៥,២លាន |
| យ៉ូខ្យាកាតា | ៤លាន |
| ភ្នំពេញ | ៣,៣ លាន |
| សេប៊ូ | ២,៨ លាន |
| ម៉ាឡាង | ២,៨ លាន |
| ប៉ាឡេមបាង | ២,៥លាន |
| ស៊ីរេបុន | ២,៥លាន |
| ចូហ៊រ បាហ៊្រូ | ២,៤លាន |
| ដេនប៉ាសា | ២,២លាន |
| ម៉ាន់ដាឡាយ | ២លាន |

### ផែនទី ២៖ ទីក្រុង និងទីក្រុងធំៗនៅអាស៊ីអាគ្នេយ៍



## កត្តាហានិភ័យបរិស្ថានរួមបញ្ចូលគ្នាជាពិសេសនៅអាស៊ីអាគ្នេយ៍៖ ការស្រុតដី និងផលប៉ះពាល់នៃកម្តៅភពផែនដីនៅលើនីវ៉ូទឹកសមុទ្រ

តំបន់ទីក្រុងនៅអាស៊ីអាគ្នេយ៍សុទ្ធសឹងតែស្ថិតនៅតំបន់ដីល្បាប់ដែលមានប្រជាពលរដ្ឋរស់នៅតាន់តាប់ និងជាតំបន់ដីសណ្តនៅលើដីទន់ជ្រាយ ដែលលាតសន្ធឹងដល់តំបន់វាលស្រែជិតខាង។ ការធ្វើនគរូបនីយកម្ម និងឧស្សាហូបនីយកម្មឆាប់រហ័សនៅក្នុងតំបន់បែបនេះបង្កឲ្យមានការស្រុតដី និងការស្រុតផ្ទៃខាងលើរបស់ដីដែលបង្កឲ្យមាននូវទឹកជំនន់ជាច្រើន ជាពិសេសក្នុងរដូវខ្យល់មូសុង។

ការស្រុតដីបង្កមកពីកត្តាច្រើនយ៉ាង។ តាមរយៈអ្នកជំនាញមកពីវិទ្យាស្ថានឌែលតារេស (Deltares) ដែលជាវិទ្យាស្ថានឯករាជ្យលើការស្រាវជ្រាវអនុវត្តន៍ ក្នុងជំនាញទឹក និងផ្ទៃខាងក្រោមបានឲ្យដឹងថា កត្តាធំបំផុត "នៅតែស្ថិតនៅលើការបូមទឹកក្រោមដី"។ ប៉ុន្តែ ពួកគេបន្ថែមថា "ទម្ងន់អគារពិតណាស់ចូលរួមចំណែកក្នុងការសង្កត់ស្រទាប់កំណស្តើង។ តំបន់ឆ្នេរទាំងនេះបង្កើតឡើងដោយស្រទាប់ខ្សាច់ជាច្រើន រួមជាមួយនឹងដីឥដ្ឋ និងដីកំប៉ុស (Peat)ដែលពួកវាមានភាពទន់ជ្រាយជាពិសេស"។

ទីក្រុងស្រុតចុះពិតជាងាយនឹងរងគ្រោះដោយសារកំណើននីវ៉ូទឹកសមុទ្រណាស់។ យោងតាមរបាយការណ៍ពិសេសរបស់ ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការប្រែប្រួលអាកាសធាតុ (IPCC) ស្តីពីមហាសមុទ្រ និងទឹកកក (Cryosphere) ក្នុងបរិបទការប្រែប្រួលអាកាសធាតុដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលជាសមាជិកនៃក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការប្រែប្រួលអាកាសធាតុ (IPCC) នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៩ កន្លងទៅនេះ បានបង្ហាញថា នីវ៉ូទឹកសមុទ្រ និងមហាសមុទ្រអាចកើនឡើងដល់កម្ពស់១,១០មនៅត្រឹមឆ្នាំ២១០០ប្រសិនបើយើងមិនធ្វើអ្វីមួយនោះទេ។ ការព្យាករណ៍ខាងក្រោមនេះបង្ហាញពីផលវិបាកនៃកំណើននីវ៉ូទឹកសមុទ្រទៅលើបណ្តាទីក្រុងនានាក្នុងតំបន់អាស៊ី ក្នុងករណីកម្តៅភពផែនដី ស្ថិតក្នុងកម្រិត ២អង្សា ដែលជាកម្រិតត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងឆ្នាំ២០១៥ និងប្រៀបធៀបនឹងករណីដែលកម្តៅដែលឡើងដល់ ៤អង្សា។

**រូបភាព ២៖** កំណើននីវ៉ូទឹកសមុទ្រសកល (SLR) និងការស្រុតដីជាមធ្យមសម្រាប់ទីក្រុងនៅតាមតំបន់ឆ្នេរ (សូមចំណាំថា ការស្រុតដីអាចមានភាពខុសគ្នានៅក្នុងតំបន់ទីក្រុងផ្សេងគ្នា អាស្រ័យទៅតាមកម្រិតទឹកក្រោមដី និងលក្ខណៈស្រទាប់ក្រោមដី) ការស្រុតដីនៅក្នុងទីក្រុងដែលកំពុងស្រុតចុះ




**ប្រភព៖** Deltares, 2015

**តារាងទី២** ចំនួនប្រជាជនបច្ចុប្បន្ននៅក្រោមការកើនឡើងនៃកម្រិតទឹកជំនន់ជាមធ្យមប្រចាំឆ្នាំក្នុងឆ្នាំ២០៥០ ប្រទេសចំណាត់ថ្នាក់ខ្ពស់ទាំង ៦ លើការកាត់បន្ថយការបញ្ចេញឧស្ម័នកម្រិតមធ្យម

| ប្រទេស | SRTM | Coastal DEM | ការប្រែប្រួល |
|---|---|---|---|
| ១. ចិន (ដីគោក) | ២៩ លាននាក់ | ៩៣ លាននាក់ | +៦៧ លាននាក់ |
| ២. បង់ក្លាដែស | ៥ លាននាក់ | ៤២ លាននាក់ | +៣៧ លាននាក់ |
| ៣. ឥណ្ឌា | ៥ លាននាក់ | ៣៦ លាននាក់ | +៣១ លាននាក់ |
| ៤. វៀតណាម | ៩ លាននាក់ | ៣១ លាននាក់ | +២២ លាននាក់ |
| ៥. ឥណ្ឌូនេស៊ី | ៥ លាននាក់ | ២៣ លាននាក់ | +១៨ លាននាក់ |
| ៦. ថៃ | ១ លាននាក់ | ១២ លាននាក់ | +១១ លាននាក់ |
| សរុបជាសកល | ៧៩ លាននាក់ | ៣០០ លាននាក់ | +២២១ លាននាក់ |

Moderate emissions cuts

(RCP 4.5), Kopp et al. 2014. median climate sensitivity, Population exposure estimates do not factor in potential coastal defenses, such as seawalls or levees

**ប្រភព៖** Climate Central, Oct. 2019

ហានិភ័យផ្សេងទៀតសម្រាប់ទីក្រុងទាំងនេះគឺ ការបំពុលផ្ទៃទឹក និងការរីងស្ងួតនៃទឹកក្រោមដី បើទោះជាមានភ្លៀងធ្លាក់ច្រើនក៏ដោយនោះ ដោយសារតែការបូមទឹកពីប្រភពក្រោមដីដើម្បីផ្គត់ផ្គង់ប្រជាពលរដ្ឋសម្រាប់ប្រើប្រាស់ និងការកើនឡើងនៃថ្នល់បេតុងជំនួសឲ្យដីមមោក និងដើមកោងកាងដែលជាប្រភពជួយរក្សាទឹក និងបំពេញឡើងវិញដែលផ្តល់ឲ្យដោយធម្មជាតិនោះ។ ហានិភ័យក៏អាចកើនឡើងចំពោះការប្រេះស្លាន និងទំនប់ ក៏ដូចជា ឧបទ្ទវហេតុដែលកើតចេញពីបណ្ដាញអេឡិចត្រូនិច និងបំពង់ទឹកផងដែរ។ កត្តាមួយទៀតដែលមើលមិនសូវឃើញ ប៉ុន្តែនៅតែគួរឲ្យព្រួយបារម្ភនោះគឺ ការខូចខាតផ្លូវដែលអាចបង្កឲ្យមានការបាក់រលំផ្លូវ និងតំបន់ផ្លូវដើរផ្សេងៗ ក៏ដូចជាស្នាមប្រេះដែលពេលខ្លះមានប្រវែងច្រើនគីឡូម៉ែត្រ ដែលអាចគំរាមកំហែងដល់បណ្ដាញថាមពល និងផ្លូវរថភ្លើងផងដែរ។ ការផ្អៀងអគារ និងការចុះខ្សោយនៃគ្រឹះអគារក៏អាចធ្វើឲ្យមានហានិភ័យក្នុងការដួលរលំអគារផងដែរ។

## យុទ្ធសាស្ត្របន្សាំ និងទប់ទល់ទៅនឹងហានិភ័យ

វិធានការដើម្បីទប់ទល់ទៅនឹងហានិភ័យទាំងនេះត្រូវបានផ្តួចផ្តើមឡើងយ៉ាងជោគជ័យក្នុងតំបន់ទីក្រុងមួយចំនួន។ ឧទាហរណ៍ ទីក្រុងតូក្យូ ដែលស្រុតចុះជម្រៅ ៤,២៥ម ក្នុងចន្លោះឆ្នាំ១៩០០ និង២០១៣ ពេលនេះមិនមានការស្រុតចុះទៀតទេ។ ក្នុងឆ្នាំ១៩៦៨ ដើម្បីពន្យឺតការស្រុតចុះ រដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ញត្តិក្នុងការកម្រិតការបូមទឹកក្រោមដី និងបង្កើតប្រភពទឹកផ្សេងៗមានដូចជា បង្កើតទំនប់អាងទន្លេ និងការប្រោះទឹកកខ្វក់ឡើងវិញ។ ទីក្រុងសៀងហៃដែលស្រុតចុះ ២,៥ម ចាប់តាំងពីឆ្នាំ១៩២០

**រូបភាពទី១.** ការស្រុតដីមើលពីទស្សនៈពហុវិស័យ




ប្រភព: Deltares ឆ្នាំ ២០១៥

បានធ្វើការសាកល្បងដាក់បញ្ចូលឡើងវិញនូវស្រទាប់ទឹកក្នុងដីសិប្បនិម្មិត។ ទីក្រុងបាងកកដែលបានសង់លើកម្ពស់ ១,៥ ម ពីនីវ៉ូទឹកសមុទ្រពេលនោះបានស្រុតចុះ ១០ ស.ម ជារៀងរាល់ឆ្នាំរហូតដល់ប៉ុន្មានឆ្នាំមុននេះ។ សាលាក្រុងគ្រប់គ្រងបាននូវការពន្យឺតនូវការស្រុតចុះ ដែលសព្វថ្ងៃនេះគ្រប់គ្រងការស្រុតដីត្រឹមមួយ ឬពីរស.មប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតការបង្កើតសួនធំៗដូចជាសួនសតវត្សរ៍ (Centenary Park) បានជួយទប់ទល់ទឹកជំនន់ និងជួយស្តុកទឹកនៅពេលមានព្រឹត្តិការណ៍គ្រោះធម្មជាតិ។

ខណៈដែលយុទ្ធសាស្ត្របន្សាំពេលខ្លះ គឺសម្រាប់តំបន់ទីប្រជុំជនតែមួយ វិធានការទប់ទល់ គឺជាផ្នែកមួយដែលតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងដែលធំជាងមុន ដើម្បីកម្រិតកំណើននីវ៉ូទឹកសមុទ្រតាមរយៈការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ដើម្បីសម្រេចបានកិច្ចការនេះ វិធានការទាំងនេះទាមទារឲ្យមានសកម្មភាពស្របគ្នានៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលក្នុងការគាំទ្រគោលនយោបាយថាមពលដែលមានប្រសិទ្ធភាព និងសន្សំសំចៃជាងមុនដែលផ្តល់អាទិភាពទៅលើថាមពលកកើតឡើងវិញតាមដែលអាចទៅរួច និងការប្រឹងប្រែងក្នុងការកាត់បន្ថយការប្រើប្រាស់ឥន្ធនៈហ្វូស៊ីល។

## តួនាទីរបស់សភា

ការត្រួតពិនិត្យ និងគ្រប់គ្រងទឹក គឺមានសារៈសំខាន់ណាស់ក្នុងប្រវត្តិសាស្ត្រនៃការកសាងប្រទេសនៅអាស៊ីអាគ្នេយ៍។ អ្វីដែលថ្មីនោះគឺ ឥទ្ធិពលដ៏សម្បើមនៃការប្រែប្រួលអាកាសធាតុ។ ដើម្បីលើកកម្ពស់យុទ្ធសាស្ត្របន្សាំ និងទប់ទល់ សភាអាចផ្តួចផ្តើមបង្កើតច្បាប់ជួយលើកកម្ពស់ការយល់ដឹងរបស់សាធារណជន តាមដានពីប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងពង្រឹងកិច្ចសហប្រតិបត្តិការតំបន់។

### ក. ច្បាប់ និងបទបញ្ញត្តិ

ដើម្បីដាក់កម្រិតការប្រើប្រាស់ទឹកជាទូទៅ និងជាពិសេសទឹកក្រោមដី និងដើម្បីគ្រប់គ្រងនគរូបនីយកម្ម យើងត្រូវការច្បាប់ ជាពិសេសក្នុងករណីដែលរដ្ឋាភិបាលមានការស្ទាក់ស្ទើរក្នុងការធ្វើសកម្មភាព។ ប្រសិនបើប្រជាពលរដ្ឋមិនបានផលប្រយោជន៍ពីបណ្តាញចែកចាយទឹកស្អាតប្រកបដោយប្រសិទ្ធភាព (ដែលជាករណីរបស់ប្រជាពលរដ្ឋចំនួន ៦៥% នៅទីក្រុងហ្សាការតា) ពួកគេនឹងបន្តបូមទឹកពីស្រទាប់ទឹកក្នុងដីដែលវានឹងបង្កឲ្យបញ្ហាស្រុតដីក្នុងទីក្រុងនេះកាន់តែធ្ងន់ធ្ងរឡើង។ នៅទីក្រុងហ្សាការតាត្រូវបានគំរាមកំហែងខ្លាំងដោយសារបញ្ហា ២យ៉ាងគឺ បញ្ហាស្រុតដី និងកំណើននីវ៉ូទឹកសមុទ្រ។ការឆ្លើយតបរបស់ប្រទេសនេះទៅនឹងបញ្ហា

ទាំងអស់នេះគឺ ការសាងសង់ជញ្ជាំងកម្ពស់ ៤ ម៉ែត្រដែលមានប្រវែង ៣២ គ.ម។ ដំណាក់កាលទីមួយជញ្ជាំងប្រវែង ៨ គ.ម ត្រូវបានចាប់ផ្តើមសាងសង់ក្នុងឆ្នាំ២០១៤ ហើយគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២៥។ ការប្តេជ្ញាចិត្តនេះត្រូវបានអ្នកបរិស្ថានរិះគន់យ៉ាងខ្លាំង ដោយសារវាតម្រូវឲ្យមានការសង់ជញ្ជាំងបាំងឆ្នេរប្រវែង ៥០០ គ.ម ដែលរចនាឡើងដើម្បីការពារទីក្រុងរបស់ខ្លួនទប់ទល់នឹងសមុទ្រចាក់។ តម្លៃនៃគម្រោងនេះ ដែលមានឈ្មោះថា ផែនការមេសម្រាប់ការអភិវឌ្ឍតំបន់ឆ្នេរចម្រុះរដ្ឋធានីជាតិ ត្រូវបានគេប៉ាន់ស្មានថាចំណាយអស់ទឹកប្រាក់ចំនួន ៤០ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹងចំនួនថវិកាដែលអាចសាងសង់ទីក្រុងមួយថ្មីបាន។

អភិក្រមរបស់ប្រទេសថៃក្នុងការដោះស្រាយបញ្ហាស្រុតដីក្នុងរាជធានីរបស់គេគឺ ការប្រើប្រាស់នូវបទបញ្ញត្តិយ៉ាងតឹងរ៉ឹងបំផុត ដែលដំណោះស្រាយនេះស្រដៀងទៅនឹងអភិក្រមរបស់ជនជាតិជប៉ុននៅក្នុងទីក្រុងតូក្យូ។ ច្បាប់ស្តីពី ទឹកក្រោមដីរបស់ទីក្រុងបាងកកត្រូវបានអនុម័តក្នុងឆ្នាំ១៩៧៧ ដើម្បីគ្រប់គ្រងទឹកឲ្យបានប្រសើរជាងមុន ដែលច្បាប់នេះបានដាក់គោលដៅទៅលើតំបន់ដែលងាយរងគ្រោះបំផុត។ ចាប់ពីពេលនោះមកកម្រិតស្រុតដីក្នុងរាជធានីត្រូវបានកាត់បន្ថយ តែមិនទាន់បានឈប់នោះទេដោយសារតែការបូមទឹកខុសច្បាប់នៅតែបន្ត បើទោះបីជាមិនសូវមានច្រើនក៏ដោយ។

ខណៈកំពុងបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្របន្សាំ រដ្ឋាភិបាលត្រូវតែពិចារណាអំពីហានិភ័យអាកាសធាតុនៅពេលសិក្សាវាយតម្លៃទៅលើផលប៉ះពាល់ជាសក្តានុពលទៅលើបុគ្គល និងភាគីពាក់ព័ន្ធផ្សេងទៀត។

## ខ. ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងភាគីពាក់ព័ន្ធ

សភាអាចជួយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋស្តីពី បញ្ហាប្រឈម និងគោលនយោបាយដែលចាំបាច់ត្រូវដឹងដើម្បីបន្សាំ និងទប់ទល់ទៅនឹងបញ្ហាប្រឈមនៃហានិភ័យនៃការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំសន្និសីទកិច្ចពិគ្រោះយោបល់ជាមួយក្រុមអ្នកជំនាញ បេសកកម្មរបស់សភា និងការចុះអង្កេតក្នុងតំបន់ជាដើម។ កិច្ចការទាំងនេះចាំបាច់ត្រូវតែ៖

- កំណត់កត្តាដែលងាយរងគ្រោះចំពោះតំបន់ សេដ្ឋកិច្ច បរិស្ថាន និងប្រជាពលរដ្ឋដែលបង្កមកពីការប្រែប្រួលអាកាសធាតុ
- លើកកម្ពស់ការយល់ដឹងស្តីពី ហានិភ័យដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងតម្រូវការក្នុងការត្រៀមខ្លួនចំពោះហានិភ័យទាំងនោះ
- កំណត់ផលប៉ះពាល់ដែលអាចកើតមាន និងចាត់ចំណាត់ថ្នាក់លើភាពសំខាន់ លទ្ធភាពដែលអាចទៅរួច និងភាពបន្ទាន់របស់ផលប៉ះពាល់ទាំងនោះ
- តាមដាន និងវាយតម្លៃមើលថា តើមានការកើតឡើងនូវការផ្លាស់ប្តូរដែលគិតទុកជាមុនទៅលើបរិស្ថានឬទេ ហើយប្រសិនបើមាន តើវាស្ថិតនៅក្នុងល្បឿនណា
- គណនាការចំណាយ និងផលប្រយោជន៍នៃយុទ្ធសាស្ត្របន្សាំនានា (ការមិនធ្វើអ្វីសោះ ការប្តូរទីតាំង ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការបំលែងសកម្មភាពសេដ្ឋកិច្ច ។ល។)
- វិភាគលើការឆ្លើយតបរបស់យុទ្ធសាស្ត្របន្សាំ និងលទ្ធផលរបស់វា
- បន្តសិក្សាវាយតម្លៃពីហានិភ័យ និងយុទ្ធសាស្ត្រដែលបានដាក់ចេញ។

## គ. ការតាមដានសមិទ្ធផល

គណៈកម្មាធិការចំពោះកិច្ចរបស់សភា គួរធ្វើសវនកម្ម និងអធិការកិច្ចប្រចាំឆ្នាំ ដើម្បីវាយតម្លៃពីកម្រិតនៃការអនុវត្តច្បាប់។

## ឃ. កិច្ចសហប្រតិបត្តិការក្នុងតំបន់

បណ្តាប្រទេសអាស៊ានមានបរិស្ថានធម្មជាតិដូចគ្នា ដំណើរការនគរូបនីយកម្មមមាញឹកដូចគ្នា បញ្ហាទឹកដូចគ្នា និងការគំរាមកំហែងអាកាសធាតុដូចគ្នា។ ដូចនេះ វាផ្តល់ប្រយោជន៍ស៊ីជម្រៅឲ្យគ្នាទៅវិញទៅមកក្នុងស្មារតីរួមរបស់អាស៊ាន ដែលត្រូវមានការចែករំលែកបទពិសោធន៍ និងឧទាហរណ៍នៃការអនុវត្តល្អៗ ដើម្បីសន្សំសំចៃពេលវេលាក្នុងការទប់ទល់ទៅនឹងគ្រោះមហន្តរាយទាំងនេះ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិនៃកម្ពុជា (NIDIR) ។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ៖ https://www.pcasia.org ។

# ៣.៣ ការប្រែប្រួលអាកាសធាតុ និងការការពារតំបន់ព្រៃធម្មជាតិ៖ ទស្សនៈពីខាងតំបន់អាស៊ីអាគ្នេយ៍

## បរិបទ

ការប្រែប្រួលបម្រែបម្រួលអាកាសធាតុកំពុងបង្កឲ្យមានផលប៉ះពាល់អវិជ្ជមានជាច្រើនទៅដល់ ប្រព័ន្ធអេកូឡូស៊ី ផលិតកម្មកសិកម្មនិងសេដ្ឋកិច្ច [១, ២, ៣]។ ឥទ្ធិពលរបស់វាបានធ្វើឲ្យរដូវប្រាំងអូសបន្លាយវែងជាងមុន ការកើនឡើងនូវសីតុណ្ហភាពក្នុងបរិយាកាសនិងគ្រោះធម្មជាតិពាក់ព័ន្ធនឹងជំនន់ទឹកភ្លៀងកើតឡើងកាន់តែញឹកញាប់ [៤, ៥]។ បម្រែបម្រួលទាំងនេះបានប៉ះពាល់ជាខ្លាំងទៅលើប្រព័ន្ធផលិតកម្មស្បៀងរបស់ពិភពលោក ហើយទំហំនៃការប៉ះពាល់ទៀតសោតប្រែប្រួលទៅតាមតំបន់[៥]។

ការកាប់បំផ្លាញព្រៃឈើជាកត្តាចម្បងមួយដែលចូលរួមចំណែកធ្វើឲ្យមានការប្រែប្រួលអាកាសធាតុ។ ការបាត់បង់គំរបព្រៃឈើនាំទៅដល់ការប្រែប្រួលនៃវដ្តទឹកនៅក្នុងបរិយាកាស និងថយចុះនូវបរិមាណពពកដែលជាហេតុនាំឲ្យមានការប្រែប្រួលលក្ខខណ្ឌអាកាសធាតុ។ ការកាប់បំផ្លាញព្រៃឈើក៏ចូលរួមចំណែកទៅដល់ការកើនឡើងកំដៅផែនដីដោយវាបានបន្ថែមបរិមាណ $CO_2$ កាន់តែច្រើនទៅក្នុងបរិយាកាស[៦]។ ការរានដីព្រៃសម្រាប់កសិកម្មនិងការកាប់ឈើសម្រាប់ពាណិជ្ជកម្មគឺជាកត្តាចម្បងដែលធ្វើឲ្យបាត់បង់ព្រៃឈើ ហើយដែលភាគច្រើនឃើញមាននៅតំបន់អាម៉ាហ្សូន និងតំបន់ត្រូពិចផ្សេងទៀតដូចជាអាស៊ីអាគ្នេយ៍ជាដើម[៧, ៨]។ ជាឧទាហរណ៍ គ្រាន់តែការផ្លាស់ប្តូររបៀបនៃការប្រើប្រាស់ដីនៅតំបន់ត្រូពិចបានធ្វើឲ្យមានការបញ្ចេញឧស្ម័នផ្ទះកញ្ចក់បន្ថែមចូលទៅក្នុងបរិយាកាសប្រមាណពី១៤-២០% លើបរិមាណសរុបដែលបានបញ្ចេញទូទាំងពិភពលោករវាងឆ្នាំ២០០០-២០០៧ [៧]។ការកើនឡើងនូវតម្រូវការស្បៀងនិងផលិតផលកសិកម្មក្នុងពិភពលោកជំរុញនូវការអនុវត្តកសិកម្មបែបអតិផល ហើយការរានដីព្រៃសម្រាប់កសិកម្មក៏កាន់តែបន្ត[៩]។

ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើនិងការខិតខំស្តារព្រៃឈើឡើងវិញជាជម្រើសដែលមានប្រសិទ្ធភាពនិងចំណាយតិចក្នុងការកាត់បន្ថយការកើនឡើងកំដៅផែនដី និងការទប់ទល់ទៅនឹងការប្រែប្រួលអាកាសធាតុ[៦,៩]។ អត្ថបទនេះរៀបរាប់ អំពីស្ថានភាពរបស់ព្រៃត្រូពិចនៅអាស៊ីអាគ្នេយ៍ រួមជាមួយនឹងការពិភាក្សាពីផលប៉ះពាល់នានានៃការកាប់បំផ្លាញព្រៃឈើនិងការប្រែប្រួលអាកាសធាតុ និងសង្ខេបគោលនយោបាយដែលប្រទេសនីមួយៗបានដាក់ចុះដើម្បីដោះស្រាយបញ្ហាទាំងនេះ។

## ស្ថានភាពព្រៃឈើនៅអាស៊ីអាគ្នេយ៍

ផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើនៅអាស៊ីអាគ្នេយ៍បានធ្លាក់ចុះជាលំដាប់ ដោយសារកំណើននៃការរានដីព្រៃសម្រាប់ការធ្វើកសិកម្ម[១០,១១]។ ការអភិវឌ្ឍកសិកម្មក្នុងតំបន់ប្រព្រឹត្តិទៅយ៉ាងឆាប់រហ័សក្នុងអំឡុងពេលនៃបដិវត្តន៍បៃតងដែលជំរុញដោយការកើនឡើងនូវតម្រូវការផលិតផលកសិកម្ម[១២]។ ទាំងនេះអាចមើលឃើញយ៉ាងជាក់ច្បាស់តាមរយៈកំណើនផលិតកម្មដំណាំពាណិជ្ជកម្ម [១៣,១៤]។ ទិន្នន័យបានបង្ហាញពីការធ្លាក់ចុះនៃគំរបព្រៃឈើស្ទើរគ្រប់ប្រទេសទាំងអស់ក្នុងតំបន់លើកលែងតែប្រទេសវៀតណាម ឡាវ និងហ្វីលីពីន (រូបភាពទី១)។ សម្រាប់ប្រទេសឡាវ គោលនយោបាយប្រើប្រាស់ដីដែលបានរៀបចំដើម្បីកាត់បន្ថយកសិកម្មពនេចរ និងកំណត់តំបន់ព្រៃបម្រុងបានចូលរួមចំណែកសំខាន់ក្នុងការកាត់បន្ថយការរានដីព្រៃសម្រាប់ការធ្វើកសិកម្ម[១៥] ។

ផ្ទៃដីកសិកម្មរបស់ប្រទេសថៃបានកើនពី២៣% ក្នុងឆ្នាំ១៩៦០ ទៅដល់៤២% ក្នុងឆ្នាំ១៩៩៣ ដែលក្នុងរយៈពេលដូចគ្នាផ្ទៃដីកសិកម្មរបស់ប្រទេសម៉ាឡេស៊ីបានកើន ១១%[១៦]។ កំណើនតម្រូវការប្រេងឆា និងជីវៈឥន្ធនៈសកលបានធ្វើឲ្យផលិតកម្មដូងប្រេងនៅប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ីកើនឡើងយ៉ាងខ្លាំងក្នុងចន្លោះ ឆ្នាំ១៩៩០-២០០៧[១៧]។ ព្រៃឈើប្រមាណជា ៨លានហិកតាត្រូវបានកាប់ដើម្បីយកដីសម្រាប់ដាំដូងប្រេង ហើយមានការបម្រុងទុកដីព្រៃជាច្រើនលានហិកតាថែមទៀតសម្រាប់ការពង្រីកការដាំដុះដំណាំនៅពេលសម្រាប់អនាគត [១៨]។ ត្រឹមឆ្នាំ២០០៤ ប្រមាណជា៨៥% នៃប្រេងដូងក្នុងពិភពលោកត្រូវបានផលិតក្នុងប្រទេសទាំងពីរនេះ [១៣]។ ក្នុងឆ្នាំ២០១៤ ផ្ទៃដីសម្រាប់ផលិតកម្មដូងប្រេងកើនដល់ ១៥លានហិកតា[១៩]។

ការបាត់បង់ព្រៃឈើកើតមានគួរឲ្យកត់សម្គាល់ក្នុងប្រទេសកម្ពុជា ឥណ្ឌូនេស៊ី និងមីយ៉ាន់ម៉ា ក្នុងអំឡុងឆ្នាំ ១៩៩០-២០១៦។ គំរបព្រៃឈើធ្លាក់ចុះពី៧៣ ទៅ៥២% សម្រាប់កម្ពុជា ពី៦៥ ទៅ៤៩% ក្នុងប្រទេសឥណ្ឌូនេស៊ី និងពី៦០ទៅ៤៣% សម្រាប់ប្រទេសមីយ៉ាន់ម៉ា។ ប្រទេសកម្ពុជា និងឥណ្ឌូនេស៊ីជាប្រទេសដែលមានការពង្រីកផ្ទៃដីសម្រាប់កសិកម្មលឿនបំផុតក្នុងតំបន់ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ[១៦]។ ក្រៅពីការរានដីព្រៃសម្រាប់វិស័យ

កសិកម្ម ការកាប់ព្រៃឈើសម្រាប់ពាណិជ្ជកម្ម គឺជាមូលហេតុចម្បងនៃការបាត់បង់ព្រៃឈើនៅប្រទេសមីយ៉ាន់ម៉ា[២០]។ ប្រទេសកម្ពុជាក៏ដូចជាប្រទេសឡាវ និងមីយ៉ាន់ម៉ាដែរ ការវិនិយោគលើវិស័យកសិកម្មយ៉ាងសន្ធឹកសន្ធាប់ពីប្រទេសចិនរួមជាមួយនឹងដីព្រៃដែលទំនេរ ហើយមានតំលៃថោកបានជំរុញឲ្យមានការដាំដុះនូវដំណាំពាណិជ្ជកម្មមួយចំនួនដូចជាកៅស៊ូនិងដំឡូងមីជាដើម[២១,២២]។ មានការប៉ាន់ស្មានថា ផ្ទៃដីដាំកៅស៊ូក្នុងតំបន់នឹងកើនឡើងបួនដងត្រឹមឆ្នាំ ២០៥០ ហើយភាគច្រើននៃដីទាំងនេះគឺបានមកពីការរានដីព្រៃធម្មជាតិ[២៣] ។

## ផលប៉ះពាល់បណ្តាលមកពីការកាប់បំផ្លាញព្រៃឈើនិងការប្រែប្រួលអាកាសធាតុ

ដូចបានរៀបរាប់ពីខាងដើម ការកាប់បំផ្លាញព្រៃឈើបានចូលរួមចំណែកដល់ការកើនឡើងកំដៅផែនដីនិងជំរុញឲ្យមានការប្រែប្រួលអាកាសធាតុ[៦]។ អាស៊ីអាគ្នេយ៍កំពុងរងគ្រោះពីបាតុភូតធម្មជាតិដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុដែលមានដូចជា ទឹកជំនន់ រលកកំដៅ ភាពរាំងស្ងួត ភ្លើងឆេះព្រៃ និងព្យុះស៊ីក្លូន។ល។ នៅឆ្នាំ២១០០ សីតុណ្ហភាពជាមធ្យមនៅប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងវៀតណាមនឹងកើនប្រមាណជា ៤.៨0C ហើយនីវ៉ូទឹកសមុទ្រនឹងកើនបន្ថែម៧០សង់ទីម៉ែត្រ[២៤]។ ការកើនឡើងសីតុណ្ហភាពនេះនឹងបង្កឲ្យមានការផ្លាស់ប្តូររបបភ្លៀងមូសុងក៏ដូចជាការមកដល់យឺតនៃរដូវវស្សា ហើយទឹកជំនន់រដូវវស្សាដែលមានលក្ខណៈកាន់តែធ្ងន់ធ្ងរខ្លាំងជាងមុន[២៥]។ តាំងពីឆ្នាំ២០០៩ ប្រទេសអាស៊ីអាគ្នេយ៍ដីគោកដូចជា កម្ពុជា វៀតណាម ថៃ មីយ៉ានម៉ា និងឡាវ បានទទួលកំរិតទឹកភ្លៀងធ្លាក់តិចជាងបរិមាណជាមធ្យមរយៈពេលវែងរបស់ខ្លួនដោយក្នុងពេលជាមួយគ្នាប្រទេសហ្វីលីពីនបានរងនូវបាតុភូត El Nino ដែលបណ្តាលឲ្យរដូវវស្សាមកយឺត ហើយមានរយៈពេលខ្លីជាងមុន[២៤]។

ភាពមិនទៀងទាត់របស់ដំណើរទឹកភ្លៀង ការកើនឡើងកំដៅ និងលក្ខខណ្ឌអាកាសធាតុមិនអំណោយផលផ្សេងទៀតដូចជាភាពរាំងស្ងួតនិងទឹកជំនន់បានប៉ះពាល់ជាខ្លាំងលើទិន្នផលដំណាំ ហើយដែលធ្វើឲ្យវិស័យកសិកម្មក្លាយជាវិស័យមួយដែលងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុ។ ការកើនឡើងកំដៅត្រូវបានគេរកឃើញថា មានទំនាក់ទំនងជាមួយនឹងការធ្លាក់ចុះនៃទិន្នផលដំណាំ[២៦, ២៧]។ ការសិក្សាថ្មីៗបង្ហាញថា ការកើនឡើងកំដៅត្រឹម ១0C អាចធ្វើឲ្យទិន្នផលស្រូវក្នុងតំបន់ធ្លាក់ចុះប្រមាណ១០%។ នៅក្នុងសេនារីយ៉ូនៃការប្រែប្រួលអាកាសធាតុក្នុងពេលបច្ចុប្បន្ននិងប្រសិនបើគ្មានវិធីសាស្រ្តនិងបច្ចេកទេសកសិកម្មសម្រាប់បន្សាំទៅនឹងការប្រែប្រួលអស់ទាំងនេះទេ ទិន្នផលស្រូវក្នុងប្រទេសហ្វីលីពីន ថៃ និងវៀតណាមត្រឹមឆ្នាំ២១០០ អាចនឹងធ្លាក់ចុះប្រមាណពាក់កណ្តាល និងប្រហែលជា៣៤% សម្រាប់ប្រទេសឥណ្ឌូនេស៊ី [២៤]។ ក្នុងរយៈពេលថ្មីៗនេះ ភាពរាំងស្ងួតក្នុងប្រទេសថៃ និងហ្វីលីពីនបានបង្កឡើងជាបញ្ហាទាក់ទងទៅនឹងការខ្វះខាតទឹកប្រើប្រាស់ក្នុងវិស័យកសិកម្ម[២៤,២៨] ។

**រូបភាពទី ១៖** និន្នាការនៃការប្រែប្រួលគំរបព្រៃឈើ




**ប្រភព៖** World Development Indicators 2018

ភាពមិនទៀងទាត់របស់ជំណើរទឹកភ្លៀង ការកើនឡើងនីវ៉ូទឹកសមុទ្រ និងការកើនឡើងកំហាប់អំបិលក្នុងទឹកនៅតាមតំបន់ទំនាបទន្លេនៃប្រទេសវៀតណាម និងមីយ៉ាន់ម៉ាបានធ្វើឲ្យតំបន់ទាំងនេះងាយរងគ្រោះទៅនឹងការជាំទឹកការលិចទឹកជាប្រចាំ និងការកើនសារជាតិអំបិលនៅក្នុងដី[២៤]។ ទឹកជំនន់នៅប្រទេសឥណ្ឌូនេស៊ីប៉ះពាល់ដីស្រែ២៦៨.៨២៣ហិកតា និងខូចខាតផលស្រូវប្រមាណ១.៣៤៤លានតោន[២៤]។ ការកើនឡើងនីវ៉ូទឹកសមុទ្រនឹងបណ្តាលឲ្យលិចលង់ដីស្រែពី ១៥-២០លានហិចតា ទូទាំងអាស៊ីអាគ្នេយ៍ ហើយដែលបង្កជាការគំរាមកំហែងទៅដល់សន្តិសុខស្បៀងរបស់ប្រទេសក្នុងតំបន់[២៤]។ការកើនឡើងនីវ៉ូទឹកសមុទ្រត្រឹម៤០សង់ទីម៉ែត្រ អាចធ្វើឲ្យប្រជាជន ២១លានអ្នកដែលរស់នៅតាមតំបន់ឆ្នេរនិងតាមដងទន្លេនៅអាស៊ីអាគ្នេយ៍បាត់បង់ទីលំនៅ។ តាមការព្យាករណ៍ ១១% នៃជនជាតិវៀតណាមនឹងរងផលប៉ះពាល់ប្រសិនបើនីវ៉ូទឹកសមុទ្រឡើងមួយម៉ែត្រ[២៩]។ បច្ចុប្បន្ននេះ ផ្នែកខ្លះរបស់ទីក្រុងចាការតាគឺស្ថិតនៅក្រោមនីវ៉ូសមុទ្ររួចទៅហើយ ដែលក្នុងពេលជាមួយគ្នានេះទីក្រុងបាងកក និងម៉ានីលកំពុងរងការគំរាមកំហែងពីការកើនឡើងកំពស់ទឹកសមុទ្រ ភ្លៀងធ្លាក់គំហុកជាប្រចាំ និងព្យុះស៊ីក្លូនត្រូពិច[៣០]។

ការប្រែប្រួលអាកាសធាតុធ្វើឲ្យមានការប្រែប្រួលលក្ខណៈរបស់មូសុងវស្សា។ ការប្រែប្រួលនេះគួបផ្សំជាមួយនឹងការកសាងទំនប់វារីអគ្គិសនីជាច្រើននៅតាមដងទន្លេមេគង្គបានធ្វើឲ្យប៉ះពាល់ដល់ដំណើរលំហូរ និង លក្ខណៈរបស់ទឹកទន្លេ និងការកើនកំដៅក្នុងអាងទន្លេ[២៤,៣១]។ បើតាមគណៈកម្មការទន្លេមេគង្គកម្រិតទឹក ទន្លេមេគង្គក្នុងឆ្នាំ២០២០បានធ្លាក់ចុះដល់កម្រិតទាបបំផុត មិនធ្លាប់មានក្នុងរយៈពេល៦០ឆ្នាំ។ ផលិតភាពនិងសេវាអេកូឡូស៊ីរបស់បឹងទន្លេសាបនឹងទទួលផលប៉ះពាល់អវិជ្ជមានខ្លាំងពីការប្រែប្រួលនិងការអភិវឌ្ឍទាំងនេះ[៣២]។រដូវប្រាំងដែលយូរជាងមុនការកើនឡើងកំដៅផែនដី និងការផ្លាស់ប្តូររបៀបប្រើប្រាស់ដីបានផ្តល់នូវលក្ខខណ្ឌដែលងាយបង្កឲ្យមានភ្លើងឆេះព្រៃ[៣៣]។ ភ្លើងឆេះព្រៃនៅកាលីម៉ាន់តាននិងកោះស៊ូម៉ាត្រារបស់ឥណ្ឌូនេស៊ីបានបំផ្លាញសេវាអេកូឡូស៊ីព្រៃឈើ ជីវៈចម្រុះ និងធ្វើឲ្យមានការប្រែប្រួលវដ្តទឹកក្នុងបរិយាកាស និងលក្ខខណ្ឌអាកាសធាតុក្នុងតំបន់[៣៣]។ ការប្រែប្រួលអាកាសធាតុនិងការកើនឡើងកំដៅផែនដីជាកត្តាដែលធ្វើឲ្យពូជដើមឈើមួយចំនួនដូចជាស្រល់និងកោងកាងពិបាកលូតលាស់និងរីកសាយ[៣៤,៣៥]។ ស្រដៀងគ្នានេះដែរ ការប្រែប្រួលអាកាសធាតុបាននាំទៅដល់ការផ្លាស់ប្តូរលក្ខណៈគីមីនិងរូបសាស្ត្ររបស់សមុទ្រដែលបណ្តាលអោយមានការប្រែប្រួលលក្ខខណ្ឌរដូវកាលរបស់ត្រី និងបរិមាណត្រីពីតំបន់មួយទៅតំបន់មួយ។ ការប្រែប្រួលនេះអាចនឹងធ្វើឲ្យធ្លាក់ចុះនូវបរិមាណត្រីនៅតំបន់អាស៊ីអាគ្នេយ៍ប្រហែលជា១០% នៅឆ្នាំ២០៥០[៣៦]។

## គោលនយោបាយសម្រាប់ការអភិរក្សតំបន់ព្រៃធម្មជាតិ

ការការពារធនធានព្រៃឈើ គឺជាចំណុចស្នូលរបស់គោលនយោបាយបរិស្ថាននិងការប្រែប្រួលអាកាសធាតុរបស់ប្រទេសស្ទើរតែទាំងអស់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍[៣៧]។ ក្របខ័ណ្ឌគតិយុត្តិនិងអភិក្រមផ្សេងៗត្រូវបានអនុវត្ត[៣៨]។ នៅថ្នាក់តំបន់ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍បានបង្កើតក្រុមការងារបច្ចេកទេសពីរដែលធ្វើការលើ (១)ការអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះ(AWGNCB)(២)ការគ្រប់គ្រងធនធានទឹក (AWGWRM)។ ក្រុមការងារទាំងពីរនេះជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងតំបន់ដើម្បីប្រយុទ្ធប្រឆាំងទៅនឹងការកាប់បំផ្លាញព្រៃឈើ និងជំរុញការដាំដុះនិងស្តារព្រៃធម្មជាតិឡើងវិញ។ បន្ថែមពីលើនេះអាស៊ានក៏បានផ្តួចផ្តើមឲ្យមានក្របខ័ណ្ឌយុទ្ធសាស្ត្រមួយចំនួនទៀតដូចជា ក្របខ័ណ្ឌពហុវិស័យអាស៊ានលើការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រអាស៊ានសម្រាប់ដោះស្រាយបញ្ហាក្នុងវិស័យកសិកម្ម ព្រៃឈើនិងជលផល និងគំនិតផ្តួចផ្តើម Heart of Borneo ជាដើម[៣៩]។ ក្រុមការងារពិសេសមួយត្រូវបានបង្កើតនៅឆ្នាំ២០០២ ដើម្បីរៀបចំគម្រោងវិញ្ញាបនកម្មព្រៃឈើសម្រាប់អាស៊ាន [៤០]។ សេចក្តីប្រកាសទាក់ទងនឹងនិរន្តរភាពបរិស្ថានត្រូវបានអនុម័តដោយអាស៊ានក្នុងឆ្នាំ២០០៧ ដែលគោលបំណងសំខាន់មួយរបស់សេចក្តីប្រកាស គឺដើម្បីពង្រឹងការអនុវត្តច្បាប់សម្រាប់ការប្រយុទ្ធប្រឆាំងជាមួយនឹងការកាប់បំផ្លាញ និងការជួញដូរឈើខុសច្បាប់។ សេចក្តីប្រកាសនេះបាននាំឲ្យមានការបង្កើតនូវបណ្តាញចែករំលែកព័ត៌មានក្នុងតំបន់ដើម្បីពង្រឹងការអនុវត្តច្បាប់និងអភិបាលកិច្ចព្រៃឈើ[៤០]។ ប្រទេសកម្ពុជា ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន និងថៃជាសមាជិកអង្គការព្រៃឈើត្រូពិចអន្តរជាតិ(ITTO)[៣៧]។សម្រាប់ថ្នាក់ជាតិ ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព(Sustainable Forest Management SFM) គឺជាស្នូលរបស់គោលនយោបាយគ្រប់គ្រងព្រៃឈើ[៣៧]។ នៅក្រោម SFM គោលការណ៍អនុវត្ត (Code of Practice COP) ត្រូវបានរៀបចំដើម្បីការអនុវត្តច្បាប់គ្រប់គ្រងព្រៃឈើ និងដើម្បីកាត់បន្ថយផលប៉ះពាល់ដែលបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើដល់បរិស្ថាន និងសង្គម។ អាស៊ានអនុម័ត COP នៅឆ្នាំ២០០១។ ប្រទេសមួយចំនួនដូចជា កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី និងមីយ៉ាន់ម៉ាបានរៀបចំ COP

របស់ខ្លួនក្នុងឆ្នាំ២០០៩[៣៧]។ កំណែទម្រង់ចម្បងៗក្នុងវិស័យព្រៃឈើត្រូវបានចាប់អនុវត្តតាំងពីឆ្នាំ១៩៩៩ នៅក្នុងប្រទេសឥណ្ឌូនេស៊ី ហ្វីលីពីន ថៃ និងក្រោយមកកម្ពុជានិងវៀតណាម[៣៨]។ ប្រទេសថៃហាមឃាត់ការកាប់ព្រៃឈើចាប់តាំងពីឆ្នាំ១៩៨៨។ ដោយអនុវត្តតាមសេចក្តីប្រកាសទីក្រុងបាលីវិធានការស្រដៀងគ្នាដើម្បីទប់ស្កាត់ការលួចកាប់និងជួញដូរឈើខុសច្បាប់ត្រូវបានអនុវត្តក្នុងប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី និង ហ្វីលីពីន [៤០]។ ប្រទេសឥណ្ឌូនេស៊ីបានអនុម័តច្បាប់មួយចំនួនដើម្បីការពារធនធានព្រៃឈើ[៤១]។ កម្ពុជាក៏ដូចជាបណ្តាប្រទេសអាស៊ានជិតខាងបានរៀបចំគោលការណ៍ណែនាំស្តីពីជីវចម្រុះគ្រប់ជ្រុងជ្រោយសម្រាប់ការគ្រប់គ្រងព្រៃសម្បទាន[៣៧]។

ជាការឆ្លើយតបទៅនឹង UNFCCC និងពិធីសារក្យូតូ បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍បានបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ក្នុងទប់ទល់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំ និងអនុវត្តកម្មវិធី REDD និង REDD+ មួយចំនួនធំនៃកម្មវិធីនេះគឺផ្តោតទៅលើការអភិរក្សព្រៃឈើនិងការលើកកម្ពស់ការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព [៤២,៤៣,៤៤]។ នៅក្នុងយុទ្ធសាស្ត្រ REDD+ ថ្នាក់ជាតិ ជាឧទាហរណ៍ ប្រទេសហ្វីលីពីនបានអនុវត្តដោយយកចិត្តទុកដាក់នូវយន្តការការពារព្រៃឈើនៅទូទាំងតំបន់ការពារ។ កម្មវិធីនេះមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការជំរុញសន្និធិកាបូនរបស់ប្រទេស បើទោះជាវាបានកាត់ផ្តាច់ប្រជាពលរដ្ឋនៅក្នុងតំបន់ពីប្រភពចំណូលរបស់ពួកគេក៏ដោយ។ លក្ខណៈស្រដៀងគ្នានេះត្រូវបានមើលឃើញពីការអនុវត្តគម្រោងការពារព្រៃឈើនៅក្នុងប្រទេសថៃ [៤៤]។ គម្រោងការពារព្រៃឈើនៅឥណ្ឌូនេស៊ីបានជះផលវិជ្ជមានយ៉ាងច្រើនទាំងក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន និងការផ្តល់ផលប្រយោជន៍ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ នេះក៏ដោយសារអត្ថប្រយោជន៍នានាដែលបានមកពីការគ្រប់គ្រងព្រៃឈើត្រូវបានផ្តល់ទៅឲ្យប្រជាពលរដ្ឋក្នុងតំបន់វិញ[៤៤] ។ សហគមន៍ ព្រៃឈើ ជាផ្នែកសំខាន់ក្នុងកម្មវិធីគ្រប់គ្រងព្រៃឈើរបស់ប្រទេសមីយ៉ាន់ម៉ា [៤៥] ។ ប្រទេសឡាវបានអនុវត្តដោយជោគជ័យនូវកម្មវិធី គ្រប់គ្រងការប្រើប្រាស់ដីតាមរយៈការកាត់បន្ថយការរានដីព្រៃដើម្បីកសិកម្ម និងការរក្សាព្រៃធម្មជាតិ[១៥]។ ប្រទេសកម្ពុជាបានអនុវត្តគម្រោង REDD ថ្នាក់ជាតិតាំងពីឆ្នាំ២០១១ ក្នុងគោលបំណងដើម្បីជំរុញការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងដើម្បីលក់ឥណទានកាបូន។ គម្រោងក៏មានគោលដៅដើម្បីទ្រទ្រង់សហគមន៍ព្រៃឈើ និងលើកកម្ពស់ការគ្រប់គ្រងតំបន់ព្រៃការពារ[៤៦]។

## តួនាទីរបស់សភា

ទោះបីជាមានកិច្ចខិតខំទាំងនេះប៉ុន្តែតំបន់ព្រៃធម្មជាតិនៅអាស៊ីអាគ្នេយ៍នៅតែបន្តធ្លាក់ចុះ ហើយឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុក៏កាន់តែកើនឡើង។ ប្រឈមទៅនឹងបញ្ហាទាំងនេះ តួនាទីរបស់សភាក្នុងការធានាឲ្យបាននូវប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់និងគោលនយោបាយពាក់ព័ន្ធគឺរឹតតែមានសារៈសំខាន់។ជាមួយនឹងមុខងារត្រួតពិនិត្យ សភាអាចកោះប្រជុំជាប្រចាំជាមួយនឹងក្រសួងពាក់ព័ន្ធដើម្បីកំណត់ពីការប្រឈមនានាក្នុងការអនុវត្តនិងពង្រឹងការអនុវត្តច្បាប់។ សភាអាចយកឱកាសនេះសម្រាប់ផ្តល់ជាយោបល់និងគំនិតឲ្យបានទាន់ពេលវេលាមុននឹងសម្រេចអនុម័តច្បាប់ ឬការធ្វើវិភាជថវិកា។

សភាអាចពិចារណាធ្វើវិសោធនកម្មច្បាប់ និងគោលនយោបាយគ្រប់គ្រងព្រៃឈើ តាមរយៈការផ្តល់នូវធាតុចូលសំខាន់ៗក្នុងដំណាក់កាលរៀបចំវិសោធនកម្ម ដើម្បីធានាឲ្យបានថា ការអនុវត្តច្បាប់ទាំងនោះនឹងចូលរួមដោះស្រាយបញ្ហាពិតប្រាកដមែន។ ការត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាពពីក្រសួងពាក់ព័ន្ធក៏អាចផ្តល់នូវព័ត៌មានសំខាន់ៗទាក់ទិនទៅនឹងនិន្នាការអភិវឌ្ឍន៍ក្នុងវិស័យនីមួយៗ។ សភាអាចប្រមូលនូវធាតុចូលនិងបទពិសោធន៍ល្អៗបន្ថែមទាក់ទងទៅនឹងការអភិវឌ្ឍ វិស័យកសិកម្មនិងព្រៃឈើនិងការប្រែប្រួលអាកាសធាតុពីបណ្តាអង្គការសង្គមស៊ីវិលដែលធ្វើការផ្ទាល់ និងពីរបកគំហើញដែលបានមកពីការស្រាវជ្រាវថ្មីៗរបស់ស្ថាប័នស្រាវជ្រាវ។ ការដាក់បញ្ចូលនូវធាតុចូលទាំងនេះអាចធានាបានថា បញ្ហាដែលបានកើតឡើងនៅតំបន់មូលដ្ឋានត្រូវបានជ្រួតជ្រាបដល់ និងទទួលបានអន្តរាគមន៍ពីសភា។ ក្នុងន័យនេះ សមាជិកសភាអាចបន្តពាំនាំនិងចែករំលែកនូវព័ត៌មានដែលខ្លួនទទួលបានទៅដល់ថ្នាក់ដឹកនាំជាតិ។ សភាអាចប្រើប្រាស់មុខងារជាតំណាងរបស់ខ្លួនដើម្បីពិចារណារៀបចំការចុះមូលដ្ឋាននិងរៀបចំវេទិកាពិគ្រោះយោបល់សាធារណៈដើម្បីបង្កើន ការយល់ដឹងរបស់ប្រជាពលរដ្ឋទាក់ទងទៅនឹងការកាប់បំផ្លាញព្រៃឈើនិងការប្រែប្រួលអាកាសធាតុ។

បណ្តាសភាអាស៊ានអាចធ្វើការជាមួយគ្នាដើម្បីចែករំលែកបទពិសោធន៍និងមេរៀនល្អៗទាក់ទងទៅនឹងវិធីសាស្ត្រក្នុងការទប់ទល់និងបន្សាំជាមួយនឹងការប្រែប្រួលអាកាសធាតុ។ ការប្រឈមធំៗមួយចំនួនដូចជា ការកាប់បំផ្លាញព្រៃឈើរដូវប្រាំងដែលអូសបន្លាយយូរជាងមុន ទឹកជំនន់ ការកើនឡើងកំដៅ និងជោគជ័យក្នុងការអនុវត្តនូវកម្មវិធី REDD និង REDD+ ពិតជាធ្វើបានប្រសើរបំផុតជាមួយនឹងក្របខ័ណ្ឌពហុភាគី។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានសភាកម្ពុជា (PIC)។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ ៖ https://www.pcasia.org ។

# ៣.៤ ប្រសិទ្ធភាពនៃច្បាប់ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលបណ្តាលមកពីបម្រែបម្រួលអាកាសធាតុ

## ការអនុវត្តច្បាប់បរិស្ថាននៅអាស៊ីជាពិសេសនៅអាស៊ីអាគ្នេយ៍

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើទឹក ស្បៀង និងថាមពល មានភាពខុសគ្នារវាងតំបន់ និងប្រទេស ដោយហេតុផលភូមិសាស្ត្រអាកាសធាតុ (geoclimatic reasons) ក៏ដូចជា ហេតុផលប្រជាសាស្ត្រ និងហេតុផលសេដ្ឋកិច្ចសង្គម។

យោងតាមអង្គការសហប្រជាជាតិតំបន់អាស៊ីជាពិសេសតំបន់អាស៊ីអាគ្នេយ៍គឺជាតំបន់ដែលទទួលការគំរាមកំហែងខ្លាំងបំផុតពីការប្រែប្រួលអាកាសធាតុ។ ទោះយ៉ាងណាហាក់ដូចជាមិនទាន់ឃើញមានគំនិតផ្តួចផ្តើមបញ្ចូលគ្នានៅថ្នាក់តំបន់នៅអាស៊ីច្រើននៅឡើយទេ ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងនេះ ជាពិសេសក្នុងក្របខ័ណ្ឌអាស៊ាន។ អនុតំបន់អាស៊ីអាគ្នេយ៍ដែលមានប្រជាជនជាង ៦២០លាននាក់ ដឹងច្បាស់ពីទំនាក់ទំនងរវាងវិបត្តិអាកាសធាតុ ការអភិវឌ្ឍប្រកបដោយចីរភាព និងសន្តិសុខប្រជាជន ដោយសារតែប្រទេសចំនួន៤ ក្នុងចំណោមប្រទេសចំនួន១០ ដែលទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុច្រើនជាងគេនៅលើពិភពលោកគឺជារដ្ឋជាសមាជិកអាស៊ាន (ប្រទេសឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន និងវៀតណាម) [៤៧]។ បណ្តាប្រទេសទាំងនេះដូចជាបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ទាំងមូល តែងប្រឈមមុខជានិច្ចជាមួយព្យុះស៊ីក្លូននិងទឹកជំនន់។ យោងតាមអង្គការសហប្រជាជាតិ ប្រជាជនចំនួន ៧០%នៃចំនួនប្រជាជនពិភពលោកដែលនឹងរងផលប៉ះពាល់ខ្លាំងបំផុតពីការកើនឡើងកម្ពស់ទឹកសមុទ្រ គឺជាប្រជាជនដែលកំពុងរស់នៅក្នុងបណ្តាប្រទេសអាស៊ាន [៤៨]។

អាស៊ានបានសម្តែងការព្រួយបារម្ភជារួម អំពីការប្រែប្រួលអាកាសធាតុនៅក្នុងសេចក្តីប្រកាសជាច្រើនហើយបានអនុម័តផែនការសកម្មភាពជាក់លាក់តាមវិស័យនិងធ្វើសេចក្តីសម្រេចចិត្តក្នុងតំបន់ដើម្បីដោះស្រាយការបំពុលឆ្លងព្រំដែន [៤៩] និងការការពារជីវចម្រុះ [៥០]។ ទោះយ៉ាងណាផែនការតំបន់ដើម្បីដោះស្រាយបញ្ហាបរិស្ថានទាំងមូលមិនទាន់មានការឯកភាពគ្នាដោយសមាគមអាស៊ាននៅឡើយទេ។ ទោះយ៉ាងណាក៏ដោយ អាស៊ានបានប្រកាសថាផែនការយុទ្ធសាស្ត្រអាស៊ាននេះ នៅកំពុងរៀបចំឡើងដោយមានឈ្មោះថា ផែនការបរិស្ថានយុទ្ធសាស្ត្រអាស៊ាន (ASEAN Strategic Environmental Plan) [A] [៥១]។

ផែនការសកម្មភាពលម្អិតបន្ថែមនេះរៀបចំឡើងក្នុងគោលបំណងផ្តល់ជាឯកសារណែនាំសម្រាប់អាស៊ានដើម្បីជំរុញកិច្ចសហប្រតិបត្តិការបរិស្ថានក្នុងចំណោមរដ្ឋជាសមាជិករបស់ខ្លួនរហូតដល់ឆ្នាំ២០២៥។ ទោះយ៉ាងណាគួរកត់សម្គាល់ថា ខណៈដែលអង្គការសហប្រជាជាតិអះអាងថាការតភ្ជាប់រវាងទឹក ស្បៀង និងថាមពល គឺជាស្នូលនៃការអភិវឌ្ឍប្រកបដោយចីរភាព[៥២] ហើយអង្គការស្បៀងអាហារនិងកសិកម្មរបស់អង្គការសហប្រជាជាតិ (FAO) បានណែនាំថា ការតភ្ជាប់ទឹក ស្បៀង និងថាមពលជាចំណុចដែលត្រូវតែយកមកពិចារណាជានិច្ច នៅពេលគិតពីជម្រើសវិធានការដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ[៥៣]។ ការតភ្ជាប់នេះហាក់ដូចជាមិនទាន់បានឃើញជាផ្នែកច្បាស់លាស់នៅក្នុងចំណោមចំណុចអាទិភាពទាំង៧ ដែលត្រូវបញ្ចូលក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រនេះទេ [៥៤]។ សម្រាប់សហភាពអឺរ៉ុបវិញដោយមានកិច្ចសហការជាមួយដៃគូដទៃទៀត បានបង្កើតធនធានតាមអ៊ីនធឺណេត ដែលនេះបានបង្ហាញយ៉ាងច្បាស់នូវគោលការណ៍តភ្ជាប់ទឹក ស្បៀង និងថាមពលនេះ [៥៥]។

ពិតណាស់ ការប្រែប្រួលអាកាសធាតុត្រូវតែដោះស្រាយនៅកម្រិតពហុភាគី។ [B] ទោះយ៉ាងណា ខណៈដែលកិច្ចព្រមព្រៀងពហុភាគីជាសកលទទួលបានការយកចិត្តទុកដាក់ខ្លាំងនោះក៏ដោយក៏កិច្ចព្រមព្រៀងថ្នាក់តំបន់ និងអនុតំបន់នៅមានសារៈសំខាន់កាន់តែខ្លាំងឡើងៗជាពិសេសលើបញ្ហាបរិស្ថានសំខាន់ៗ ព្រោះចំណេះដឹងក្នុងតំបន់បានអនុញ្ញាតឲ្យរកជម្រើសដំណោះស្រាយជាក់លាក់បាន និងពីព្រោះកិច្ចព្រមព្រៀងថ្នាក់តំបន់និងអនុតំបន់នោះបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងជាមិនខានទៀតផង។ [៥៤ ទំ.៣៥] ក្នុងករណីខ្លះដូចជាការជួញដូរកាកសំណល់ (សំរាម) គ្រោះថ្នាក់និងការនាំចូលដោយគេចពន្ធនូវផលិតផលសត្វព្រៃ ការអនុវត្តការប្រយុទ្ធប្រឆាំងនឹងការជួញដូរនិងការនាំចូលដោយគេចពន្ធនោះមានការលំបាក ប្រសិនបើគ្មានកិច្ចសហប្រតិបត្តិការក្នុងតំបន់ ឬអនុតំបន់ ឬជាកិច្ចសហប្រតិបត្តិការទ្វេភាគី និងការចែករំលែកព័ត៌មានទៅវិញទៅមក [៥៦]។

ទោះយ៉ាងណារដ្ឋនីមួយៗនៅតែអាចអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ទៅលើទឹកដី សេដ្ឋកិច្ច និងប្រជាជនរបស់ខ្លួន។ គិតត្រឹមឆ្នាំ២០១៧ ប្រទេសចំនួន១៧៦ បានអនុម័តក្របខ័ណ្ឌគតិយុត្តិបរិស្ថាន ១៥០ប្រទេសបានដាក់

ការការពារបរិស្ថាន ឬសិទ្ធិទទួលបានបរិស្ថានល្អនៅក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន ហើយ ១៦៤ ប្រទេសបានបង្កើតស្ថាប័នរដ្ឋាភិបាលទទួលខុសត្រូវចំពោះការការពារបរិស្ថាន (សូមមើលតារាង “បណ្តាប្រទេសអាស៊ីដែលមានក្របខ័ណ្ឌគតិយុត្តបរិស្ថានក្នុងឆ្នាំ១៩៧២ ១៩៩២ និង២០១៧”)។ [១៣] សិទ្ធិ ច្បាប់ និងស្ថាប័នបរិស្ថានទាំងនេះបានចូលរួមចំណែកក្នុងការកាត់បន្ថយការកើនឡើងនៃការបំផ្លាញបរិស្ថាន ហើយក្នុងករណីខ្លះបានចូលរួមចំណែកក្នុងការធ្វើអោយការបំផ្លាញនោះថយចុះតែម្តង។ សិទ្ធិ ច្បាប់ និងស្ថាប័នបរិស្ថានទាំងនោះក៏បានចូលរួមចំណែកក្នុងការនាំប្រយោជន៍ដល់ប្រជាជនឲ្យទទួលបានផលសុខភាពសាធារណៈ សេដ្ឋកិច្ចសង្គម និងសិទ្ធិមនុស្សល្អៗ ដែលតែងតែរួមចំណែកការពារបរិស្ថាន [៥៧ ទំ.៨]។

ទោះយ៉ាងណា ការអនុវត្តច្បាប់និងបទបញ្ញត្តិបរិស្ថានច្រើនតែមិនគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមបរិស្ថាន។ ពេលខ្លះច្បាប់ខ្វះស្តង់ដារច្បាស់លាស់ឬអាណត្តិអំណាចចាំបាច់។ ច្បាប់ខ្លះទៀតមិនសមស្របនឹងបរិបទជាតិ និងមូលដ្ឋាន ដូច្នេះប្រឈមនឹងបញ្ហាដែលមិនបានមើលឃើញទុកជាមុន។ ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនផ្តល់អាទិភាពដល់ម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចនៅពេលបែងចែកមូលនិធិសាធារណៈ និងកំណត់អាទិភាពសម្រាប់សកម្មភាពរបស់រដ្ឋាភិបាល។ [C] ដោយមូលហេតុនេះ ក្រសួងបរិស្ថានខ្វះធនធាន និងជាស្ថាប័នខ្សោយផ្នែកនយោបាយ បើប្រៀបធៀបទៅនឹង ក្រសួងដែលទទួលខុសត្រូវក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងគ្រប់គ្រងធនធានធម្មជាតិ។ [៥៧ ទំ.៨] ខណៈជំនួយបច្ចេកទេស និងហិរញ្ញវត្ថុអន្តរជាតិបានជួយប្រទេសជាច្រើនក្នុងការបង្កើតក្របខ័ណ្ឌគតិយុត្តិស្តីពីបរិស្ថាន ប៉ុន្តែទាំងថវិកាជាតិនិងជំនួយអន្តរជាតិមិនមានភាពគ្រប់គ្រាន់ដើម្បីបង្កើតភ្នាក់ងារបរិស្ថានរឹងមាំដែលចាំបាច់ដើម្បីពង្រឹងឲ្យបានគ្រប់គ្រាន់នូវសមត្ថភាពរបស់បុគ្គលិកស្ថាប័នបរិស្ថានផ្សេងៗដូចជា សមត្ថភាពរបស់ចៅក្រមជាតិផងដែរ ក្នុងការងារពាក់ព័ន្ធនឹងច្បាប់បរិស្ថាន ឬដើម្បីរៀបចំឡើងនូវការអប់រំអំពីច្បាប់ និងការអនុវត្តច្បាប់នោះប្រកបដោយចីរភាព [៥៧ ទំ.៣]។

កង្វះខាតក្នុងការអនុវត្តច្បាប់បរិស្ថានមិនត្រូវបានឃើញតែក្នុងប្រទេសកំពុងអភិវឌ្ឍន៍តែប៉ុណ្ណោះទេ។ យោងតាមលទ្ធផលនៃការពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ របស់ប្រទេសសមាជិកសហភាពអឺរ៉ុបដែលបានចេញផ្សាយនៅឆ្នាំ២០១៧ ដោយគណៈកម្មការអឺរ៉ុប បណ្តាប្រទេសអភិវឌ្ឍន៍ជាច្រើនបានអនុម័តច្បាប់ស្តីពី បរិស្ថានយ៉ាងតឹងរឹង (គឃ្លើន) និងគ្រប់ជ្រុងជ្រោយ ដែលឆ្លើយតបគ្រប់បញ្ហាបរិស្ថាន ប៉ុន្តែការអនុវត្តច្បាប់ទាំងនោះរបស់ប្រទេសអភិវឌ្ឍន៍ទាំងនោះប្រឈមមុខនឹងការលំបាកជាច្រើនដែលធ្វើឲ្យការអនុវត្តនេះមានការរារាំង [D] [៥៧ ទំ.១៣]។

ចុងបញ្ចប់ការបង្កើតសារពើភ័ណ្ឌពេញលេញនៃច្បាប់ និងបទបញ្ញាជាតិ គឺជាកិច្ចការដែលមិនអាចធ្វើទៅរួចនោះទេ ព្រោះបរិស្ថានជាបញ្ហាអន្តរវិស័យដែលគ្របដណ្តប់លើវិស័យជាច្រើន (កសិកម្ម នគរូបនីយកម្ម ការដឹកជញ្ជូន ថាមពល ការប្រើប្រាស់ស្បៀង ប្រព័ន្ធជារាសាស្ត្រ ឧស្សាហកម្ម ការបណ្តុះបណ្តាល។ល។) ច្បាប់ស្តីពី បរិស្ថានក៏រួមបញ្ចូលគ្នាជាមួយទម្រង់ និងបទដ្ឋានច្បាប់ផ្សេងៗ ជាច្រើនផងដែរ (រាប់ពីបទដ្ឋានភូមិ និងសង្គមតាមបែបប្រពៃណី រហូតដល់ច្បាប់របស់ប្រទេសនានា និងបទដ្ឋានដែលត្រូវបានអនុម័តដោយក្រុមហ៊ុន និងអង្គការផ្សេងៗដោយស្ម័គ្រចិត្ត)។ ច្បាប់ស្តីពីបរិស្ថានក៏គ្របដណ្តប់ លើកម្រិតអភិបាលកិច្ចជាច្រើន (រាប់ពីអភិបាលកិច្ចទំនៀមទម្លាប់ ក្នុងចំណោមប្រជាជនជនជាតិដើមភាគតិច និងជនបទ រហូតដល់អភិបាលកិច្ចថ្នាក់ក្រោមជាតិ និងអភិបាលកិច្ចជាតិ រួមទាំងបទបញ្ញត្តិរដ្ឋាភិបាលក្នុងតំបន់និងអន្តរជាតិ)។លើសពីនេះទៀត ការអនុវត្តច្បាប់បរិស្ថាន ជាការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន ភ្នាក់ងារ ឬមន្ទីរមួយចំនួននៅកម្រិតរដ្ឋាភិបាលជាច្រើន។

## អាស៊ីជាតំបន់ដែលប្រឈមបំផុតនឹងការប្រែប្រួលអាកាសធាតុ

បញ្ជីនៃហានិភ័យអាកាសធាតុដែលបណ្តាប្រទេសអាស៊ីត្រូវបានប្រឈមមុខគឺមានហានិភ័យអាកាសធាតុនោះជាច្រើន។ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិអាល្លឺម៉ង់ដែលមានឈ្មោះថា Germanwatch Global Climate Risk Index បានបង្ហាញថា ប្រទេសចំនួន៦ ក្នុងចំណោមប្រទេសចំនួន ១០ ដែលរងផលប៉ះពាល់ខ្លាំងបំផុតក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ គឺនៅអាស៊ី (ភូមា ហ្វីលីពីន បង់ក្លាដែស ប៉ាគីស្ថាន វៀតណាម និងថៃ)។ ជាងនេះទៅទៀត ទីក្រុងអាស៊ីជាច្រើន គឺជាទីក្រុង នៅតាមឆ្នេរសមុទ្រ ដូចជាបុមបៃ ម៉ានីល ហ្សាការតា សៀងហៃ បាងកក ឬសិង្ហបុរី។ រដ្ឋធានីខ្លះដូចជា រដ្ឋធានីឥណ្ឌូណេស៊ី ស្ថិតនៅក្រោមកម្រិតទឹកសមុទ្ររួចទៅហើយ។ យោងតាមធនាគារពិភពលោក ការកើនឡើងទឹកសមុទ្រនៅអាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍នឹងប៉ះពាល់ប្រជាជនពី ៣៧ ទៅ ៩០លាននាក់ (អាស្រ័យលើកំរិតនៃការកើនឡើងនេះ៖ ពី១ទៅ៣ម៉ែត្រ) ជាពិសេសនៅប្រទេសវៀតណាម ចិន និងឥណ្ឌូនេស៊ី។ អាស៊ីខាងត្បូងកាន់តែរងផលប៉ះពាល់ ជាពិសេសប្រទេសបង់ក្លាដែស និងឥណ្ឌា។

ចំណែកការកើនឡើងនៃសីតុណ្ហភាព ការកើនឡើងនេះនឹងប៉ះពាល់ជាពិសេសអាស៊ីខាងត្បូង។ នៅឆ្នាំ២០៥០ ប្រជាជនឥណ្ឌាមួយភាគបី អាចរងនូវសីតុណ្ហភាពយ៉ាងខ្លាំង (លើសពី ៣៥ អង្សាសេ) យ៉ាងហោចណាស់បីខែក្នុងមួយឆ្នាំ។ ការឡើងកម្ដៅផែនដីត្រូវបានគេរំពឹងថានឹងជះឥទ្ធិពលដល់ទិន្នផលដំណាំក្នុងសមាមាត្រគួរឲ្យកត់សម្គាល់ ជាពិសេសនៅឧបទ្វីបឥណ្ឌា(ក្នុងចន្លោះពី៨-១០%អាស្រ័យលើប្រភេទពូជ)។បញ្ហាស្បៀងគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ខ្លួនឯង (food self-sufficiency) កំពុងក្លាយជាកង្វល់ដ៏ធំនៅក្នុងតំបន់នេះ ដែលកំណើនប្រជាជននៅតែខ្ពស់បំផុតនៅអាស៊ី។

ប្រភេទគ្រោះមហន្តរាយអាកាសធាតុដ៏សាហាវមួយទៀត (ព្យុះទីហ្វុង) កំពុងបោកបក់ដល់ឆ្នេរសមុទ្រអាស៊ីជាមួយនឹងការកើនឡើងនូវទំហំ (magnitude)គួរឲ្យកត់សម្គាល់ ជាពិសេសនៅក្នុងប្រទេសហ្វីលីពីន ជប៉ុន ចិន និងឥណ្ឌូនេស៊ី។ ការយល់ដឹងអំពី ហានិភ័យច្រើនប្រភេទ ពីប្រជាជននិងមតិសាធារណៈ កំពុងកើនឡើង និងអាចនាំឲ្យមានការសម្រេចចិត្តនយោបាយថ្មីនិងសកម្មជាងមុន [៥៩]។

ក្នុងចំណោមតំបន់នានាក្នុងពិភពលោកដែលទទួលរងនូវការខ្វះខាតទឹក អាស៊ីកំពុងប្រឈមនឹងកង្វះ ធនធានមនុស្ស ស្ថាប័ន និងហិរញ្ញវត្ថុដែលរឹតត្បិតការទទួលបានទឹក ទោះបីជាតំបន់នេះមានធនធានធម្មជាតិសម្បូរបែបយ៉ាងក៏ដោយ។ ការទទួលបានទឹកដែលមានកំរិតនេះ មានផលវិបាកធ្ងន់ធ្ងរដល់ផលិតកម្មកសិកម្ម [៦០ ទំ.៣៦]។ ទឹកទន្លេតិចក្រោម ២៥% នៃទឹកទន្លេសរុបត្រូវបានដកយកទៅប្រើដើម្បីបំពេញតម្រូវការរបស់ប្រជាជនហើយអាហារូបត្ថម្ភមានការខ្វះខាតកាន់តែធ្ងន់ធ្ងរ។ ផ្ទុយទៅវិញ មានការកើនឡើងនូវការទទួលបានធនធានទឹកនៅអឺរ៉ុបខាងជើង នៅប្រទេសរុស្ស៊ី និងនៅអាម៉េរិកខាងជើង ដែលធ្វើឲ្យអាចមានការកើនឡើងនូវផលិតកម្មកសិកម្មនៅឯទីនោះ [៦០ ទំ.៣៦]។

## អាស៊ីជាប្រភពពាក់កណ្តាលនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងពិភពលោក

នៅឆ្នាំ២០១៨ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅទ្វីបអាស៊ីស្មើនឹងចំនួនជិតពាក់កណ្តាលនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងពិភពលោក និងស្មើនឹង២ភាគ៣នៃការកើនឡើងនៃការបញ្ចេញឧស្ម័នកាបូនិកក្នុងឆ្នាំ២០១៧ ដែលជាសមាមាត្រមួយដែលអាចនៅបន្តក្នុងរយៈពេលមួយទសវត្សរ៍ទៀត។ ជនជាតិអាស៊ីបានវិនិយោគយ៉ាងច្រើនក្នុងថាមពលកកើតឡើងវិញ (renewable_energy) និងក្នុងថាមពលដែលមានប្រសិទ្ធភាព (energy_efficiency) ប៉ុន្តែការប្តេជ្ញាចិត្តបច្ចុប្បន្នរបស់ពួកគេនៅតែមិនទាន់គ្រប់គ្រាន់ដើម្បីបញ្ចៀសនិន្នាការនេះ។ សកម្មភាពបន្ថែម ដូចជាការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ និងការបំផ្លាញព្រៃឈើនៅអាស៊ី ជាពិសេសនៅឥណ្ឌូណេស៊ី ក៏មានសារៈសំខាន់ផងដែរ ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នក្នុងពិភពលោក [៦១]។

ការផ្ទុះឡើងនៃការបញ្ចេញឧស្ម័ន បណ្តាលភាគច្រើនមកពីដំណើរការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងខ្លាំងនៅអាស៊ីដើម្បីតាមឲ្យទាន់ប្រទេសអភិវឌ្ឍន៍ក្នុងរយៈពេល៥០ឆ្នាំ កន្លងមកនេះ ដែលផ្អែកលើឧស្សាហកម្មហេដ្ឋារចនាសម្ព័ន្ធ និងការនាំចេញ ជាមួយនឹងការប្រើប្រាស់ថាមពលហួសកំរិត។ ទោះបីជា អត្រានៃការបញ្ចេញឧស្ម័ននោះក្នុងមនុស្សម្នាក់នៅក្នុងប្រទេសអាស៊ីមួយចំនួនដូចជាឥណ្ឌា និងឥណ្ឌូនេស៊ីនៅតែទាបជាងមធ្យមភាគពិភពលោកក៏ដោយ ក៏ការបញ្ចេញឧស្ម័ននោះនៅតែខ្ពស់ជាងមធ្យមភាគនៅក្នុងប្រទេសអភិវឌ្ឍន៍នៅក្នុងតំបន់អាស៊ីដូចជា ប្រទេសចិន និងម៉ាឡេស៊ី [៦៣]។ សូមមើលតារាង “ការវិវឌ្ឍន៍នៃការបញ្ចេញឧស្ម័នកាបូនិចក្នុងមនុស្សម្នាក់ចន្លោះពីឆ្នាំ១៩៧០-២០១៤”)។ ទោះយ៉ាងណាអាស៊ីក៏ជាទ្វីបដែលងាយទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលអាចបង្កអន្តរាយដល់ចក្ខុវិស័យសម្រាប់កំណើននាពេលអនាគត។

លើសពីនេះទៀត ត្រឹមឆ្នាំ២១០០ កំដៅអាចធ្វើឲ្យមនុស្សមិនអាចរស់នៅបាននៅអាស៊ីខាងត្បូង។ នេះបើយោងតាមការស្រាវជ្រាវថ្មីៗនេះដោយវិទ្យាស្ថានបច្ចេកវិទ្យាម៉ាសាឈូសេត (MIT) ដែលបានចេញផ្សាយនៅក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រ Sciences Advances។ អ្នកវិទ្យាសាស្ត្រព្រមានថា ប្រសិនបើមិនមានវិធានការណាមួយដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទេនោះ "ការកើនឡើងសីតុណ្ហភាព និងសំណើមនៅរដូវក្ដៅអាចឈានដល់កម្រិតមួយដែលហួសពីសមត្ថភាពរបស់រាងកាយមនុស្សក្នុងការរស់រាន ដោយគ្មានការការពារ"។

តំបន់ជនបទមានផលប៉ះពាល់ច្រើនជាងទីក្រុង បើទោះបីជាទីក្រុង (ដែលមានចំនួនប្រជាជនខ្ពស់) នេះហើយដែលផលិតការបំពុលភាគច្រើន។ ហានិភ័យខ្លាំងបំផុតនៃអំឡុងពេលអនាគតនៃកំដៅខ្លាំង ត្រូវបានប្រមូលផ្តុំនៅជុំវិញតំបន់កសិកម្មដែលមានប្រជាជនច្រើនបំផុតនៅអាងគង្គាន (The Ganges Basin) និងអាង Indus។ អាស៊ីខាងត្បូងដែលជាតំបន់មួយដែលមានប្រជាជនប្រមាណ ១ភាគ៥ នៃចំនួនប្រជាជនពិភពលោក ប្រឈមមុខនឹងហានិភ័យនៃការប្រែប្រួលអាកាសធាតុ ដែលមិនមានការកត់សំគាល់ ដោយសារតែការរួមផ្សំគ្នាដែលមិនធ្លាប់មានពីមុនមកនៃគ្រោះមហន្តរាយធម្មជាតិធ្ងន់ធ្ងរ និងភាពងាយរងគ្រោះខ្លាំងបំផុត [៦២]។

## ផែនទី ៣៖ ផូស៊ីលឥន្ធនៈ និងការបញ្ចេញឧស្ម័ន $CO_2$ តាមប្រទេស



## អាស៊ីជាតំបន់ដែលមានតម្រូវការស្បៀងអាហារច្រើនជាងគេ

បើយោងតាមការព្យាករណ៍នៅឆ្នាំ២០៥០ពិភពលោកនឹងមានប្រជាជនប្រមាណ៩ពាន់លាននាក់ ហើយស្បៀងអាហារនឹងក្លាយជាបញ្ហាធំមួយនៅទូទាំងពិភពលោក។ បច្ចុប្បន្នប្រជាជន៨៥០លាននាក់ មិនទាន់បានទទួលស្បៀងអាហារគ្រប់គ្រាន់ ដើម្បីបំពេញតម្រូវការចាំបាច់របស់ពួកគេនៅឡើយទេ ដូច្នេះ ផលិតកម្មស្បៀងអាហារត្រូវតែកើនឡើងយ៉ាងខ្លាំងទៅដល់ពេលនោះ [E] [៦៣]។

នៅទ្វីបអាស៊ីមានតម្រូវការស្បៀងអាហារធំបំផុត និងច្រើនជាងនៅទ្វីបអាហ្វ្រិកទៅទៀត។ ដើម្បីឲ្យប្រជាជនដែលមានការកើនឡើងនេះអាចទទួលបាននូវស្បៀងអាហារដែលពួកគេត្រូវការ ការធ្វើកសិកម្មត្រូវតែមានការកែលម្អជាច្រើនដើម្បីប្រសិទ្ធភាពនៃការធ្វើកសិកម្មនោះឲ្យប្រសើរឡើង ទាំងសម្រាប់កសិកម្មអាស្រ័យទឹកភ្លៀង (rain_fed_agriculture) ក៏ដូចជាកសិកម្មដែលអាស្រ័យលើប្រព័ន្ធធារាសាស្ត្រ (irrigated_agriculture) ប៉ុន្តែនេះមិនគ្រប់គ្រាន់ទេ ពីព្រោះដីទំនងជាមានតម្លៃថ្លៃជាងមុន (តម្លៃនីត្រាតកំណត់តាមតម្លៃប្រេងនិងផូស្វាត (phosphate)ហើយទុនបម្រុងអាចអស់)។ ទោះយ៉ាងណាក៏ដោយ ហាក់ដូចជា (ដូចដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងតារាង៦និង៧) តំបន់មួយចំនួនខ្លះមិនមានដីបង្កបង្កើនផល (arable_land) គ្រប់គ្រាន់ទេ ជាពិសេសនៅអាស៊ី និងមជ្ឈឹម បូព៌ា/អាហ្វ្រិកខាងជើង (Middle_East/North_Africa) ដែលមានចំនួនប្រជាជនច្រើនជាងពាក់កណ្តាលនៃចំនួនប្រជាជនសរុបក្នុងពិភពលោក។ នៅអាស៊ី ៧៥% នៃដីបង្កបង្កើនផល (arable_land) បានត្រូវគេធ្វើអាជីវកម្មរួចហើយ។ សេណារីយ៉ូនេះតម្រូវឲ្យមានការផ្លាស់ប្តូរបច្ចេកវិជ្ជាសំខាន់ៗដើម្បីបង្កើនប្រសិទ្ធភាព (+៥០% នៃកសិកម្មដែលផ្គត់ផ្គង់ដោយទឹកភ្លៀង និងស្រោចស្រពនៅទ្វីបអាស៊ី) ជាមួយនឹងការវិនិយោគដែលមានការគ្រប់គ្រង និងការកំណត់ទៅលើប្រព័ន្ធធារាសាស្ត្រ [៦០ ទំ.២០]។

## ការវិភាគហិរញ្ញប្បទាននៃគម្រោងដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅអាស៊ី

ទិន្នន័យដកស្រង់ពីគេហទំព័ររបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (Climate_Fund_Update) បង្ហាញថា សម្រាប់ប្រទេសចំនួន១៨ នៅអាស៊ី [៦៤] មានសរុបទឹកប្រាក់ចំនួន៤,៥ពាន់លានដុល្លារអាម៉េរិក ត្រូវបានផ្តល់ដោយកម្មវិធីនិងមូលនិធិឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុពហុភាគីចំនួន១៨សម្រាប់អនុវត្តគម្រោង និងកម្មវិធីចំនួន៤៥៣។ ទោះយ៉ាងណាថវិកាយ៉ាងច្រើនត្រូវបានផ្តល់ដល់បណ្តាប្រទេសដែលមានកំណើនសេដ្ឋកិច្ចខ្ពស់ ដូចជាឥណ្ឌានិងឥណ្ឌូនេស៊ី ជាពិសេសសម្រាប់ការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (mitigation) ប៉ុន្តែមិនមែនសម្រាប់ឆ្លើយតបទៅនឹងបញ្ហាផលប៉ះពាល់នេះដោយចីរភាពទេ (adaptation)។ម្យ៉ាងវិញទៀត ប្រទេសមួយចំនួនដែលមានហានិភ័យពីការប្រែប្រួលអាកាសធាតុ ដូចជាប្រទេសស្រីលង្កាបានទទួលថវិកាតិចតួច។

នៅក្នុងឆ្នាំ២០១៩ ចំនួនទឹកប្រាក់ ៧៤៩លានដុល្លារអាម៉េរិកដែលត្រូវផ្តល់ហិរញ្ញប្បទានដល់គម្រោង ចំនួន១០ ត្រូវបានអនុម័ត។ ហិរញ្ញប្បទាននេះភាគច្រើនបានមកពីមូលនិធិបៃតងសម្រាប់អាកាសធាតុ (Green_Climate_Fund)[៦៥] ហើយជាងពាក់កណ្តាលនៃគម្រោងទាំងនេះគឺជាគម្រោងសម្រាប់ការកាត់បន្ថយ (mitigation) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ មូលនិធិបៃតងសម្រាប់អាកាសធាតុ (Green_Climate_Fund) បានអនុម័តផ្តល់ហិរញ្ញប្បទានក្នុងតំបន់អាស៊ីឲ្យគម្រោងចំនួនមួយសម្រាប់ឆ្លើយតបទៅនឹងបញ្ហាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដោយចីរភាព (adaptation) និងគម្រោងពហុគ្រួសារចំនួនបួនបន្ថែមលើគម្រោងកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (mitigation) ចំនួន៥ ដែលស្មើនឹងទឹកប្រាក់សរុបចំនួន ៦១៩លានដុល្លារ នៅឆ្នាំ២០១៨ [E] [៦៦]។

ហិរញ្ញប្បទានលក្ខណៈទ្វេភាគីទៅទ្វីបអាស៊ីក៏បានបំពេញបន្ថែមលំហូរនៃហិរញ្ញប្បទានលក្ខណៈពហុភាគីផងដែរ។ នេះរួមបញ្ចូលទាំងមូលនិធិអាកាសធាតុទ្វេភាគីមកពីប្រទេសអូស្ត្រាលី អាល្លឺម៉ង់ និង ចក្រភពអង់គ្លេសដែលសកម្មនៅក្នុងតំបន់[G][៦៦]។សន្ធិសញ្ញាមិត្តភាពនិងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ក៏ត្រូវបានចុះហត្ថលេខារវាងប្រទេសអាល្លឺម៉ង់ និងអាស៊ាន នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។ ចំណុចសំខាន់ក្នុងការប្តេជ្ញាចិត្តរួមគ្នានេះ គឺការប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាប្រឈមជាសកលរួមគ្នា-ដូចជាការគ្រប់គ្រងសកលភាវូបនីយកម្មការប្រែប្រួលអាកាសធាតុ និងបញ្ហាពាណិជ្ជកម្ម [៦៦]។

លើសពីនេះទៀតដោយសារតែអាស៊ីជាតំបន់មានចំនួនប្រជាជនទីក្រុងធំជាងគេបំផុតនៅលើពិភពលោក ហើយទីក្រុងនិងទីប្រជុំជននៅអាស៊ីកំពុងមានការអភិវឌ្ឍ និងកំណើនមិនធ្លាប់មានពីមុនមកធ្វើឲ្យយល់ច្បាស់ថា ហិរញ្ញវត្ថុជាង៣០០លានដុល្លារ ត្រូវបានអនុម័តសម្រាប់តំបន់នេះលើគម្រោងនានាដែលមានគោលបំណងគាំទ្រដល់ទិដ្ឋភាព

## ផែនទី ៤៖ កម្រិតហានិភ័យនៃការប្រែប្រួលអាកាសធាតុ




| ចំណាត់ថ្នាក់ | ប្រទេស | ប្រភេទ |
|---|---|---|
| ១ | បង់ក្លាដេស | ខ្ពស់ |
| ២ | សៀរ៉ាឡេអូន | ខ្ពស់ |
| ៣ | ស៊ូដង់ខាងត្បូង | ខ្ពស់ |
| ៤ | នីហ្សេរីយ៉ា | ខ្ពស់ |
| ៥ | ឆាដ | ខ្ពស់ |
| ៦ | ហៃទី | ខ្ពស់ |
| ៧ | អេត្យូពី | ខ្ពស់ |
| ៨ | ហ្វីលីពីន | ខ្ពស់ |
| ៩ | សាធារណរដ្ឋអាហ្វ្រិកកណ្តាល | ខ្ពស់ |
| ៩ | អេរីទ្រា | ខ្ពស់ |

ប្រភព: Maplecroft 2014|1 Henry Street, Bath BA1 1JS, United Kingdom| t: +44(0)1225420000|www.maplecroft.com|info@maplecroft.com

ផ្សេងៗនៃការអភិវឌ្ឍទីក្រុងដែលប្រើកាបូនទាប និងមានភាពធន់នឹងអាកាសធាតុ។ [៣២]

បញ្ហាប្រឈមហាក់ដូចជាមានពីរសម្រាប់អាស៊ី។ ទីមួយ ដើម្បីអនុវត្តតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ២០១៥ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅអាស៊ីត្រូវការឲ្យកាត់បន្ថយ ដើម្បីសហគមន៍អន្តរជាតិអាចទប់ទល់នឹងការកើនឡើងសីតុណ្ហភាពបានយ៉ាងល្អក្រោម២អង្សាសេ។ ទីពីរបណ្ដាប្រទេសនៅអាស៊ី ត្រូវការបង្កើតយុទ្ធសាស្ត្រ ដើម្បីធានាបានវិបុលភាព និងសន្តិសុខក្នុងតំបន់។

## តើសភានិងសមាជិក សមាជិកាសភា មានតួនាទីអ្វីខ្លះ?

សភានិងសមាជិក សមាជិកាសភាមានតួនាទីពីរ។ ដោយសារបញ្ហាការប្រែប្រួលអាកាសធាតុ ឆ្លងកាត់ព្រំដែនប្រទេស គឺសភានិងសមាជិក សមាជិកាសភាអាចដាក់បញ្ហាការប្រែប្រួលអាកាសធាតុនោះ នៅក្នុងរបៀបវារៈសម្រាប់កិច្ចពិភាក្សាថ្នាក់ជាតិនិងការប្រជុំអន្តរសភា។ សភាត្រូវការរួមជាមួយអំណាចរដ្ឋធម្មនុញ្ញផ្សេងៗទៀត ដើម្បីផ្ដល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះបញ្ហាប្រឈមនៃការផ្លាស់ប្ដូរអាកាសធាតុ និងសន្តិសុខ ទឹក ស្បៀង ថាមពល នៅលើទឹកដីរបស់ខ្លួន។

### នៅថ្នាក់តំបន់

ទាក់ទងទៅនឹងការទូតសភានៅថ្នាក់តំបន់ និងសមាជិក សមាជិកាសភាអាស៊ានអាចបង្កើតផែនការក្នុងតំបន់ ដើម្បីដោះស្រាយបញ្ហាបរិស្ថានទាំងមូល។

បន្ទាប់មក សមាជិក សមាជិកាសភាអាស៊ាននឹងអាចពង្រីកវិធីសាស្ត្ររបស់ខ្លួនបន្ថែមទៀត ដើម្បីពិចារណាលើបណ្ដាញភ្ជាប់ទឹក ស្បៀង ថាមពល នៅពេលបង្កើតទស្សនវិស័យយុទ្ធសាស្ត្រសម្រាប់អាស៊ាន។ អត្ថប្រយោជន៍នៃការមានផែនការប្រកបដោយប្រសិទ្ធភាពគឺជាក់ស្ដែង ព្រោះអាស៊ី គឺជាតំបន់ដែលប្រឈមនឹងហានិភ័យដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុច្រើនជាងគេ។

នៅកម្រិតអន្តរតំបន់ ការសន្ទនារវាងអង្គការក្នុងតំបន់ (ដូចជាអាស៊ាន សហភាពអឺរ៉ុប។ល។) ជាពិសេសរវាងអង្គការអន្តរសភាក្នុងតំបន់ (ដូចជា AIPA, សភាអឺរ៉ុប។ល។) ក៏ដូចជាការប្រជុំអន្តរសភាដែលរៀបចំឡើងសម្រាប់ត្រៀមកិច្ចប្រជុំកំពូលថ្នាក់អន្តរតំបន់ (ដូចជា ASEP) គឺជាឱកាសផ្លាស់ប្ដូរយោបល់និងជំហរដ៏សំខាន់ ដើម្បីជំរុញនិងពង្រឹងកិច្ចព្រមព្រៀងសាមគ្គីភាពអន្តរតំបន់។ នៅក្នុងបរិបទទាំងនេះ ដំណោះស្រាយថ្មីអាចលេចឡើង។ ឧទាហរណ៍ អឺរ៉ុបអាចជួយអាស៊ីទប់ទល់ នឹងឱនភាពផលិតកម្មកសិកម្ម និងតម្រូវការស្បៀងអាហាររបស់ខ្លួនដោយផ្ដល់នូវការគាំទ្រផ្នែកបច្ចេកវិទ្យាក្នុងវិស័យកសិអាហារ (agro_food_sector) ហើយអាស៊ីក៏អាចឆ្លើយតបទៅវិញដោយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច ដោយសារតែការកាត់បន្ថយការបញ្ចេញឧស្ម័ននៅអាស៊ីនេះ គឺជាអាទិភាពចម្បងរបស់សហភាពអឺរ៉ុបតែម្ដង។

### នៅថ្នាក់ជាតិ

ទោះបីការប្រែប្រួលអាកាសធាតុពិតជាបញ្ហាប្រឈមពិភពលោកក៏ដោយ វិធីសាស្ត្រដែលត្រូវបានអនុម័តដោយសភានៃប្រទេសនីមួយៗ មិនចាំបាច់ដូចគ្នាទេ។ បច្ចុប្បន្នមូលនិធិអឺរ៉ុបសម្រាប់អាស៊ី មាននិន្នាការគាំទ្រកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយ (mitigation) ជាជាងការខិតខំដើម្បីដោះស្រាយបញ្ហាតាមរបៀបប្រកបដោយចីរភាព (adaptation)។ សភាអាស៊ី អាចពិចារណា លើជម្រើសគោលនយោបាយដើម្បីដោះស្រាយបញ្ហា ដែលកើតឡើងពីការប្រែប្រួលអាកាសធាតុប្រកបដោយចីរភាពនិងដោយគិតពីកាលៈទេសៈជាក់លាក់នៅប្រទេសនីមួយៗ។

បច្ចុប្បន្ននេះ ច្បាប់ខ្លះខ្វះស្តង់ដារច្បាស់លាស់ ឬអាណត្តិ និងសិទ្ធិអំណាចចាំបាច់ ឬមិនសមស្របក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមជាក់ស្ដែងនានា។ បញ្ហានេះអាចមានផលវិបាកធំធេងណាស់ព្រោះបរិស្ថាន គឺជាបញ្ហាអន្តរវិស័យដែលគ្របដណ្ដប់លើវិស័យជាច្រើន (កសិកម្ម នគរូបនីយកម្ម ការដឹកជញ្ជូន ថាមពល ស្បៀង ប្រព័ន្ធធារាសាស្ត្រ ឧស្សាហកម្ម ការបណ្ដុះបណ្ដាល។ល។)។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គឺធំធេង ដូច្នេះការអនុវត្តច្បាប់និងបទបញ្ញាបរិស្ថាននោះ ច្រើនតែមិនគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងបញ្ហាបរិស្ថានឲ្យគ្រប់ជ្រុងជ្រោយ។ លើសពីនេះទៅទៀត ដោយសារតែឧបសគ្គថវិកាតែងតែមានជានិច្ច ការសម្របសម្រួលគ្នាមានភាពចាំបាច់។ នេះជាមូលហេតុដែលសមាជិក សមាជិកាសភាក្នុងមុខងារជាតំណាង មុខងារនីតិកម្ម (ធ្វើការអនុម័តច្បាប់ថ្មីបន្ទាប់ពីការវាយតម្លៃផលប៉ះពាល់ ឬការធ្វើវិសោធនកម្មច្បាប់) និងមុខងារត្រួតពិនិត្យ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថាដំណោះស្រាយត្រូវបានរៀបចំឡើងនិងអនុវត្តប្រកបដោយប្រសិទ្ធភាពដើម្បីនាំមកនូវផលប្រយោជន៍ដល់ប្រជាជនដែលត្រូវរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

**បដិសេធការទទួលខុសត្រូវ៖** អត្ថបទនេះគឺជាការបកប្រែក្រៅផ្លូវការដោយ វិទ្យាស្ថានសភាកម្ពុជា (PIC)។ អត្ថបទដើមជាភាសាអង់គ្លេសមានក្នុងសៀវភៅដែលមានចំណងជើងថា Atlas of Parliamentary Diplomacy ដែលអាចទាញយកពីគេហទំព័រ ៖ https://www.pcasia.org ។

# ៣.៥ សន្តិសុខថាមពលអឺរ៉ុប៖ បញ្ហាប្រឈមក្នុងការធ្វើពិពិធកម្ម និងការបំបែកកាបូនឌីអុកស៊ីតចេញពីរបាយឥន្ធនៈ

## ថាមពលចម្រុះ

ពាក្យថា "សន្តិសុខថាមពល" រួមបញ្ចូលនូវបញ្ហាជាច្រើន។ បញ្ហាទាំងនោះរួមមានការប្រែប្រួលអាកាសធាតុពិភពលោក លក្ខណៈធម្មជាតិនៃឥន្ធនៈផូសស៊ីលដែលមិនអាចកកើតឡើងវិញបាន និងការព្រួយបារម្ភជុំវិញការផលិតថាមពលនុយក្លេអ៊ែរ។ បញ្ហាប្រឈមបន្ថែមកើតចេញពីការរំខានដល់ការផ្គត់ផ្គង់ថាមពល ជាពិសេសការប្រើថាមពលទាំងនោះជាអាវុធ និងតម្លៃខ្ពស់ក្នុងការនាំចូលថាមពល។ ជាទូទៅគេតែងតែឃើញមានការយកចិត្តទុកដាក់តែទៅលើការផ្គត់ផ្គង់ថាមពល តែពេលនេះគេក៏គួរតែគិតគូរផងដែរពីបញ្ហាតម្រូវការថាមពល ជាពិសេសក្រោយពេលដែលមានការលេចចេញនូវ "Prosumer" នៃថាមពល ដែលមានន័យថាបុគ្គលដែលជាអ្នកប្រើប្រាស់ផង និងផលិតផង។

បន្ទាប់ពីប្រទេសចិន និងសហរដ្ឋអាមេរិក សហភាពអឺរ៉ុបមានការប្រើប្រាស់ថាមពលសរុបក្នុងស្រុកធំជាងគេក្នុងលេខរៀងទីបីនៅលើពិភពលោក។ សហភាពអឺរ៉ុបជួបប្រទះនឹងការប្រឈមលើបញ្ហាគោលនយោបាយជាច្រើនទាក់ទងទៅនឹងការផ្គត់ផ្គង់ថាមពលនាពេលអនាគតរបស់ខ្លួន។ គោលនយោបាយទាំងនោះរួមមានការផ្លាស់ប្តូរទីផ្សារថាមពល និងរចនាសម្ព័ន្ធតម្រូវការថាមពល ក៏ដូចជាការធ្វើពិពិធកម្ម និងការបំបែកកាបូនឌីអុកស៊ីតចេញពីរបាយឥន្ធនៈដើម្បីឆ្ពោះទៅកាន់ប្រព័ន្ធថាមពលស្អាត និងមាននិរន្តរភាពជាងមុន។ ដើម្បីជួយដោះស្រាយការផ្លាស់ប្តូរនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងប្រជាសាស្ត្រ គឺទាមទារចាំបាច់នូវបច្ចេកវិទ្យាថ្មីដែលការដោះស្រាយនេះជាវិធីដែលឈានទៅកំរិតការបញ្ចេញឧស្ម័នផ្ទះកញ្ចក់(GHG) និងការបញ្ចេញចោលកាកសំណល់នុយក្លេអ៊ែរ។

ថាមពលចម្រុះដែលប្រើនៅក្នុងប្រទេសទាំង ២៨ របស់អឺរ៉ុប ភាគច្រើនលើសលប់ គឺប្រេង និងឧស្ម័ន។ ចាប់តាំងពីឆ្នាំ១៩៨០មក អឺរ៉ុបមិនមានសមត្ថភាពក្នុងការផ្គត់ផ្គង់ប្រេងឆៅដោយខ្លួនឯងទេ។ ស្ថានភាពប្រហែលគ្នានេះក៏ចាប់ផ្តើមកើតមានក្នុងការផ្គត់ផ្គង់ឧស្ម័នធម្មជាតិដែរ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៩០ដែរ។ នៅឆ្នាំ២០១៧ ការពឹងផ្អែកលើការនាំចូលថាមពលរបស់សហភាពអឺរ៉ុបបានឈានដល់ ៥៥,១% (ឧស្ម័នធម្មជាតិ ធ្យូងថ្ម និងប្រេងរួមបញ្ចូលគ្នា)។ បណ្តាប្រទេសដែលជាប្រភពនៃការផ្គត់ផ្គង់ថាមពលក៏មានការផ្លាស់ប្តូរនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ប៉ុន្តែប្រទេសរុស្ស៊ីនៅតែរក្សាបាននូវទីតាំងរបស់ខ្លួនជាអ្នកនាំមុខក្នុងការផ្គត់ផ្គង់ប្រេងឆៅ និងឧស្ម័នធម្មជាតិ ហើយពេលនេះក៏ជាក្លាយជាអ្នកផ្គត់ផ្គង់ឥន្ធនៈរឹង (ធ្យូងថ្ម) ដ៏សំខាន់ផងដែរ។ ទោះយ៉ាងណាក៏ដោយចាប់តាំងពីឆ្នាំ២០០៤ មក ប្រទេសដៃគូនាំចូលថ្មីៗបានលេចរូបរាងឡើង ឧទាហរណ៍ដូចជាប្រទេសមកពីតំបន់កាសព្យែន (Caspian) ជាដើម។

បញ្ហាសន្តិសុខនៃការផ្គត់ផ្គង់ថាមពលរបស់សហភាពអឺរ៉ុបបានក្លាយជាបញ្ហាភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ចដ៏ធំ។ អ្វីដែលសំខាន់ចំពោះសន្តិសុខក្នុងការផ្គត់ផ្គង់ថាមពលអឺរ៉ុបដែរនោះគឺថា តួអង្គខាងក្រៅ មានដូចជារុស្ស៊ី ចិន និងសហរដ្ឋអាមេរិកកំពុងតែសម្លឹងមើលតំបន់នេះក្នុងក្រសែភ្នែកដើម្បីស្វែងរកផលប្រយោជន៍ភូមិសាស្ត្រនយោបាយ។ សក្តានុពលនៃតំបន់នេះគឺធំខ្លាំងណាស់ នៅពេលដែលតំបន់មួយនេះត្រូវបានធ្វើសមាហរណកម្មទៅក្នុងទីផ្សារពិភពលោក ប៉ុន្តែគន្លងប្រវត្តិសាស្ត្ររបស់តំបន់នេះបានរារាំងយ៉ាងខ្លាំងដល់ដំណើរការប្រែប្រួលដ៏ងាយមួយនេះ។

សហភាពអឺរ៉ុបបានឯកភាពលើការធ្វើបច្ចុប្បន្នភាពគ្រប់ជ្រុងជ្រោយទៅលើក្របខ័ណ្ឌគោលនយោបាយថាមពលរបស់ខ្លួន ដើម្បីសម្រួលដល់ការផ្លាស់ប្តូរពីការប្រើឥន្ធនៈផូសស៊ីលឆ្ពោះទៅរកការប្រើថាមពលស្អាតជាងមុន និងដើម្បីគោរពតាមការប្តេជ្ញារបស់ខ្លួនចំពោះកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ផលិតកម្មថាមពលបឋមឬថាមពលក្នុងទម្រង់ធម្មជាតិ និងទម្រង់មិនទាន់កែច្នៃនៅក្នុងសហភាពអឺរ៉ុបមានចំនួនសរុបចំនួន ៧៥៨ Mtoe ក្នុងឆ្នាំ [I] ២០១៧។ បើយើងសង្កេតមើលពីរយៈពេលជាយូរកន្លងទៅ ផលិតកម្មក្នុងឆ្នាំ២០១៧ មានកម្រិតទាបជាងកាលពីរយៈពេលមួយទសវត្សរ៍មុនចំនួន ១២,១%។ ប្រទេសជាសមាជិកសហភាពអឺរ៉ុបដែលមានផលិតកម្មថាមពលបឋមកំរិតខ្ពស់ជាងគេ គឺមានប្រទេសបារាំង(១៧,៤%)បន្ទាប់មកចក្រភពអង់គ្លេស(១៥,៦%) និងអាល្លឺម៉ង់ (១៥,៣%) ។

ផលិតកម្មថាមពលបឋមក្នុង EU-28 បានមកពីប្រភពថាមពលផ្សេងៗគ្នាជាច្រើន។ បើយើងមើលពីទំហំនៃការរួម

ចំណែកនៃប្រភពថាមពល គឺប្រភពដែលសំខាន់ជាងគេ គឺបានមកពីប្រភពថាមពលកកើតឡើងវិញដែលមានចំនួន ២៩,៩% នៃផលិតកម្មសរុបរបស់ EU-២៨ ក្នុងឆ្នាំ២០១៧។

កម្ដៅពីប្រភពនុយក្លេអ៊ែរស្ថិតនៅលំដាប់ទី ២ ក្នុងអត្រា ២៧,៨% នៃផលិតកម្មថាមពលបឋមសរុប។ នៅប្រទេសបារាំង កម្ដៅបានមកពីនុយក្លេអ៊ែរមានអត្រា ៧៩% នៃផលិតកម្មថាមពលជាតិបឋម។ នៅបែលហ្ស៊ិក និងស្លូវ៉ាគី មានចំណែកច្រើនជាងពាក់កណ្ដាលនៃផលិតកម្មកម្ដៅបានពីនុយក្លេអ៊ែរនេះ ហើយប្រទេសសមាជិក ១១ ដទៃទៀត មានផលិតកម្មកម្ដៅបានមកពីនុយក្លេអ៊ែរតិចជាងពាក់កណ្ដាលនៃផលិតកម្មកម្ដៅដែលបានមកពីថាមពលដំបូងសរុប។ ប្រទេសជាសមាជិកចំនួន ១៤ ទៀតរបស់ EU មិនមានការផលិតថាមពលពីនុយក្លេអ៊ែរទេ។

ចំណែកនៃធ្យូងថ្ម (Solid fossil fuel) ក្នុងឆ្នាំ ២០១៧ មានអត្រាចំនួន ១៦,៤% ហើយចំណែកនៃឧស្ម័នធម្មជាតិមានអត្រាចំនួន ១៣,៦%។ ចំណែកនៃប្រេងឆៅមានក្នុងអត្រា ៨,៨%។ ប្រភពថាមពលកកើតឡើងវិញមានអត្រាកំណើនប្រហែលគ្នាក្នុងអំឡុងពីឆ្នាំ២០០៧-២០១៧ ហើយបានកើនលើសពីអត្រាកំណើននៃប្រភេទថាមពលដទៃទៀតដែលរួមបញ្ចូលគ្នា។ ផលិតកម្មនៃថាមពលចេញពីប្រភពដែលកកើតឡើងវិញបានកើនឡើងចំនួន ៦៥,៦% ក្នុងអំឡុងពេលនេះ។ កម្រិតផលិតកម្មចេញពីប្រភពថាមពលដំបូងផ្សេងៗទៀតបានធ្លាក់ចុះ។ ឧទាហរណ៍៖ ផលិតកម្មថាមពលនុយក្លេអ៊ែរបានធ្លាក់ចុះចំនួន ១២,៨%។

## ភាពពឹងផ្អែកផ្នែកថាមពល

ការធ្លាក់ចុះនៃផលិតកម្មបានមកពីប្រភពថាមពលដំបូងបានបង្កឲ្យមានស្ថានភាពមួយ ដែលសហភាពអឺរ៉ុបត្រូវពឹងផ្អែកកាន់តែខ្លាំងឡើងៗលើការនាំចូលប្រភពថាមពលបឋម និងផលិតផលបន្ទាប់បន្សំសម្រាប់ផលិត ថាមពល (ឧ. ឧស្ម័ន/ប្រេងម៉ាស៊ូត)។ ការនាំចូលថាមពលរបស់ EU-២៨ មានកំរិតលើសពីការនាំចេញក្នុងចំនួន ៩៤៨ Mtoe ក្នុងឆ្នាំ២០១៧។ ប្រទេសនាំចូលសុទ្ធសាធ និងធំបំផុត គឺ អាល្លឺម៉ង់ អ៊ីតាលី បារាំង និងអេស្ប៉ាញ។ កាលពីមុនប្រទេសដាណឺម៉ាក និងចក្រភពអង់គ្លេស គឺជាប្រទេសដែលនាំចេញសុទ្ធសាធនូវថាមពល ប៉ុន្តែសព្វថ្ងៃនេះ គ្មានប្រទេសជាសមាជិកនៃសហភាពអឺរ៉ុបណាមួយអាចទទួលនូវឈ្មោះនេះបានទៀតទេ។ ចាប់តាំងពីឆ្នាំ២០១៣ នៅពេលដែលការនាំចូលថាមពលរបស់ប្រទេសដាណឺម៉ាកបានផ្ដើមកើនលើសពីការអត្រានៃការនាំចេញ គ្រប់ប្រទេសជាសមាជិកសហភាពអឺរ៉ុបទាំងអស់បានក្លាយជាអ្នកនាំចូលថាមពលសុទ្ធសាធទាំងអស់គ្នា។ បើធៀបទៅនឹងទំហំប្រជាជនប្រទេសនាំចូលឈានមុខគេក្នុងឆ្នាំ២០១៧ គឺ ប្រទេសលុចសំបួ ម៉ាល់តា និងបែលហ្ស៊ិក។

តែទោះជាយ៉ាងណាប្រភពចម្បងនៃការនាំចូលថាមពលរបស់សហភាពអឺរ៉ុបពិតជាមានការផ្លាស់ប្ដូរ។ ប្រទេសរុស្ស៊ីបានរក្សាតំណែងជាអ្នកផ្គត់ផ្គង់ថាមពលឈានមុខដល់សហភាពអឺរ៉ុប ក្នុងអំឡុងឆ្នាំ២០០៧-២០១៧ ហើយប្រទេសនោះ គឺជាអ្នកផ្គត់ផ្គង់ប្រេងឆៅដ៏ចម្បងក្នុងឆ្នាំ២០១៧ ក្នុងចំណែក ៣០,៣%។ អ្នកផ្គត់ផ្គង់ធំជាងគេទី២ គឺ ប្រទេសន័រវែស (១១,៤%)។ ប្រេងឆៅដែលផ្គត់ផ្គង់ដោយប្រទេសអ៊ីរ៉ាក់ និងកាហ្សាក់ស្ថាន មានការកើនឡើងគួរឲ្យកត់សម្គាល់ដែលមានចំនួនឈានដល់ ៨,២% និង ៧,៤% ដែលធ្វើឲ្យប្រទេសទាំងពីរនេះក្លាយជាអ្នកផ្គត់ផ្គង់ធំទី៣ និងទី៤ របស់សហភាពអឺរ៉ុប ដែលនាំមុខប្រទេសអារ៉ាប៊ីសាអូឌីត។

ការនាំចូលឧស្ម័នធម្មជាតិរបស់សហភាពអឺរ៉ុប គឺមកពីប្រទេសរុស្ស៊ី (៣៨,៧%ភាគរយ) និងន័រវែស (២៥,៣%)។ ចំណែកនៃអ្នកផ្គត់ផ្គង់ធំជាងគេទីបី គឺអាល់ហ្សេរី (១០,៦%) ដែលបានធ្លាក់ចុះចាប់តាំងពីឆ្នាំ២០០៧ មក ខណៈដែលចំណែកមកពីប្រទេសកាតាបានកើនឡើងលើសពីទ្វេដង (៥,២%)។

នៅឆ្នាំ២០១៧ ចំណែកចម្បងនៃការនាំចូលធ្យូងថ្មរឹងរបស់សហភាពអឺរ៉ុប គឺមកពីប្រទេសរុស្ស៊ី (៣៨,៩%)។ ប្រទេសផ្គត់ផ្គង់ធំជាងគេទី២ គឺកូឡុំប៊ី (១៦,៩%)។ សហរដ្ឋអាម៉េរិកបានក្លាយជាប្រទេសផ្គត់ផ្គង់ធំជាងគេទី៣ ក្នុងឆ្នាំ២០១៧ ដែលក្នុងអត្រា ១៦,៩%។

សន្តិសុខនៃការផ្គត់ផ្គង់ថាមពលដំបូងរបស់សហភាពអឺរ៉ុបកំពុងតែមានហានិភ័យ ដោយសារការនាំចូលរបស់ខ្លួនបានមកតែពីដៃគូមួយចំនួនប៉ុណ្ណោះ។ ចំនួនជិត ៣/៤ (៧៤,៦%) នៃការនាំចូលឧស្ម័នធម្មជាតិរបស់ EU-២៨ គឺបានមកពីប្រទេសរុស្ស៊ី ន័រវែស និងអាល់ហ្សេរី ហើយ ៧២,៧% នៃការនាំចូលធ្យូងថ្មរឹងមានប្រភពមកពីប្រទេសរុស្ស៊ី កូឡុំប៊ី និងសហរដ្ឋអាម៉េរិក។ ការនាំចូលប្រេងឆៅពុំសូវប្រមូលផ្ដុំក្នុងចំណោមប្រទេសផ្គត់ផ្គង់ធំៗ ដូចជា រុស្ស៊ី ន័រវែស និងអ៊ីរ៉ាក់ (៤៩,៩%) ទេ។

ការពឹងផ្អែករបស់សហភាពអឺរ៉ុបទៅលើការនាំចូលថាមពលបានកើនឡើងពី ៤៤% ក្នុងឆ្នាំ១៩៩០ ដល់ ៥៥,១% ក្នុងឆ្នាំ២០១៧ ដែលនេះជាកម្រិតមួយខ្ពស់បំផុតក្នុងពេលបច្ចុប្បន្ន។ ចាប់តាំងពីឆ្នាំ២០០៤ ការនាំចូលថាមពលសុទ្ធសាធមានទំហំធំជាងផលិតកម្មថាមពលបឋមរបស់សហភាពអឺរ៉ុប។ បើយើងមើលឲ្យបានលម្អិត យើងឃើញថា ក្នុងតាំងពីឆ្នាំ២០១៧ តាមការកត់ត្រា គឺមានអត្រាខ្ពស់បំផុតក្នុងការនាំចូលប្រេងឆៅ (៨៦,៧%) និង

ឧស្ម័នធម្មជាតិ (៧៤,៣%)។ អត្រានាំចូលធ្យូងថ្មបានឈានដល់ចំនួន ៤៣,៩% ។

## ការដោះស្រាយបញ្ហាប្រឈម

ថាមពលជាងពាក់កណ្តាលរបស់ EU-២៨ បានការផ្គត់ផ្គង់មកពីប្រទេសក្រៅពីសហភាពអឺរ៉ុប ចំណែកនេះបានបន្តកើនឡើងក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ ដោយសារតែរុស្ស៊ីមានជម្លោះជាមួយនឹងប្រទេសឆ្លងកាត់ បញ្ហានេះបាននាំឲ្យមានការរំខានដល់ការផ្គត់ផ្គង់ថាមពលពីរុស្ស៊ីដែលជាប្រភពនាំចូលចម្បងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ការព្រួយបារម្ភពីសន្តិសុខនៃការផ្គត់ផ្គង់ថាមពលមានកាន់តែខ្លាំងឡើង ដោយសារជម្លោះរវាងប្រទេសរុស្ស៊ី និងប្រទេសអ៊ុយក្រែន។ បំពង់បង្ហូរថ្មីដើម្បីធានាដល់ការផ្គត់ផ្គង់បន្ថែម គឺមាន Nord Stream ១ និង Nord Stream ២។ បំពង់បង្ហូរ Nord Stream ឆ្លងកាត់ពីប្រទេសរុស្ស៊ីតាមរយៈសមុទ្របាល់ទិច (ដោយមិនបាច់ឆ្លងប្រទេសដទៃ)ទៅកាន់សហភាពអឺរ៉ុប។ បំពង់បង្ហូរ Trans Adriatic ភ្ជាប់ពីតួកគីទៅប្រទេសអ៊ីតាលី ឆ្លងកាត់ប្រទេសក្រិក និងប្រទេសអាល់បានី ដែលបង្ហូរឧស្ម័នមកពីតំបន់សមុទ្រកាសព្យែនទៅសហភាពអឺរ៉ុប។ ហើយវិធានការណ៍ថ្មីសម្រាប់ទីផ្សារប្រេង និងឧស្ម័នត្រូវបានរៀបចំឡើងដើម្បីបង្ការកុំឲ្យមានភាពរំខានដល់ការផ្គត់ផ្គង់។

ភាពស្មុគស្មាញខាងភូមិសាស្ត្រនយោបាយក្នុងតំបន់ដែលបណ្តាលមកពីការប្រកួតប្រជែងផលប្រយោជន៍រវាងតួអង្គទាំងអស់ បានរាំងការធ្វើសមាហរណកម្មដោយរលូននៃតំបន់កូកាស៊ីសខាងត្បូង និងតំបន់កាសព្យែនទៅក្នុងទីផ្សារពិភពលោក។ ការពឹងផ្អែករបស់តំបន់ទៅលើប្រទេសឆ្លងកាត់សម្រាប់ការធ្វើទីផ្សារផលិតកម្មអ៊ីដ្រូកាបូនបាននាំឲ្យមានចម្ងល់ថា តើគ្មាននយោបាយអនុញ្ញាតឲ្យមានការធ្វើពិពិធកម្មផ្លូវដឹកជញ្ជូន ក្នុងខណៈដែលមានការកើនឡើងនៃផលិតកម្មឬទេ? នៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសរុស្ស៊ី កាហ្សាក់ស្ថាន តួកម៉េនីស្ថាន អាស៊ែបៃហ្សង់ និងអ៊ូសបេគីស្ថានបានយល់ឃើញថា ទុនអ៊ីដ្រូកាបូនដ៏ច្រើនដែលពួកគេមានអាចក្លាយជាមូលដ្ឋានដ៏ល្អសម្រាប់ការប្រកួតប្រជែងនាពេលអនាគតរបស់ពួកគេនៅក្នុងពិភពលោក ដែលការអភិវឌ្ឍនៅតែពឹងផ្អែកលើការផ្គត់ផ្គង់ឥន្ធនៈផូសស៊ីល។

សហគមន៍ថាមពល (Energy Community) បានដាក់សំណើនៅក្នុងខែតុលា ឆ្នាំ២០០៥ ដើម្បីស្នើសុំឲ្យប្រទេសជិតខាងធ្វើសមាហរណកម្មទៅក្នុងទីផ្សារថាមពលផ្ទៃក្នុង។ប្រភពនៃថាមពលចម្រុះដ៏ទូលំទូលាយនិងពិពិធកម្មនៃអ្នកផ្គត់ផ្គង់ ផ្លូវដឹកជញ្ជូន និងយន្តការនានាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវការផ្គត់ផ្គង់ថាមពល។ នៅខែឧសភា ឆ្នាំ២០១៤ គណៈកម្មការអឺរ៉ុបបានចេញនូវយុទ្ធសាស្ត្រសន្តិសុខថាមពលរបស់ខ្លួន ក្នុងគោលបំណងធានាឲ្យមានស្ថិរភាពក្នុងការផ្គត់ផ្គង់ថាមពលឲ្យបានគ្រប់គ្រាន់។

ក្រៅពីទស្សនៈដែលផ្តោតលើផ្នែកផ្គត់ផ្គង់ដើម្បីធានាសន្តិសុខថាមពល វិធានការខាងតម្រូវការ ឧទាហរណ៍ដូចជា ការសន្សំថាមពល និងការប្រើថាមពលដែលប្រកបដោយប្រសិទ្ធភាពនិងការសន្សំសំចៃក៏ដើរតួនាទីយ៉ាងច្បាស់ប្រាកដនៅក្នុងយុទ្ធសាស្ត្រសន្តិសុខថាមពលរបស់សហភាពអឺរ៉ុបដែរ។

សេចក្តីណែនាំស្តីពី ប្រសិទ្ធភាពដោយការសន្សំសំចៃថាមពលឆ្នាំ២០១២ (២០១២/២៧/EU) បានបង្កើតនូវវិធានការចងជាកាតព្វកិច្ចដើម្បីជួយសហភាពអឺរ៉ុបក្នុងការសម្រេចឲ្យបាននូវគោលដៅនៃប្រសិទ្ធភាពដោយការសន្សំសំចៃនូវថាមពលឲ្យបាន២០%របស់ខ្លួនត្រឹមឆ្នាំ២០២០។ នេះមានន័យថា ការប្រើប្រាស់ថាមពលរបស់សហភាពអឺរ៉ុបទាំងមូលមិនគួរលើសពី ១៤៨៣ Mtoe នៃថាមពលដំបូង ឬ ១.០៨៦ Mtoe នៃថាមពលចុងក្រោយឡើយ។ ក្រោមការណែនាំនេះ រាល់ប្រទេសជាសមាជិកសហភាពអឺរ៉ុបទាំងអស់ត្រូវប្រើប្រាស់ថាមពលឲ្យកាន់តែមានប្រសិទ្ធិភាពដោយការសន្សំសំចៃនៅគ្រប់ដំណាក់កាលទាំងអស់ក្នុងចង្វាក់ថាមពល ក្នុងនោះរួមមានការផលិតថាមពល ការបញ្ជូន ការចែកចាយ និងការប្រើប្រាស់ចុងក្រោយ។

ក្នុងបរិបទនៃសេចក្តីណែនាំឆ្នាំ២០១២ នេះដែលវិធានការសំខាន់ៗជាច្រើនត្រូវបានអនុម័តនៅទូទាំងសហភាពអឺរ៉ុប ដើម្បីបង្កើននូវប្រសិទ្ធភាពដោយការសន្សំសំចៃនៃការប្រើថាមពលនៅអឺរ៉ុបក្នុងនោះរួមមាន៖

- ការកាត់បន្ថយការលក់ថាមពលជាតិប្រចាំឆ្នាំឲ្យបាននៅត្រឹម ១.៥%
- ការកែលម្អឡើងវិញឲ្យមានប្រសិទ្ធភាពប្រកបដោយការសន្សំសំចៃលើការប្រើថាមពលក្នុងចំណោមប្រទេសនៃសហភាពអឺរ៉ុបឲ្យបាននៅត្រឹមអត្រាយ៉ាងហោច ៣% ក្នុងមួយឆ្នាំ សម្រាប់អគារដែលជាកម្មសិទ្ធិរបស់ និងកាន់កាប់ដោយរដ្ឋាភិបាលកណ្តាល
- ការរៀបចំយុទ្ធសាស្ត្រកែលម្អឡើងវិញរយៈពេលវែងថ្នាក់ជាតិ អំពីការប្រមូលព័ត៌មានទាក់ទងនឹងអគារទាំងអស់នៅគ្រប់ប្រទេសនៅអឺរ៉ុប
- ការបង្កើតឲ្យមានវិញ្ញាបនបត្រចាំបាច់បញ្ជាក់ពីការប្រើថាមពលដោយប្រសិទ្ធភាពនិងសន្សំសំចៃ ដែលត្រូវភ្ជាប់ជាមួយនឹងរាល់ការលក់ និងជួលអគារ

- ការរៀបចំផែនការសកម្មភាព ស្តីពីការប្រើថាមពលប្រកបដោយប្រសិទ្ធភាព និងការសន្សំសំចៃថាមពលថ្នាក់ជាតិ (NEEAP) រៀងរាល់បីឆ្នាំម្តង
- ការបង្កើតស្តង់ដារប្រសិទ្ធភាព និងការសន្សំសំចៃនៃការប្រើប្រាស់ថាមពលអប្បបរមា និងបិទស្លាកលើផលិតផលជាច្រើន ដូចជា ម៉ាស៊ីនដាំទឹក គ្រឿងប្រើប្រាស់ក្នុងផ្ទះ អំពូលភ្លើង និងទូរទស្សន៍ (ស្លាកថាមពល និងការរចនាដោយបញ្ចូលនូវលក្ខណៈវិនិច្ឆ័យសម្រាប់ការពារបរិស្ថាន [eco design])
- ការដាក់ចេញនូវផែនការបង្កើតកុងទ័រវៃឆ្លាត (smart meters) សម្រាប់កត់ត្រាថាមពលដែលប្រើប្រាស់ ចំនួន ២០០លាន សម្រាប់ភ្ជាប់ទៅនឹងឧបករណ៍អគ្គិសនី និង ៤៥លាន សម្រាប់ភ្ជាប់ទៅនឹងឧបករណ៍ប្រើឧស្ម័ននៅត្រឹមឆ្នាំ២០២០
- កម្មវិធីកាតព្វកិច្ចដែលតម្រូវឲ្យក្រុមហ៊ុនផលិតថាមពលត្រូវតែសន្សំឲ្យបានថាមពលប្រចាំឆ្នាំនូវអត្រា១,៥% នៃការលក់ប្រចាំឆ្នាំដល់អ្នកប្រើប្រាស់ចុងក្រោយ
- សវនកម្មថាមពលចំពោះក្រុមហ៊ុនធំៗត្រូវតែធ្វើឡើងយ៉ាងតិចណាស់រៀងរាល់បួនឆ្នាំម្តង
- ការពារសិទ្ធិអ្នកប្រើប្រាស់ដើម្បីទទួលបានទិន្នន័យប្រើប្រាស់ថាមពលក្នុងពេលភ្លាមៗ (Real-time) និងពីពេលមុនៗដោយងាយស្រួល និងឥតគិតថ្លៃ។

